វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

# ទំនប់វារីអគ្គិសនីកំចាយ៖

## ការវាយតម្លៃផលប៉ះពាល់របស់ទំនប់ លើសហគមន៍មូលដ្ឋាន និងបរិស្ថាន






ភ្នំពេញ, កម្ពុជា
ខែតុលា ឆ្នាំ២០១៣

## ទំនប់វារីអគ្គិសនីកំចាយ៖

ការវាយតម្លៃផលប៉ះពាល់របស់ទំនប់លើសហគមន៍មូលដ្ឋាន និងបរិស្ថាន

រូបថតគំរបសៀវភៅ៖ ការផលិតល្ងូ(កញ្ជ្រែ) នៅភូមិអូរតូច (រូបលើឆ្វេង) ទំនប់កំចាយមើលពីខាងក្រៅរបង ដែលការពារមិនអោយគេចូលទៅដល់ (រូបលើកណ្តាល) ដើមឈើងាប់ដែលជន់លិចដោយអាងស្តុកទឹកទំនប់កំចាយ (រូបលើស្តាំ) និង ទេសភាពរមណីយដ្ឋានទឹកឈូ (រូបធំជាងគេ)។

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែតុលា ឆ្នាំ២០១៣
ស្រាវជ្រាវដោយ៖ លោក ប៉េឡេ ហ្គាតកេ (Pelle GÄTKE) និង
លោក អ៊ុន បូរិន (Un Borin)
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីបរិស្ថាន គម្រោងសិទ្ធិសហគមន៍ និងទំនប់វារីអគ្គិសនី
និងគម្រោងតាមដានគោនយោបាយកសិកម្ម)
សម្របសម្រួលការស្រាវជ្រាវដោយ៖ លោកស្រី សៅ វិច្ឆិកា មន្ត្រីស្រាវជ្រាវ
រចនាអត្ថបទដោយ៖ លោក ភួន យូ មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ

រូបភាពទាំងអស់ក្នុងរបាយការណ៍នេះថតដោយ លោក ប៉េឡេ ហ្គាតកេ លើកលែងតែរូបភាពណាដែលបញ្ជាក់ជូននូវប្រភពដើម។

## សេចក្តីបញ្ជាក់៖

ទស្សនៈបង្ហាញក្នុងរបាយកាណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

# សេចក្តីថ្លែងអំណរគុណ

ជាបឋមសូមថ្លែងអំណរគុណចំពោះវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា រួមមានគម្រោងសិទ្ធិសហគមន៍ និងទំនប់វារីអគ្គិសនី និងគម្រោងតាមដានគោលនយោបាយកសិកម្ម ចំពោះការធ្វើអោយការសិក្សានេះកើតចេញជារូបរាង។ អ្នកនិពន្ធពេញចិត្តជាខ្លាំងចំពោះការគាំទ្រ និងកិច្ចសហការដ៏ល្អពីសំណាក់កម្មវិធីបរិស្ថាន និងមន្ត្រីស្រាវជ្រាវរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា តាំងពីដើមដល់ចប់ក្នុងការសិក្សានេះ។

សូមអរគុណជាពិសេសចំពោះសមាជិក សហគមន៍ និងអាជ្ញាធរមូលដ្ឋាន នៅឃុំអណ្តូងខ្មែរ ឃុំកំពង់ត្រែង និងឃុំម៉ាក់ប្រាង ដែលបានចំណាយពេលវេលារបស់ពួកគាត់ចូលរួមក្នុងការសម្ភាស ដែលជាកត្តាដ៏សំខាន់នៃការស្រាវជ្រាវនេះ។ ជាពិសេសសូមអរគុណប្រជាជនរងគ្រោះនៅ ភូមិអូរតូច ភូមិមាត់ពាម ភូមិអណ្តូងជីមើន ភូមិស្ទឹងប្រាំពីរ និងភូមិថ្មីខាងជើង ដែលបានអនុញ្ញាតអោយក្រុមស្រាវជ្រាវបានយល់ដឹងពីជីវិត និងការចិញ្ចឹមជីវិតរបស់ពួកគាត់ ដែលជាប្រភពព័ត៌មានដ៏សំខាន់សម្រាប់ការសិក្សានេះ។ យើងខ្ញុំក៏សូមអរគុណចំពោះក្រុមចុះស្រាវជ្រាវនៅតំបន់សិក្សា ដែលដឹកនាំដោយលោក អ៊ុន បូរិន ចំពោះការស្ម័គ្រចិត្ត ទាន់ពេលវេលា និងយ៉ាងហ្មត់ចត់។

លើសពីនេះទៀត សូមអរគុណដល់មន្ត្រីរាជរដ្ឋាភិបាល ដែលបានចំណាយពេលវេលាចែករំលែកចំណេះដឹង និងមតិយោបល់របស់ពួកគាត់។ ក្រុមហ៊ុនស៊ីណូហៃដ្រូ ក៏បានផ្តល់ព័ត៌មានដល់ការសិក្សាស្រាវជ្រាវនេះ និងបានសម្រួលអោយក្រុមស្រាវស្រាវបានទៅទស្សនាសំណង់ទំនប់ផងដែរ។ សូមអរគុណ អង្គការសង្គមស៊ីវិលនៅខេត្តកំពត រួមមានសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស(លីកាដូ) និងសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា(អាដហុក) ចំពោះការចែករំលែកព័ត៌មាន ហើយអរគុណសមាជិកនៃសម្ព័ន្ធទន្លេកម្ពុជា (RCC) ចំពោះការផ្តល់យោបល់លើលទ្ធផលនៃការស្រាវជ្រាវនេះ។

សូមអរគុណផងដែរ ចំពោះលោកស្រី អេម ត្រានដឹម (Ame Trandem) លោក ម៉ាក ហ្គ្រីមស្ទីត (Mark Grimsditch) លោក ឈិត សំអាត លោក តឹក វណ្ណារ៉ា លោកស្រី ជា ផល្លីកា លោកស្រី សៅ វិច្ឆិកា លោក សៅ វិបុល និង ក្រុមហ៊ុនអារុណាតិចណូឡូជីអិលធីឌី (Aruna Technology Ltd) សម្រាប់ការផ្តល់ព័ត៌មាន និងមតិយោបល់។

# មាតិកា


បញ្ជីគំនូសតាង និងតារាង....................................................................iv
បញ្ជីអក្សរកាត់.........................................................................................v

**សេចក្តីសង្ខេប**.......................................................................................vii

**សេចក្តីផ្តើម**..........................................................................................១
១. អំពីទីតាំងសិក្សា.................................................................................៤
២. អំពីទំនប់វារីអគ្គិសនីកំចាយ..................................................................៨
៣. វិធីសាស្ត្រស្រាវជ្រាវ...........................................................................១១
៣.១ ការចុះសិក្សា និងសម្ភាសនៅតំបន់គម្រោង.......................................១១
៣.២ កត្តាប្រឈមក្នុងការទទួលបានព័ត៌មាន.............................................១៣
៣.៣ ការបង្ហាញ និងការបញ្ជាក់ពីភាពពិតត្រឹមត្រូវនៃលទ្ធផល
ស្រាវជ្រាវ...................................................................................១៣

**ទិដ្ឋភាពនៃការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅប្រទេសកម្ពុជា**...............១៥
១. ទស្សនៈអំពីការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅប្រទេសកម្ពុជា....................១៥
២. ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅប្រទេសកម្ពុជា...........១៨
២.១ ទិសដៅអនាគតនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន..........២១

**លទ្ធផលនៃការស្រាវជ្រាវ**.....................................................................២៤
១. ផលប៉ះពាល់លើការចិញ្ចឹមជីវិត និងប្រាក់ចំណូល...................................២៤
១.១ ផលប៉ះពាល់ដែលអ្នកប្រកបរបរកាប់ឬស្សីជួបប្រទះ.......................២៤
១.១.១ ការប្រមូលផល ការខិតខំ និងការប្រើប្រាស់ពេលវេលា
កាប់ឬស្សី.......................................................................២៤
១.១.២ ការរកប្រាក់ចំណូល និងការពឹងអាស្រ័យលើមុខរបរ
កាប់ឬស្សី.......................................................................២៩
១.១.៣ ការចូលរួមរបស់ស្ត្រី និងអនាគតនៃការប្រកបរបរ
កាប់ឬស្សី.......................................................................៣៤
១.២ សហគមន៍ឬស្សីនៅភូមិអូរតូច.........................................................៣៦
១.៣ ការធ្លាក់ចុះនៃការប្រមូលអនុផលព្រៃឈើ.......................................៣៧
១.៤ ផលប៉ះពាល់លើវិស័យទេសចរណ៍..................................................៤០
១.៤.១ ការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរ និងប្រាក់ចំណូល ................៤១

១.៤.២ ផលប៉ះពាល់លើស្ត្រី និងអនាគតនៃទេសចរណ៍នៅ
រមណីយដ្ឋានទឹកឈូ.....................................................៤៥
១.៥ ការកើនឡើងនៃការប្រកបរបរកាប់អុសបណ្តោះអាសន្ន..................៤៧
១.៦ ការប្រែប្រួលនៃធនធានជលផល..................................................៥០
១.៧ ការខកខានមិនបានទូទាត់សំណង...............................................៥៤
១.៨ អំពីយេនឌ័រ.............................................................................៥៩
២. ការប្រើប្រាស់ទឹក ការផ្លាស់ប្តូរក្នុងវិស័យកសិកម្ម និងការប្រែប្រួល
អាកាសធាតុ....................................................................................៦០
២.១ ការប្រើប្រាស់ទឹកព្រែកកំចាយ និងគុណភាពទឹក.............................៦០
២.១.១ ការប្រើប្រាស់ទឹកសម្រាប់វិស័យកសិកម្ម...............................៦៣
២.២ ការផ្លាស់ប្តូរនៃវិស័យកសិកម្ម និងប្រព័ន្ធទឹកស្រោចស្រព................៦៥
២.៣ ការប្រែប្រួលអាកាសធាតុ និងទំនប់វារីអគ្គិសនីកំចាយ....................៦៨
៣. ការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងទឹកជំនន់ ថាមពលអគ្គិសនី និង
ហេដ្ឋារចនាសម្ព័ន្ធ..............................................................................៧២
៣.១ ការផ្គត់ផ្គង់ទឹក...........................................................................៧២
៣.២ ការគ្រប់គ្រងទឹកជំនន់..................................................................៧៤
៣.៣ ការផ្លាស់ប្តូរការផ្គត់ផ្គង់ និងតម្លៃអគ្គិសនី........................................៧៥
៣.៤ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ.......................................................៧៩
៤. វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានក្នុងរបាយការណ៍វាយតម្លៃហេតុ
ប៉ះពាល់បរិស្ថាន និងសង្គម : ការសន្យា និងការអនុវត្ត............................៨២
៤.១ ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានសំខាន់ៗ
នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម.............៨៥
៤.១.១ ផលប៉ះពាល់លើប្រព័ន្ធជលសាស្ត្ររបស់ព្រែកកំចាយ............៨៥
៤.១.២ ការបាត់បង់ព្រៃឈើ និងជម្រកសត្វព្រៃ..................................៨៧
៤.១.៣ ផលប៉ះពាល់លើធនធានជលផល.........................................៩០
៤.១.៤ ផលប៉ះពាល់លើគុណភាពទឹក...............................................៩១
៤.១.៥ ផលប៉ះពាល់លើវិស័យទេសចរណ៍ និងគ្រួសារពឹងផ្អែកលើ
អនុផលព្រៃឈើ................................................................៩៥
៤.២ ស្ថានភាព និងអនាគតនៃផែនការគ្រប់គ្រងបរិស្ថាន និងវិធានការ
កាត់បន្ថយហេតុប៉ះពាល់បរិស្ថាន...................................................៩៦
៤.៣ កត្តាប្រឈមនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន.........................៩៩

**ការពិភាក្សា**..........................................................................................១០១
១. កត្តាប្រឈមទាក់ទងទៅនឹងទំនប់វារីអគ្គិសនីកំចាយ..............................១០១
១.១ ការរង់ចាំការអនុវត្តៈ ក្តីរំពឹងចំពោះក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា.............................................................១០២
១.២ ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដ៏អាថិកំបាំង.១០៥
១.៣ ការចូលរួម និងការទទួលបានព័ត៌មាន.........................................១០៧
១.៤ លទ្ធផលនៃកង្វះព័ត៌មាន និងការចូលរួម.......................................១១០
១.៥ ផលប៉ះពាល់ចំពោះអ្នកប្រកបរបរកាប់ឫស្សី.................................១១១

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**...................................................................១១៣
សេចក្តីសន្និដ្ឋាន...........................................................................................១១៣
អនុសាសន៍..................................................................................................១១៩
អនុសាសន៍សម្រាប់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅកម្ពុជា...........១២០
អនុសាសន៍ទាក់ទងនឹងគម្រោងទំនប់វារីអគ្គិសនីកំចាយ.......................១២៥

**ឯកសារយោង**.............................................................................................១៣១

**ឧបសម្ព័ន្ធ**..................................................................................................១៣៤

ឧបសម្ព័ន្ធ «ក»: ផែនទីអាងស្តុកទឹក និងភូមិនៅខ្សែទឹកខាងក្រោមទំនប់ វារីអគ្គិសនីកំចាយ..........................................................១៣៤
ឧបសម្ព័ន្ធ «ខ»: ការសម្ភាស និងការសិក្សានៅមូលដ្ឋាន..............................១៣៥
ឧបសម្ព័ន្ធ «គ»: ដំណើរការដែលនាំអោយមានការបំភាយឧស្ម័នផ្ទះកញ្ចក់ ពីអាងស្តុកទឹកនៃទំនប់វារីអគ្គិសនី.....................................១៣៨
ឧបសម្ព័ន្ធ «ឃ»: ប្រភពនៃការផ្គត់ផ្គង់ទឹកនៅក្នុងភូមិដែលបានសិក្សា...........១៣៩
ឧបសម្ព័ន្ធ «ង»: ស្ថាប័នដែលតាមដានមើលការអនុវត្ត EMP........................១៤០

# បញ្ជីគំនូសតាង និងតារាង

## បញ្ជីគំនូសតាង


គំនូសតាង១: មធ្យោបាយទៅកាប់ឫស្សីនៅមុន និងក្រោយការសាងសង់ទំនប់...២៦
គំនូសតាង២: បម្រែបម្រួលប្រាក់ចំណូលនៃគ្រួសារប្រកបរបរកាប់ឫស្សី.............៣១
គំនូសតាង៣ និង៤: ចំណូលប្រចាំថ្ងៃនៃគ្រួសារប្រកបរបរកាប់ឫស្សីមុន និង ក្រោយពេលសាងសង់...........................................................៣២
គំនូសតាង៥: លទ្ធផលនៃការធ្លាក់ចុះប្រាក់ចំណូលពីការកាប់ឫស្សី...................៣៣
គំនូសតាង៦: ប្រាក់ចំណូលពីការប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូ នៅមុន និងក្រោយការសាងសង់ទំនប់វារីអគ្គិសនីកំចាយ.........................៤៤
គំនូសតាង៧ និង៨: ប្រាក់ចំណូលប្រចាំថ្ងៃនៃគ្រួសារលក់ដូរនៅរមណីយដ្ឋានទឹកឈូ នៅមុននិងក្រោយការសាងសង់ទំនប់វារីអគ្គិសនី..........................៤៥
គំនូសតាង៩: ទិន្នផលត្រីនៅប្រព័ន្ធព្រែកកំចាយពីឆ្នាំ២០០៦ដល់ ឆ្នាំ២០១០.........៥១


## បញ្ជីគំនូសតាង


តារាងទី១: ឃុំដែលបានធ្វើការសិក្សា................................................................៥
តារាងទី២: ភូមិដែលបានជ្រើសរើសសម្រាប់ការសិក្សា.......................................៦
តារាងទី៣: ចំនួនភ្ញៀវទេសចរនៅរមណីយដ្ឋានទឹកឈូ និងប្រាក់ចំណូល ឆ្នាំ២០០៦-២០១១.........................................................................៤២
តារាងទី៤: ស្ថានភាពនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន............................៩៧

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADHOC | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| BNP | ឧទ្យានជាតិបូកគោ (Bokor National Park) |
| CDM | យន្តការអភិវឌ្ឍន៍ស្អាត |
| DIME | មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល |
| DoA | មន្ទីរកសិកម្ម |
| DoE | មន្ទីរបរិស្ថានកំពត (Department of Environment) |
| DoWRAM | មន្ទីរធនធានទឹក និងឧតុនិយម |
| EAC | អាជ្ញាធរអគ្គិសនីកម្ពុជា |
| EIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| EMP | ផែនការគ្រប់គ្រងបរិស្ថាន |
| ESIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| FGD | ការពិភាក្សាជាក្រុម |
| FiA | រដ្ឋបាលជលផល |
| GHG | ឧស្ម័នផ្ទះកញ្ចក់ |
| GWH | គីឡូវ៉ាត់ម៉ោង |
| IESIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង |
| KES | អគ្គិសនីកំពត |
| Km | គីឡូម៉ែត្រ |
| Km² | គីឡូម៉ែត្រការ៉េ |
| KWS | រដ្ឋាករទឹកកំពត |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ |
| Masl | កំពស់ទឹកខ្ពស់ជាងនីវ៉ូទឹកសមុទ្រ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |

| | |
|---|---|
| MoE | ក្រសួងបរិស្ថាន |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MW | ម៉េហ្គាវ៉ាត់ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NGOF | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា |
| NTFP | អនុផលព្រៃឈើ |
| PFiA | រដ្ឋបាលជលផលខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| Sinohydro | ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ |
| $ | រូបិយប័ណ្ណដុល្លារអាមេរិក |
| TCTS | រមណីយដ្ឋានទឹកឈូ |
| WCD | គណៈកម្មការពិភពលោក ស្តីពីទំនប់ |

# សេចក្តីសង្ខេប

ទំនប់វារីអគ្គិសនីកំចាយ គឺជាគម្រោងទំនប់វារីអគ្គិសនីខ្នាតធំដំបូងគេបង្អស់នៅប្រទេសកម្ពុជាដែលគួរចាត់ទុកជាករណីពិសោធន៍ដ៏សំខាន់ ដែលអាចផ្តល់ចំណេះដឹងដ៏មានតម្លៃដល់ភាពត្រឹមត្រូវតាមក្របខ័ណ្ឌច្បាប់ និងនីតិវិធីពាក់ព័ន្ធនឹងការអនុវត្តគម្រោងទំនប់វារីអគ្គិសនី។ ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើផលប៉ះពាល់បរិស្ថាន និងសង្គម ក្រោយពីការបញ្ចប់គម្រោងមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដែលបានលើកឡើងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានធ្វើការសិក្សា ហើយហេតុប៉ះពាល់ផ្សេងៗដែលជួបប្រទះដោយសហគមន៍មូលដ្ឋានក៏ត្រូវបានធ្វើការស្រាវជ្រាវ និងវិភាគផងដែរ។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលបានអនុម័តកាលពីខែកក្កដា ឆ្នាំ២០១២ បានធ្វើឡើងក្រោយការសាងសង់ទំនប់វារីអគ្គិសនីកំចាយប្រមាណជា៥ឆ្នាំ។ ដូច្នេះ របាយការណ៍នេះកើតឡើងយឺតពេលពេកក្នុងការយកទៅប្រើប្រាស់ ដើម្បីបំពេញមុខងារក្នុងការផ្តល់ព័ត៌មានក្នុងដំណើរការសម្រេចចិត្ត។ ដោយគិតពីក្របខណ្ឌច្បាប់ និងគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងប្រទេសកម្ពុជា ការសាងសង់ទំនប់វារីអគ្គិសនីកំចាយបានចាប់ផ្តើមមុនពេលកំណត់។ ដូចគ្នានេះដែរ ផែនការគ្រប់គ្រងបរិស្ថានដែលបានចាត់ទុកថាជាមគ្គុទេសក៍ សម្រាប់ការអនុវត្តរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដើម្បីបញ្ចៀសពីផលប៉ះពាល់មិនចាំបាច់នានាដែលអាចនឹងកើតឡើង គឺមិនបានរៀបចំនៅមុនការចាប់ផ្តើមគម្រោងទេ។ បើយោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលបានអនុម័តក្រោយការអនុវត្តគម្រោងនោះជាទូទៅ គេមើលឃើញថាការអនុវត្តកិច្ចការពារបរិស្ថាន និងសង្គម មានកម្រិតតិចតួចបំផុត ហើយវានៅឆ្ងាយពីអ្វីដែលគេតម្រូវអោយធ្វើ។

ផលប្រយោជន៍ផ្សេងៗ និងថាមពលអគ្គិសនីដែលផលិតបានពីទំនប់បានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ប្រជាជន និងឧស្សាហកម្មដែលនៅឆ្ងាយពី

ទំនប់។ រីឯនៅតំបន់មូលដ្ឋានវិញ ការសាងសង់ទំនប់វារីអគ្គិសនីបានត្រឹមតែធ្វើអោយបាត់បង់ព្រៃឈើ និងកែប្រែលក្ខណៈធម្មជាតិរបស់ព្រែកនៅភាគអាគ្នេយ៍នៃឧទ្យានជាតិបូកគោប៉ុណ្ណោះ។ ការបាត់បង់ព្រៃឈើរាប់បញ្ចូលទាំងតំបន់ព្រៃឫស្សីដ៏មានទិន្នផលខ្ពស់ដែលសហាគមន៍មូលដ្ឋានប្រើប្រាស់តាមប្រពៃណី។ លើសពីនេះទៀត រមណីយដ្ឋានទឹកឈូដែលជាទីពេញនិយមនោះ បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការថយចុះនៃចំនួនភ្ញៀវទេសចរ។ ជាលទ្ធផល ការសាងសង់ទំនប់វារីអគ្គិសនីបណ្តាលអោយមានផលប៉ះពាល់បរិស្ថាន និងសង្គមមួយចំនួនដែលបង្កឲ្យមានការផ្លាស់ប្តូរអវិជ្ជមានដល់ការចិញ្ចឹមជីវិតរបស់ប្រជាជនដែលរស់នៅក្នុងតំបន់។ សហាគមន៍ជាច្រើនបានជួបប្រទះការធ្លាក់ចុះនៃការចិញ្ចឹមជីវិតរបស់ពួកគាត់ ផ្ទុយទៅវិញ ពួកគាត់បែរជាទទួលបានការគាំទ្រតិចតួចពីអាជ្ញាធរមូលដ្ឋានដែលទំនងជាត្រូវគាបសង្កត់ដោយមន្ត្រីថ្នាក់លើរបស់ពួកគេ ដែលធ្វើអោយពួកគេមិនអាចជួយសហាគមន៍មូលដ្ឋានបាន។ បន្ថែមពីនេះទៀត ក្រុមហ៊ុនស៊ីណូហៃដ្រូដែលជាអ្នកសាងសង់ទំនប់វារីអគ្គិសនីកំចាយ មិនសូវជាយកចិត្តទុកដាក់ក្នុងការកែតម្រូវស្ថានការណ៍ទាំងនេះឡើយ។

តាមរយៈការចុះសិក្សាស្រាវជ្រាវ និងការសម្ភាសទូលំទូលាយជាមួយភាគីពាក់ព័ន្ធសំខាន់ៗនៅតំបន់សិក្សា ការសិក្សានេះរកឃើញថាមានសមាជិកសហាគមន៍ជាច្រើនមិនត្រូវបានគេរាប់បញ្ចូលក្នុងដំណើរការចូលរួម ទាក់ទងទៅនឹងការអភិវឌ្ឍទំនប់វារីអគ្គិសនីនេះទេ។ ដូច្នេះ ហើយបានជាប្រជាជនទាំងនោះមិនសូវមានចំណេះដឹងអំពីទំនប់វារីអគ្គិសនីនេះ។ តាមការស្ទង់មតិប្រជាជនចំនួន១០០គ្រួសារ ដែលពឹងផ្អែកលើការកាប់ឫស្សី និងវិស័យទេសចរណ៍នៅរមណីយដ្ឋានទឹកឈូ បង្ហាញថាដោយសារតែការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ក្រុមប្រជាជនទាំងនោះបានប្រឈមនឹងការថយចុះប្រាក់ចំណូល។ ការថយចុះនៃចំនួនភ្ញៀវទេសចរយ៉ាងច្រើនសន្ធឹកសន្ធាប់នៅកំឡុងដំណាក់កាលសាងសង់ទំនប់ពីចំនួនប្រមាណ ២៧៨.០០០នាក់ នៅឆ្នាំ២០០៦ មកត្រឹម ៦៥.០០០នាក់ នៅឆ្នាំ២០១១ បានបណ្តាលអោយប្រាក់ចំណូលរបស់អ្នកដែលមានមុខរបរអាស្រ័យលើវិស័យទេសចរណ៍ សម្រាប់ការចិញ្ចឹមជីវិតមានការធ្លាក់ចុះ។ប្រជាជនទាំងនេះ សព្វថ្ងៃរកចំណូលបានជាមធ្យមចំនួន

ប្រមាណតែ២៨% ប៉ុណ្ណោះ នៃប្រាក់ចំណូលដែលពួកគាត់ធ្លាប់ទទួលបាននៅមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ ការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរបង្កឡើងជាចំបងដោយសារការធ្វើអោយខូចគុណភាពទឹក និងការខ្វះទឹកនៅក្នុងព្រែកនៅកំឡុងពេលសាងសង់ទំនប់។

គ្រួសារដែលប្រកបរបរកាប់ឫស្សីយល់ឃើញថា ប្រាក់ចំណូលរបស់គេបានធ្លាក់ចុះជាមធ្យមពី (១៥.០០០រៀល ទៅ ២៥.០០០រៀល) ក្នុង១ថ្ងៃ នៅមុនពេលសាងសង់ទំនប់មកត្រឹមប្រមាណ (១០.០០០រៀល ទៅ ២០.០០០រៀល) ក្នុង១ថ្ងៃ នៅពេលបច្ចុប្បន្ន។ សព្វថ្ងៃ គ្រួសារដែលប្រកបរបរកាប់ឫស្សីប្រមាណ៧៩% រកប្រាក់ចំណូលបាន២០.០០០រៀល ឬតិចជាងនេះក្នុង១ថ្ងៃ។ បើប្រៀបធៀបនៅមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ចំនួននេះមានត្រឹមតែ៥៣% ប៉ុណ្ណោះ។ ការធ្លាក់ចុះនៃប្រាក់ចំណូលនេះ បណ្តាលមកពីផលលំបាកជាងមុនក្នុងការកាប់ឫស្សីអោយបានគ្រប់គ្រាន់ ព្រមទាំងការកើនឡើងនៃការចំណាយពេលវេលា និងការចំណាយប្រាក់ក្នុងការប្រមូល និងដឹកជញ្ជូនឫស្សី។ ផលប៉ះពាល់អវិជ្ជមានមួយទៀតដែលបង្កឡើងដោយទំនប់វារីអគ្គិសនីកំចាយ គឺការធ្លាក់ចុះនៃទិន្នផលដំច្រើនពីការធ្វើនេសាទលក្ខណៈគ្រួសារនៅខ្សែទឹកខាងក្រោមទំនប់វារីអគ្គិសនី។

ការសិក្សាក៏បានរកឃើញផងដែរថា ការសាងសង់ទំនប់វារីអគ្គិសនីបានប៉ះពាល់គួរអោយកត់សម្គាល់ចំពោះស្ត្រីនៅក្នុងសហគមន៍មូលដ្ឋាន។ ស្ត្រីមកពីគ្រួសារដែលពឹងអាស្រ័យលើការប្រកបរបរកាប់ឫស្សី បានរងផលប៉ះពាល់លើទំរង់នៃការកាប់ឫស្សីរបស់ពួកគាត់ (ប្តូរពីអ្នកប្រកបរបរកាប់ឫស្សីទៅជាអ្នកមិនប្រកបរបរកាប់ឫស្សី) ហើយស្ត្រីដែលពឹងផ្អែកលើវិស័យទេសចរណ៍ជាមុខរបរ បានជួបប្រទះការធ្លាក់ចុះប្រាក់ចំណូល និងប្រាក់សម្រាប់ចំណាយរបស់ពួកគាត់យ៉ាងខ្លាំង។ លើសពីនេះទៀត ស្ត្រីជាច្រើនសព្វថ្ងៃកំពុងប្រឈមនឹងបន្ទុកការងារបន្ថែម ព្រោះត្រូវទទួលបន្ទុកថែរក្សាគ្រួសារ និងផ្ទះសម្បែងតែម្នាក់ឯងបណ្តោះអាសន្ន ដោយសារបុរសដែលទៅកាប់ឫស្សីត្រូវស្នាក់នៅក្នុងព្រៃជាច្រើនយប់។ បុរសធ្វើដូច្នេះ ដើម្បីអាចកាប់ឫស្សីអោយបានច្រើនគ្រប់គ្រាន់។ ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់

បរិស្ថាន និងសង្គម មិនមានការវិភាគពីផលប៉ះពាល់លើយែនឌ័រឡើយ ដូច្នេះ គេគួរបញ្ចូលបញ្ហាយែនឌ័រនៅក្នុងការវាយតម្លៃនៅពេលអនាគត។

ការសម្អាតឈើមិនអស់ពីក្នុងអាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយ នៅមុនពេលបញ្ចូលទឹកក្នុងអាង បានផ្តល់ផលប្រយោជន៍បណ្តោះអាសន្នដល់គ្រួសារមួយចំនួនដែលបានចាប់យករបរកាប់អុស និងលក់អុសជាមធ្យោបាយចិញ្ចឹមជីវិតថ្មីមួយ។ ការសម្អាតដើមឈើ និងរុក្ខជាតុសរីរាង្គនៅក្នុងអាងមិនបានអស់ បានធ្វើអោយមានការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលអាចបន្តមានជាច្រើនទសវត្សទៅមុខទៀត ហើយអាចរួមចំណែកធ្វើអោយមានការបំភាយឧស្ម័នមេតាន ដែលជាសមាសធាតុមួយក្នុងការធ្វើអោយមានការកើនឡើងកំដៅផែនដី បើទោះជាមានបរិមាណតិចតួចក្តី។ ប្រសិនបើ ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាគោរពអោយបានខ្ជាប់ខ្ជួននូវផែនការគ្រប់គ្រងបរិស្ថាន បញ្ហានេះនឹងមិនអាចកើតឡើងបានឡើយ។

ទោះបីជានៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មានការយកចិត្តទុកដាក់លើកសិកម្មក៏ដោយ កន្លងមកមិនមានគម្រោងអភិវឌ្ឍន៍ទឹកស្រោចស្រពត្រូវបានគេធ្វើឡើងនៅឡើយទេ។ យ៉ាងណាមិញ ទឹកសាបក្នុងព្រែកនៅខ្សែទឹកខាងក្រោមដែលមានច្រើនជាងមុននៅរដូវប្រាំង អាចជួយបង្កើនផលិតផលកសិកម្មផ្នែកដំណាំឈើហូបផ្លែ។ ទន្ទឹមគ្នានេះដែរ ទឹកជំនន់ និងគ្រោះមហន្តរាយនៃទឹកជំនន់ដែលគេរំពឹងថានឹងមិនអាចកើតមានដូចកាលពីមុន អាចនឹងកាត់បន្ថយឱកាសនៃការបាត់បង់ដើមឈើហូបផ្លែ ប៉ុន្តែអាចនឹងកើនឡើងដើមឈើហូបផ្លែនៅកន្លែងថ្មីៗថែមទៀត។

យ៉ាងហោចណាស់មានប្រជាជនចំនួន១០គ្រួសារ ដែលរងផលប៉ះពាល់ដោយសារការសាងសង់បណ្តាញបញ្ជូនចរន្ត នៅមិនទាន់ទទួលបានសំណងនៅឡើយ។ អាជ្ញាធរខេត្តបានប្រាប់គ្រួសាររងគ្រោះទាំងនោះថា វាគ្រោះថ្នាក់ណាស់ដែលពួកគាត់រស់នៅក្រោមខ្សែបញ្ជូនចរន្តអគ្គិសនីបែបនេះ ហើយពួកគាត់គួរតែរើផ្ទះចេញពីតំបន់ដែលប្រឈមនឹងគ្រោះថ្នាក់នេះ។ ប៉ុន្តែអស់រយៈពេល៩ខែ មកហើយ បន្ទាប់ពីអាជ្ញាធរខេត្តបានផ្តល់ដំណឹង គ្រួសាររងគ្រោះទាំងនោះមិនទាន់បានទទួល

ព័ត៌មានច្បាស់លាស់ទាក់ទងទៅនឹងសំណងឡើយ។ ប្រជាជនដែលរងគ្រោះទាំងនោះបានព្យាយាមជម្រាបអាជ្ញាធរមូលដ្ឋានអំពីករណីរបស់គេ ប៉ុន្តែពួកគាត់ទទួលបានការគាំទ្រតិចតួចពីអាជ្ញាធរ។ ជាទូទៅរាល់ការទំនាក់ទំនងរវាងសហាគមន៍ និងក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ ត្រូវឆ្លងកាត់មន្ត្រីរដ្ឋាភិបាល។ មធ្យោបាយទំនាក់ទំនងបែបនេះមិនបានធ្វើអោយប្រជាជនដែលរងគ្រោះ មានទំនាក់ទំនងដោយផ្ទាល់ជាមួយក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូទេ ដូច្នេះវានាំអោយការអនុវត្តគម្រោងនេះមិនសូវមានតម្លាភាព។

នៅក្នុងសហាគមន៍ខ្លះ ក្រុមគ្រួសារជាច្រើនមិនទាន់មានអគ្គិសនីប្រើប្រាស់នៅឡើយ ប៉ុន្តែតម្លៃថាមពលអគ្គិសនីបានថយចុះប្រមាណជា១៦% ទៅ ២៣% សម្រាប់អ្នកដែលបានភ្ជាប់បណ្តាញអគ្គិសនីរដ្ឋរួច។ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាផ្នែកមួយនៃគម្រោងទំនប់វារីអគ្គិសនីកំចាយ ប៉ុន្តែផ្លូវថ្នល់មិនទាន់ឆ្លើយតបទៅនឹងការចង់បានរបស់សហាគមន៍មូលដ្ឋាន ដែលរំពឹងថាក្រុមហ៊ុនស៊ីណូហៃដ្រូនឹងជួសជុលផ្លូវដែលមានសភាពទ្រុឌទ្រោមទាំងនោះ។ សំណង់បណ្តោះអាសន្នសម្រាប់ប្រើប្រាស់នៅកំឡុងពេលការសាងសង់ទំនប់ ត្រូវគេបន្សល់ទុកខ្លះនៅតំបន់ក្បែរទំនប់ដែលធ្វើអោយខូចសោភ័ណភាពនៅទីកន្លែងនោះ។

ប្រសិនបើក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ចំពោះការធ្លាក់ចុះនៃការចិញ្ចឹមជីវិតរបស់ប្រជាជនដែលពឹងផ្អែកលើវិស័យទេសចរណ៍ជាមុខរបរ ក៏ដូចជាយកចិត្តទុកដាក់ចំពោះផលប៉ះពាល់អវិជ្ជមានចំពោះប្រជាជនដែលប្រកបរបរកាប់ឫស្សី និងប្រមូលអនុផលព្រៃឈើ នោះពួកគេអាចបានធ្វើអោយស្ថានភាពប្រសើរឡើងយ៉ាងហោចក៏បានជាអន្លើដែរ តាមរយៈការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន។ ថវិកាចំនួន១លានដុល្លារអាមេរិក ត្រូវគេលៃទុកសម្រាប់ទូទាត់សំណងដល់ការថយចុះក្នុងវិស័យទេសចរណ៍ និងការបាត់បង់ប្រាក់ចំណូលពីការប្រមូលអនុផលព្រៃឈើ។ ថវិកាមួយចំនួននៃថវិកាទាំងនេះ គួរយកទៅប្រើសម្រាប់សាងសង់ស្ពានយោលនៅរមណីយដ្ឋានទឹកឈូសារជាថ្មី ដោយសារវាបានបាក់រលំកាលពីឆ្នាំ២០០៩ នៅកំឡុងពេល

សាងសង់ទំនប់វារីអគ្គិសនីកំចាយ។ សម្រាប់អ្នកប្រកបរបរកាប់ឫស្សី ការចូលទៅដល់តំបន់ព្រៃឫស្សីដែលនៅសេសសល់អាចនឹងប្រសើរឡើង តាមរយៈការសាងសង់ផ្លូវមួយខ្សែដែលមានប្រវែង ៣ ទៅ ៤គីឡូម៉ែត្រ។ តែគួរអោយសោកស្តាយសហគមន៍ដែលរងគ្រោះមិនទាន់ទទួលបានជំនួយ ឬផលប្រយោជន៍ណាមួយពីថវិកាដែលគេលៃទុកសម្រាប់ទូទាត់សំណងទាំងនេះនៅឡើយ។

ក្រុមហ៊ុនសាងសង់ទំនប់ស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាមិនបានអនុវត្តការតាមដានការផ្លាស់ប្តូរគុណភាពទឹក និងប្រព័ន្ធជលសាស្ត្រ កម្រិតទឹកប្រៃ និងធនធានជលផលអោយបានត្រឹមត្រូវឡើយ។ កត្តានេះធ្វើអោយមានការលំបាកក្នុងការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់អោយបានទាន់ពេលវេលា ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ប្តូរទាំងនេះ។ លើសពីនេះទៀត ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានមិនបានពេញលេញ ធ្វើអោយកាត់បន្ថយឱកាសទទួលបានបទពិសោធន៍ល្អៗ ពីគម្រោងទំនប់វារីអគ្គិសនីកំចាយ។ ផ្ទុយទៅវិញ គម្រោងនេះបានបង្ហាញពីផលវិបាកមួយចំនួនដែលអ្នកអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកម្ពុជា គួរយកចិត្តទុកដាក់សម្រាប់ ការអភិវឌ្ឍគម្រោងទំនប់វារីអគ្គិសនីនៅពេលអនាគត។ ដំណើរការអនុវត្តគម្រោងបង្ហាញថា ត្រូវមានការកែលំអកង្វះខាតរវាងវិធានការតម្រូវដោយច្បាប់ និងភាពជាក់ស្តែងនៃការអនុវត្តគម្រោងទំនប់វារីអគ្គិសនី។ ស្ថានភាពបែបនេះ ទាមទារអោយមានការពិនិត្យសារជាថ្មីនូវគម្រោងប្រភេទនេះនៅក្នុងប្រទេសកម្ពុជា។

កន្លងមក ក្រុមហ៊ុនសាងសង់ទំនប់ស៊ីណូហៃដ្រូ មិនមានឆន្ទៈគោរពតាមស្តង់ដាដែលមានរៀបរាប់ក្នុងផែនការគ្រប់គ្រងបរិស្ថាន នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ហើយក៏មិនមានឆន្ទៈអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ចាំបាច់នានា និងការតាមដានដែលតម្រូវអោយមាន។ ដូច្នេះ ការទទួលខុសត្រូវដ៏ធំត្រូវធ្លាក់ទៅលើរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំការងារទាំងនេះ។ ការធ្វើបែបនេះ បង្កអោយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមធ្វើឡើងមិនទាន់ពេលក្នុងការជួយផ្តល់ព័ត៌មានដល់រាជរដ្ឋាភិបាល ក្នុងការសម្រេចថាតើគួរតែអនុម័តយល់ព្រម ឬមិនអនុម័តយល់ព្រមចំពោះគម្រោងអភិវឌ្ឍន៍ទំនប់

វារីអគ្គិសនី នៅពេលដែលគម្រោងកំពុងដំណើរការសាងសង់ទៅហើយ។ តាមរយៈការសិក្សាស្រាវជ្រាវបង្ហាញថា មានការយល់ខុសក្នុងចំណោមមន្ត្រីរាជរដ្ឋាភិបាលមួយចំនួនថា ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅតំបន់គម្រោងទំនប់វារីអគ្គិសនីកំចាយមានភាពប្រសើរឡើង ដោយសារការសាងសង់ទំនប់វារីអគ្គិសនីនេះ។ មន្ត្រីរាជរដ្ឋាភិបាលទាំងនោះយល់ខុសថា អ្នកប្រកបរបរកាប់ឬស្សីឥឡូវអាចចូលទៅរកធនធានដែលពួកគេពឹងអាស្រ័យសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ ប្រសើរជាងមុន។ ប៉ុន្តែវាផ្ទុយទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រដល់ជនក្រីក្រ ដោយសារគម្រោងទំនប់វារីអគ្គិសនីកំចាយកំពុងតែរុញច្រានសមាជិកសហគមន៍មូលដ្ឋានជាច្រើនអោយកាន់តែធ្លាក់ក្នុងភាពក្រីក្រថែមទៀត។

កំណត់ត្រានៃការអនុវត្តរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់ខ្សោយ មានន័យថា វាតម្រូវអោយមានចំណាត់ការបន្ទាន់ដើម្បីធ្វើអោយប្រសើរឡើងនូវហេតុប៉ះពាល់អវិជ្ជមានរបស់គម្រោង។ ទោះបីជា ទំនប់វារីអគ្គិសនីបានបង្កអោយមានផលអាក្រក់ជាច្រើនដល់ការចិញ្ចឹមជីវិត នៃគ្រួសារនៅមូលដ្ឋានរាប់រយគ្រួសារក៏ដោយក៏ការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងនៅពេលអនាគតមិនទាន់ហួសពេលនៅឡើយដែរ។ ប៉ុន្តែ កត្តានេះតម្រូវអោយមានវិធានការតឹងរ៉ឹងពីក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីធានាបាននូវការអនុវត្តរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់។ ឧបមាថាគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីធំៗជាច្រើនត្រូវបានគេធ្វើផែនការ ឬក៏កំពុងដាក់អោយសាងសង់នៅប្រទេសកម្ពុជា វាចាំបាច់ណាស់ដែលរាជរដ្ឋាភិបាលគួរធ្វើអោយប្រសើរឡើងនូវស្តង់ដា និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តនូវរាល់គោលការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ខ្លួនដល់គម្រោងទាំងនេះ។ កំណត់ត្រាមិនល្អនៃការចូលរួមតិចតួចកង្វះតម្លាភាព និងគណនេយ្យភាព ត្រូវតែធ្វើអោយប្រសើរឡើង។ បើពុំនោះទេ សហគមន៍រងគ្រោះអាចនឹងមិនត្រូវគេយកចិត្តទុកដាក់ដដែលនៅក្នុងគម្រោងទំនប់វារីអគ្គិសនីនៅពេលអនាគត ហើយវានឹងនាំមកនូវផលអាក្រក់ជាច្រើនដែលជាលទ្ធផលនៃការអភិវឌ្ឍទំនប់វារីអគ្គិសនីនៅប្រទេសកម្ពុជា។

## អនុសាសន៍សំខាន់ៗចំពោះរាជរដ្ឋាភិបាលកម្ពុជា

- រាល់ភាគីពាក់ព័ន្ធដោយរាប់បញ្ចូលទាំងសហាគមន៍មូលដ្ឋាន គួរតែត្រូវបានអញ្ជើញអោយចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។
- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ដែលបានបញ្ចប់ និងអនុម័តរួចដោយមានបញ្ចូលវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលបានកំណត់ច្បាស់លាស់ និងមានការឯកភាព គួរមានជាស្រេចនៅមុនពេលមានការអនុម័តយល់ព្រម ចំពោះគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី។ លើសពីនេះ របាយការណ៍ទាំងអស់គួរត្រូវបានបោះពុម្ពផ្សាយអោយបានទាន់ពេលវេលា។
- កំណត់អោយបានច្បាស់លាស់នូវការទទួលខុសត្រូវទាំងឡាយរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធនានា។
- គួរពិនិត្យឡើងវិញរាល់នីតិវិធី និងគោលការណ៍ច្បាប់ដែលមានស្រាប់ទាំងផ្លូវការ និងមិនផ្លូវការ ដែលពាក់ព័ន្ធនឹងគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅកម្ពុជា។ ក្របខណ្ឌច្បាប់សម្រាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថានគួរតែត្រូវបានពង្រឹង និងចាត់វិធានការដើម្បីធានាបាននូវការប្រព្រឹត្តតាមច្បាប់នៅពេលអនាគត ដោយអ្នកអភិវឌ្ឍន៍គម្រោង និងរាជរដ្ឋាភិបាលកម្ពុជាខ្លួនឯង។
- ការតាមដានគម្រោងគួរតែធ្វើអោយប្រសើរឡើង ដើម្បីធានាបាននូវការប្រព្រឹត្តិតាមសេចក្តីតម្រូវអោយអនុវត្តក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម។
- គួរធានាអោយបានថាកង្វល់អំពីបរិស្ថាន និងសង្គម ដោយរាប់បញ្ចូលទាំងវិធានការកាត់បន្ថយហេតុប៉ះពាល់ ត្រូវដាក់ជាអាទិភាពនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៅពេលអនាគត ដូច្នេះផលប៉ះពាល់អវិជ្ជមានមិនត្រូវធ្លាក់លើបុគ្គលណាម្នាក់ ក្រោយការអនុវត្តគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី។
- គួរពិចារណាពីការបង្កើតច្បាប់ដែលធានាបាននូវការចែករំលែកផលប្រយោជន៍ពីគម្រោងដល់សហាគមន៍ដែលរងគ្រោះ។

ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលតម្រូវ សម្រាប់គម្រោងទំនប់វារីអគ្គិសនីកំចាយបានរាំងស្ទះ ដោយសារខ្វះការផ្ទេរការទទួលខុសត្រូវរវាងក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាអោយបានច្បាស់លាស់។ ស្ថានភាពបែបនេះត្រូវការអោយមានការកែតម្រូវ នៅមុនពេលការអភិវឌ្ឍសំខាន់ណាមួយអាចកើតមានឡើង។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវ:

- រៀបចំអោយមានការប្រជុំជាន់ខ្ពស់សម្រាប់ក្រសួង និងមន្ទីរ ដែលទទួលបន្ទុកការងារពាក់ព័ន្ធទាំងអស់។ ការប្រជុំគួរតែកំណត់ការបែងចែកការទទួលខុសត្រូវអោយបានច្បាស់លាស់ រវាងក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងការបែងចែកមូលនិធិសម្រាប់ការវាយតម្លៃ និងតាមដានចាំបាច់នានាដើម្បីអនុវត្តការទទួលខុសត្រូវទាំងអស់នោះ។
- បោះពុម្ពផ្សាយការបែងចែកការទទួលខុសត្រូវដែលបានសម្រេចចុងក្រោយ និងផែនការជាក់លាក់សម្រាប់ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ ហើយផ្សព្វផ្សាយព័ត៌មាននេះទៅសហគមន៍មូលដ្ឋាននៅក្នុងការប្រជុំថ្នាក់ភូមិ។
- ធានាថាក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ អនុវត្តតាមរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានសន្យា ដោយរាប់បញ្ចូលទាំងការទូទាត់សំណងសម្រាប់ការដែលមិនអាចចូលទៅរកអនុផលព្រៃឈើ និងការបាត់បង់ប្រាក់ចំណូលពីការធ្លាក់ចុះនៃវិស័យទេសចរណ៍។

**អនុសាសន៍សំខាន់ៗចំពោះក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ**

ដើម្បីកែតម្រូវហេតុប៉ះពាល់អវិជ្ជមានមួយចំនួន ដែលសហគមន៍រងផលប៉ះពាល់ដោយសារទំនប់វារីអគ្គិសនីនៅមូលដ្ឋានបានជួបប្រទះ ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូត្រូវ៖

- ប្រតិកម្មត្រលប់ និងស្នើអោយមានកិច្ចប្រជុំជាន់ខ្ពស់ជាមួយរាជរដ្ឋាភិបាល កម្ពុជាដើម្បីទទួលបានការកំណត់ច្បាស់លាស់ នៃការទទួលខុសត្រូវសម្រាប់ការប្រតិបត្តិវិធានការកាត់បន្ថយផលប៉ះពាល់។
- បំពេញការទទួលខុសត្រូវរបស់ខ្លួនទៅនឹងសហគមន៍មូលដ្ឋាន តាមរយៈការជម្រុញអោយមានកិច្ចសន្ទនាដោយផ្ទាល់ជាមួយអ្នកភូមិដែលរងគ្រោះ។

- ជួយធ្វើឲ្យរាល់ព័ត៌មានទាក់ទងនឹងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមអាចរកបានជាសាធារណៈ ហើយគោរពតាមរាល់វិធានការដែលបានបង្ហាញនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឬផែនការគ្រប់គ្រងបរិស្ថាន។
- បង្កើតយន្តការបណ្តឹងសារទុក្ខ ដែលអាចអោយសហគមន៍លើកឡើងនូវរាល់បញ្ហារបស់ពួកគេដោយផ្ទាល់ជាមួយក្រុមហ៊ុន។

ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ដែលប្រឈមដោយសហគមន៍មូលដ្ឋាន វិធានការបន្ទាន់ៗមួយចំនួនដែលក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូគួរធ្វើរួមមាន៖

- កសាងផ្លូវ ដើម្បីធ្វើអោយប្រសើរឡើងនូវការចូលទៅកាប់ឫស្សី និង ធនធានអនុផលព្រៃឈើដទៃទៀត។
- សម្រួលអោយមានការសាងសង់ស្ពានយោលថ្មីមួយនៅរមណីយដ្ឋានទឹកឈ្វ។
- ជួយធ្វើអោយទំនប់ជាកន្លែងទាក់ទាញភ្ញៀវទេសចរ តាមរយៈការអនុញ្ញាតអោយភ្ញៀវទេសចរបានចូលទស្សនាទំនប់វារីអគ្គិសនី។

**អនុសាសន៍សំខាន់ៗចំពោះសង្គមស៊ីវិល**

- តាមដានការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ អោយបានជិតដល់ ដោយរាប់បញ្ចូលទាំងការដាំកូនឈើ ដើម្បីធានាបានថាក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាបានបំពេញរាល់ការទទួលខុសត្រូវរបស់ខ្លួន។
- ជួយសហគមន៍មូលដ្ឋានដោយធ្វើយ៉ាងណាអោយកង្វល់ និងសេចក្តីត្រូវការរបស់គេបានដឹងឮដល់រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ។
- ស្នើអោយក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាអនុវត្តរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីទូទាត់សំណងដល់ការដែលមិនអាចចូលទៅរកអនុផលព្រៃឈើបាន និងការថយចុះនៃវិស័យ

ទេសចរណ៍នៅរមនីយដ្ឋានទឹកឈូ។  សង្គមស៊ីវិលក៏គួរតែជួយត្រួតពិនិត្យចំនុចនេះ ដើម្បីធ្វើអោយប្រាកដថាការសន្យាទាំងអស់ត្រូវបានបំពេញ។

- ទាមទារអោយមានការបោះពុម្ពផ្សាយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផ្សព្វផ្សាយជាសាធារណៈ។

ចំពោះអនុសាសន៍ទាំងស្រុង សូមមើលនៅចុងបញ្ចប់នៃរបាយការណ៍នេះ។

# សេចក្តីផ្តើម

ដោយសារការផលិតថាមពលអគ្គិសនីក្នុងប្រទេសនៅមានកម្រិតទាប នៅឡើយ មានការប្រឈមនឹងតម្លៃអគ្គិសនីខ្ពស់ ព្រមទាំងវិសាលភាពអគ្គិសនីដែលគ្រប ដណ្តប់នៅតំបន់ក្រៅទីក្រុងសំខាន់ៗនៅមានកម្រិតទាប ដូច្នេះរាជរដ្ឋាភិបាលយល់ថា ការផលិតថាមពលវារីអគ្គិសនី ជាមធ្យោបាយមួយដ៏ប្រសើរដែលអាចបង្កើនបរិមាណ ផលិតថាមពលអគ្គិសនីនៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ២០១១ ការផ្គត់ផ្គង់ថាមពល អគ្គិសនីនៅក្នុងប្រទេសមានប្រមាណ៣៩% ហើយមានត្រឹមតែ១៩% ប៉ុណ្ណោះ នៃក្រុម គ្រួសារដែលរស់នៅទីជនបទអាចប្រើប្រាស់ថាមពលអគ្គិសនីនេះបាន។ ប្រទេស កម្ពុជានាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាងប្រមាណជា៩៥% នៃថាមពលសរុប ក្នុងប្រទេស ហើយមានថាមពលអគ្គិសនីច្រើនជាង៥០% បានមកពីការផលិតដោយ ប្រេងឥន្ធនៈ។ ទោះបីជាចំនួនរោងចក្រថាមពលវារីអគ្គិសនី និងធ្យូងថ្ម និងបរិមាណ ថាមពលអគ្គិសនីផលិតតាមរយៈប្រភពទាំងពីរនេះកំពុងតែកើនឡើងក៏ដោយ តាម ការប៉ាន់ស្មាន បរិមាណថាមពលអគ្គិសនីដែលអាចផលិតបានតាមរយៈប្រភពទាំង ពីរនេះមានត្រឹមតែបីភាគរយ[1] នៃថាមពលអគ្គិសនីសរុប នៅឆ្នាំ២០១១ ប៉ុណ្ណោះ នៅ មុនប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយ។[2]

តាមរយៈផែនការឆ្នាំ២០០៣ ដែលបានធ្វើឡើងដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយមានការគាំទ្រពីគណៈកម្មការទន្លេមេគង្គ បានប៉ាន់ប្រមាណថា សក្តានុពលថាមពលវារីអគ្គិសនីរបស់ប្រទេសកម្ពុជា ដែលបានពីការសាងសង់ទំនប់ កាត់ទន្លេពេញផ្ទៃប្រទេស អាចផលិតថាមពលអគ្គិសនីបានប្រហែល ១០.០០០ ម៉េហ្គាវ៉ាត់។[3] នៅឆ្នាំ២០១១ ថាមពលវារីអគ្គិសសនីប្រមាណជា ១.០០០ ម៉េហ្គាវ៉ាត់ ឬ

---

[1] ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឆ្នាំ២០១២

[2] បន្ទាប់ពីការដាក់ដំណើរការទំនប់វារីអគ្គិសនីកំចាយចាប់ពីចុង ឆ្នាំ២០១១ រួមជាមួយទំនប់វារីអគ្គិសនីរោងចក្រ អគ្គិសនីដើរ ដោយថាមពលធ្យូងថ្មមួយចំនួនកំពុងត្រូវគេសាងសង់ ការផលិតថាមពលអគ្គិសនី តាមរយៈប្រភពទាំង នេះនឹងកើនឡើងនៅឆ្នាំបន្តបន្ទាប់។

[3] អាយ ភី អេស (IPS) ឆ្នាំ២០០៨

ត្រូវជា១០% នៃសក្តានុពលថាមពលសរុបត្រូវបានគេដាក់អោយសាងសង់ ហើយមានអនុស្សរណៈយោគយល់លើគម្រោងចំនួន ២.២០០ មេហ្គាវ៉ាត់ បន្ថែមទៀត ដែលត្រូវបានគេចុះហត្ថលេខាយល់ព្រមជាស្រេច។[៤] គម្រោងទំនប់វារីអគ្គិសនីជាច្រើនអាចនាំមកនូវការបាត់បង់ និងមានហេតុប៉ះពាល់ផ្នែកសង្គម និងបរិស្ថានធ្ងន់ធ្ងរ ដោយសារទំនប់ទាំងនោះ បើមិនស្ថិតនៅក្នុងតំបន់ឧទ្យានជាតិ តំបន់ការពារសត្វព្រៃ ក៏ស្ថិតនៅក្នុងតំបន់ដែលសហគមន៍នៅខ្សែទឹកខាងលើ ក៏ដូចជាសហគមន៍នៅខ្សែទឹកខាងក្រោមរស់នៅពឹងអាស្រ័យនឹងទន្លេ ព្រមទាំងធនធានធម្មជាតិដែលនឹងរងប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គិសនីទាំងនោះដែរ។

ការស្រាវជ្រាវថ្មីៗដទៃទៀតអំពីគម្រោងទំនប់វារីអគ្គិសនីកំចាយ បានសិក្សាទៅលើការជាប់ទាក់ទងគ្នារវាងការធ្វើវិនិយោគរបស់ចិន និងថាមពល វារីអគ្គិសនីនៅប្រទេសកម្ពុជា។[៥] ចំណែកការសិក្សាស្រាវជ្រាវនេះវិញផ្តោតលើផលប៉ះពាល់បរិស្ថាន និងសង្គម ដែលបង្កឡើងដោយទំនប់ ជាពិសេសយកចិត្តទុកដាក់លើផលវិបាករបស់សហគមន៍មូលដ្ឋាន ដែលពីមួយជំនាន់ទៅមួយជំនាន់រស់នៅពឹងអាស្រ័យលើអនុផលព្រៃឈើ ដែលបច្ចុប្បន្នត្រូវទឹកជន់លិចធនធានធម្មជាតិដែលធ្លាប់មានច្រើនក្រៃលែងនៅទីនោះ។ គម្រោងទំនប់វារីអគ្គិសនីកំចាយមានវិធានការកាត់បន្ថយហេតុប៉ះពាល់មួយចំនួន ដែលបានសរសេរលំអិតនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម[៦] និងផែនការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុន។ វិធានការទាំងនេះនឹងត្រូវលើកឡើងក្នុងការសិក្សានេះផងដែរ ដើម្បីវាយតម្លៃពីការខិតខំប្រឹង

[៤] ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឆ្នាំ២០១២

[៥] ហ្គ្រីមស្ឌីត្ច (Grimsditch, M.) ឆ្នាំ២០១២; ហេនសេនហ្គឺស (Hensengerth, O.) ឆ្នាំ២០១២; និង មីដុលតុន (Middleton, C.) ឆ្នាំ២០០៨

[៦] ច្បាប់ចុងក្រោយនៃរបាយការណ៍ ESIA គឺនៅខែមេសា ឆ្នាំ២០១១។ របាយការណ៍នេះត្រូវគេដឹងជាទូទៅថាជា ESIA ចុងក្រោយ។ ប៉ុន្តែយោងតាម នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន របាយការណ៍ ESIA ចុងក្រោយត្រូវគេអនុម័ត នៅខែកក្កដា ឆ្នាំ២០១២។ ក្រសួងបរិស្ថានមិនបានចែករំលែករបាយការណ៍ ដែលត្រូវបានគេអនុម័តយល់ព្រមនោះឡើយ ដូច្នេះគេមិនដឹងថាតើរបាយការណ៍នោះដូចនឹងរបាយការណ៍ ESIA នៅខែមេសា ឆ្នាំ២០១១ ដែរឬទេ។

ប្រែងរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តនូវវិធានការ និងផែនការទាំងអស់នោះ។

អត្ថប្រយោជន៍នៃការសាងទំនប់វារីអគ្គិសនីនេះ ត្រូវបានគេមើលឃើញជាក់ច្បាស់តាមរយៈការបង្កើនការផលិតថាមពលអគ្គិសនី និងឱកាសដ៏ប្រសើរក្នុងការគ្រប់គ្រងទឹកស្រោចស្រព និងទឹកជំនន់។ រីឯផលអវិជ្ជមានរបស់ទំនប់វារីអគ្គិសនីវិញ ត្រូវបានគេមើលឃើញតិចតួចណាស់ ហើយពិបាកព្យាករ និងវាយតម្លៃទៀតផង។ យ៉ាងណាមិញ ការឃាំងផ្លូវទឹកត្រូវគេយល់ជាទូទៅថានាំអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជលសាស្ត្ររបស់ទន្លេ និងរបបទឹកជំនន់ដែលបង្កជាឧបសគ្គដល់ការចរាចរបស់ត្រី និងរឹតត្បិតដល់ការនាំដីល្បាប់ដ៏មានជីជាតិ។ ពូជត្រីដែលពឹងផ្អែកលើលំហូរធម្មជាតិរបស់ទន្លេសម្រាប់ពងកូនអាចនឹងបាត់បង់ ហើយផលិតផលកសិកម្មអាចនឹងថយចុះ ដោយសារមិនមានទឹកជំនន់ធម្មជាតិគ្រប់គ្រាន់ និងការធ្លាក់ចុះនៃជីជាតិដី។ កត្តាមួយទៀតគួរពិចារណា នៅពេលប្រទេសកម្ពុជាអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីរបស់ខ្លួននាពេលអនាគតនោះ គឺការបំភាយឧស្ម័នផ្ទះកញ្ចក់ពីអាងស្តុកទឹកដែលរួមចំណែកអោយមានការប្រែប្រួលអាកាសធាតុ ជាពិសេសនៅតំបន់ត្រូពិច ដូច្នេះហើយ វាមិនអាចចាត់ទុកថាជាប្រភពថាមពលស្អាតដោយស្វ័យប្រវត្តិនោះទេ។

អាទិភាពមួយក្នុងចំណោមអាទិភាពសំខាន់ៗ ដែលរាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងក្នុងសិក្ខាសាលាជាតិស្តីពីទស្សនៈវិស័យកម្ពុជា ក្នុងឆ្នាំ២០១២ នៅខែកុម្ភៈ ឆ្នាំ២០១២ នៅទីក្រុងភ្នំពេញនោះ គឺគោលនយោបាយការរីកចំរើនទូលាយគាំទ្រដល់ជនក្រីក្រ។ ស្ថិតក្នុងបរិបទនៃការបញ្ចូលគ្នារវាងទិសដៅកាត់បន្ថយភាពក្រីក្រ និងកំណើននេះហើយដែលការស្រាវជ្រាវនេះធ្វើការវាយតម្លៃនូវផលប៉ះពាល់នៃការសាងសង់ទំនប់វារីអគ្គិសនីទៅលើសហគមន៍មូលដ្ឋាន និងបរិស្ថាន។ ការស្រាវជ្រាវនេះធ្វើឡើងដើម្បីពិនិត្យអោយឃើញថា តើប្រជាជនក្រីក្រមួយចំនួនក្នុងចំណោមប្រជាជនក្រីក្រក្នុងប្រទេសអាច ឬមិនអាចនឹងទទួលបាននូវអត្ថប្រយោជន៍ពីគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីកំចាយដែលមានតម្លៃ២៨០លានដុល្លារអាមេរិក បែបណាខ្លះ។ ទន្ទឹមនឹងនេះ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ ដែលរួមចំណែកក្នុងគោលនយោបាយគាំទ្រជនក្រីក្រ និង

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ត្រូវបានលើកយកមកពិភាក្សាក្នុងការសិក្សានេះផងដែរ។ ក្នុងន័យជំរុញដល់រាល់ភាគីពាក់ព័ន្ធ និងអ្នកធ្វើការសម្រេចចិត្ត ដើម្បីបង្កើត និងពង្រឹងនូវយន្តការការពារទប់ទល់នឹងហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅប្រទេសកម្ពុជា អនុសាសន៍នឹងផ្តល់ជូននៅចុងបញ្ចប់នៃរបាយការណ៍នេះ។

## ១. អំពីទីតាំងសិក្សា

ទំនប់វារីអគ្គិសនីកំចាយស្ថិតនៅឃុំម៉ាក់ប្រាង ស្រុកទឹកឈូ ខេត្តកំពត នៅប្រទេសកម្ពុជា។ ទំនប់នេះមានទីតាំងក្នុងឧទ្យានជាតិបូកគោ នៅជិតព្រំប្រទល់ភាគអាគ្នេយ៍នៃឧទ្យាន។ យោងតាមនាយកដ្ឋានឧទ្យានជាតិ ទំនប់នេះស្ថិតនៅក្នុង «តំបន់ប្រើប្រាស់ដែលមាននិរន្តរភាព» ជាតំបន់គោលដៅប្រើប្រាស់របស់ឧទ្យានជាតិដែលគេអនុញ្ញាតអោយមានការប្រមូលអនុផលព្រៃឈើតំបន់សហគមន៍ព្រៃឈើ តំបន់វិនិយោគ និងតំបន់ការពាររបស់សហគមន៍។ ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ ទទួលបានការអនុញ្ញាតអភិវឌ្ឍថាមពលវារីអគ្គិសនី និងអេកូទេសចរណ៍លើផ្ទៃដីទំហំ២២០០ ហិចតា ក្នុងទីតាំងឧទ្យានជាតិបូកគោ។[៧] ទោះជាទីតាំងគម្រោងនេះមិនតម្រូវឲ្យមានការផ្លាស់ប្តូរទីលំនៅប្រជាជន ដោយសារមិនមានភូមិនៅខ្សែទឹកខាងលើទំនប់ ប៉ុន្តែទីតាំងដែលទឹកជន់លិចនោះជាទីតាំងប្រកបដោយព្រៃឫស្សីក្រាស់ៗដែលជាវត្ថុធាតុដើមដ៏សំខាន់សម្រាប់ការផលិតលួ (កញ្ជែ) របស់ប្រជាជនជាង៥០០គ្រួសារ ដែលរស់នៅសហគមន៍ខាងក្រោមទំនប់។[៨] ការប្រមូលអនុផលព្រៃឈើដទៃទៀតដូចជា ផ្តៅ និងផ្លែឈើព្រៃតាមរដូវកាលជាចំណែកបញ្ចូលគ្នានៃជីវិតអ្នកភូមិជាច្រើនដែលផ្តល់ប្រភពប្រាក់ចំណូលបន្ថែមយ៉ាងសំខាន់ ជាពិសេសនោះសម្រាប់គ្រួសារដែលមានជីវភាពក្រីក្រ។[៩] ផែនទីអាងស្តុកទឹក និងភូមិនៅខ្សែទឹកខាងក្រោមទំនប់អាចមើលនៅក្នុងឧបសម្ព័ន្ធ «ក»។

---

[៧] ក្រសួងបរិស្ថាន, នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២

[៨] ឃុំអណ្តូងខ្មែរ ២០/៨-២០១២

[៩] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ឆ្នាំ២០០៧

តំបន់ដែលទទួលរងផលប៉ះពាល់ដោយការសាងសង់ទំនប់ គ្របដណ្តប់លើឃុំម៉ាក់ប្រាង ឃុំកំពង់ត្រែង និងឃុំអណ្តូងខ្មែរ។ សរុបមានចំនួន១៣ភូមិ នៅក្នុងឃុំទាំងនោះ តែមិនមែនភូមិទាំងអស់សុទ្ធតែរងផលប៉ះពាល់ដោយទំនប់នោះទេ។ ភូមិចំនួន៥ ក្នុងចំណោមភូមិដែលរងផលប៉ះពាល់ច្រើនបំផុតត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ។ តារាងទី១ សង្ខេបព័ត៌មានអំពីឃុំដែលបានធ្វើការសិក្សា។ នៅឃុំម៉ាក់ប្រាង ភូមិមាត់ពាម និងភូមិស្នំប្រាំពីរ ជាភូមិរងផលប៉ះពាល់ដោយផ្ទាល់ពីគម្រោងទំនប់។ ទោះជាភូមិនៅឃុំអណ្តូងខ្មែរស្ថិតនៅឆ្ងាយជាង១០គីឡូម៉ែត្រ ពីតំបន់ទំនប់វារីអគ្គិសនី មានភូមិចំនួនពីរទៀតគឺភូមិអូរតូច និងភូមិថ្មីខាងជើងដែលរងផលប៉ះពាល់ដោយទំនប់យ៉ាងខ្លាំង ដោយសារមានអ្នកភូមិជាច្រើននៅភូមិនេះរស់អាស្រ័យលើព្រៃឫស្សីដែលជន់លិចដោយសារទឹកពីអាងស្តុកទឹករបស់ទំនប់។[១០] ផលប៉ះពាល់លើប្រជាជនរស់នៅឃុំកំពង់ត្រែងមានកម្រិតតិចតួចជាងភូមិអណ្តូងខ្មែរ ប៉ុន្តែក៏មានផលប៉ះពាល់មួយចំនួនពីការសាងសង់ខ្សែបណ្តាញអគ្គិសនី ដែលបញ្ជូនចរន្តអគ្គិសនីចេញពីទំនប់ដែរ។ តារាងទី២ សង្ខេបព័ត៌មានអំពីភូមិទាំងអស់ ដែលត្រូវជ្រើសរើសសម្រាប់ការសិក្សានេះ។

**តារាងទី១: ឃុំដែលបានធ្វើការសិក្សា**[១១]

| ឈ្មោះឃុំ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប | ចំនួនស្ត្រី |
|---|---|---|---|
| ម៉ាក់ប្រាង | ១០៦៣ | ៥១៨៦ | ២៦៣៨ |
| អណ្តូងខ្មែរ | ២១៦៥ | ១០.០៤៧ | ៥៣៣៦ |
| កំពង់ត្រែង | ១៣៩៧ | ៦៧៥៨ | ៣៤៨៨ |

[១០] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; មេឃុំអណ្តូងខ្មែរ ២០/០៨-២០១២

[១១] ទាក់ទាងតាមទូរសព្ទជាមួយមេឃុំម៉ាក់ប្រាង ២៤/១២/២០១២; មេឃុំអណ្តូងខ្មែរ ២០/៨-២០១២; មេឃុំកំពង់ត្រែង ១៦/៨-២០១២; ទាក់ទងតាមទូរសព្ទជាមួយមេឃុំកំពង់ត្រែង ២៤/១១-២០១២

តារាងទី២: ភូមិដែលបានជ្រើសរើសសម្រាប់ការសិក្សា[១២]

| ឈ្មោះភូមិ | ឃុំ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប | ចំនួនស្ត្រី |
|---|---|---|---|---|
| ស្នំប្រាំពីរ | ម៉ាក់ប្រាង | ៦៥៥ | ៣,១០៣ | ១៥៧៤ |
| មាត់ពាម | ម៉ាក់ប្រាង | ៣០៨ | ១,៤៧៥ | ៧៦៥ |
| អូរតូច | អណ្តូងខ្មែរ | ៤៣៥ | ២,១៧៥ | ១១៥១ |
| ថ្មីខាងជើង | អណ្តូងខ្មែរ | ៤៤៥ | ២,៣៨០ | ១២៣២ |
| អណ្តូងជីមើន | កំពង់ត្រែង | ៣៥៣ | ១,៧៤៤ | ៩០៩ |

## លក្ខណៈនៃភូមិនាំងប្រាំ

**ភូមិស្នំប្រាំពីរ:** ចំការដំណាំឈើហូបផ្លែ និងវាលស្រែគ្របដណ្តប់ទិដ្ឋភាពទូទៅនៃភូមិនេះ។លើសពីនេះទៀត រមណីយដ្ឋានទឹកឈ្យូស្ថិតក្នុងភូមិនេះ ដូច្នេះហើយបានជាប្រជាជនក្នុងភូមិនេះ ភាគច្រើនមានមុខរបរទាក់ទងនឹងវិស័យទេសចរណ៍ ដូចជា ការលក់អាហារ ផ្លែឈើ និងភេសជ្ជៈ។ ប្រជាជនចំនួន១៩៨គ្រួសារ មានដីធ្វើស្រែដែលមានទំហំតូចជាង១ហិចតា ហើយ៤៣១គ្រួសារ មិនមានដីធ្វើស្រែទាល់តែសោះ។ ប្រជាជន២៩៨គ្រួសារ មានដីដាំដំណាំឈើហូបផ្លែតូចជាង១ហិចតា ហើយប្រជាជនចំនួន៣១៨គ្រួសារទៀត មិនមានដីដាំដំណាំឈើហូបផ្លែទាល់តែសោះ។ មានអ្នកភូមិចំនួន៥៧នាក់ ក្នុងនោះ១៦នាក់ ជាស្ត្រី ជាអ្នកប្រមូលអនុផលព្រៃឈើ ដែលជាមុខរបរសំខាន់សម្រាប់ពួកគាត់។ ការដាំបន្លែ ការចិញ្ចឹមសត្វ និងការធ្វើនេសាទជាមុខរបរផ្សេងទៀត ដែលមិនសូវពេញនិយមសម្រាប់ប្រជាជននៅភូមិស្នំប្រាំពីរ។ ក្នុងចំណោមអ្នកដែលប្រមូលអនុផលព្រៃឈើនៅក្នុងព្រៃរាល់ថ្ងៃ មានប្រជាជនប្រមាណជា៧០% ចូលទៅកាប់អុស និង៣០%ទៀត ចូលទៅប្រមូលអនុផល

[១២] ទាក់ទងទូរសព្ទជាមួយមេឃុំម៉ាក់ប្រាង ២៤/១២/២០១២; ទាក់ទងទូរសព្ទជាមួយមេឃុំអណ្តូងខ្មែរ ១២/១២/២០១២; អនុប្រធានភូមិថ្មីខាងជើង ២៧/៨-២០១២; ទាក់ទងទូរសព្ទជាមួយមេឃុំកំពង់ត្រែង ១២/១២/២០១២

ផ្សេងៗពីព្រៃឈើ។[១៣] មានប្រជាជនក្នុងភូមិស្នំប្រាំពីរតិចតួចណាស់ដែលចូលទៅកាប់ឫស្សី។[១៤]

**ភូមិមាត់ពាម**: មានអ្នកភូមិប្រមាណជា៧០% មានចំការដំណាំឈើហូបផ្លែ ហើយប្រហែលជា១០% ជាកម្មករធ្វើការនៅក្នុងចំការដំណាំឈើហូបផ្លែនោះ។ អ្នកភូមិស្នំប្រាំពីរតិចតួចណាស់ដែលទៅលក់ផ្លែឈើ ភេសជ្ជៈ និងអាហារនៅរមណីយដ្ឋានទឹកឈូរ ហើយភាគច្រើនពួកគាត់ទៅលក់ដូរនៅថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកពេលបុណ្យទានប៉ុណ្ណោះ។ ទោះបីជា ប្រជាជនភាគច្រើនមិនពឹងផ្អែកលើផលិតផលព្រៃឈើក៏ដោយ មានអ្នកភូមិមាត់ពាមប្រមាណជា៣០គ្រួសារ មានមុខរបរចិញ្ចឹមជីវិតជាអ្នកប្រកបរបរកាប់ឫស្សី និងធ្វើកញ្ច្រែងសម្រាប់ដាក់ត្រីចំហុយ។ អ្នកភូមិប្រមាណជា២០% ជាពិសេសអ្នកដែលមានដីធ្លីតិចតួចទៅប្រមូលអនុផលព្រៃឈើពីភ្នំ។ អ្នកភូមិធ្លាប់ធ្វើការនេសាទខ្លះដែរ ប៉ុន្តែសកម្មភាពនេសាទទាំងនោះគ្រាន់តែជាមុខរបរបន្ទាប់បន្សំរបស់ពួកគាត់ប៉ុណ្ណោះ។[១៥]

**ភូមិអណ្តូងជីមើន**: ភូមិនេះគ្របដណ្តប់ដោយវាលស្រែ និងចំការដំណាំឈើហូបផ្លែ ហើយមានការផលិតស្ករត្នោតពីដើមត្នោតដែលមាននៅក្នុងភូមិ។ ជាទូទៅប្រជាជននៅក្នុងភូមិអណ្តូងជីមើនមិនប្រមូលអនុផលព្រៃឈើទេ ហើយក៏មិនមានការកាប់ឫស្សី ឬការផលិតល្ងួ (កញ្ជ្រែ) ដែរ។ ចំណែកសកម្មភាពទាក់ទងនឹងវិស័យទេសចរណ៍ក៏មិនឃើញមានផងដែរព្រោះអ្នកភូមិអណ្តូងជីមើនមិនមានប្រកបមុខរបររកស៊ីនៅរមណីយដ្ឋានទឹកឈូឡើយ។[១៦]

**ភូមិថ្មីខាងជើង និងភូមិអូរតូច**: ភូមិដែលនៅជិតខាងគ្នាទាំងពីរនេះ គេសំគាល់ដោយមានមុខរបរពឹងអាស្រ័យលើអនុផលព្រៃឈើ ជាពិសេសនោះគឺឫស្សី។ អ្នកភូមិខ្លះមានដីធ្វើស្រែ ប៉ុន្តែភាគច្រើននៃដីស្រែទាំងនោះមានទំហំតូចខ្លាំងណាស់ដែលនាំអោយគ្រួសារមួយចំនួនមិនមានស្រូវគ្រប់គ្រាន់ សម្រាប់បរិភោគអោយបានពេញមួយ

---

[១៣] ស្ថិតិភូមិស្នំប្រាំពីរ ឆ្នាំ២០១១

[១៤] ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[១៥] ទៅពិនិត្យមើល ភូមិអណ្តូងជីមើន ៣០/៨-២០១២

[១៦] ឃុំអណ្តូងខ្មែរ ២០/៨/២០១២

ឆ្នាំឡើយ។ យោងតាមមេឃុំអណ្តូងខ្មែរ មានប្រជាជនចំនួន៣៤៧គ្រួសារ ជាអ្នកប្រកបរបរកាប់ឫស្សី នៅភូមិអូរត្វេច និងមាន១៦០គ្រួសារ ទៀត ជាអ្នកប្រកបរបរកាប់ឫស្សីនៅភូមិថ្មីខាងជើង។ មានអ្នកភូមិតិចតួចណាស់មានមុខរបរជាអ្នកនេសាទ។ ចំពោះអ្នកប្រកបរបរនេសាទពួកគាត់ទៅនេសាទនៅឯសមុទ្រ ដោយមិនទៅនេសាទនៅឯព្រែកកំចាយឡើយ។ ប្រជាជននៅក្នុងភូមិទាំងពីរនេះមិនមានប្រកបមុខរបរនៅរមណីយដ្ឋានទឹកឈូឡើយ។[១៧]

នៅភូមិអូរត្វេច មានដីស្រែសរុប ៦៨.៨ហិចតា ហើយជាមធ្យមមួយគ្រួសារមានដីតូចជាងកន្លះហិចតា។ តាមការប៉ាន់ស្មាន ៧០% ទៅ ៩០% នៃគ្រួសារនៅភូមិអូរត្វេចចូលទៅកាប់ឫស្សីហើយយកមកផលិតជាល្ង (កញ្ជេ) ដែលនេះជាចំណូលដ៏សំខាន់សម្រាប់ពួកគាត់។[១៨] ចំណែកនៅភូមិថ្មីខាងជើង មានប្រជាជនប្រមាណជា ២០គ្រួសារ ប្រកបរបរជាអ្នកធ្វើស្រែ ហើយពាក់កណ្តាលនៃពួកគាត់ចូលទៅកាប់ឫស្សីផងដែរ។ ហើយអ្នកប្រកបរបរធ្វើស្រែទាំងនេះ ភាគច្រើន មានដីស្រែតូចជាង ១ ហិចតា។ ចំពោះប្រជាជនចំនួន១០គ្រួសារផ្សេងទៀត មានដីដាំដំណាំឈើហូបផ្លែ ដូចជា ធូរេន និងចេក។ ដោយសារភូមិនៅជិតនឹងក្រុងកំពត ប្រជាជនមួយផ្នែកមានមុខរបររកស៊ីនៅទីក្រុងកំពត។[១៩]

## ២. អំពីទំនប់វារីអគ្គិសនីកំចាយ

ទំនប់វារីអគ្គិសនីកំចាយដែលមានកំលាំងផលិតថាមពល ១៩៤ម៉េហ្គាវ៉ាត់ ស្ថិតនៅប្រមាណជា១៥គីឡូម៉ែត្រ ពីទីក្រុងកំពត នៅភាគអាគ្នេយ៍នៃរមណីយដ្ឋានទឹកឈូ ហើយមានចំងាយប្រមាណជា៤.៥គីឡូម៉ែត្រ ខាងលើរមណីយដ្ឋានទឹកឈូ។ នៅខាងក្រោមទំនប់ធំ ជាទំនប់ទីពីរដែលស្ថិតនៅប្រមាណជា៣០០ម៉ែត្រ ខាងលើរមណីយដ្ឋានទឹកឈូ។ លើសពីការផ្តល់ទឹកសម្រាប់ផលិតថាមពលអគ្គិសនី គោលបំណងមួយទៀតនៃទំនប់វារីអគ្គិសនីនេះ គឺផ្តល់ជាប្រភពទឹកសម្រាប់ការផ្គត់

---

[១៧] ប្រធានភូមិអូរត្វេច ១៨/៨/២០១២; មេឃុំអណ្តូងខ្មែរ ២០/៨/២០១២; ពិភាក្សាក្រុមនៅភូមិអូរត្វេច ២៩/៨/២០១២

[១៨] អនុប្រធានភូមិថ្មីខាងជើង ២៧/៨/២០១២

[១៩] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១

ផ្តល់ការប្រើប្រាស់ និងទឹកស្រោចស្រពដល់ដីកសិកម្ម។ ទំនប់នេះជាគម្រោងសាងសង់ ប្រតិបត្តិ និងផ្ទេរ រយៈពេល៤៤ឆ្នាំ ដែលជារយៈពេលដ៏យូរក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ នៅខែកុម្ភៈ ឆ្នាំ២០០៦។[២០] ដំណើរការអនុម័តយល់ព្រមលើគម្រោងនេះបានកើតឡើងនៅក្នុងកំឡុងពេលចរចារបិទទ្វារ[២១] ហើយគម្រោងទំនប់វារីអគ្គិសនីនេះហាក់បីដូចជាត្រូវបានគេជម្រុញអោយចេញជារូបរាងយ៉ាងឆាប់រហ័ស ដោយអោយតម្លៃជាចំបងលើការអភិវឌ្ឍថាមពល និងហិរញ្ញវត្ថុ នៅពេលដែលកង្វល់អំពីបរិស្ថាន និងសង្គមស្ទើរតែមិនត្រូវគេយកទៅពិចារណា។ គម្រោងនេះជាគម្រោងទំនប់វារីអគ្គិសនីខ្នាតធំដំបូងគេបង្អស់នៅប្រទេសកម្ពុជា។



រូបភាព: ទំនប់វារីអគ្គិសនីកំចាយ

សមត្ថភាពផលិតរបស់ទំនប់ គឺមានកំលាំងថាមពល ១៩៤ម៉េហ្គាវ៉ាត់ ហើយថាមពលផលិតដែលរំពឹងទុកប្រចាំឆ្នាំគឺ ៤៩៨ ជីហ្គាវ៉ាត់ម៉ោង[២២] (៤៩៨.០០០.០០០ គីឡូវ៉ាត់ម៉ោង)។ ប៉ុន្តែបើយោងតាមប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រី នៅខែកុម្ភៈ ឆ្នាំ២០១៣ នៅរដូវប្រាំងសមត្ថភាពផលិតរបស់ទំនប់អាចថយចុះដល់ ៦០

[២០] របាយការណ៍ ESIA ខែមេសា ឆ្នាំ ២០១២, សេចក្តីសង្ខេបជាភាសាអង់គ្លេស ទំ.៤

[២១] http://www.internationalrivers.org/campaigns/cambodia - ទាញយក ៤/១២/២០១២

[២២] របាយការណ៍ ESIA ខែមេសា ឆ្នាំ ២០១២, សេចក្តីសង្ខេបជាភាសាអង់គ្លេស ទំ.១៥

ម៉េហ្គាវ៉ាត់។[២៣] ថាមពលអគ្គិសនីភាគច្រើនត្រូវគេផលិតតាមរយៈទួប៊ីនចំនួនបីដែលទទួលបានទឹកពីបំពង់បញ្ចេញទឹកក្រោមដី។[២៤] ទំនប់នេះគឺជាសំណង់កំពស់១១២ម៉ែត្រ ដែលមានកម្រិតទឹកអតិប្បរមា១៥២ម៉ែត្រ ខ្ពស់ជាងកម្រិតទឹកសមុទ្រ។ កម្រិតផ្ទុកពេញសមត្ថភាពរបស់អាងគឺ១៥០ម៉ែត្រ និងកម្រិតដំណើរការអតិបរិមាគឺ១៣០ម៉ែត្រ ខ្ពស់ជាងកម្រិតទឹកសមុទ្រ។ កម្រិតទឹកក្នុងអាងស្តុកទឹក នៅខែសីហា ឆ្នាំ២០១២គឺមានកំពស់១៤៨ម៉ែត្រ ខ្ពស់ជាងកម្រិតទឹកសមុទ្រ។[២៥] ទោះជាមានផែនការថានឹងអភិវឌ្ឍតំបន់គម្រោងអោយទៅជាតំបន់សម្រាប់ទាក់ទាញទេសចរក៏ដោយ បច្ចុប្បន្នតំបន់គម្រោងទំនប់វារីអគ្គិសនីត្រូវបានការពារដោយទាហានជាច្រើន និងរបងលួសបន្លាហើយមិនអនុញ្ញាតអោយចូលទៅមើលទំនប់ជាសាធារណៈឡើយ។

ទីតាំងទំនប់ស្ថិតនៅក្នុងរមណីយដ្ឋានទឹកឈូ នាំអោយមានការតវ៉ាជំទាស់ដោយសារមានការបាត់បង់ព្រៃឈើ សត្វព្រៃ និងជីវចម្រុះនៅក្នុងតំបន់ និងផលប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹករបស់ព្រែកកំចាយ។ យ៉ាងណាមិញផ្ទៃដីប្រមាណជា ២,០០០ហិចតា (២គីឡូម៉ែត្រការ៉េ) ដែលបាត់បង់សម្រាប់ធ្វើអាងស្តុកទឹកមានទំហំតូចនៅឡើយ បើសិនប្រៀបធៀបទៅនឹងគម្រោងទំនប់វារីអគ្គិសនីដទៃទៀត ដូចជាគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលមានសមត្ថភាពផលិតថាមពល៤០០ម៉េហ្គាវ៉ាត់ នៅខេត្តស្ទឹងត្រែង។ គម្រោងទំនប់សេសានក្រោម២ រំពឹងថានឹងជន់លិចផ្ទៃដីដ៏ធំធេងប្រមាណជា៣៤,៣០៨ហិចតា។[២៦] ប្រសិនជាគម្រោងនេះប្រព្រឹត្តដូចផែនការមែននោះ វាអាចនឹងជន់លិចផ្ទៃដីជាង១៧ដង នៃផ្ទៃអាងស្តុកទឹករបស់ទំនប់កំចាយ នៅពេលដែលគម្រោងទំនប់នេះផលិតថាមពលអគ្គិសនីបានច្រើនជាងត្រឹមតែ២ដងនៃទំនប់កំចាយប៉ុណ្ណោះ។ នេះនាំអោយមានចម្ងល់ពីប្រសិទ្ធភាពនៃការប្រើប្រាស់ដី ដែលជាកត្តាគួរត្រូវពិចារណាសម្រាប់គម្រោងទំនប់

---

[២៣] http://cnv.org.kh/en/?p=3495 - ទាញយក ១១/៣/២០១៣

[២៤] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១២, សេចក្តីសង្ខេបជាភាសាអង់គ្លេស ទំ.៤ និងក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/10/2012

[២៥] ក្រុមហ៊ុនស៊ីណូហៃដ្រូ ឆ្នាំ ២០០៧; ទៅពិនិត្យមើលទំនប់វារីអគ្គិសនីកំចាយ ២៩/៨/២០១២

[២៦] ឌីខេមបូឌាដេលី ២៤-២៥/១១/២០១២

វារីអគ្គិសនីពាក់ព័ន្ធផ្សេងទៀត។ តាមទស្សនៈនៃការប្រើប្រាស់ដីប្រយោជន៍នៃទីតាំងទំនប់កំចាយគឺ ផ្ទៃដីដែលត្រូវជន់លិចមានទំហំតូច។ ទោះជាយ៉ាងនេះក្តី អត្ថប្រយោជន៍នេះនៅមានទំហំតិចតួចនៅឡើយ ដើម្បីជួសជុលផលប៉ះពាល់ទាំងឡាយដែលកើតឡើងនៅតំបន់រងគ្រោះដោយសារគម្រោងទំនប់វារីអគ្គិសនី។

## ៣. វិធីសាស្ត្រស្រាវជ្រាវ

### ៣.១ ការចុះសិក្សា និងសម្ភាសន៍នៅតំបន់គម្រោង

ការចុះទៅសិក្សាស្រាវជ្រាវនៅតំបន់គម្រោង បានធ្វើឡើងលើកទីមួយនៅខែសីហា ចាប់ពី ថ្ងៃទី១៤ ដល់ ថ្ងៃទី៣១ លើកទីពីរ នៅខែកញ្ញា ចាប់ពីថ្ងៃទី១៤ ដល់ ថ្ងៃទី១៨ និងម្តងទៀត ធ្វើនៅខែតុលា ចាប់ពី ថ្ងៃទី១៧ ដល់ ថ្ងៃទី២០ ឆ្នាំ២០១២ នៅឃុំចំនួនបី ដែលមានទីតាំងនៅតំបន់ដែលទទួលរងផលប៉ះពាល់ដោយសារទំនប់វារីអគ្គិសនីកំចាយនៅខេត្តកំពត។ ព័ត៌មាននៅក្នុងរបាយការណ៍នេះផ្អែកលើការសម្ភាសពិស្តារ និងការពិគ្រោះយោបល់ជាមួយសមាជិកគ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង សង្គមស៊ីវិល ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានរួមជាមួយព័ត៌មានដែលបានពីការរំលឹកទ្រឹស្តីពាក់ព័ន្ធផ្សេងៗ (សូមមើលឧបសម្ព័ន្ធ ខ» សម្រាប់បញ្ជីអ្នកដែលបានសម្ភាសន៍)។

ជាផ្នែកមួយនៃការចុះសិក្សាស្រាវជ្រាវនៅតំបន់គម្រោង ក្រុមអ្នកស្រាវជ្រាវបានធ្វើការស្ទង់មតិជាមួយប្រជាជនចំនួន ១០០គ្រួសារ មកពីសហគមន៍ដែលស្ថិតនៅតំបន់រងផលប៉ះពាល់ដោយសារគម្រោង។ ក្នុងនោះ ក្រុមអ្នកស្រាវជ្រាវបានសម្ភាសន៍អ្នកប្រកបរបរកាប់ឫស្សីចំនួន ៧៨នាក់ មកពីភូមិអូរតូច ភូមិថ្មីខាងជើង និងភូមិមាត់ពាម និងអ្នកប្រកបរបរលក់ដូរចំនួន ២២នាក់ នៅរមណីយដ្ឋានទឹកឈូ ដើម្បីស្វែងយល់អំពីឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានដែលកើតចេញពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ ដើម្បីស្វែងយល់ និងទទួលបានមតិយោបល់ពីរាល់ភាគីពាក់ព័ន្ធក្រុមអ្នកស្រាវជ្រាវបានខិតខំសម្ភាសន៍មន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ រួមមានមន្ត្រីថ្នាក់ក្រសួង និងថ្នាក់មន្ទីរនានា។ ក៏ប៉ុន្តែ ដោយសារហេតុផលមួយចំនួន ដែលក្រុមអ្នក

ស្រាវជ្រាវបានជួបប្រទះ ភាគីពាក់ព័ន្ធមួយចំនួនបានបដិសេធមិនផ្តល់ព័ត៌មានសម្រាប់ការសិក្សានេះ។

មានការសម្ភាសរវាងបុគ្គលម្នាក់ៗ និងការពិភាក្សាជាក្រុម ដើម្បីធ្វើយ៉ាងណាអោយទទួលបានព័ត៌មានច្រើនពីសហាគមន៍ដែលរងគ្រោះដោយសារគម្រោង។ ក្រុមអ្នកស្រាវជ្រាវបានជ្រើសរើសតំបន់សម្ភាសន៍ ដោយផ្អែកលើព័ត៌មានដែលបានពីការស្រាវជ្រាវឯកសារពាក់ព័ន្ធ ដូចជារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជំហានដំបូង ឆ្នាំ២០០៦ និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ខែមេសា ឆ្នាំ២០១១[២៧] ព្រមទាំងព័ត៌មានដែលទទួលបានពីបុគ្គលសំខាន់ៗដែលយល់ដឹងអំពីទីតាំងគម្រោង និងសហាគមន៍ដែលរងគ្រោះដោយគម្រោង។ អ្នកដែលបានចូលរួមក្នុងការសម្ភាស ភាគច្រើនត្រូវបានជ្រើសរើសនៅនឹងភូមិ និងតំបន់ជុំវិញគម្រោងដោយផ្ទាល់ ហើយការជ្រើសរើសក៏ផ្អែកលើព័ត៌មានដែលទទួលបានពីភាគីពាក់ព័ន្ធដែរ។ ក្នុងពេលរៀបចំ និងកំឡុងពេលសម្ភាសន៍ ក្រុមអ្នកស្រាវជ្រាវបានយកចិត្តទុកដាក់លើការយកព័ត៌មានជាក់លាក់អំពីយៃនឌ័រ។ ជាទូទៅ ក្រុមស្រាវជ្រាវសម្ភាសន៍អាជ្ញាធរមូលដ្ឋាននៅក្នុងសហាគមន៍មុនគេ បន្ទាប់មកធ្វើការសម្ភាសពិស្តារ និង ធ្វើការពិភាក្សាជាក្រុមជាមួយអ្នកភូមិដែលរងគ្រោះដោយសារគម្រោងទំនប់វារីអគ្គិសនី។ ក្រៅពីការស្ទង់មតិជាមួយក្រុមគ្រួសារតាមផ្ទះ មានការសម្ភាសជាង៤៥ករណី និងការអង្កេតផ្ទាល់បានធ្វើឡើងនៅតំបន់សិក្សានេះផងដែរ។ ដើម្បីទទួលបានចំណេះដឹងអំពីផលប៉ះពាល់នៅតំបន់គម្រោង ក្រុមអ្នកស្រាវជ្រាវបានទៅពិនិត្យមើលនៅអាងស្តុកទឹកដោយផ្ទាល់ផងដែរ។

---

[២៧] ទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានរៀបចំដោយក្រុមហ៊ុន សាវ៉ាក់ (SAWAC) សម្រាប់ក្រុមហ៊ុនស៊ីណូហៃដ្រូ ។ យោងតាមនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម សម្រាប់ទំនប់វារីអគ្គិសនីកំចាយ ត្រូវបានគេអនុម័តយល់ព្រមនៅខែកក្កដា ឆ្នាំ២០១២។ ទោះបីអ្នកស្រាវជ្រាវខិតខំស្នើសុំច្បាប់ចំលងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពីក្រសួងបរិស្ថាន ប៉ុន្តែការខិតខំនេះមិនអាចទៅរួចឡើយ។

## ៣.២ គន្លាប្រឈមក្នុងការទទួលបានព័ត៌មាន

តាមរយៈការស្រាវជ្រាវនេះ បានបង្ហាញអំពីការប្រឈមក្នុងការទទួលបានព័ត៌មានអំពីទំនប់វារីអគ្គិសនីកំចាយ ហើយនឹងតួនាទីនៃស្ថាប័នរដ្ឋាភិបាលមួយចំនួន។ មន្ត្រីនៅក្រសួងមួយចំនួនមិនបានឆ្លើយតបទៅនឹងសំណើសុំសម្ភាសន៍របស់អ្នកស្រាវជ្រាវ ហើយស្ថាប័នរដ្ឋាភិបាលដទៃទៀតទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត បានបដិសេធមិនផ្តល់ព័ត៌មានដល់ក្រុមអ្នកស្រាវជ្រាវ។ ហេតុផលទូទៅនៃការបដិសេធសំណើសុំសម្ភាសន៍នោះគឺថា គម្រោងទំនប់វារីអគ្គិសនីកំចាយជាគម្រោងថ្នាក់ជាតិ។ ចំណែកឯមន្ត្រីពាក់ព័ន្ធនៅថ្នាក់ជាតិវិញ បែរជាមិនចាប់អារម្មណ៍ ឬបានច្រានចោលសំណើសុំជួបសម្ភាសន៍ ឬប្រជុំជាមួយពួកគេទៅវិញ។

## ៣.៣ ការបង្ហាញ និង ការបញ្ជាក់ពីភាពពិតត្រឹមត្រូវនៃលទ្ធផលស្រាវជ្រាវ

បន្ទាប់ពីមានការចុះសិក្សាស្រាវជ្រាវដោយផ្ទាល់ និងកិច្ចសម្ភាសន៍នៅតំបន់គម្រោង កិច្ចពិភាក្សាពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋានត្រូវបានធ្វើឡើងចំនួនពីរលើកផ្សេងគ្នា នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ នៅខេត្តកំពត។ កិច្ចពិភាក្សាពិគ្រោះយោបល់នេះ ធ្វើឡើងក្នុងគោលបំណងដើម្បីជម្រាបដល់ភាគីពាក់ព័ន្ធថ្នាក់មូលដ្ឋានអំពីលទ្ធផលនៃការស្រាវជ្រាវ និងដើម្បីបញ្ជាក់ព័ត៌មាន និងទិន្នន័យដែលទទួលបានពីសហគមន៍ទាំងនោះ។ ការបង្ហាញលទ្ធផលស្រាវជ្រាវដល់សហគមន៍ឃើញថាមានការពិភាក្សាយ៉ាងសកម្ម ដែលនាំអោយមានចំណុចជាច្រើនទៀត ត្រូវបញ្ជាក់បន្ថែមអោយបានកាន់តែច្បាស់ជាមួយសហគមន៍។ សមាជិកសហគមន៍ចំនួន១៥នាក់ ដែលបានចូលរួមក្នុងកម្មវិធីនោះ បានចែករំលែកបទពិសោធន៍ផ្ទាល់ដែលពួកគាត់បានជួបប្រទះ។[២៨] បន្ថែមលើបទបង្ហាញលទ្ធផលស្រាវជ្រាវដល់សមាជិកសហគមន៍ដែលបានរៀបចំធ្វើនៅពេលព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ អាជ្ញាធរមូលដ្ឋានក៏ត្រូវបានអញ្ជើញអោយចូលរួមក្នុងការស្តាប់បទបង្ហាញអំពីរបកគំហើញដូចគ្នានៅពេលរសៀលផងដែរ។ តែគួរអោយសោកស្តាយមានអាជ្ញាធរមូលដ្ឋានតែម្នាក់គត់ ក្នុងចំណោមអាជ្ញាធរមូលដ្ឋានទាំងឡាយដែលគេ

[២៨] ការបង្ហាញរបកគំហើញទៅសហគមន៍មូលដ្ឋាន ខេត្តកំពត ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

រំពឹងថានឹងចូលរួមកម្មវិធីនោះបានមកចូលរួម។[២៩] ក្នុងការខិតខំផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវអោយបានទៅដល់អ្នកសម្រេចចិត្តថ្នាក់មូលដ្ឋាន ក្រុមអ្នកស្រាវជ្រាវបានចែកចាយច្បាប់ថតចម្លងនៃបទបង្ហាញដល់អាជ្ញាធរមូលដ្ឋានមួយចំនួន។ ក្នុងនាមជាអ្នកតំណាងអោយសង្គមស៊ីវិល អ្នកតំណាងមកពីសមាគមអាដហុក អង្គការសិទ្ធិមនុស្សលីកាដូនៅខេត្តកំពត និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាបានចូលរួមក្នុងកម្មវិធីធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវនេះផងដែរ។

[២៩] ការបង្ហាញរបកគំហើញដល់អាជ្ញាធរមូលដ្ឋាន ខេត្តកំពត ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

## ១. ទស្សនៈអំពីការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅប្រទេសកម្ពុជា

នៅពេលថ្មីៗនេះ លោកអូលីវើ ហិនសុិនហ្គឺស (Oliver Hensengerth) បានសិក្សាអំពីកម្រិតនៃការអនុវត្តតាមស្តង់ដាបរិស្ថាន និងសង្គមក្នុងបរិបទថ្នាក់ជាតិ និងអន្តរជាតិ ដោយក្រុមហ៊ុនចិនដែលវិនិយោគលើថាមពលវារីអគ្គិសនីនៅប្រទេសកម្ពុជា។ ជាងនេះទៀត គាត់បានសិក្សាស្វែងយល់អំពីតួនាទីដែលបំពេញដោយភាគីប្រទេសកម្ពុជា និងភាគីប្រទេសចិន។ យោងតាមរបាយការណ៍នៅឆ្នាំ២០១២ គាត់បានធ្វើការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់លើការគ្រប់គ្រងបរិស្ថាន ដែលគេអនុវត្តនៅក្នុងបរិបទប្រទេសកម្ពុជា ដើម្បីអោយដឹងថា តើរាជរដ្ឋាភិបាលកម្ពុជាពិតជាបានធ្វើការពិនិត្យតាមដានក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ ដែលដំណើរការទំនប់វារីអគ្គិសនីកំចាយពិតប្រាកដដែរ ឬទេ។[៣០] ក្រុមហ៊ុនចិនកំពុងតែ ឬនឹងសាងសង់ស្ថានីយថាមពលវារីអគ្គិសនីចំនួន៧ ដែលជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។[៣១] វាមានសារៈសំខាន់ខ្លាំងណាស់ដែលក្រុមហ៊ុនទាំងនោះសហការជាមួយរាជរដ្ឋាភិបាលកម្ពុជានិងប្រជាជនរងគ្រោះដោយគម្រោងក្នុងក្របខណ្ឌនៃការថែរក្សាសង្គម និងបរិស្ថាននៅមុនពេលនៅកំឡុងពេល និងនៅក្រោយពេលសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងទំនប់វារីអគ្គិសនី។ រីឯការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់ទំនប់កំចាយនេះវិញ នឹងពិនិត្យកាន់តែស៊ីជម្រៅពីតួនាទីដែលរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ ត្រូវបំពេញ ហើយវាអាចជាការបំពេញបន្ថែមលើរបកគំហើញរបស់ លោក ហិន សុិនហ្គឺសផងដែរ។

[៣០] ហិនសិនហ្គឹស (Hensengerth, O.) ២០១២, ទំ. ៤

[៣១] ហិនសិនហ្គឹស (Hensengerth, O.) ២០១២, ទំ. ៥

នៅឆ្នាំ២០០៧ ប្រហែលជា៩០% នៃថាមពលអគ្គិសនីផលិតក្នុងស្រុក អាស្រ័យដោយប្រេងឥន្ធនៈ។[៣២] កម្រិតទាបនៃអគ្គិសនីកម្ម និងតម្លៃប្រេងឥន្ធនៈថ្លៃ បង្ហាញថាប្រទេសកម្ពុជាត្រូវបង្កើនការផលិតអគ្គិសនី និងការធ្វើឲ្យមានស្វ័យផ្គត់ផ្គង់ថាមពលអគ្គិសនីប្រកបដោយនិរន្តរភាព។ ហេតុផលទាំងនេះហាក់បីដូចជាកម្លាំងរុញច្រានចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា ឲ្យកាន់តែចង់អភិវឌ្ឍថាមពលវារីអគ្គិសនី។ ទោះជាយ៉ាងណាក៏ដោយ ក្នុងដំណើរការនៃការធានាអោយបាននូវការផ្គត់ផ្គង់អគ្គិសនីប្រកបដោយទំនុកចិត្ត ដើម្បីបំពេញតម្រូវការរីកចំរើនសេដ្ឋកិច្ចនោះ ប្រទេសកម្ពុជាមិនទាន់មានលទ្ធភាពចៀសផុតពីបញ្ហាបរិស្ថាន និងសង្គម ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍថាមពលវារីអគ្គិសនីខ្នាតធំនៅឡើយទេ។

នៅក្នុងរបាយការណ៍ផ្សាយនៅឆ្នាំ២០០០ របស់គណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនី បង្ហាញពីសេចក្តីត្រូវការនៃការប្រែក្លាយការគ្រប់គ្រងទំនប់វារីអគ្គិសនី ដោយមិនត្រឹមតែសម្រេចបាននូវគោលបំណងបច្ចេកទេសប៉ុណ្ណោះទេ ថែមទាំងរាប់បញ្ចូល និងអោយអទិភាពដល់គោលបំណងអភិវឌ្ឍន៍ផងដែរ តាមរយៈការពិចារណាទៅលើកត្តាសង្គម និងបរិស្ថាន។ អនុសាសន៍នេះបានធ្វើឡើងដោយយោងតាមការសិក្សាដ៏ទូលំទូលាយរបស់គណៈកម្មការពិភពលោកស្តីពីទំនប់ ដោយធ្វើការពិនិត្យលើទំនប់វារីអគ្គិសនីធំៗចំនួន១,០០០នៅជុំវិញពិភពលោក។[៣៣] តាមរយៈភាពលំបាកដែលកើតចេញពីទស្សនៈបច្ចេកទេស និងសេដ្ឋកិច្ច ការទទួលយកវិធីគ្រប់គ្រងដែលអាចប្រែប្រួលបានជារឿងសំខាន់ សម្រាប់ការសម្រេចចិត្តនានាដែលអាចប្រែប្រួលទៅតាមបរិបទនៃលក្ខខណ្ឌបរិស្ថាន សង្គម និងរូបសាស្ត្រ។ ដើម្បីបំពេញតម្រូវការផ្សេងទៀតជាជាងបំពេញតែតម្រូវការនៃការផលិតថាមពលអគ្គិសនីនោះ អ្នកប្រតិបត្តិគម្រោងទំនប់វារីអគ្គិសនីត្រូវតែមានឆន្ទៈទំនាក់ទំនង និងសហការអោយបានល្អជាមួយភាគីពាក់ព័ន្ធទាំងឡាយ ដោយរាប់បញ្ចូលទាំងសហគមន៍មូលដ្ឋានផងដែរ។[៣៤]

---

[៣២] ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ខែកក្កដា ឆ្នាំ២០០៩; ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឆ្នាំ២០១២

[៣៣] គណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនី ឆ្នាំ២០០០ ទំព័រ. iii

[៣៤] គណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនី ឆ្នាំ២០០០ ទំព័រ. ២៧៤

វិស័យវារីអគ្គិសនីនៅប្រទេសកម្ពុជា កំពុងរីកចំរើនយ៉ាងឆាប់រហ័ស។ ប៉ុន្តែ ដោយសារប្រទេសមួយនេះមិនទាន់មានបទពិសោធន៍ និងជំនាញគ្រប់គ្រាន់សម្រាប់សាងសង់ទំនប់វារីអគ្គិសនីខ្នាតធំៗដោយខ្លួនឯងបាន ប្រទេសកម្ពុជាបច្ចុប្បន្នពឹងផ្អែកលើក្រុមហ៊ុនចិន សម្រាប់ការអភិវឌ្ឍទំនប់វារីអគ្គិសនីទាំងនោះ។ ដូចគ្នានេះដែរ ប្រទេសកម្ពុជាមានបទពិសោធន៍តិចតួចក្នុងការធានាបាននូវកិច្ចការពារបរិស្ថាន និងសង្គមដ៏ល្អប្រសើរសម្រាប់គម្រោងអភិវឌ្ឍន៍ដែលមានផលប៉ះពាល់ខ្ពស់។ របកគំហើញមួយផ្សេងទៀតរបស់គណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនី គឺខ្វះដំណើរការវាយតម្លៃជាផ្លូវការសម្រាប់គម្រោងទំនប់វារីអគ្គិសនីខ្នាតធំៗ ជុំវិញពិភពលោក។[៣៥] តាមរយៈបទពិសោធន៍ដ៏មានកម្រិតនៅក្នុងប្រទេសកម្ពុជា មានហានិភ័យខ្ពស់នៃការបង្កើតកំហុសឆ្គងដដែលៗ ដោយការសម្រេចចិត្តមិនបានត្រឹមត្រូវដែលការសម្រេចិត្តទាំងនោះត្រូវគេធ្វើឡើងដោយមិនមានចំណេះដឹងគ្រប់គ្រាន់។ ទន្លេ និងធនធានធម្មជាតិដ៏សន្ទឹកសន្ធាប់ ព្រមទាំងធនធានជលផលដ៏ច្រើនក្រៃលែងនៃប្រទេសកម្ពុជា ជាទ្រព្យសម្បត្តិដ៏មានតម្លៃបម្រើប្រយោជន៍អោយប្រជាជននៅទីជនបទ។ លោក មីដុលតុន (Middleton) ក្រើនរំលឹកថា «ការអភិវឌ្ឍថាមពលវារីអគ្គិសនីដែលមិនមានការគិតពិចារណាពេញលេញ អាចនឹងធ្វើអោយខូចធនធានទាំងអស់នោះជារៀងរហូត»[៣៦] ដូច្នេះហើយបានជាមានការតស៊ូមតិអោយរាជរដ្ឋាភិបាលកម្ពុជា អនុវត្តតាមអនុសាសន៍នៅក្នុងរបាយការណ៍របស់គណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនី។ គណៈកម្មការពិភពលោក ស្តីពីទំនប់វារីអគ្គិសនី បានជម្រុញផងដែរថា ការទូទាត់សំណងគួរតែគិតគូដល់ «រាល់ការបាត់បង់ឱកាសនៃការចិញ្ចឹមជីវិត ដូចជាការបាត់បង់ឱកាសនៃការធ្វើនេសាទ»។[៣៧] ដូចគ្នានេះដែរ ការបាត់បង់ឱកាសចូលទៅកាប់ឫស្សី ឬក៏រកអនុផលព្រៃឈើគួរតែត្រូវទូទាត់សំណងជូនផងដែរ។ ស្រដៀងគ្នានេះដែរ អង្គការទន្លេអន្តរជាតិបានផ្តល់អនុសាសន៍ផងដែរថា គម្រោងទំនប់វារីអគ្គិសនី គួរផ្តល់សិទ្ធិដល់អ្នកដែលអ្នករងគ្រោះដោយគម្រោង

[៣៥] គណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនី ឆ្នាំ២០០០ ទំព័រ. ៣១២

[៣៦] មីដុលតុន (Middleton) ឆ្នាំ២០០៨ ទំព័រ. ៥

[៣៧] គណៈកម្មការពិភពលោក ស្តីពីទំនប់វារីអគ្គិសនី ឆ្នាំ២០០០ ទំព័រ. ២៧២

ដើម្បីធ្វើអោយការចិញ្ចឹមជីវិតរបស់ពួកគាត់ប្រសើរឡើង។[៣៨] បន្ថែមលើយន្តការការពារបរិស្ថាន និងសង្គម ការសិក្សានេះក៏ត្រួតពិនិត្យផងដែរ នូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រង និងពិនិត្យតាមដានការអនុវត្តគម្រោងទំនប់វារីអគ្គិសនីកំចាយ។

## ២. ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅប្រទេសកម្ពុជា

ក្របខណ្ឌច្បាប់សម្រាប់ដំណើរការ នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បង្ហាញពីសេចក្តីណែនាំសម្រាប់បង្កើត និងអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ យោងតាមគោលការណ៍សម្រាប់រៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ២០០៩ ក្នុងប្រទេសកម្ពុជា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញគឺត្រូវបង្កើតវិធីសាស្ត្រនានា ដើម្បីកំណត់អោយបាននូវហេតុប៉ះពាល់អវិជ្ជមាន និងធ្វើអោយប្រសើរឡើងនូវរាល់ហេតុប៉ះពាល់អវិជ្ជមានទាំងនោះ។[៣៩] យ៉ាងណាមិញ នៅមានកំហុសឆ្គងមួយចំនួនក្នុងក្របខណ្ឌនៃការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឧទាហរណ៍ មិនទាន់មានភាពច្បាស់លាស់ទាក់ទងទៅនឹងការចូលរួម ហើយភាគច្រើនប្រការនេះមិនត្រូវបានគេអនុវត្តនៅឡើយ។ តាមរយៈការសិក្សាមួយនៅឆ្នាំ២០០៨ លោក មីដុលតុន បានរកឃើញថាការគ្រប់គ្រងហេតុប៉ះពាល់បរិស្ថាន និងសង្គម នៃការសាងសង់ទំនប់វារីអគ្គិសនីមិនត្រូវបានគេបង្ហាញជាសាធារណៈឡើយ។ដូច្នេះហើយផែនការណាមួយសម្រាប់ស្តារឡើងវិញនូវការចិញ្ចឹមជីវិត ឬសម្រាប់គ្រប់គ្រងបរិស្ថានមិនមានសម្រាប់សាធារណជនឡើយ។ កង្វះខាតនៃការផ្សាយអោយដឹងជាសារណៈនេះហើយ នាំអោយភាគីពាក់ព័ន្ធមិនអាចដឹងបានថាតើគម្រោងទំនប់វារីអគ្គិសនីផ្តល់ផលប្រយោជន៍អ្វីខ្លះ ដល់សហគមន៍មូលដ្ឋានដែលរងគ្រោះដោយសារគម្រោងអភិវឌ្ឍន៍នោះ។[៤០]

---

[៣៨] http://www.internationalrivers.org/resources/the-world-commission-on-dams-framework- a-brief-introduction-2654 - ទាញយកអត្ថបទ ៤/១២/២០១២

[៣៩] សេចក្តីប្រកាសគោលការណ៍ទូទៅសម្រាប់ការសរសេររបាយការណ៍ជំហ៊ានដំបូងនិងចុងក្រោយស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន, ឧបសម្ព័ន្ធ១

[៤០] មីដុលតុន (Middleton, C.) ឆ្នាំ២០០៨, ទំព័រ.៦៦

សេចក្តីណែនាំ នៅឆ្នាំ២០០៩ លើកឡើងថា ផែនការគ្រប់គ្រងបរិស្ថាន គួរបញ្ចូល *«កាលវិភាគសម្រាប់ធ្វើការត្រួតពិនិត្យបរិស្ថាននៅកំឡុងពេលនៃសាងសង់ ប្រតិបត្តិការ និងការបញ្ចប់គម្រោង»* លើសពីនេះអ្នកអនុវត្តគម្រោងគួរកំណត់ថា អ្នកណានឹងពិនិត្យតាមដានគម្រោងទំនប់វារីអគ្គិសនី ហើយស្តង់ដាបរិស្ថានអ្វីខ្លះ ឬគោលការណ៍ណាខ្លះត្រូវបានគេអនុញ្ញាត។[៤១] ប្រាកដណាស់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម រួមនឹងផែនការគ្រប់គ្រងបរិស្ថាន ត្រូវមាននៅមុនការចាប់ផ្តើមគម្រោង ដូច្នេះ គេអាចប្រើសម្រាប់ពិនិត្យតាមដានគម្រោងនៅដំណាក់កាលសាងសង់គម្រោងទំនប់វារីអគ្គិសនី។ គេមិនបានអនុវត្តបែបនេះសម្រាប់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីកំចាយទេ ដោយសារគោលការណ៍សម្រាប់ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនត្រូវបានអនុវត្តត្រឹមត្រូវ។

សារៈសំខាន់នៃការស្នើអោយមានស្តង់ដាខ្ពស់ សម្រាប់ទំនប់វារីអគ្គិសនីកំចាយនោះ គឺត្រូវលើកឡើងដោយ លោក មីដុលតុន ដែលយល់ឃើញថា គេគួរធានាអោយមាន *«ដំណើរការសម្រេចចិត្តប្រកបដោយគណនេយ្យភាព ការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធប្រកបដោយតម្លាភាព និង ការចូលរួមជាសាធារណៈយ៉ាងទូលំទូលាយ ពីសំណាក់ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គិសនី និងអង្គការសង្គមស៊ីវិល»*។[៤២] យ៉ាងណាមិញ សេចក្តីប្រាថ្នាចង់អោយរាជរដ្ឋាភិបាលកម្ពុជា អនុវត្តតាមស្តង់ដាខ្ពស់ សម្រាប់គម្រោងទំនប់វារីអគ្គិសនីកំចាយមិនអាចប្រព្រឹត្តទៅបានឡើយ ដោយសារក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូខកខានមិនបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមអោយបានទាន់ពេលវេលាតាមដែលគោលការណ៍តម្រូវអោយធ្វើនៅមុនពេលការសាងសង់ទំនប់វារីអគ្គិសនីត្រូវបានចាប់ផ្តើម។ តាមពិតនោះការអនុម័តយល់ព្រមលើរបាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានគេធ្វើឡើងប្រហែលជាប្រាំពីរខែ បន្ទាប់ពីការសម្ពោធដាក់អោយដំណើរការទំនប់វារីអគ្គិសនី

[៤១] សេចក្តីប្រកាសគោលការណ៍ទូទៅសម្រាប់ការសរសេររបាយការណ៍ជំហានដំបូង និងចុងក្រោយស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន, ឧបសម្ព័ន្ធ១

[៤២] មីដុលតុន (Middleton, C.) ឆ្នាំ២០០៨ ទំព័រ.៦៦

កំចាយនេះ។[៤៣] ករណីនេះ វាហួសពេលទៅហើយដែលរបាយការណ៍អាចបំពេញតួនាទីណាមួយក្នុងដំណើរការនៃការសម្រេចចិត្ត។ ការមិនយកចិត្តទុកដាក់លើការបង្កើតរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជាមួយនឹងដំណើរការអភិវឌ្ឍមិនច្បាស់លាស់ ជាសញ្ញាណមិនល្អសម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅក្នុងប្រទេសនៅពេលអនាគត។ ប្រសិនបើដំណើរការអនុម័តយល់ព្រមលើគម្រោងទំនប់វារីអគ្គិសនីកំចាយក្លាយជាគំរូមួយនៅក្នុងវិស័យនេះ វាបានជះឥទ្ធិពលអវិជ្ជមានរួចទៅហើយដល់គម្រោងថាមពលអគ្គិសនីដទៃទៀត ដែលគេបាននឹងកំពុងសាងសង់។

ទោះជាការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ យឺតយ៉ាវយ៉ាងនេះក្តី នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថានបានផ្តល់យោបល់ថា ការធ្វើការវាយតម្លៃហេតុប៉ះពាល់ ក្រោយពីគម្រោងទំនប់វារីអគ្គិសនីកំចាយបានបញ្ចប់ដូចជាការវាយតម្លៃនេះជាដើម វាជាការរួសរាន់ពេកហើយ។

កាន់តែព្រួយបារម្ភទៀតនោះ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានយល់ឃើញថា ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានគួរតែចាប់ផ្តើមនៅខែមករា ឆ្នាំ២០១៣ ដែលមានរយៈពេល៦ខែ បន្ទាប់ពីការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។[៤៤] ការយោងទៅតាមហេតុផលដែលថាការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន គួរតែប្រព្រឹត្តទៅបន្ទាប់ពីការអនុម័តយល់ព្រមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បាន៦ខែ នាំអោយដំណោះស្រាយផ្សេងៗទៅនឹងហេតុប៉ះពាល់សង្គម និងបរិស្ថាន នៅកំឡុងដំណាក់កាលសាងសង់មិនត្រូវគេអើពើឡើយ។ យោងតាមហេតុផលនេះការខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងការបាត់បង់ប្រាក់ចំណូលក្នុងចំណោមសហាគមន៍រងគ្រោះដោយសារគម្រោងទំនប់វារីអគ្គិសនីកំចាយត្រូវបានគេអនុវត្តយឺតយ៉ាវខ្លាំងពេកដែលមិនអាចបំពេញនូវគោលបំណងរបស់សហាគមន៍បាន។

---

[៤៣] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន, ១០/១០-២០១២

[៤៤] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន ១០/១០-២០១២

ការផ្តល់រយៈពេលដ៏ខ្លីសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ធ្វើអោយលទ្ធភាពនៃការថែរក្សាបរិស្ថាន និងបំរើអោយការការពារសង្គមប្រកបដោយប្រសិទ្ធិភាព កាន់តែមានភាពទន់ខ្សោយ។ រយៈពេលចំនួន៣០ថ្ងៃ ជារយៈពេលកំណត់ដោយច្បាប់សម្រាប់រាជរដ្ឋាភិបាលកម្ពុជាពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលរយៈពេលនេះរាប់បញ្ចូលទាំងរយៈពេលនៃកិច្ចពិគ្រោះយោបល់ជាសាធារណៈផងដែរ។ តាមរយៈពេលវេលានេះ គេត្រូវធ្វើសេចក្តីសម្រេចចិត្ត ដើម្បីសម្រេចថាតើគម្រោងទំនប់វារីអគ្គិសនីនោះគួរអនុម័តយល់ព្រមដែរឬទេ។[៤៥] ចំនុចខ្សោយពាក់ព័ន្ធនឹងបញ្ញត្តិនេះគឺថា «ប្រសិនបើក្រសួងបរិស្ថានមិនបានឆ្លើយតបនឹងលទ្ធផលស្រាវជ្រាវ និងអនុសាសន៍នៃរបាយការណ៍ (ក្នុងរយៈពេល៣០ថ្ងៃ) ទេ ក្រសួង ឬស្ថាប័នដែលទទួលបន្ទុកអនុម័តយល់ព្រមលើគម្រោងនឹងសន្មត់ថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជំហ៊ានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលគេពិនិត្យឡើងវិញនោះស្របតាមលក្ខណៈវិនិច្ឆ័យនៃអនុក្រឹត្យ។[៤៦] លោក កាវេនណា (Kavenagh) បារម្ភអំពីផលវិបាកដែលអាចកើតមានពីបញ្ញត្តិនេះថា *«បើយើងក្រឡេកមើលសមត្ថភាពដ៏មានកម្រិតរបស់ក្រសួងបរិស្ថាន ដើម្បីពិនិត្យឡើងវិញនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាទិដ្ឋភាពច្បាប់មួយដែលគួរអោយបារម្ភណាស់។ ក្នុងន័យនេះ ប្រសិនបើ ការពិនិត្យឡើងវិញទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនបានធ្វើឡើង ដូច្នេះរបាយការណ៍នោះត្រូវគេចាត់ទុកថាអនុម័តយល់ព្រម។»*[៤៧]

## ២.១ ទិសដៅអនាគតនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

កាលពីខែវិច្ឆិកា ឆ្នាំ២០១២ ក្រសួងបរិស្ថានបានបញ្ជាក់ថា នៅចន្លោះឆ្នាំ ២០០៤ ដល់ ឆ្នាំ២០១១ មានគម្រោងអភិវឌ្ឍន៍ត្រឹមតែ ១១០គម្រោងប៉ុណ្ណោះ ក្នុងចំណោមគម្រោងអភិវឌ្ឍន៍ប្រហែលជា ២.០០០គម្រោង ដែលបានបញ្ជូន

[៤៥] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា/កាវេនណាហ្វ (Kavenagh, M. et al.) ឆ្នាំ២០១២ ទំព័រ. ១៦

[៤៦] អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩ មាត្រា១៨

[៤៧] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា/កាវេនណាហ្វ (Kavenagh, M. et al.) ឆ្នាំ២០១២ ទំព័រ. ១៧

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មកកាន់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ដោយសារការអនុវត្តតាមដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានភាពទន់ខ្សោយបែបនេះ ការធ្វើបច្ចុប្បន្នភាពក្របខណ្ឌនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការពង្រឹងការអនុវត្តដំណើរការរបស់វាជាកត្តាចាំបាច់។ កត្តាប្រឈមចំបងនោះ គឺថាច្បាប់ដែលមានរួចហើយមិនមានទម្ងន់គ្រប់គ្រាន់ដើម្បីធានាអោយក្រុមហ៊ុនទាំងឡាយនោះធ្វើការត្រួតពិនិត្យបរិស្ថាន ដែលគេតម្រូវអោយធ្វើមុនពេលចាប់ផ្តើមគម្រោងទំនប់វារីអគ្គិនីរបស់ខ្លួន។ កង្វះចំណាត់ការនៃការផាកពិន័យចំពោះក្រុមហ៊ុន ដែលមិនបានបញ្ជូនរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងៗទៀត ដែលនាំអោយក្រុមហ៊ុនទាំងនោះមិនសូវគោរពតាមគោលការណ៍ច្បាប់។[៤៨] ឆ្លើយតបនឹងបញ្ហានេះ បញ្ញត្តិនៅក្នុងច្បាប់ពង្រាងស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានចែងអំពីការពិន័យតាមច្បាប់ចំពោះក្រុមហ៊ុននិងបុគ្គលហើយការតម្រូវអោយមានការពិគ្រោះយោបល់ជាមួយសហាគមន៍ ដែលរងគ្រោះដោយសារគម្រោងទំនប់វារីអគ្គិសនី អាចនឹងត្រូវគេបញ្ជាក់បន្ថែម។ ដោយការធ្វើអោយមានការចូលរួមជាសារធារណៈជាដំណាក់កាលដ៏សំខាន់ ក្រុមហ៊ុនគួរផ្សាយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គេ តាមរយៈប្រព័ន្ធអ៊ិនធឺណិត ដែលអាចធ្វើអោយសាធារណជនស្វែងរករបាយការណ៍នោះបានកាន់តែច្រើន។ សំខាន់បំផុតនោះក្នុងបរិបទប្រទេសកម្ពុជាបច្ចុប្បន្នច្បាប់ថ្មីនេះអាចចែងផងដែរ អំពីសេចក្តីតម្រូវរាល់គម្រោងទំនប់វារីអគ្គិសនី និងសកម្មភាពទាំងអស់អោយគោរពតាមច្បាប់ ទោះបីជាមានការអនុញ្ញាតពីក្រសួងដទៃក៏ដោយ។ ក្រសួងបរិស្ថានចាត់ទុកច្បាប់ពង្រាងថ្មីថាជាគន្លឹះដើម្បីចៀសផុតពីការមិនចុះសម្រុងគ្នារវាងក្រុមហ៊ុនអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី និងសហាគមន៍មូលដ្ឋាន។[៤៩]

នៅក្នុងសេចក្តីអធិប្បាយស្តីពីការទូទាត់សំណង និងការរៀបចំការតាំងទីលំនៅជាថ្មីដល់អ្នកភូមិ ដែលជាប់ពាក់ព័ន្ធទៅនឹងទំនប់វារីអគ្គិសនីសេសានក្រោម

[៤៨] ការសែតឌឺខេមបូឌាដៃលី ២៣/១១/២០១២
[៤៩] ការសែតឌឺខេមបូឌាដៃលី ២៣/១១/២០១២

២ អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីប្រាប់អោយដឹងថា រាជរដ្ឋាភិបាលកម្ពុជា«*ប្រាថ្នាចង់បានកិច្ចការទាំងអស់ត្រូវបានគេដោះស្រាយរួចរាល់រវាងប្រជាជន និងក្រុមហ៊ុន*» តាមហេតុផលនេះរដ្ឋាភិបាល«*មិនចង់ជ្រៀតជ្រែកការងារនេះឡើយ*» ប៉ុន្តែ «*ចង់ផ្តល់សិទ្ធិដល់ក្រុមហ៊ុនអភិវឌ្ឍន៍ និងប្រជាជនឯកភាពគ្នាទៅវិញទៅមក។*» លើសពីនេះទៅទៀតការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីដោះស្រាយជម្លោះត្រូវបានផ្តល់យោបល់ដោយអ្នកនាំពាក្យរូបនោះផងដែរថា «*ដោយហេតុនេះហើយ យើងអោយយោបល់ថាករណីទាំងនេះត្រូវបញ្ជូនទៅតុលាការ។*» [៥០] នៅពេលថ្លឹងថ្លែងពីភាពសាកសម និងផលប្រយោជន៍ដែលអាចកើតមាន ឬក៏គុណវិបត្តិនានានៃគោនយោបាយបែបនេះ សមត្ថភាពចរចាដ៏ទន់ខ្សោយរបស់ប្រជាជននៅទីជនបទ ដែលគេជិតអោយរើចេញពីដីធ្លីរបស់ខ្លួនគួរត្រូវបានគេពិចារណា។ ប្រជាជនជាច្រើនមិនទាន់មានមធ្យោបាយខ្សែបណ្តាញ និងបទពិសោធន៍នៅឡើយ ដូច្នេះហើយពួកគាត់ស្ថិតក្នុងជំហរមួយដែលទន់ខ្សោយ ក្នុងការទៅតតាំងជាមួយក្រុមហ៊ុន ឬក៏អ្នកអភិវឌ្ឍន៍គម្រោងដែលមានទំនាក់ទំនងនយោបាយ និងទទួលបានការប្រឹក្សាយោបល់ផ្លូវច្បាប់ប្រសើរជាងពួកគាត់។ អ្នកភូមិហាក់ដូចជាមិនអាចប្រជែងក្នុងបណ្តឹងតុលាការបែបនេះបានឡើយ។

[៥០] លោកផាយស៊ីផាន, អ្នកនាំពាក្យទីស្តីការរដ្ឋមន្ត្រី, ភ្នំពេញប៉ុស្តិ៍២៩/១១/២០១២

# លទ្ធផលនៃការស្រាវជ្រាវ

## ១. ផលប៉ះពាល់លើការចិញ្ចឹមជីវិត និងប្រាក់ចំណូល

ការសាងសង់ទំនប់វារីអគ្គិសនីកំចាយបានជះឥទ្ធិពលដល់ប្រាក់ចំណូល និងការចិញ្ចឹមជីវិតនៃសមាជិកសហគមន៍នៅទីនោះរាប់រយនាក់។ ជាពិសេស អ្នកប្រកបរបរកាប់ឫស្សី និងអ្នកចូលទៅប្រមូលអនុផលព្រៃឈើ ព្រមទាំងអ្នកលក់ដូរនៅរមណីយដ្ឋានទឹកឈូជាអ្នកដែលរងផលប៉ះពាល់អវិជ្ជមាន ដោយសារការផ្លាស់ប្តូរដែលបង្កឡើងដោយការសាងសង់ទំនប់។ ការជន់លិចព្រៃឫស្សីដ៏ណែនណាន់តាន់តាប់ និងសំខាន់បំផុត ព្រមទាំងតំបន់ប្រមូលអនុផលព្រៃឈើនៅទឹកឈូ ដើម្បីជាកន្លែងធ្វើអាងស្តុកទឹករបស់ទំនប់ធ្វើអោយមានការលំបាក និងកាត់បន្ថយការចូលទៅប្រមូលធនធានធម្មជាតិទាំងនោះ ដែលសហគមន៍មូលដ្ឋានពឹងអាស្រ័យសម្រាប់ការចិញ្ចឹមជិវិតរបស់ពួកគាត់។ ទន្ទឹមគ្នានេះដែរ អ្នកលក់ដូរនៅរមណីយដ្ឋានទឹកឈូបានកត់សម្គាល់ថា ចំនួនភ្ញៀវទេសចរបានថយចុះជាបន្តបន្ទាប់ដោយសារការសាងសង់ទំនប់ ហើយវាបានធ្វើឲ្យថយចុះនូវកម្រិតទឹក និងបង្កអោយមានការបំពុលទឹកយ៉ាងខ្លាំង។ ដោយសារតែការជន់លិចនៃអាងស្តុកទឹក អ្នកប្រកបរបរកាប់ឫស្សីសម្រាប់ចិញ្ចឹមជីវិតជាង ៥០០គ្រួសារ ឥឡូវត្រូវតែធ្វើដំណើរក្នុងចំងាយឆ្ងាយជាងមុនដើម្បីទៅកាប់ឫស្សី។ លើសពីនេះទៀត ដោយសារការធ្វើដំណើរយ៉ាងឆ្ងាយ សព្វថ្ងៃអ្នកប្រកបរបរកាប់ឫស្សីជាច្រើនយល់ឃើញថា វាចាំបាច់ណាស់ដែលពួកគាត់ត្រូវស្នាក់នៅក្នុងព្រៃដើម្បីកាប់ឫស្សី។[៥១]

### ១.១ ផលប៉ះពាល់ដែលអ្នកប្រកបរបរកាប់ឫស្សីជួបប្រទះ

#### ១.១.១ ការប្រមូលផល ការខិតខំ និងការប្រើប្រាស់ពេលវេលាកាប់ឫស្សី

នៅមុនពេលការសាងសង់ទំនប់វារីអគ្គិសនី អ្នកប្រកបរបរកាប់ឫស្សីភាគច្រើនប្រើកង់ជាមធ្យោបាយធ្វើដំណើរទៅកាប់ឫស្សី និងដឹកជញ្ជូនឫស្សីត្រលប់ពីតំបន់ទឹក

---

[៥១] ឃុំម៉ាក់ប្រាង ១៥/៨/២០១២; ប្រធានភូមិមាត់ពាម ១៨/៨/២០១២; ប្រធានភូមិស្នំប្រាំពីរ ១៧/៨/២០១២

ឈូមកវិញ។ តាមការស្ទង់មតិជាមួយអ្នកប្រកបរបរកាប់ឬស្សីចំនួន ៧៨នាក់ មកពីភូមិអូរតូច ភូមិថ្មីខាងជើង និងភូមិមាត់ពាម បង្ហាញថាមាន ៩៧% នៃពួកគាត់បានប្រើកង់ជាមធ្យោបាយធ្វើដំណើរទៅកាប់ឬស្សី នៅមុនការសាងសង់ទំនប់វារីអគ្គិសនី។ ក្រោយការសាងសង់ទំនប់វារីអគ្គិសនី មានអ្នកប្រកបរបរកាប់ឬស្សីត្រឹមតែ ៣៣% ប៉ុណ្ណោះ ធ្វើដំណើរទៅកាប់ឬស្សីដោយកង់ ហើយពួកគេប្រមាណជា ៣៦% ធ្វើដំណើរទៅកាប់ឬស្សីដោយម៉ូតូ។ លើសពីនេះទៀត សព្វថ្ងៃអ្នកប្រកបរបរកាប់ឬស្សី ៨១% ប្រើក្បូនឆ្លងអាងស្តុកទឹកដើម្បីធ្វើដំណើរទៅកាប់ឬស្សី ហើយ ៧៨% នៃពួកគាត់ត្រូវតែប្រើរថយន្តឈ្នួលដើម្បីដឹកជញ្ជូនឬស្សីត្រលប់មកផ្ទះវិញ។ ប្រជាជនត្រូវធ្វើដំណើរឆ្លងអាងស្តុកទឹកទៅកាប់ឬស្សីដើម្បីអោយបានទៅដល់តំបន់ដែលមានឬស្សីច្រើនជាងតំបន់នៅខាងក្រោមទំនប់វារីអគ្គិសនី។ ការផ្លាស់ប្តូរនៃមធ្យោបាយប្រមូលផលឬស្សីមានបង្ហាញនៅក្នុងគំនូសតាងទី១។

**ការផ្លាស់ប្តូរទីតាំង និងរយៈពេលប្រមូលផលឬស្សី**

យោងតាមអ្នកប្រកបរបរកាប់ឬស្សីជាច្រើនអ្នកមកពីភូមិអូរតូច និងភូមិថ្មីខាងជើងបានអោយដឹងថា ទំហំព្រៃឬស្សីដែលបាត់បង់ដោយសារអាងស្តុកទឹកមានទំហំធំជាងតំបន់ព្រៃឬស្សីដែលនៅសេសសល់។[៥២] អនុប្រធានភូមិ ថ្មីខាងជើងបានប៉ាន់ប្រមាណថា តំបន់ព្រៃឬស្សី ប្រមាណជា២០% នៃតំបន់ព្រៃឬស្សីសរុប បានបាត់បង់ដោយសារអាងស្តុកទឹកនៃទំនប់វារីអគ្គិសនីកំចាយ។ ប៉ុន្តែគាត់ក៏បានប្រាប់ឲ្យដឹងផងដែរថា នៅពេលប្រៀបធៀបព្រៃឬស្សីនៅសេសសល់នៅក្បែរ ឬនៅខាងក្រោមទំនប់វារីអគ្គិសនី ដែលអាចចូលទៅប្រមូលផលរួចវិលត្រឡប់បានមានតិចជាងព្រៃឬស្សីដែលបានជន់លិចខ្លាំងណាស់។ ពីមុនពួកគាត់ចូលទៅប្រមូលផលឬស្សីនៅតំបន់ដីទំនាប ហើយមិនចាំបាច់ត្រូវឡើងភ្នំ និងជម្រាលភ្នំដូចពួកគាត់ធ្វើនៅពេលបច្ចុប្បន្ននោះឡើយ។ ទោះបីជាជួបប្រទះនូវការលំបាកយ៉ាងណាក៏ដោយ អនុប្រធានភូមិថ្មីខាងជើងមិនបានឃើញអ្នកភូមិឈប់ទៅប្រមូលអនុផលព្រៃឈើឡើយ។ គាត់បាន

[៥២] បុរសកាប់ឬស្សីមកពីភូមិអូរតូច ២០/៨/២០១២; គ្រួសារកាប់ឬស្សីពីភូមិអូរតូច ២២/៨/២០១២; ស្ត្រីត្បាញលូនៅភូមិថ្មីខាងជើង ១៧/៨/២០១២; ការពិភាក្សាក្រុមនៅភូមិថ្មីខាងជើង ២៧/៨/២០១២; ពិភាក្សាក្រុមភូមិអូរតូច ២៩/៨/២០១២

បញ្ជាក់ថា *"មុខរបរចំបងរបស់ពួកគេគឺទៅកាប់ឫស្សីហើយនឹងធ្វើល្វ ដូចនេះតើអោយពួកគេឈប់ម្តេចកើត?"*[៥៣] ប្រធានភូមិអូរតូចបានពន្យល់ថា ឥឡូវអ្នកភូមិត្រូវធ្វើដំណើរទៅកាប់ឫស្សីឆ្ងាយជាងមុន ហើយពួកគាត់ត្រូវភ្ញាក់ពីព្រលឹមជាងមុន។ ទោះបីជាការធ្វើដំណើរទៅដល់ទំនប់មានភាពងាយស្រួលជាងមុន ដោយសារមានផ្លូវថ្មីក៏ដោយអ្នកប្រកបរបរកាប់ឫស្សីត្រូវដើរឆ្ងាយជាងមុនពីកន្លែង ដែលគេកាប់ឫស្សីមកដល់កន្លែងទុកកង់របស់ពួកគាត់។[៥៤]




គំនូសតាង១: មធ្យោបាយធ្វើដំណើរទៅកាប់ឬស្សីនៅមុន និងក្រោយការសាងសង់ទំនប់

នៅមុនពេលការសាងសង់ទំនប់ អ្នកប្រកបរបរកាប់ឫស្សីទាំងអស់ចូលទៅកាប់ឫស្សីនៅតំបន់ទឹកឈ្វដែលត្រូវទឹកជន់លិចនៅពេលបច្ចុប្បន្ន។ ពួកគាត់អាចកាប់ឫស្សីបានគ្រាប់គ្រាន់នៅតំបន់នោះពេញមួយឆ្នាំ ព្រោះវាជាព្រៃឫស្សីក្រាស់ និងមានទិន្នផលខ្ពស់ ដោយសារវាស្ថិតនៅវាលទំនាបតាមមាត់ព្រែកកំចាយ។ ប្រធាននាយកដ្ឋានឧទ្យានជាតិនៃក្រសួងបរិស្ថានបានពន្យល់ថា ព្រៃឫស្សីធ្លាប់មានច្រើនបំផុតនៅតាមមាត់ព្រែកកំចាយ ហើយមានតិចតួចបំផុតនៅតាមជម្រាលភ្នំ។[៥៥]

---

[៥៣] អនុប្រធានភូមិថ្មីខាងជើង ២៧/៨/២០១២

[៥៤] ប្រធានភូមិអូរតូច ១៨/៨/២០១២

[៥៥] នាយកដ្ឋានឧទ្យានជាតិនៃក្រសួងបរិស្ថាន ៩/១០/២០១២

សព្វថ្ងៃនេះ អ្នកប្រកបរបរកាប់ឫស្សីត្រូវចូលទៅកាប់ឫស្សីបើមិននៅតាមជម្រាលភ្នំនៅក្បែរទំនប់ ក៏នៅតាមតំបន់នៅក្បែរអាងស្តុកទឹកដែរ។ តំបន់ព្រៃឫស្សីធំៗ និងមានទិន្នផលខ្ពស់បំផុតដែលនៅសល់ គឺស្ថិតនៅផ្នែកម្ខាងទៀត នៃអាងស្តុកទឹកដែលមានទំហំប្រមាណជា ២០០០ហិចតា (២០គីឡូម៉ែត្រការ៉េ)។ មានតែទូក ឬក្បូនប៉ុណ្ណោះ ដែលអាចទៅដល់តំបន់ឫស្សីនេះ។[៥៦] យោងតាមការស្ទង់មតិជាមួយអ្នកប្រកបរបរកាប់ឫស្សី ៩៧% នៃពួកគាត់បានប្រាប់ថាតំបន់ព្រៃឫស្សីឥឡូវនៅឆ្ងាយជាងមុន។ អ្នកប្រកបរបរកាប់ឫស្សីភាគច្រើនត្រូវតែឆ្លងអាងស្តុកទឹកដើម្បីទៅកាប់ឫស្សី ហើយមានតែ ២៤% នៃពួកគាត់ប៉ុណ្ណោះទៅកាប់ឫស្សីនៅជម្រាលភ្នំនៅតំបន់ក្បែរទំនប់ដែលជាតំបន់ពួកគេអាចធ្វើដំណើរទៅដល់ដោយកង់។



រូបភាពៈ អ្នកប្រកបរបរកាប់ឫស្សីជាមួយកង់របស់គាត់ នៅជិតទំនប់កំចាយ

នៅពេលចូលទៅរកកាប់ឫស្សីនៅម្ខាងទៀត នៃជម្រាលភ្នំ ពួកគាត់ត្រូវដើរយ៉ាងហោចណាស់ពី ១ម៉ោង ទៅ ៣ម៉ោង ដើម្បីទៅដល់កន្លែងកាប់ឫស្សី។ តំបន់ជម្រាលភ្នំនៅជិតទំនប់ ដែលមានព្រៃឫស្សីរប៉ាត់រប៉ាយនោះ ពិបាកចូលទៅដល់ ហើយព្រៃឫស្សីនៅទីនោះ មិនសូវមានទិន្នផល និងគុណភាពខ្ពស់ឡើយ។ ឥឡូវឫស្សីពិបាករកជាងមុន ហើយអ្នកប្រកបរបរកាប់ឫស្សីភាគច្រើនកាប់ឫស្សីបានតិចជាងមុន ឬពួកគាត់ត្រូវចំណាយពេលយូរជាងមុន ដើម្បីកាប់ឫស្សីអោយបានប្រហាក់ប្រហែលមុនពេល

[៥៦] ការពិភាក្សាក្រុមនៅភូមិអូរតូច ២៩/៨/២០១២; ពិភាក្សាក្រុម ភូមិថ្មីខាងជើង ២៧/៨/២០១២; បុរសប្រកបរបរកាប់ឫស្សី មកពីភូមិអូរតូច ២០/៨/២០១២; គ្រួសារប្រកបរបរកាប់ឫស្សីភូមិអូរតូច ២២/៨/២០១២; ស្ត្រីត្បាញល្ហ នៅភូមិថ្មីខាងជើង១៧/៨/២០១២; បុរសប្រកបរបរកាប់ឫស្សី ២០/១០/២០១២

សាងសង់ទំនប់កំចាយ។[៥៧] នៅមុនពេលសាងសង់ទំនប់ អ្នកប្រកបរបរកាប់ឫស្សីត្រូវដើរប្រហែលជា៥០ ទៅ ៥០០ម៉ែត្រ ហើយប្រើពេលច្រើនបំផុត៣០នាទី ទៅ ១ម៉ោង ដើម្បីជញ្ជូនឫស្សីត្រលប់មកដល់ផ្លូវ និងកង់របស់ពួកគាត់។ ប៉ុន្តែ បន្ទាប់ពីទំនប់វារីអគ្គិសនីត្រូវបានគេសាងសង់រួច ចំពោះអ្នកចូលទៅកាប់ឫស្សីនៅតាមជម្រាលភ្នំនៅជិតទំនប់វារីអគ្គិសនី ត្រូវដើរឆ្ងាយជាងមុនខ្លាំងណាស់។ ៥៧% នៃពួកគាត់ត្រូវដើររយៈពេល២ ទៅ ៣ម៉ោង យូរជាងមុនពេលសាងសង់ទំនប់វារីអគ្គិសនី ដើម្បីចូលទៅកាប់ឫស្សី ហើយមាន៣០% នៃពួកគាត់ត្រូវដើរលើសពី៣ម៉ោង យូរជាងកាលដែលគេដើរទៅកាប់ឫស្សីពីមុនការសាងសង់ទំនប់វារីអគ្គិសនី។ ចំពោះអ្នកឆ្លងអាងស្តុកទឹកធ្វើដំណើរទៅកាប់ឫស្សី ពួកគាត់ត្រូវតែជិះក្បូនយ៉ាងហោចណាស់ក៏២ម៉ោងដែរ ហើយជាទូទៅពួកគាត់ត្រូវសម្រាកក្នុងព្រៃចាប់ពី២ទៅ៤យប់។ ពួកគាត់ត្រូវតែសម្រាកក្នុងព្រៃជាច្រើនយប់ ដោយសារការធ្វើដំណើរយូរជាងមុន និងត្រូវកាប់ឫស្សីអោយបានច្រើនគ្រប់គ្រាន់ ដើម្បីសល់ប្រាក់មួយចំនួនក្រោយពីទូទាត់សោហ៊ុយធ្វើដំណើរ។[៥៨]

ទោះបីជាអ្នកប្រកបរបរកាប់ឫស្សីជួបការលំបាកខ្លាំងជាងមុនក៏ដោយ ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ ឬក៏រាជរដ្ឋាភិបាលសុទ្ធតែមិនបានខិតខំប្រឹងប្រែងដោះស្រាយនូវបម្រែបម្រួលនៃឱកាសដែលអាចចូលទៅរកកាប់ឫស្សី និងការថយចុះនៃបរិមាណព្រៃឫស្សីដែលនៅសេសសល់នៅឡើយ។ ក្នុងការសម្ភាសន៍មន្ត្រីជាច្រើនមិនបានដឹងទាល់តែសោះអំពីផលលំបាក ដែលអ្នកប្រកបរបរកាប់ឫស្សីបានជួបប្រទះបន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនី។ ការមិនបានដឹងព័ត៌មាននេះកើតចេញមកពីការខ្វះខាតចំណេះដឹងអំពីស្ថានភាពជាក់ស្តែង ដែលសហគមន៍បានប្រឈម។ ឧទាហរណ៍ មន្ត្រីខ្លះបានប្រាប់អោយដឹងថា ការប្រមូលផលឫស្សីឥឡូវងាយស្រួលជាងមុន ដោយសារការសាងសង់ផ្លូវថ្មីនៅខាងក្រោមទំនប់ និងការដែល

---

[៥៧] ការពិភាក្សាក្រុមនៅភូមិអូរតូច ២៩/៨/២០១២; ការពិភាក្សាក្រុមនៅភូមិថ្មីខាងជើង ២៧/៨/២០១២; បុរសប្រកបរបរកាប់ឫស្សី មកពីភូមិអូរតូច ២០/៨/២០១២; គ្រួសារប្រកបរបរកាប់ឫស្សី ភូមិអូរតូច ២២/៨/២០១២; ស្ត្រីត្បាញល្អីនៅភូមិថ្មីខាងជើង១៧/៨/២០១២; បុរសប្រកបរបរកាប់ឫស្សី ២០/១០/២០១២

[៥៨] ការស្ទង់មតិពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២; អ្នកប្រកបរបរកាប់ឫស្សី និងបើកក្បូន ២០/១០/២០១២

អ្នកប្រកបរបរកាប់ឫស្សីអាចបណ្តែតឫស្សីតាមទឹកនៅក្នុងអាងស្តុកទឹក។[៥៩] ក៏ប៉ុន្តែពួកគេមិនបានពន្យល់អោយបានច្បាស់ថា តើផ្លូវថ្មីនោះអាចជួយអ្នកប្រកបរបរកាប់ឫស្សីដែលធ្លាប់ចូលទៅកាប់ឫស្សី នៅកន្លែងដែលត្រូវទឹកជន់លិចនៅពេលបច្ចុប្បន្នដូចម្តេចនោះទេ។ ផ្លូវអាចចូលទៅដល់ទំនប់ ប៉ុន្តែការចូលទៅអោយដល់តំបន់ប្រមូលឫស្សីកាលពីមុននោះត្រូវបានឃាំងជិតឈឹងដោយសារទំនប់វារីអគ្គិសនី។ លើសពីនេះទៀត ការបណ្តែតឫស្សីតាមទឹកក្នុងអាងមានភាពងាយស្រួលតិចតួចណាស់ដល់អ្នកប្រកបរបរកាប់ឫស្សី ព្រោះគេត្រូវជញ្ជូនឫស្សីពីកន្លែងដែលគេកាប់វានៅម្ខាងទៀតនៃអាងស្តុកទឹក ហើយនៅកន្លែងចតក្បូនដែលស្ថិតនៅមាត់ច្រាំងនៃអាងស្តុកទឹកតាមដងភ្នំនៅខាងស្តាំនៃទំនប់វារីអគ្គិសនី។





រូបភាព: ក្បូនដឹកអ្នកប្រកបរបរកាប់ឫស្សីតាមអាងស្តុកទឹក(រូបខាងឆ្វេង) និងអ្នកប្រករបរកាប់ឫស្សីកំពុងចងឫស្សីដែលកាប់បានដាក់លើម៉ូតូរបស់គេ (រូបខាងស្តាំ)

### ១.១.២ ការរកប្រាក់ចំណូល និងការពឹងអាស្រ័យលើមុខរបរកាប់ឫស្សី

ដំណើរការនៃការផលិតល្អី (កញ្ជ្រែ) ចាប់ផ្តើមពីការកាប់ឫស្សី។ ជាទូទៅ ប្តីជាអ្នកធ្វើដំណើរទៅកាប់ឫស្សីសម្រាប់ផលិតល្អីប្រមាណជា ១០ល្អី (កញ្ជ្រែ) អាស្រ័យទៅតាមទំហំនៃល្អី (កញ្ជ្រែ) ដែលគេផលិតផងដែរ។ ក្រោយមកប្រពន្ធ និងប្តី ជួនកាលមានការជួយពីកូនៗ នាំគ្នាច្រៀក និងបិតឫស្សីនោះ ហើយត្បាញជាល្អីនៅផ្ទះ។

[៥៩] ឃុំអណ្តូងខ្មែរ២០/១០/២០១២; នាយកដ្ឋានឧទ្យានជាតិនៃក្រសួងបរិស្ថាន ៩/១០/២០១២; មន្ទីរបរិស្ថានខេត្តកំពត ១៨/១០/២០១២; ប្រធានភូមិអូរត្នូច ១៨/៨/២០១២

ជាទូទៅ ក្នុងរយៈពេល២ថ្ងៃ គ្រួសារមួយអាចផលិតលួ (កញ្ជែ) បានចំនួន១០ ដែលគេអាចលក់បានប្រហែលជា៤០.០០០រៀល វាស្មើនឹងប្រាក់ចំណូល ២០.០០០រៀល ក្នុង១ថ្ងៃ ក្នុងមួយគ្រួសារ សម្រាប់ការងារមនុស្សចំនួនពីរនាក់។ បែបបទនៃការប្រមូលផលឫស្សី និងការផលិតលួ (កញ្ជែ) ត្រូវគេធ្វើបែបនេះដដែលៗជាបន្តបន្ទាប់ និងត្រូវគេអនុវត្តបែបនេះពីមួយជំនាន់ទៅមួយជំនាន់។[៦០] ជាធម្មតា ឈ្មួញកណ្តាលទិញលួ (កញ្ជែ) ទាំងនោះ ហើយយកវាទៅលក់បន្តនៅខេត្តដទៃទៀត។ នៅរដូវនេសាទ មានតម្រូវការលួ (កញ្ជែ) ជាច្រើននៅតំបន់បឹងទន្លេសាប។

យោងតាមការស្ទង់មតិ អ្នកភូមិជាច្រើនបានជួបប្រទះនឹងការបាត់បង់ប្រាក់ចំណូលពីការប្រកបមុខរបរកាប់ឫស្សី ក្រោយពេលការសាងសង់ទំនប់វារីអគ្គិសនី។ ប្រាក់ចំណូលរបស់អ្នកប្រកបមុខរបរកាប់ឫស្សីបានធ្លាក់ចុះ ដោយសារការលំបាក និងពេលវេលាចំណាយក្នុងការចូលទៅកាប់ឫស្សី។ ស្របពេលគ្នានេះដែរ ការកើនឡើងនៃការចំណាយក្នុងការធ្វើដំណើរទៅកាប់ឫស្សីបាននាំអោយមានការកាត់បន្ថយប្រាក់ចំណេញដែលបានមកពីការផលិតលួ (កញ្ជែ) ។ នៅពេលធ្វើការប្រៀបធៀបប្រាក់ចំណូលមុនពេលការសាងសង់ទំនប់វារីអគ្គិសនី ជាមួយនឹងប្រាក់ចំណូលបច្ចុប្បន្ន ជាមធ្យមអ្នកប្រកបរបរកាប់ឫស្សីបានជួបប្រទះនឹងការធ្លាក់ចុះនៃប្រាក់ចំណូលប្រមាណជាបីភាគរយ។[៦១] ផលប៉ះពាល់នៃការធ្លាក់ចុះប្រាក់ចំណូលលើការចិញ្ចឹមជីវិតនៃអ្នកប្រកបរបរកាប់ឫស្សី ដែលមើលទៅហាក់ដូចជាតិចតួចមិនអាចស្តែងចេញភ្លាមៗនោះទេ។ ដើម្បីស្វែងយល់ពីផលប៉ះពាល់ពិតប្រាកដនោះការផ្លាស់ប្តូរនៃការចំណាយនៃក្រុមគ្រួសារប្រកបរបរកាប់ឫស្សីទាំងនោះ ត្រូវតែរាប់បញ្ចូល។ ត្រង់ចំណុចនេះ តាមការស្ទង់មតិបានបង្ហាញថា អ្នកប្រកបរបរកាប់ឫស្សីធ្លាប់ចំណាយជាមធ្យម ៤.១០០រៀល ក្នុងការធ្វើដំណើរទៅកាប់ឫស្សីមួយលើកៗ (រយៈពេល១ថ្ងៃ) ប៉ុន្តែ ឥឡូវពួកគាត់ចំណាយជាមធ្យម ៣៧.២៥០រៀល ក្នុងការធ្វើ

---

[៦០] អនុប្រធានភូមិថ្មីខាងជើង ២៧/៨/២០១២; ស្ត្រីត្បាញលួនៅភូមិថ្មីខាងជើង ១៧/៨/២០១២; គ្រួសារប្រកបរបរកាប់ឫស្សី មកពីភូមិអូរតូច ៣១/៨/២០១២

[៦១] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៥-១៨/៩/២០១២

ដំណើរទៅកាប់ឫស្សីមួយលើកៗ (រយៈពេលពី១ ទៅ ៥ថ្ងៃ)។[៦២] ការចំណាយបន្ថែមទាក់ទងនឹងការកាប់ឫស្សីនេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រាក់ចំណូលរបស់គ្រួសារ។

ការពិនិត្យទៅលើភាពខុសគ្នានៃប្រាក់ចំណូលរបស់គ្រួសារបង្ហាញថា គ្រួសារប្រកបរបរកាប់ឫស្សីជាច្រើនជួបប្រទះនឹងការធ្លាក់ចុះប្រាក់ចំណូលយ៉ាងខ្លាំង ហើយមានគ្រួសារតិចតួចណាស់ ដែលអាចបង្កើនប្រាក់ចំណូលរបស់ពួកគាត់គួរអោយកត់សម្គាល់។ ជាលទ្ធផលនៃភាពផ្សេងគ្នានេះ បាននាំអោយមានលទ្ធភាពផ្សេងគ្នាក្នុងការចូលទៅទាញយកផលពីធនធានធម្មជាតិ និងប្រាក់ចំណូលក្នុងគ្រួសារ។ នេះវាផ្ទុយទៅនឹងទិសដៅនៃការរីកចំរើនទូលាយដែលគាំទ្រដល់ជនក្រីក្រ របស់រាជរដ្ឋាភិបាលកម្ពុជា។ ប្រាក់ចំណូលនៃក្រុមគ្រួសារប្រកបរបរកាប់ឫស្សីដែលបានស្ទង់មតិនៅមុន និងក្រោយពេលការសាងសង់ទំនប់មានបង្ហាញនៅក្នុងគំនូសតាង «២,៣,៥» ខាងក្រោម។[៦៣]




គំនូសតាង២: បម្រែបម្រួលប្រាក់ចំណូលនៃគ្រួសារប្រកបរបរកាប់ឫស្សី

លទ្ធផលស្ទង់មតិបង្ហាញថា មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើការបែងចែកប្រាក់ចំណូលក្នុងចំណោមសមាជិកសហគមន៍ ដែលបានចូលរួមក្នុងការសិក្សានេះ។

---

[៦២] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

[៦៣] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ១៤-១៨/៩/២០១២ ប្រាក់ចំណូលត្រូវគេបង្ហាញនៅក្នុងគំនូសតាង២, ៣ និង៤ មុនពេលកាត់ការចំណាយទាក់ទងនឹងការប្រកបរបរកាប់ឫស្សីចេញ

នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនី ប្រជាជនចំនួន ៤៧% នៃគ្រួសារអ្នកប្រកបរបរកាប់ឫស្សី រកប្រាក់ចំណូលបានច្រើនជាង ២០.០០០រៀល ក្នុង១ថ្ងៃ ហើយបន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនី មានគ្រួសារអ្នកប្រកបរបរកាប់ឫស្សីចំនួនត្រឹមតែ ២១% ប៉ុណ្ណោះ រកប្រាក់ចំណូលបានច្រើនជាង ២០.០០០រៀល ក្នុង១ថ្ងៃ។ ចំនួនគ្រួសារដែលរកប្រាក់ចំណូលបានពី ១០.០០០ ទៅ ២០.០០០រៀល មានត្រឹមតែ ៥៣% នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនី ហើយបានកើនឡើងដល់ ៧៩% បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនី (មើលគំនូសតាង៣ និង៤)។ គួរអោយកត់សម្គាល់មានគ្រួសារមួយចំនួន (ប្រាំភាគរយ) សព្វថ្ងៃរកប្រាក់ចំណូលបានពី ៣០.០០០ ទៅ ៣៥.០០០រៀល ក្នុង១ថ្ងៃ ជាចំនួនដែលមិនមានគ្រួសារណាធ្លាប់រកចំណូលបាននៅមុនពេលសាងសង់ទំនប់វារីអគ្គិសនី។[៦៤] ការធ្លាក់ចុះនូវប្រាក់ចំណូលដ៏សន្ធឹកសន្ធាប់នេះធ្វើអោយប៉ះពាល់ដល់ការទិញម្ហូបអាហារ និងការចំណាយលើការអប់រំកូនៗរបស់ពួកគាត់។ ដូច្នេះ ការរងផលប៉ះពាល់ដោយសារទំនប់ធ្វើអោយបាត់បង់ឱកាសរបស់គ្រួសារដែលប្រកបរបរកាប់ឫស្សីទាំងនេះ ក្នុងការបង្កើនការចិញ្ចឹមជីវិតរបស់ពួកគាត់។




**គំនូសតាង៣ និង៤: ចំណូលប្រចាំថ្ងៃនៃគ្រួសារប្រកបរបរកាប់ឫស្សីមុន និងក្រោយពេលសាងសង់ទំនប់វារីអគ្គិសនី**

---

[៦៤] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

## ការអាស្រ័យលើប្រាក់ចំណូលពីការប្រកបរបរកាប់ឫស្សី

សម្រាប់គ្រួសារប្រកបរបរកាប់ឫស្សីទាំងអស់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះបង្ហាញថា ឫស្សីដើរតួជាអនុផលព្រៃឈើសំខាន់បំផុតសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់។ មានអ្នកប្រកបរបរកាប់ឫស្សីប្រមាណជា ៩៥% បញ្ជាក់ថាពួកគាត់អាចទទួលបានប្រាក់ចំណូលច្រើនជាងពាក់កណ្តាល ពីការប្រមូលអនុផលព្រៃឈើ ហើយអ្នកប្រកបរបរកាប់ឫស្សីចំនួន ៦០% បង្ហាញថា ពួកគាត់ទទួលបានប្រាក់ចំណូលពីការប្រមូលផលឫស្សី និងអនុផលព្រៃឈើផ្សេងទៀតច្រើនជាង ៧៥% នៃប្រាក់ចំណូលសរុបរបស់ពួកគាត់។ ទន្ទឹមគ្នានេះដែរមានតែ ៥% ប៉ុណ្ណោះនៃអ្នកប្រកបរបរកាប់ឫស្សី មានចំការដំណាំឈើហូបផ្លែ ហើយ២៩% នៃពួកគាត់មានដីធ្វើស្រែបន្តិចបន្តួច។ ចំពោះអ្នកដែលមានដីស្រែ ភាគច្រើនមិនអាចធ្វើស្រែអោយគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារពួកគាត់ឡើយ នេះបញ្ជាក់អោយឃើញថាការពឹងផ្អែកលើប្រាក់ចំណូលពីមុខរបរកាប់ឫស្សីមានកម្រិតខ្ពស់ណាស់។ ចៅសង្កាត់អណ្តូងខ្មែរបានលើកឡើងថា *«ឫស្សីផ្តល់ប្រាក់ចំណូលចាំបាច់សម្រាប់គ្រួសារដែលកាប់ឫស្សី។ បើមិនមានឫស្សីទេ អ្នកភូមិនឹងជួបប្រទះនឹងការលំបាក ព្រោះពួកគេមានដីធ្លីបន្តិចបន្តួចប៉ុណ្ណោះ។»*[៦៥] ការសិក្សានេះក៏បានរកឃើញផងដែរថា អ្នកភូមិ




គំនូសតាង៥: លទ្ធផលនៃការធ្លាក់ចុះប្រាក់ចំណូលពីការកាប់ឫស្សី

[៦៥] ឃុំអណ្តូងខ្មែរ ២០/៨-២០១២

ដទៃទៀតដូចជាម្ចាស់ផ្ទះលក់ទំនិញនៅក្នុងភូមិអូរតូច និងភូមិថ្មីខាងជើងដែលជាភូមិមានអ្នកអាស្រ័យនឹងមុខរបរកាប់ឫស្សីច្រើន ក៏រស់ពឹងអាស្រ័យនឹងឫស្សី ផងដែរ ពីព្រោះចំណូលរបស់ពួកគាត់ បានមកពីការទិញដូរទំនិញផ្សេងៗពីសំណាក់អ្នកប្រកបរបរកាប់ឫស្សីក្នុងភូមិ។[៦៦] ទោះជាប្រាក់ចំណូលរបស់អ្នកប្រកបរបរកាប់ឫស្សីបានផ្លាស់ប្តូរគួរអោយកត់សម្គាល់ដោយសារការសាងសង់ទំនប់វារីអគ្គិសនីក៏ដោយ ក៏ចំនួនសមាជិកគ្រួសារដែលពឹងផ្អែកលើមុខរបរកាប់ឫស្សីស្ថិតនៅដដែល បើយោងតាមចំនួនបុរស និងស្ត្រីពាក់ព័ន្ធនឹងមុខរបរកាប់ឫស្សី និងការផលិតល្អ (កញ្ជេ)។[៦៧] គំនូសតាង «៥» បង្ហាញពីឥទ្ធិពលមួយចំនួននៃការធ្លាក់ចុះនៃប្រាក់ចំណូលដែលបានពីការកាប់ឫស្សី។[៦៨]

### ១.១.៣ ការចូលរួមរបស់ស្ត្រី និងអនាគតនៃការប្រកបរបរកាប់ឫស្សី

មុនការសាងសង់ទំនប់វារីអគ្គិសនី ស្ត្រីជាច្រើនបានទៅកាប់ឫស្សីនៅតំបន់ទឹកឈូ ប៉ុន្តែឥឡូវមានស្ត្រីតិចតួច និងកម្រទៅកាប់ឫស្សី ដូចកាលមុនការសាងសង់ទំនប់វារីអគ្គិសនី។ សព្វថ្ងៃ ស្ត្រីមួយចំនួននៅតែចង់ទៅកាប់ឫស្សី ប៉ុន្តែស្វាមីរបស់គាត់មិនអោយពួកគាត់ទៅកាប់ឫស្សីទៀតឡើយ ដោយសារការធ្វើដំណើរទៅកាប់ឫស្សីឥឡូវនៅឆ្ងាយ និងពិបាកជាងនៅមុនការសាងសង់ទំនប់វារីអគ្គិសនី។ ចំណែកពេលខ្លះ ស្ត្រីក៏មិនអោយស្វាមីរបស់គាត់ដែលមានវ័យចំណាស់ កំលាំងខ្សោយ ឬសុខភាពមិនល្អទៅកាប់ឫស្សីដែរ ទោះបីជាស្វាមីគាត់ចង់ទៅកាប់ឫស្សីយ៉ាងណាក៏ដោយ។[៦៩] ការសិក្សានេះរកឃើញផលប៉ះពាល់សំខាន់ដែលស្ត្រីជួបប្រទះនោះ គឺការផ្លាស់ប្តូរនៃទំរង់ប្រមូលឫស្សីរបស់ស្ត្រី ព្រោះស្ត្រីបានប្តូរពីអ្នកប្រកបរបរកាប់ឫស្សីទៅជាអ្នកមិនប្រកបរបរកាប់ឫស្សី។ នៅមុនការសាងសង់ទំនប់វារីអគ្គិសនីទាំងបុរសទាំងស្ត្រី រួមទាំងមនុស្សវ័យចំណាស់ សុទ្ធតែអាចចូលទៅកាប់ឫស្សីនៅតំបន់ទឹកឈូ

---

[៦៦] ម្ចាស់ហាងនៅថ្មីខាងជើង ១៧/៨/២០១២

[៦៧] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

[៦៨] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

[៦៩] ការបង្ហាញរបកគំហើញ ដល់សហគមន៍មូលដ្ឋាន ខេត្តកំពត ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

បានយ៉ាងងាយស្រួល។ សព្វថ្ងៃ វាលំបាកណាស់សម្រាប់មនុស្សវ័យចំណាស់ និងស្ត្រីក្នុងការទៅកាប់ឫស្សី ដោយសារពួកគាត់ត្រូវតែឡើងភ្នំខ្ពស់ៗ ឬឆ្លងអាងស្តុកទឹកទំនប់វារីអគ្គិសនី និងស្នាក់នៅក្នុងព្រៃ។[៧០] តាមរយៈការស្ទង់មតិបង្ហាញថា ស្ត្រីឥឡូវជួបការលំបាកជាងមុនក្នុងការទៅកាប់ឫស្សី និងស្នាក់នៅក្នុងព្រៃជាច្រើនយប់។[៧១]

## អនាគតនៃការប្រមូលឫស្សី

និន្នាការនៅពេលថ្មីៗនេះគឺថា មិនមានឫស្សីគ្រប់គ្រាន់ដើម្បីកាប់នៅក្នុងតំបន់ទឹកឈូនៅជិតទំនប់ទៀតឡើយ។ ដូច្នេះ មានអ្នកប្រកបរបរកាប់ឫស្សីច្រើនថែមទៀតគិតថានឹងឆ្លងអាងស្តុកទឹកទៅកាប់ឫស្សី។ ការអភិវឌ្ឍនេះធ្វើអោយអ្នកប្រកបរបរកាប់ឫស្សីព្រួយបារម្ភថា តើមានឫស្សីគ្រប់គ្រាន់សម្រាប់ពួកគាត់បន្តការចិញ្ចឹមជីវិតតាមប្រពៃណីរបស់ពួកគេនៅពេលអនាគតដែរឬទេ។ ក្រុមគ្រួសារដែលពឹងផ្អែកលើមុខរបរកាប់ឫស្សីមានកង្វល់ពីប្រាក់ចំណូល ដែលពួកគាត់រកបានពីការប្រកបរបរកាប់ឫស្សីសព្វថ្ងៃ និងពេលអនាគត ថាបានសមល្មមគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិតរបស់ពួកគាត់ដែរឬទេ។ នៅមុនពេលការសាងសង់ទំនប់វារីអគ្គិសនី ប្រាក់ចំណូលដែលពួកគាត់រកបានពីការប្រកបរបរកាប់ឫស្សី បានចូលក្នុងហោប៉ៅរបស់ពួកគាត់តែម្នាក់ឯង។ តែបន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនី និងការបាត់បង់ឱកាសក្នុងការចូលទៅអាស្រ័យផលពីព្រៃនៅតំបន់ទឹកឈូ ស្ថានភាពរបស់ពួកគាត់សព្វថ្ងៃ ត្រូវចំណាយលុយជាច្រើនលើឈ្នួលក្បូន និងរថយន្ត។ អ្នកប្រកបរបរកាប់ឫស្សីមួយចំនួនបង្ហាញនូវការមិនពេញចិត្ត ក្នុងការដែលប្រាក់ចំណូលពួកគាត់មួយចំណែកធំបានហូរចូលក្នុងហោប៉ៅអ្នកដទៃ ដែលជាអ្នកសម្បូរទ្រព្យសម្បត្តិជាងពួកគាត់។

គេអាចយល់តាមរយៈការសម្ភាសជាមួយសមាជិកសហគមន៍ថា អ្នកប្រកបរបរកាប់ឫស្សីមានទំនាក់ទំនងជិតស្និទ្ធជាមួយមុខរបរមួយនេះ ហើយពួកគាត់មើល

---

[៧០] ពិភាក្សាក្រុមភូមិអូរតូច ២៩/៨/២០១២; ពិភាក្សាក្រុម ភូមិថ្មីខាងជើង ២៧/៨/២០១២; បុរសប្រកបរបរកាប់ឫស្សី ២០/៨/២០១២

[៧១] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

ឃើញជម្រើសតិចតួចក្រៅពីការចូលទៅកាប់ឫស្សី និងការផលិតលូ (កញ្ជេ)។ មានកត្តាស្មុគស្មាញជាច្រើនចំពោះការរកជម្រើសចិញ្ចឹមជីវិតដទៃទៀត។ កត្តាទាំងនោះរួមមានឱកាសការងារដ៏មានកម្រិត កង្វះជំនាញក្នុងចំណោមអ្នកប្រកបរបរកាប់ឫស្សី កង្វះដីកសិកម្ម និងឧបសគ្គកើតចេញពីវប្បធម៌ ឬទំលាប់ដែលស៊ាំជាមួយការងាររបស់ខ្លួនធ្លាប់ធ្វើ ដែលធ្វើអោយមានការរារាំងដល់ការធ្វើការងារក្នុងលក្ខខណ្ឌថេរណាមួយ ដូចជាការងារក្នុងរោងចក្រជាដើម។





រូបភាព: យុវជនកំពុងផលិតលូទំហំធំនៅភូមិអូរតូច (រូបខាងឆ្វេង) និងស្ត្រីកំពុងក្រងកញ្ជ្រែងសម្រាប់ដាក់ត្រីចំហុយនៅភូមិមាត់ពាម (រូបខាងស្តាំ)

## ១.២ សហគមន៍ឫស្សីនៅភូមិអូរតូច

គិតដល់ការបាត់បង់ព្រៃឫស្សីនៅតំបន់ទឹកឈូ គម្រោងឫស្សីមួយត្រូវបានគេផ្តួចផ្តើមបង្កើតនៅភូមិអូរតូចដោយអង្គការមួយនៅ ឆ្នាំ២០០៦ ឬ២០០៧ ដែលគេគិតថាអាចនឹងជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការបាត់បង់ព្រៃឫស្សី នៅតំបន់អាងស្តុកទឹក។ តំបន់មួយនៅលើភ្នំទឹកចេញដែលជាផ្នែកមួយនៃឧទ្យានជាតិបូកគោត្រូវបានគេផ្តល់អោយសហគមន៍អូរតូច សម្រាប់ធ្វើជាតំបន់ការពារដោយសហគមន៍ ប៉ុន្តែដើមឫស្សីហាក់បីដូចជាលូតលាស់មិនបានល្អឡើយ។ ពាក់កណ្តាលនៃតំបន់សហគមន៍នោះត្រូវបានគេដាំឫស្សី ផ្តៅ និងកូនឈើផ្សេងៗទៀត ប៉ុន្តែឫស្សីពី ៥០% ទៅ ៨០% បានងាប់ជាបន្តបន្ទាប់។ ទោះបីជាគេដាំឫស្សី និងកូនឈើផ្សេងៗនៅតំបន់សហគមន៍នោះទាំងមូល ហើយឫស្សី និងកូនឈើទាំងអស់នោះលូតលាស់បានល្អក៏ដោយ តែតំបន់នោះអាចផ្គត់ផ្គង់ឫស្សីសម្រាប់អ្នកប្រកបរបរកាប់ឫស្សីនៅ

ភូមិអូរតូចបានប្រមាណជា១ខែ ក្នុង១ឆ្នាំ ប៉ុណ្ណោះ។[៧២] គម្រោងដាំឫស្សីនេះមិនមានសកម្មភាពទេ ដោយសារគ្មានថវិកាសម្រាប់ដាំឫស្សី និងរុក្ខជាតិដទៃទៀត។[៧៣] មន្ទីរបរិស្ថានខេត្តកំពតបានប្រាប់អោយដឹងថា សហាគមន៍ឫស្សីអូរតូចត្រូវបានគេបង្កើតដើម្បីកាត់បន្ថយការកាប់ឫស្សីពីឧទ្យានជាតិបូកគោ ហើយទំហំនៃតំបន់គម្រោងនោះគឺ៤៧៣ ហិចតា។[៧៤] ប្រជាជនខ្លះនៅភូមិអូរតូចគិតថាគម្រោងនោះមានទំនាក់ទំនងនឹងការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ប៉ុន្តែក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ បែរជាមិនពាក់ព័ន្ធនឹងគម្រោងឫស្សីនោះក្នុងរូបភាពណាមួយ បើទោះជាការគាំទ្រផ្នែកហិរញ្ញវត្ថុក៏មិនមែនដែរ។[៧៥]

## ១.៣ ការធ្លាក់ចុះនៃការប្រមូលអនុផលព្រៃឈើ

ទោះបីជាឫស្សីជាធនធានអនុផលព្រៃឈើដ៏សំខាន់បំផុត សម្រាប់អ្នកប្រមូលអនុផលព្រៃឈើភាគច្រើននៅភូមិអូរតូច ភូមិថ្មីខាងជើង និងភូមិមាត់ពាមក៏ដោយ ក៏សមាជិកសហាគមន៍នៅទីនោះ ព្រមទាំងនៅភូមិដទៃទៀតនៅក្នុងតំបន់ រួមទាំងភូមិស្នំប្រាំពីរ បានទៅបោចផ្តៅ បេះផ្លែសំរង ក្រឡាញ់ យុស និងម៉ាក់ប្រាង និងរើសជ័រចុងជាលក្ខណៈប្រពៃណីនៅតំបន់ដែលត្រូវទឹកជន់លិចសព្វថ្ងៃ។ គេបោចផ្តៅសម្រាប់ផលិតជាដែលូ (កញ្ជេ) រីឯអនុផលព្រៃឈើដទៃទៀតភាគច្រើនត្រូវគេលក់អោយឈ្មួញកណ្តាល។ ផ្លែឈើព្រៃភាគច្រើនមានផ្លែតាមរដូវរបស់វា ហើយអាចមានផ្លែសម្រាប់ប្រមូលផលក្នុងរយៈពេល១ខែ ទៅ ៣ខែ ដូច្នេះ វាផ្តល់ប្រាក់ចំណូលបណ្តោះអាសន្ន និងមិនស្ថិតស្ថេរដល់អ្នកភូមិ។[៧៦]

ដើមសំរងដែលបាត់បង់ ដោយសារការសាងសង់អាងស្តុកទឹកទំនប់វារីអគ្គិសនីមានប្រមាណជា៥០% ទៅ ៧០% នៃដើមសំរងដែលមាននៅក្នុងតំបន់ព្រៃ

[៧២] ប្រធានភូមិអូរតូច ១៨/៨/២០១២; គ្រួសារប្រកបរបរកាប់ឫស្សី មកពីភូមិអូរតូច ២២/៨/២០១២; ពិភាក្សាក្រុមភូមិអូរតូច ២៩/៨/២០១២

[៧៣] ប្រធានសហាគមន៍ឫស្សី ភូមិអូរតូច ២២/៨/២០១២; បុរសប្រកបរបរកាប់ឫស្សី មកពីភូមិអូរតូច ២០/៨/២០១២

[៧៤] មន្ទីរបរិស្ថានខេត្តកំពត ១៨/១០/២០១២

[៧៥] ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្តកំពត ២៩/៨/២០១២

[៧៦] ប្រធានភូមិស្នំប្រាំពីរ ១៧/៨/២០១២; ពិភាក្សាក្រុមភូមិស្នំប្រាំពីរ ២២/៨/២០១២

ដែលសហគមន៍អាចចូលទៅអាស្រ័យផល។ ប្រជាជនប្រហែលជាអាចប្រមូលផលពីផ្លែឈើព្រៃដ៏មានតម្លៃនេះបាននៅពេលអនាគត ក៏ប៉ុន្តែវាមានការលំបាកជាងមុនក្នុងការចូលទៅបេះផ្លែសំរងដែលនៅសេសសល់នោះ ដោយសារពួកគាត់ត្រូវតែឆ្លងអាងស្តុកទឹកទំនប់វារីអគ្គិសនី និងត្រូវស្នាក់នៅក្នុងព្រៃ។[៧៧] ដើមសំរងអាចមានផ្លែរយៈពេល១ឆ្នាំ ឬ ២ឆ្នាំ ជាប់ៗគ្នា ហើយក្រោយមកវាមិនមានផ្លែអាចរហូតដល់៥ឆ្នាំ។ ក្រោយពេលការសាងសង់ទំនប់វារីអគ្គិសនី ដើមសំរងមិនទាន់មានផ្លែម្តងទៀតនៅឡើយ។ ប្រាក់ចំណូលជាធម្មតានៅរដូវមានផ្លែសំរងគឺចាប់ពី ៥០.០០០ ទៅ ២០០.០០០រៀល ក្នុង១ថ្ងៃ ហើយមានអ្នកភូមិខ្លះអាចរកចំណូលបានរហូតដល់ ៥០០.០០០រៀល ក្នុង១ថ្ងៃ។ នៅរាល់រដូវមានផ្លែសំរង វាធ្វើអោយពុះសុសសាយ ហើយទាក់ទាញប្រជាជនមកពីតំបន់ដទៃទៀតនៃខេត្តកំពត ព្រមទាំងខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តតាកែវ។ ជាធម្មតា វាមានមនុស្សណែនតាន់តាប់យ៉ាងហោចណាស់ក៏មានមនុស្សប្រមាណជា១.០០០នាក់ មករកប្រមូលផលសំរងក្នុង ១ថ្ងៃ។[៧៨]

ស្ត្រីម្នាក់នៅភូមិស្នំប្រាំពីរ ធ្លាប់ទៅបេះផ្លែសំរងនៅក្នុងព្រៃនៅតំបន់ទឹកឈូ ប៉ុន្តែសព្វថ្ងៃគាត់មិនអាចបេះផ្លែសំរងបានទៀតឡើយ បន្ទាប់ពីអាងស្តុកទឹកទំនប់វារីអគ្គិសនីបានជន់លិចព្រៃឈើនោះបាត់ទៅ។ នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនីស្ទើរតែគ្រប់គ្រួសារទាំងអស់មកពីភូមិស្នំប្រាំពីរបានទៅបេះផ្លែសំរង ហើយពួកគាត់ក៏ធ្លាប់ទទួលបានប្រាក់ចំណូលជាច្រើនពីការបេះផ្លែសំរងនេះដែរ។ ជាឧទាហរណ៍ គាត់បានរំលឹកថា ប្រសិនបើមនុស្ស៣នាក់ ចូលក្នុងព្រៃរយៈពេល៣ថ្ងៃ ៣យប់ ដើម្បីរកបេះផ្លែសំរង ពួកគាត់អាចរកប្រាក់ចំណូលបាន១លានរៀល ក្នុងម្នាក់ៗ។ ជាទូទៅផ្លែសំរង១គីឡូក្រាម អាចលក់បានក្នុងតម្លៃ២០.០០០រៀល ទៅ ៣០.០០០រៀល។[៧៩]

---

[៧៧] ពិភាក្សាក្រុមភូមិស្នំប្រាំពីរ ២២/៨/២០១២

[៧៨] ពិភាក្សាក្រុមភូមិស្នំប្រាំពីរ ២២/៨/២០១២; ប្រធានភូមិស្នំប្រាំពីរ ១៧/៨/២០១២; ការបង្ហាញរបកគំហើញដល់សហគមន៍មូលដ្ឋាន ខេត្តកំពត ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

[៧៩] ប្រធានភូមិស្នំប្រាំពីរ និងជំនួយការ ១៧/៨/២០១២

ទោះជាអនុផលព្រៃឈើដទៃទៀត ក្រៅពីឫស្សីមិនបានផ្តល់ប្រាក់ចំណូលសំខាន់សម្រាប់អ្នកភូមិយ៉ាងណាក្តី តែអនុផលព្រៃឈើទាំងនោះចូលរួមចំណែកជាប្រភពប្រាក់ចំណូលបន្ថែមដ៏សំខាន់ ហើយវាផ្តល់ជម្រើសផ្សេងក្រៅពីឫស្សីសម្រាប់ប្រជាជន ដើម្បីធ្វើអោយសកម្មភាពចិញ្ចឹមជីវិតរបស់ពួកគាត់មានច្រើនប្រភព។[៨០] ការចូលទៅបោចផ្តៅអាចរកប្រាក់ចំណូលបានពី ១០.០០០រៀល ទៅ ២០.០០០រៀល ក្នុង១ថ្ងៃ ចំណែកឯផ្លែអាកោវិញ គេអាចរកប្រាក់បានពី ៤០.០០០រៀល ទៅ ៦០.០០០រៀល ក្នុង១ថ្ងៃ។ រីឯជ័រចុងវិញ មានតម្លៃចាប់ពី ៣០.០០០រៀល ទៅ ៣៧.០០០រៀល ក្នុងជ័រចុង ១០គីឡូក្រាម។[៨១] នៅភូមិស្នំប្រាំពីរ អ្នកភូមិប្រហែលជា ២០ ទៅ ៣០នាក់ ធ្លាប់ទៅបេះផ្លែមាក់ប្រាង។[៨២] យោងតាមអ្នកភូមិស្នំប្រាំពីរ ផ្លែអាកោ ដែលគេយកទៅធ្វើជាថ្នាំបុរាណ មិនអាចរកបានទៀតទេនៅតំបន់ក្បែរទឹកឈូ។[៨៣] មានអ្នកប្រកបរបរកាប់ឫស្សីចំនួន ១៥នាក់ (១៩%) ក្នុងចំណោមអ្នកប្រកបរបរកាប់ឫស្សីចំនួន ៧៨នាក់ មកពីភូមិអូរតូច ភូមិថ្មីខាងជើង និងភូមិមាត់ពាម ដែលធ្លាប់ចូលទៅកាប់ឫស្សីនៅតំបន់ដែលទឹកជន់លិចបច្ចុប្បន្ន ក៏ធ្លាប់ចូលទៅរកអនុផលដទៃទៀតព្រៃឈើ នៅមុនពេលការសាងសង់ទំនប់ដែរ។ បន្ទាប់ពីការសាងសង់ទំនប់ មានតែប្រជាជន ២នាក់ (២,៥%) ក្នុងចំណោមអ្នកប្រកបរបរកាប់ឫស្សីនៅបន្តចូលទៅរកប្រមូលអនុផលផ្សេងទៀតព្រៃឈើ។[៨៤] សម្រាប់អ្នកដែលប្រមូលអនុផលដទៃទៀតព្រៃឈើ អាចរកប្រាក់ចំណូលបានជាមធ្យម ១៩៦.៥០០រៀល ក្នុងមួយឆ្នាំ/រដូវ នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនី។[៨៥]

---

[៨០] គ្រួសារប្រកបរបរកាប់ឫស្សីមកពីភូមិអូរតូច ២២/៨/២០១២

[៨១] ការបង្ហាញរបកគំហើញដល់សហគមន៍មូលដ្ឋាន ខេត្តកំពត ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

[៨២] ប្រធានភូមិស្នំប្រាំពីរ និងជំនួយការ ១៧/៨/២០១២

[៨៣] ពិភាក្សាក្រុម ភូមិស្នំប្រាំពីរ ២២/៨/២០១២

[៨៤] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

[៨៥] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

## ១.៤ ផលប៉ះពាល់លើវិស័យទេសចរណ៍

អ្នកលក់ដូរនៅរមណីយដ្ឋានទឹកឈូមានលក់ម្ហូបអាហារ ភេសជ្ជៈ ផ្លែឈើ អាហារសម្រន់ និងនំ ព្រមទាំងមានជួលតូប និងរបស់របរផ្សេងៗទៀត ដូចជាជួលកន្ទេល និងពោងសម្រាប់ភ្ញៀវហែលទឹកលេង។ ទីតាំងទេសចរណ៍ដ៏មានប្រជាប្រិយនេះ បានទាក់ទាញភ្ញៀវទេសចរតាំងពីមុនប្រទេសទទួលបានឯករាជ្យមកម្លេះ។ មន្ទីរទេសចរណ៍ខេត្តកំពតបានប៉ាន់ប្រមាណថា មានអ្នកលក់ដូរចល័តប្រហែលជា ៣០ នាក់ នៅថ្ងៃធម្មតា និងកើនដល់ ៥០នាក់ នៅចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកផ្សេងៗ។ មានតូបប្រហែលជា ៤០ សម្រាប់ជួលអោយភ្ញៀវទេសចរ ហើយមនុស្សប្រមាណជា ២០០នាក់ ធ្វើការនៅរមណីយដ្ឋានទឹកឈូ។[៨៦] នៅរមណីយដ្ឋានទឹកឈូគេឃើញមានភោជនីយដ្ឋានពី ៤០ ទៅ ៤៥កន្លែង និងតូបលក់ផ្លែឈើប្រហែលជា ៣០កន្លែង។ ម្ចាស់ហាង ឬអ្នកជួលហាង និងតូបទាំងនោះបង់ថ្លៃឈ្នួលប្រើប្រាស់ហាង ឬតូបប្រចាំឆ្នាំជូនអាជ្ញាធរទេសចរណ៍។ យោងតាមមន្ទីរទេសចរណ៍ខេត្តកំពត ថ្លៃឈ្នួលប្រចាំឆ្នាំគឺ ១០០.០០០រៀល សម្រាប់ការជួលភោជនីយដ្ឋាន និង២៥.០០០រៀល សម្រាប់ការជួលតូបលក់ផ្លែឈើ។[៨៧] អ្នកលក់ដូរនៅរមណីដ្ឋានទឹកឈូបានបញ្ជាក់ថាថ្លៃឈ្នួលប្រចាំឆ្នាំសម្រាប់ការជួលភោជនីយដ្ឋានគឺ១០០.០០០រៀល ពិតជាត្រឹមត្រូវ ក៏ប៉ុន្តែពួកគាត់បានប្រាប់អោយដឹងថា ពួកគាត់បង់ប្រាក់ឈ្នួលសម្រាប់តូបលក់ផ្លែឈើប្រហែលជា ៦០.០០០រៀល ក្នុង១ឆ្នាំ។ បន្ថែមលើប្រាក់ឈ្នួលប្រចាំឆ្នាំនេះ មានប្រាក់ឈ្នួលប្រចាំសប្តាហ៍ និងប្រាក់ឈ្នួលមិនផ្លូវការផ្សេងទៀតដូចជាថ្លៃអនាម័យ ៥០០រៀល ដែលអ្នកលក់ដូរនៅរមណីយដ្ឋានទឹកឈូត្រូវបង់ទាំងអស់គ្នាដោយរាប់បញ្ចូលទាំងអ្នកលក់ដូរចល័តផងដែរ។[៨៨]

---

[៨៦] មន្ទីរទេសចរណ៍ ខេត្តកំពត ២៨/៨/២០១២

[៨៧] មន្ទីរទេសចរណ៍ ខេត្តកំពត ២៨/៨/២០១២

[៨៨] ស្ត្រីប្រកបរបរលក់ដូរ មកពីភូមិស្នំប្រាំពីរ ១៦/៨/២០១២; ស្ត្រីប្រកបរបរលក់ផ្លែឈើនៅរមណីយដ្ឋានទឹកឈូ ២០/៨/២០១២

### ១.៤.១ ការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរ និងប្រាក់ចំណូល

ការសាងសង់ទំនប់កំចាយ បានធ្វើអោយខូចប្រយោជន៍ដល់ការចិញ្ចឹមជីវិតនៃអ្នកប្រកបរបរនៅរមណីយដ្ឋានទឹកឈូ។ ពួកគាត់បានរៀបរាប់អំពីលំហូរទឹក និងភាពស្រស់ស្អាតបែបធម្មជាតិរបស់ព្រែកកំចាយ។ នៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនី ពួកគេបានជួបប្រទះនឹងការថយចុះនៃគុណភាពទឹកនៅព្រែកកំចាយយ៉ាងខ្លាំង ព្រោះតែការបំពុលទឹកពីសំណាក់កម្មករ និងការដ្ឋានសំណង់។ គួបផ្សំនឹងទឹកក្នុងព្រែកមានតិចតួចទៀតនោះ វាបានធ្វើអោយភ្ញៀវទេសចរជាច្រើនឈប់មកទស្សនានៅរមណីដ្ឋានមួយនេះ។ សព្វថ្ងៃ បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនីរួច ទឹកមើលទៅហាក់បីដូចជាមិនសូវមានលក្ខណៈធម្មជាតិ ហើយវាមានពណ៌មិនល្អ និងមានធុំក្លិនស្អុយ។

យោងតាមការសម្ភាសជាមួយអ្នកលក់ដូរចំនួន២២នាក់ នៅរមណីយដ្ឋានទឹកឈូ មានអ្នកប្រកបរបរនៅរមណីយដ្ឋានទឹកឈូចំនួន ៩៥% បានប្រាប់អោយដឹងថាមានភ្ញៀវទេសចរមកតំបន់ទេសចរណ៍នេះតិចជាងមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយបានចាប់ផ្តើម។[៨៩] ពួកគាត់ក៏បានពន្យល់ទៀតថា នៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនី ចំនួនភ្ញៀវទេសចរធ្លាក់ចុះរហូតដល់ប្រមាណ១០% នៃចំនួនភ្ញៀវទេសចរដែលធ្លាប់មកទស្សនានៅរមណីយដ្ឋានទឹកឈូ នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនី។ កាន់តែអាក្រក់ទៀតនោះ ភ្ញៀវទេសចរដែលបានមកលេងនៅរមណីយដ្ឋានទឹកឈូ គឺមកលេងតែរយៈពេលខ្លី ដោយសារពួកគេមិនចូលចិត្តកាលដែលកន្លែងទេសចរណ៍មួយនេះមិនមានទឹកគ្រប់គ្រាន់ និងទឹកកខ្វក់។ ដោយហេតុនេះ ភ្ញៀវទេសចរទាំងនោះចាយលុយតិចជាងមុន។[៩០] កាន់តែបន្ថែមការលំបាកដល់អ្នកលក់ដូរនៅរមណីយដ្ឋានទឹកឈូទៅទៀតនោះគឺ ស្ពានយោលដែលភ្ជាប់រមណីយដ្ឋានទឹកឈូទៅកោះមួយព័ទ្ធដោយព្រែកដ៏តូចមួយ ដែលជាទីពេញនិយមសម្រាប់ភ្ញៀវទេសចរ បានបាក់ខូចខាតទាំងស្រុងដោយទឹកជំនន់ខុសប្រក្រតីមួយនៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនី។ ទោះជាវាមិនត្រូវបានគេបង្ហាញជាផ្លូវការ ថាតើ

[៨៩] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

[៩០] ស្ត្រីម្ចាស់ហាងអាហារ នៅរមណីយដ្ឋានទឹកឈូ ២០/៨/២០១២

មូលហេតុអ្វីបានបង្កអោយមានទឹកជំនន់នៅឆ្នាំ២០០៩ ដែលបានធ្វើអោយបាក់ស្ពានយោលក៏ដោយ វាប្រាកដណាស់ថាការបាត់បង់ស្ពានយោលធ្វើអោយរមណីយដ្ឋានទឹកឈូ កាន់តែមិនអាចទាក់ទាញភ្ញៀវទេសចរចំពេលដែលអ្នកលក់ដូរនៅទីនោះកំពុងតែខិតខំពុះពាររកប្រាក់ចំណូលសម្រាប់ចិញ្ចឹមគ្រួសាររបស់ពួកគាត់។[៩១]

តាមស្ថិតិទេសចរណ៍បានបង្ហាញថា ការថយចុះនូវចំនួនភ្ញៀវទេសចរនៅរមណីយដ្ឋានទឹកឈូ មានទំហំធំធេងណាស់ ហើយការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរបានអូសបន្លាយតាំងពីពេលចាប់ផ្តើម ដល់ពេលបញ្ចប់ការសាងសង់ទំនប់កំចាយ។ នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បានបង្ហាញពីចំនួនភ្ញៀវទេសចរដែលមកលេងនៅរមណីយដ្ឋានទឹកឈូពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ និងការប៉ាន់ប្រមាណពីប្រាក់ចំណូលដែលគណនាពីវិស័យទេសចរណ៍។ មន្ទីរទេសចរណ៍ខេត្តកំពតបានផ្តល់ព័ត៌មានអំពីចំនួនភ្ញៀវទេសចរនៅឆ្នាំ ២០១១ ដូចមានបង្ហាញក្នុងតារាងទី៣ខាងក្រោម ប៉ុន្តែមិនបានផ្តល់ស្ថិតិថ្មីៗបំផុតអំពីចំនួនភ្ញៀវទេសចរនៅឆមាសទី១នៃឆ្នាំ២០១២ឡើយ។ តារាងខាងក្រោមផ្តល់ជូននូវការសង្ខេបពីការថយចុះនៃចំនួនភ្ញៀវទេសចរនៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ។

**តារាងទី៣: ចំនួនភ្ញៀវទេសចរនៅរមណីយដ្ឋានទឹកឈូ និងប្រាក់ចំណូល ឆ្នាំ២០០៦-២០១១**

| បម្រែបម្រួលនៃចំនួនភ្ញៀវទេសចរ និងការព្យាករប្រាក់ចំណូលពីវិស័យទេសចរណ៍ | | | |
|---|---|---|---|
| ឆ្នាំ | ចំនួនភ្ញៀវទេសចរសរុប | ប្រាក់ចំណូល ($) | % ចំនួនភ្ញៀវទេសចរធៀបនឹងឆ្នាំ២០០៦ |
| ២០០៦ | ២៧៧.៩៧៧ | ២.៨៦១.៩២៥ | ១០០% |
| ២០០៧ | ២៩១.០៨៦ | ២.៥១៨.០០០ | ៨៦,៧៣% |
| ២០០៨ | ២៥៩.៦៨៩ | ២.៦៩៥.១៥៥ | ៩៣,៩២% |
| ២០០៩ | ១៨០.៧៥៨ | ១.៩៥៥.៩០៥ | ៦៥,០៣% |
| ២០១០ | ៦៩.៥៩២ | ៧៦១.៣៦០ | ២៥,០២% |
| ២០១១ | ៦៥.២៣២[៩២] | ៦៩០.១៥៥[៩៣] | ២៣,៩៧% |

[៩១] មន្ទីរទេសចរណ៍ ខេត្តកំពត ២៨/៨/២០១២; ម្ចាស់ហាងពីភូមិស្នំប្រាំពីរ ២០/៨/២០១២; ស្ត្រីម្ចាស់ហាងអាហារនៅរមណីយដ្ឋានទឹកឈូ ០១/៩/២០១២

[៩២] មន្ទីរទេសចរណ៍ ខេត្តកំពត ២៨/៨/២០១២

អ្នកលក់ដូរនៅរមណីយដ្ឋានទឹកឈូភាគច្រើន បានប៉ាន់ប្រមាណថាចំនួនភ្ញៀវទេសចរនៅខែកញ្ញា ឆ្នាំ២០១២ មានប្រហែលជា ៤០% ទៅ ៥០% នៃចំនួនភ្ញៀវទេសចរដែលធ្លាប់មាននៅមុនការសាងសង់ទំនប់។[៩៤] បន្ថែមពីលើស្ថានភាពមិនល្អនៃគុណភាពរបស់រមណីយដ្ឋានទឹកឈូ នៅជំណាក់កាលសាងសង់ទំនប់វារីអគ្គិសនី អ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូ និងមន្ត្រីរាជរដ្ឋាភិបាលមួយចំនួនបានចាត់ទុកការកើនឡើងនៃចំនួនរមណីដ្ឋានទេសចរណ៍នៅខេត្តកំពត ក៏អាចជាកត្តាបង្កអោយមានការថយចុះនៃចំនួនភ្ញៀវទេសចរនៅរមណីយដ្ឋានទឹកឈូផងដែរ។[៩៥]

**ការធ្លាក់ចុះនូវប្រាក់ចំណូលរបស់អ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូ**

នៅមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ការប្រកបមុខរបរនៅរមណីយដ្ឋានទឹកឈូ បានផ្តល់ប្រាក់ចំណូលគ្រប់គ្រាន់ដល់អាជីវករនៅទីនោះដើម្បីបំពេញរាល់សេចក្តីត្រូវការក្នុងគ្រួសារ ហើយអ្នកប្រកបរបរលក់ដូរនៅទីនោះជាច្រើនអាចសន្សំប្រាក់បានមួយចំនួនសម្រាប់ប្រារព្ធពិធីផ្សេងៗ ឬករណីបន្ទាន់ណាមួយ។ ស្ថានភាពនេះបានផ្លាស់ប្តូរបន្ទាប់ពីមានការសាងសង់ទំនប់វារីអគ្គិសនី ហើយអ្នកលក់ដូរនៅទីនោះភាគច្រើនមិនអាចរកលុយបានគ្រប់គ្រាន់ ដើម្បីមានជីវភាពរស់នៅដូចកាលពួកគាត់ធ្លាប់មានពីមុនពេលសាងសង់ទំនប់វារីអគ្គិសនី ដោយមិនគិតដល់ការសន្សំប្រាក់សម្រាប់ពេលអនាគត ឬករណីបន្ទាន់នោះឡើយ។ យោងតាមការសម្ភាសអ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូទាំងអស់ ជួបប្រទះការធ្លាក់ចុះនូវប្រាក់ចំណូលពីរបររកស៊ីរបស់ពួកគាត់ ហើយជាមធ្យមពួកគាត់បានប៉ាន់ស្មានថាប្រាក់ចំណូលរបស់ពួកគាត់នៅពេលបច្ចុប្បន្នរកបានប្រមាណជា២៨% នៃប្រាក់ចំណូលដែលពួកគាត់ធ្លាប់រកបាននៅមុនពេលការសាងសង់ទំនប់វារីអគ្គិសនី។ ប្រាក់ចំណូលនៅក្នុងគ្រួសារដែលពឹងផ្អែកលើវិស័យទេសចរណ៍នៅមុន និងក្រោយការ

---

[៩៣] ការគណនាប្រាក់ចំណូលដោយអាស្រ័យលើទិន្នន័យពី ឆ្នាំ២០០៦ ដល់ ឆ្នាំ២០១០

[៩៤] ការស្ទង់មតិជាមួយអ្នកពាក់ព័ន្ធនឹងទេសចរណ៍១៤-១៨/៩/២០១២

[៩៥] ក្រសួងបរិស្ថាន, នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២; ស្ត្រីម្ចាស់ហាងអាហារ នៅរមណីយដ្ឋានទឹកឈូ ០១/៩/២០១២; ស្ត្រីប្រកបរបរលក់មាន់នៅ នៅរមណីយដ្ឋានទឹកឈូ ១/៩/២០១២

សាងសង់ទំនប់វារីអគ្គិសនី មានបង្ហាញក្នុងគំនូសតាង៦ គំនូសតាង៧ និងគំនូសតាង៨ ខាងក្រោមនេះ។[៩៦]




គំនូសតាង៦: ប្រាក់ចំណូលពីការប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូ
នៅមុន និងក្រោយការសាងសង់ទំនប់វារីអគ្គិសនីកំចាយ

នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយបានចាប់ផ្តើម ប្រាក់ចំណូលជាមធ្យមនៃគ្រួសារដែលប្រកបរបរនៅរមណីយដ្ឋានទឹកឈូគឺចំនួន ៨២.៣០០រៀល ក្នុង១ថ្ងៃ។ ក្នុងនោះ ប្រហែលជា៥៤% នៃពួកគាត់រកបានប្រាក់ចំណូលចាប់ពី ៣០.០០០រៀល ទៅ ៦០.០០០រៀល ក្នុង១ថ្ងៃ ខណៈពេលដែល២៣% នៃពួកគាត់រកប្រាក់ចំណូលបានច្រើនជាង ៧០.០០០រៀល ក្នុង១ថ្ងៃ។ បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនីប្រាក់ចំណូលជាមធ្យមនៃគ្រួសារទាំងនេះ គឺមានប្រហែលជា ២២.៧០០រៀលក្នុង១ថ្ងៃ។ ក្នុងនោះមាន៨២% នៃគ្រួសារទាំងនោះ រកប្រាក់ចំណូលពី ១០.០០០រៀល ទៅ ៤០.០០០រៀលក្នុង១ថ្ងៃ។ ដោយឡែកគ្មានគ្រួសារណាមួយរកប្រាក់ចំណូលបានច្រើនជាង ៤០.០០០រៀល ក្នុង១ថ្ងៃ ឡើយ។ មានគ្រួសារប្រមាណជា១៨% នៅពេលបច្ចុប្បន្នរកប្រាក់ចំណូលបានតិចជាង ១០.០០០រៀល ក្នុង១ថ្ងៃ។[៩៧]

[៩៦] ការសួងមតិជាមួយអ្នកពាក់ព័ន្ធនឹងទេសចរណ៍ ១៤-១៨/៩/២០១២

[៩៧] ការសួងមតិជាមួយអ្នកពាក់ព័ន្ធនឹងទេសចរណ៍ ១៤-១៨/៩/២០១២

ដូច្នេះ ការសាងសង់ទំនប់វារីអគ្គិសនីកំចាយមានផលប៉ះពាល់អវិជ្ជមានយ៉ាងធំធេងដល់គ្រួសារដែលពឹងផ្អែកលើវិស័យទេសចរណ៍នៅរមណីយដ្ឋានទឹកឈូដែលនាំអោយការចិញ្ចឹមជីវិតនៅក្នុងតំបន់នេះធ្លាក់ចុះ។







**គំនូសតាង៧ និង៨: ប្រាក់ចំណូលប្រចាំថ្ងៃនៃគ្រួសារលក់ដូរនៅរមណីយដ្ឋានទឹកឈូនៅមុននិងក្រោយការសាងសង់ទំនប់វារីអគ្គិសនី**

### ១.៤.២ ផលប៉ះពាល់លើស្ត្រី និងអនាគតនៃទេសចរណ៍នៅរមណីយដ្ឋានទឹកឈូ

ការងារដែលទាក់ទងនឹងវិស័យទេសចរណ៍ មានការចូលរួមពីស្ត្រីច្រើនជាងបុរស ដោយសារស្ត្រីអាចធ្វើការងារនេះប្រសើរជាងបុរស។ ការរៀបចំការចំអិនអាហារ និងការងារពាក់ព័ន្ធដទៃទៀតភាគច្រើនគឺស្ត្រីជាអ្នកធ្វើ។ ភាគច្រើន បុរសជួយស្ត្រីនូវការងារមួយចំនួនដូចជា ការដឹកជញ្ជូនផលិតផលទៅកាន់ និងត្រលប់ពីរមណីយដ្ឋានទឹកឈូ។ សំអាងលើទំនាក់ទំនងយ៉ាងជិតស្និទ្ធិរបស់ស្ត្រីជាមួយនឹងរបររកស៊ីនៅរមណីយដ្ឋានទឹកឈូ ការថយចុះនៃភ្ញៀវទេសចរ បានប៉ះពាល់ដោយផ្ទាល់ទៅលើស្ត្រីជាងបុរស។ តាមរយៈនេះ



រូបភាព: អ្នកលក់ផ្លែឈើនៅរមណីយដ្ឋានទឹកឈូ

អ្នកលក់ដូរចំនួន៩១% ដែលបានចូលរួមក្នុងការសិក្សា បានយល់ឃើញថាស្ត្រីជួបការលំបាកជាងមុនក្នុងការថែទាំគ្រួសារ។[៩៨]

តាមរយៈការស្ទង់មតិ និងការសម្ភាសពិស្តារ សុទ្ធតែបានបង្ហាញយ៉ាងច្បាស់ថា ផលប៉ះពាល់ចំពោះអ្នកលក់ដូរនៅរមណីយដ្ឋានទឹកឈូ នៅតែគួរអោយកត់សម្គាល់បន្ទាប់ពីប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយបានចាប់ផ្តើម នៅខែធ្នូ ឆ្នាំ២០១១។ ប៉ុន្តែ មន្ត្រីរាជរដ្ឋាភិបាលមួយចំនួនជឿថា ទេសចរណ៍នឹងប្រសើរឡើងវិញ ហើយថែមទាំងមានភ្ញៀវទេសចរច្រើនទៀតដែលនឹងមកទស្សនា នៅរមណីយដ្ឋានទឹកឈូនៅពេលអនាគត។[៩៩] ទោះបីយ៉ាងណាក៏ដោយ អ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូ មិនសូវមានភាពសុទិដ្ឋិនិយមចំពោះជំនឿដែលថានឹងមានភ្ញៀវច្រើនទៀត មកទស្សនានៅទីនោះនៅឆ្នាំក្រោយៗឡើយ ហើយពួកគាត់ក៏មិនរំពឹងថាវិស័យទេសចរនៅរមណីយដ្ឋានទឹកឈូអាចប្រែដូចកាលពីមុនដែរ។ ហេតុផលសំខាន់ចំពោះបញ្ហានេះ គឺការផ្លាស់ប្តូរនៃលំហូរទឹកធម្មជាតិនៅព្រែកកំចាយដោយពួកគាត់ជឿថា ភ្ញៀវទេសចរចូលចិត្ត «ទឹកធម្មជាតិ» ជាងទឹកដែលបានពីទំនប់វារីអគ្គិសនី។[១០០] អ្នកលក់ដូរខ្លះបានប្រាប់ថាភ្ញៀវទេសចរបានចាប់អារម្មណ៍ចង់ឃើញ និងទស្សនាទំនប់វារីអគ្គិសនីកំចាយ ក៏ប៉ុន្តែរបងលួសបន្លាព័ទ្ធជុំវិញទីតាំងទំនប់ និងទាហានការពារច្រកចូលទៅកាន់ទំនប់វារីអគ្គិសនីកំចាយមិនអាចអោយមានការចូលទៅទស្សនាទំនប់បានឡើយ។[១០១] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បានលើកឡើងថា ផលប៉ះពាល់លើវិស័យទេសចរណ៍នៅរមណីយដ្ឋានទឹកឈូកើតមានឡើងនៅកំឡុងពេលសាងសង់ទំនប់[១០២] ហើយគេយល់ឃើញថា ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី នឹងអាចទាក់ទាញភ្ញៀវទេសចរថែមទៀតមកទស្សនានៅតំបន់នោះ។ ប៉ុន្តែ ការរៀបរាប់អំពីផលប៉ះពាល់នៅកំឡុងពេលប្រតិបត្តិការ

---

[៩៨] ការស្ទង់មតិជាមួយអ្នកពាក់ព័ន្ធនឹងទេសចរណ៍ ១៤-១៨/៩/២០១២

[៩៩] មន្ទីរទេសចរណ៍ ខេត្តកំពត ២៨/៨/២០១២; មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; មេឃុំកំពង់ត្រែង ១៦/៨/២០១២

[១០០] ស្ត្រីម្ចាស់ហាងអាហារ នៅរមណីយដ្ឋានទឹកឈូ០១/៩/២០១២

[១០១] ទៅទស្សនាតំបន់នៅក្បែរទំនប់វារីអគ្គិសនីកំចាយផ្ទាល់ ១៨/៨/២០១២

[១០២] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១ ទំព័រ. ២២០-២២១

គម្រោងទំនប់វារីអគ្គិសនីកំចាយ ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មិនបានលើកឡើងពីផលប៉ះពាល់ដល់វិស័យទេសចរណ៍ឡើយ។[១០៣]

ការរារាំងភ្ញៀវទេសចរ ក្នុងការចូលទៅទស្សនាសំណង់ទំនប់វារីអគ្គិសនីកំចាយ មិនបានជួយស្តារឡើងវិញនូវការធ្វើអោយធ្លាក់ចុះនៃវិស័យទេសចរណ៍ឡើយ។ តាមរយៈការប្រកាសអោយដឹងចុងក្រោយនៃផែនការអភិវឌ្ឍន៍ទេសចរណ៍វិញនោះ កង្វះការអភិវឌ្ឍបែបនេះកាន់តែធ្វើអោយប្រជាជនខកចិត្តទៅទៀត។ ការអភិវឌ្ឍរមណីយដ្ឋានទឹកឈូ អោយទៅជារមណីយដ្ឋានទាក់ទាញភ្ញៀវទេសចរ អាចជួយឆ្លើយតបទៅនឹងឥទ្ធិពលអវិជ្ជមានមួយចំនួន ដែលប្រឈមដោយវិស័យទេសចរណ៍នៅកន្លែងនោះ។ ប៉ុន្តែការសម្ភាសជាមួយភាគីពាក់ព័ន្ធជាច្រើនមិនបានបង្ហាញអោយឃើញពីសុទិដ្ឋិនិយមចំពោះការអភិឌ្ឍក្នុងវិស័យទេសចរណ៍ នៅរមណីយដ្ឋានទឹកឈូឡើយ ដោយសារគ្មានផែនការណាមួយសម្រាប់ការអភិវឌ្ឍទេសចរណ៍ត្រូវបានគេធ្វើឡើងនៅឡើយ។[១០៤] ដូច្នេះហើយទោះបីជាមានផលលំបាកចំពោះសមាជិកសហគមន៍ ដែលប្រកបរបរនៅរមណីយដ្ឋានទឹកឈូយ៉ាងណាក្តី បញ្ហានៃការលើកស្ទួយវិស័យទេសចរណ៍និងបង្កើនចំនួនភ្ញៀវទេសចរ ហាក់បីដូចជាមិនមានការយកចិត្តទុកដាក់ប៉ុន្មានទេ ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ឬក៏ក្រុមហ៊ុនស៊ីណូហៃដ្រូ។

## ១.៥ ការកើនឡើងនៃការប្រកបរបរកាប់អុសបណ្តោះអាសន្ន

ការមិនបានយកដើមឈើដែលបានកាត់រំលំរួច អោយអស់ពីតំបន់អាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីកំចាយ នាំអោយមុខរបរកាប់អុសកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ។ ការជន់លិចតំបន់អាងស្តុកទឹកមុនកាលកំណត់ ជាហេតុបណ្តាលអោយដើមឈើដែលគេកាត់រំលំរួចជាច្រើននៅសេសសល់នៅក្នុងអាង។ អ្នកភូមិភាគច្រើនចូលទៅរកកាប់អុសទាំងនោះ ដោយការប្រើក្បូនដែលធ្វើដោយខ្លួនឯង និងយករណាយន្តកាត់ឈើ ដើម្បីកាត់អុសជាកង់ៗ ល្មមនឹង

---

[១០៣] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១ ទំព័រ. ២២៨-២៣៩

[១០៤] មន្ទីរទេសចរណ៍ ខេត្តកំពត២៨/៨/២០១២

លើកវារួចមុនពេលគេជញ្ជូនវាដាក់លើក្បូន។ អ្នកខ្លះទៀតបណ្តែតឈើទាំងនោះមករហូតដល់មាត់កំពង់។ កំណាត់អុសទាំងនោះ ត្រូវបានគេដឹកជញ្ជូនទៅភូមិស្នំប្រាំពីរដែលជាកន្លែងគេពុះច្រៀកបំបែកអុសទាំងនោះ និងចងវាជាបាច់ៗ។ បើយោងតាមច្បាប់ អ្នកភូមិមិនត្រូវបានគេអនុញ្ញាតអោយកាប់ដើមឈើរស់សម្រាប់លក់ឡើយ ប៉ុន្តែគេអាចកាប់វាធ្វើជាអុសសម្រាប់ប្រើផ្ទាល់ខ្លួនប៉ុណ្ណោះ។[១០៥] យ៉ាងណាមិញ ដើម្បីរៀបចំអាងស្តុកទឹកអោយប្រសើរ ដោយមានឈើនៅសល់ច្រើននៅក្នុងអាងស្តុកទឹក អ្នកភូមិត្រូវបានគេអនុញ្ញាតអោយចូលទៅយកឈើក្នុងអាងស្តុកទឹកទាំងនោះ។

នៅពេលដែលអ្នកភូមិខ្លះ ចូលទៅកាប់អុសទាំងនោះសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ការកាប់ និងធ្វើពាណិជ្ជកម្មអុសជាទ្រុងទ្រាយធំកំពុងតែឃើញមានជាហូរហែនៅតាមផ្លូវពីកំពតទៅទឹកឈូ។ យោងតាមប្រធានភូមិស្នំប្រាំពីរ អ្នកភូមិកាន់តែច្រើនឡើងកំពុងមានមុខរបរលក់អុស។ អ្នកភូមិចំនួនពី ២០ ទៅ ៣០នាក់ ធ្លាប់មានមុខរបរជាអ្នកកាប់អុសនៅតំបន់ទឹកឈូ ក៏ប៉ុន្តែឥឡូវមានអ្នកភូមិច្រើនជាង ៥០គ្រួសារ មកពីភូមិស្នំប្រាំពីរ ចូលទៅកាប់អុសពីអាងស្តុកទឹក។[១០៦] ការកាប់អុសបានធ្វើអោយប្រសើរឡើងដល់ជីវិតរស់នៅនៃគ្រួសារមួយចំនួន ដោយពួកគាត់អាចរកប្រាក់ចំណូលបានប្រមាណពី៣០.០០០រៀល ទៅ ៣៥.០០០រៀល ក្នុង១ថ្ងៃ។ អ្នកប្រកបរបរកាប់អុសជាច្រើន ធ្លាប់ជាអ្នកស៊ីឈ្នួលតាមរដូវកាលនៅចំការដំណាំឈើហូបផ្លែ ដូច្នេះការប្រកបរបរកាប់អុសគួរអោយទាក់ទាញដល់ពួកគាត់ជាង។ ក៏ប៉ុន្តែ ប្រយោជន៍បានពីមុខរបរមួយនេះមិនឋិតថេរនោះទេ ដោយសារឈើដែលសល់ក្នុងអាងស្តុកទឹកអាចកាប់បានប្រហែលជា១ ទៅ ៣ឆ្នាំទៀតប៉ុណ្ណោះ នឹងអស់ហើយ។[១០៧] យ៉ាងណាមិញ អត្ថប្រយោជន៍បណ្តោះអាសន្នពីការប្រកបរបរកាប់អុសនេះ អាចនាំអោយមានបញ្ហាសង្គម និងបរិស្ថាន នៅពេលដែលអុសនៅក្នុងអាងស្តុកទឹកត្រូវគេចូលទៅប្រមូល

---

[១០៥] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២; មន្ទីរបរិស្ថាន ខេត្ត ១៨/១០/ ២០១២; ពិភាក្សាក្រុមភូមិស្នំប្រាំពីរ ២២/៨/២០១២

[១០៦] ប្រធានភូមិស្នំប្រាំពីរ ១៧/៨/២០១២; អ្នកប្រកបរបរកាប់អុសនៅភូមិស្នំប្រាំពីរ ៣១/៨/២០១២

[១០៧] ពិភាក្សាក្រុមភូមិស្នំប្រាំពីរ ២២/៨/២០១២; អ្នកប្រកបរបរកាប់អុសនៅភូមិស្នំប្រាំពីរ ៣១/៨/២០១២; មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/២០១២

អស់។ ប្រជាជនដែលសព្វថ្ងៃកំពុងពឹងផ្អែកលើមុខរបរកាប់ និងលក់អុសសម្រាប់ការចិញ្ចឹមជីវិត ពួកគាត់នឹងប្រឈមមុខនឹងក្ដីលំបាកក្នុងការរក្សាអោយបាននូវប្រាក់ចំណូលរបស់ពួកគាត់។ កត្តានេះអាចនាំអោយមានការកាប់ឈើរស់ ដូច្នេះវានាំអោយបង្កើនសម្ពាធដល់ជីវចម្រុះ និងជំរកសត្វព្រៃនៃឧទ្យានជាតិបូកគោ។




រូបភាព: ការកាប់អុសនៅឯអាងស្តុកទឹក និងការងារពុះបំបែកអុសនៅតាមផ្លូវទៅទឹកឈូ

ជាគោលការណ៍ មន្ទីរបរិស្ថានខេត្តកំពត មិនអនុញ្ញាតអោយមានប្រើរណាយន្តអារឈើនៅតំបន់ឧទ្យានជាតិបូកគោឡើយ។ ក៏ប៉ុន្តែ ពួកគេបានសម្រេចអោយមានករណីលើកលែង និងអនុញ្ញាតអោយប្រើរណារយន្តអាឈើចំនួនពីរគ្រឿង ដើម្បីកាត់ឈើដែលគេប្រមូលក្នុងអាងស្តុកទឹក។ តាមរយៈការសម្ភាស និងការអង្កេតដោយផ្ទាល់នៅទីតាំងគម្រោងបង្ហាញថា មានការរីករាលដាលនៃការប្រើប្រាស់រណាយន្តអារឈើនៅពាសពេញតំបន់អាងស្តុកទឹក។ ទូកមួយចំនួនមានផ្ទុករណាយន្តអារឈើជាច្រើន និងមានឮសំលេងម៉ាស៊ីនអារឈើចេញពីមាត់អាង នៅពេលការចុះទៅមើលផ្ទាល់នៅឯអាងស្តុកទឹក។ សមាជិកសហគមន៍នៅក្នុងមូលដ្ឋានទំនប់វារីអគ្គិសនីកំចាយម្នាក់ដែលធ្វើការជាច្រើនថ្ងៃនៅទីនោះបានប្រាប់ថា មានម៉ាស៊ីនអារឈើមិនតិចជាង២០គ្រឿងឡើយ ដែលកំពុងតែប្រើប្រាស់ដោយអ្នកប្រកបរបរកាប់អុសនៅតំបន់នោះ។[១០៨] កំណើននៃការអាស្រ័យលើមុខរបរកាប់អុសរួមជាមួយការប្រើម៉ាស៊ីនអារឈើ វាអាចជាកត្តាគំរាមកំហែងដល់ព្រៃឈើក្បែរៗនោះ។ នេះអាចនាំអោយមាន

[១០៨] ទស្សនាអាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយ ២០/១០/២០១២

កង្វល់ដល់ជីវៈចម្រុះ និងព្រៃឈើគ្របដណ្តប់នៅតំបន់ឧទ្យានជាតិបូកគោ។ បើមិនមានជម្រើសប្រសើរណាមួយទេ អ្នកប្រកបរបរកាប់អុសមួយចំនួនអាចនឹងស្វែងរកប្រាក់ចំណូលពីតំបន់ ដែលពួកគាត់ធ្លាប់ចូលទៅអាស្រ័យផលតាមមធ្យោបាយផ្សេង ដែលមិនសូវមាននិរន្តរភាពដល់ធនធានទាំងនោះ។ ស្ថានភាពបែបនេះ ទាមទារអោយមន្ត្រីបរិស្ថាន និងអ្នកល្បាតឧទ្យានជាតិបូកគោ ដែលទទួលបានប្រាក់បៀវត្សទាបទាំងនោះអនុវត្តអោយបានម៉ត់ចត់ និងបដិសេធមិនទទួលយកប្រាក់ពីជនល្មើសច្បាប់ ទោះបីជាការធ្វើដូច្នេះ វាផ្ទុយនឹងផលប្រយោជន៍នៃការចិញ្ចឹមជីវិតរបស់ភាគីទាំងពីរក៏ដោយ។

## ១.៦ ការប្រែប្រួលនៃធនធានជលផល

នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ បានប៉ាន់ប្រមាណពីការបាត់បង់ធនធានជលផលនៅព្រែកកំចាយ និងព្រែកស្ទឹងកែវ ដែលជាដៃនៃព្រែកកំចាយនៅចន្លោះឆ្នាំ២០០៦ ដល់ ឆ្នាំ២០១០។ ទិន្នន័យបង្ហាញថាទិន្នផលដែលបានពីការចាប់ត្រីប្រចាំឆ្នាំបានធ្លាក់ចុះពី ២៥.៨៣៣គីឡូក្រាម នៅឆ្នាំ២០០៦ ទៅ ១៥.៩៩៩គីឡូក្រាម នៅឆ្នាំ២០១០(សូមមើលគំនូសតាង៩)។ នៅឆ្នាំ២០១០ ប្រជាជននេសាទត្រីបានត្រឹមតែប្រមាណ៦១%នៃបរិមាណទិន្នផលត្រីដែលគេធ្លាប់នេសាទបាននៅឆ្នាំ២០០៦ នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយបានចាប់ផ្តើម។ ប្រាក់ចំណូល សរុបពីធនធានជលផលដែលគេប៉ាន់ប្រមាណ បានធ្លាក់ចុះដល់៦១% គឺធ្លាក់ចុះពី ៦៣.៥៨៣ ដុល្លារអាមេរិក នៅឆ្នាំ២០០៦ ដល់ ៣៨.៧៩៨ ដុល្លារអាមេរិក នៅឆ្នាំ២០១០។[១០៩]

[១០៩] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១២, សេចក្តីសង្ខេបជាភាសាអង់គ្លេស ទំព័រ. ២១-២២




**គំនូសតាង៩: ទិន្នផលត្រីនៅប្រព័ន្ធព្រែកកំចាយឆ្នាំ២០០៦-២០១០**
(ប្រភព: របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ខែមេសា ឆ្នាំ២០១១ សេចក្តីសង្ខេបជាភាសាអង់គ្លេស)

នៅមុនពេលការសាងសង់ទំនប់វារីអគ្គិសនីកំចាយ មានទឹកជំនន់ពីរបីដងនៅខែសីហា ដែលបានធ្វើអោយមានត្រីក្រោសជាច្រើនចរាចរទៅខ្សែទឹកខាងក្រោម។ ការបំលាស់ទីត្រីនេះនាំអោយមានត្រីជាច្រើន បានធ្វើអោយគ្រួសារនៅខ្សែទឹកខាងក្រោម អាចចាប់ត្រីទាំងនោះបានប្រមាណ៥០ ទៅ១០០ គីឡូក្រាម ក្នុងកំឡុងពេល២ ទៅ ៣ថ្ងៃ ហើយមានគ្រួសារខ្លះអាចចាប់ត្រីលើសពី ១០០គីឡូក្រាម។ យោងតាមខណ្ឌរដ្ឋបាលជលផលខេត្តកំពត មានប្រជាជន ២០០ ទៅ ៣០០គ្រួសារ ធ្លាប់ធ្វើការនេសាទនៅខ្សែទឹកខាងក្រោមដោយប្រើមង នៅកំឡុងពេលដ៏មមាញឹកប៉ុន្មានថ្ងៃនោះ។ ត្រីក្រោសផ្លាស់ទីមកខ្សែទឹកខាងក្រោមដើម្បីពងកូននៅព្រែកកំចាយផ្នែកខាងក្រោមត្រង់ចំណុចដែលព្រែកកំចាយជួបជាមួយព្រែកស្ទឹងកែវ និងព្រែកកំពត។[១១០]

បន្ទាប់ពីការសាងសង់ទំនប់ បច្ចុប្បន្នទឹកជំនន់ដែលធ្លាប់តែកើតមានត្រូវបានគេកំណត់ដោយទួប៊ីន ដូច្នេះហើយបានជាត្រីមិនអាចចរាចរបានតទៅទៀត។ ការឃាំងផ្លូវទឹកនេះ ធ្វើអោយប៉ះពាល់ដល់ពូជត្រីដែលវដ្តនៃជីវសាស្រ្តរបស់វាតម្រូវអោយមានបំលាស់ទី។ ហេតុនេះហើយការចាប់ត្រីក្រោសនៅខ្សែទឹកខាងក្រោមប្រចាំឆ្នាំតាមបែបប្រពៃណីដែលធ្លាប់តែសម្បូរពីមុននោះ ហាក់បីដូចជាមិនមានទៀតទេ

---

[១១០] ខណ្ឌរដ្ឋបាលជលផល ខេត្តកំពត ២៨/៨/២០១២

បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ហើយជាទូទៅទិន្នផលត្រីនៅខាងក្រោមទំនប់កំពុងតែធ្លាក់ចុះ។ យោងតាមខណ្ឌរដ្ឋបាលជលផលខេត្តកំពត ពូជត្រីដែលគេនៅអាចចាប់បាននៅខ្សែទឹកខាងលើរួមមានត្រីតានេល ត្រីខ្ជឹង និងត្រីតានំ។ ត្រីតានេលដែលគេនេសាទបាននៅខាងលើអាងស្តុកទឹកសព្វថ្ងៃ មើលទៅដូចជាមិនសូវមានសុខភាពល្អ ប៉ុន្តែខណ្ឌរដ្ឋាបាលជលផលមិនដឹងពីមូលហេតុវានោះទេ។ ជាទូទៅ ការប្រែប្រួលនៃត្រី និងធនធានជលផលដទៃទៀត នៅអាងស្តុកទឹក និងខ្សែទឹកខាងលើគ្មាននរណាដឹងអំពីមូលហេតុនោះទេ ដោយសារពុំមានការសិក្សាណាមួយត្រូវបានគេធ្វើឡើងនៅទីនោះនៅឡើយ។[១១១]

នៅមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ប្រជាជននៅតាមព្រែកកំចាយធ្លាប់ចាប់ត្រីដោយប្រើស្នូនៅរដូវប្រាំងនៅពេលដែលព្រែកនេះមានទឹករាក់។ ប៉ុន្តែពេលមានទឹកច្រើននៅតាមព្រែកកំចាយ សកម្មភាពចាប់ត្រីដោយប្រើស្នូបែបនេះមិនអាចធ្វើបានទៀតឡើយ។ លើសពីនេះទៀត បើយោងតាមអ្នកដែលបានចូលរួមក្នុងការសម្ភាសម្នាក់ ដែលធ្វើការនៅជិតនឹងព្រែកកំចាយបានលើកឡើងថា វានឹងមិនមានត្រីធំៗនៅផ្នែកខាងក្រោមទំនប់ទៀតឡើយ។[១១២] អ្នកនេសាទនៅខ្សែទឹកខាងក្រោមភាគច្រើននេសាទត្រីបន្ទាប់បន្សំសម្រាប់ជាអាហារក្នុងគ្រួសារ និងរកប្រាក់ចំណូលបន្ថែមប៉ុណ្ណោះ។ ប្រជាជនជាច្រើនបានកាត់បន្ថយ ឬឈប់ធ្វើនេសាទដោយសារពួកគាត់មិនអាចនេសាទត្រីបានច្រើនដូចកាលពីមុន។ បើយោងតាមខណ្ឌរដ្ឋបាលជលផល កត្តាសំខាន់ដែលនាំអោយថយចុះធនធានជលផលគឺមកពីប្រព័ន្ធជលសាស្ត្រនៅផ្នែកខាងក្រោមទំនប់បានរងផលប៉ះពាល់។[១១៣]

---

[១១១] ខណ្ឌរដ្ឋបាលជលផល ខេត្តកំពត ២៨/៨/២០១២

[១១២] ស្ថានីយបូមទឹកខេត្តកំពត ១៦/៨/២០១២

[១១៣] ខណ្ឌរដ្ឋបាលជលផល ខេត្តកំពត ២៨/៨/២០១២




រូបភាព: អ្នកនេសាទនៅតាមអាងស្តុកទឹកនៃទំនប់កំចាយ (ខាងឆ្វេង) និងត្រីដែលគេនេសាទបានពីផ្នែកខាងលើនៃអាងស្តុកទឹក/ព្រែក ហើយដាក់លក់នៅផ្សារស្ទឹងប្រាំពីរ (ខាងស្តាំ)

មុនពេលការសាងសង់ទំនប់វារីអគ្គិសនី អ្នកនេសាទអាចចាប់កូនត្រីនាគ ដែលជាពពួកត្រីជិតផុតពូជនៅខ្សែទឹកខាងលើបានតិចបំផុតពី ២០ ទៅ ៣០ក្បាល ហើយពេលខ្លះអាចចាប់បានរហូតដល់ទៅ១០០ក្បាល។ ត្រីនេះគេអាចចាប់វាបាន នៅពេលមានទឹករាក់ៗនៅរដូវប្រាំង ហើយគេលក់វាសម្រាប់យកទៅតែងលំអ។ សព្វថ្ងៃ បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនី អ្នកភូមិមិនអាចចាប់កូនត្រីនេះបានទៀតឡើយ ដោយសារទឹកនៅក្នុងអាងជ្រៅ។ អាជ្ញាធរមិនប្រាកដថា តើពូជត្រីនេះកំពុងតែបាត់បង់ ឬក៏គ្រាន់តែវាពិបាកស្វែងរក។[១១៤]

ផែនការសាងសង់អាងនៅព្រែកកំចាយ ខាងក្រោមទំនប់វារីអគ្គិសនី នៅជិតរមណីយដ្ឋានទឹកឈូ ត្រូវបានគេធ្វើឡើងបន្ទាប់ពីទទួលបានសំណើរពីខណ្ឌរដ្ឋបាលជលផលខេត្តកំពត។ គម្រោងនេះ ធ្វើឡើងក្នុងន័យដើម្បីការពារពូជត្រីដោយបង្កើតអោយមានតំបន់ការពារសម្រាប់ត្រីក្រោសពង និងបង្កើតកូន។ តាមរយៈនេះគេរំពឹងថាត្រីអាចចរាចរទៅទីកន្លែងដទៃទៀតដែលប្រជាជនអាចចាប់បាន។ នៅខណ្ឌរដ្ឋបាលជលផល ពួកគេមិនទាន់បានទទួលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់ទំនប់កំចាយនៅឡើយ ហើយពួកគេមិនបានដឹងថាតើសំណើរបស់ពួកគេត្រូវបានគេទទួលយកដែរឬទេ ដោយសារពួកគេមិនទាន់បានទទួលបានព័ត៌មានអ្វីមួយ ពីក្រុមហ៊ុនសាងសង់ទំប់វារីអគ្គិសនីស៊ីណូហៃដ្រូ

[១១៤] ខណ្ឌរដ្ឋបាលជលផល ខេត្តកំពត ២៨/៨/២០១២

នៅឡើយ។ ក្រសួងទេសចរណ៍មានការព្រួយបារម្ភអំពីការសាងសង់ទំនប់ទី៣ ដែលគេធ្វើឡើងសម្រាប់តម្កល់ទឹកក្នុងអាងដើម្បីអភិរក្សព្ធជត្រី ព្រោះពួកគេខ្លាចក្រែងគម្រោងនោះនាំអោយមានផលអាក្រក់ដល់វិស័យទេសចរណ៍។[១១៥]

## ១.៧ ការខកខានមិនបានទូទាត់សំណង

នៅតំបន់គម្រោងទំនប់វារីអគ្គិសនីកំចាយ អ្នកភូមិទទួលបានសំណងសម្រាប់ការបាត់បង់ដី និងដើមឈើពាក់ព័ន្ធទៅនឹងការសាងសង់ទំនប់ និងផ្លូវ។ ដូចគ្នានេះដែរ អ្នកភូមិជាទូទៅទទួលបានសំណងនៅកន្លែងណាដែលមានផលប៉ះពាល់ដោយការសាងសង់ខ្សែបណ្តាញចែកចាយចរន្តផងដែរ។ ផ្ទុយទៅវិញ ប្រជាជននៅក្នុងភូមិដែលរងគ្រោះដោយគម្រោងទំនប់វារីអគ្គិសនីកំចាយ មិនទាន់ត្រូវបានគេទូទាត់សំណងជូនសម្រាប់ការបាត់បង់ប្រាក់ចំណូលព្រៃឈើនៅតំបន់ទឹកឈូឬការបាត់បង់ចំណូលពីការថយចុះភ្ញៀវទេសចរនៅរមណីយដ្ឋានទឹកឈូទេ។ នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមបានរៀបរាប់ថាការសាងសង់ទំនប់វារីអគ្គិសនីកំចាយ បានធ្វើអោយប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ប្រជាជនដែលពឹងផ្អែកលើអនុផលព្រៃឈើ និងអ្នកមានមុខរបរនៅរមណីយដ្ឋានទឹកឈូ។ ទោះបីជាមានផលប៉ះពាល់មួយចំនួនដល់មុខរបរប្រជាជនប្រកបរបរក្នុងវិស័យទេសចរ និងអ្នកប្រមូលអនុផលព្រៃឈើនៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីក៏ដោយ តែគួរអោយសោកស្តាយ ដោយសារស្ទើរតែមិនមានការយកចិត្តទុកដាក់ចំពោះផលប៉ះពាល់រយៈពេលវែងដែលអាចបន្តកើតមានឡើង ក្រោយពេលសាងសង់ទំនប់វារីអគ្គិសនី។[១១៦]

យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ថវិកាចំនួន ៥០០.០០០ដុល្លារអាមេរិក ត្រូវគេលៃទុកសម្រាប់ការបាត់បង់ប្រាក់ចំណូលដែលបានមកពីអនុផលព្រៃឈើ និង៥០០.០០០ដុល្លារអាមេរិក ផ្សេងទៀត ត្រូវគេលៃទុកសម្រាប់ការបាត់បង់ប្រាក់ចំណូលពីវិស័យទេសចរណ៍។ ក្រុមហ៊ុនសាងសង់

---

[១១៥] ខណ្ឌរដ្ឋបាលជលផល ខេត្តកំពត ២៨/៨/២០១២

[១១៦] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១

ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ មិនអាចពន្យល់បានថា ថវិកាទាំងនេះត្រូវគេចាយដូចម្តេច ឬថាតើគេចាយវារួចហើយ ឬក៏មិនទាន់ចាយវានោះទេ។ តាមការសម្ភាសជាមួយភាគីពាក់ព័ន្ធជាច្រើន រួមនឹងការអង្កេតនៅទីតាំងសិក្សាបង្ហាញថា ទាំងអ្នកប្រមូលអនុផលព្រៃឈើ និងគ្រួសារដែលពឹងផ្អែកលើវិស័យទេសចរណ៍ សុទ្ធតែមិនបានដឹងពីការខិតខំប្រឹងប្រែងណាមួយដែលក្រុមហ៊ុននឹងធ្វើ ដើម្បីសម្រាលដល់ការបាត់បង់ប្រាក់ចំណូលដែលក្រុមគ្រួសារទាំងនោះជួបប្រទះ ដោយសារការសាងសង់ទំនប់អគ្គិសនីកំចាយ។[១១៧] មន្ទីរទេសចរណ៍ខេត្តកំពត បានសម្គាល់ថា ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ បានលើកឡើងនូវផែនការដើម្បីទូទាត់សំណងដល់តំបន់ដែលមានផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន ក្នុងសិក្ខាសាលានៅចុងឆ្នាំ២០១១។ មន្ទីរទេសចរណ៍ខេត្តកំពត ក៏បានលើកឡើងផងដែរនូវបញ្ហានៃការថយចុះនៃចំនួនភ្ញៀវទេសចរជាប្រការដែលនឹងអាចកើតមាន។[១១៨] នៅភូមិអូរតូចប្រធានភូមិបានបញ្ជាក់ថាមិនមានសំណងណាមួយ ត្រូវបានគេទូទាត់ជូនដល់អ្នកប្រមូលអនុផលព្រៃឈើនៅភូមិរបស់គាត់ឡើយ។[១១៩]

## ការរង់ចាំទទួលសំណង

យោងតាមក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ រាល់សំណងទាក់ទងនឹងការសាងសង់បណ្តាញបញ្ជូនចរន្ត ត្រូវបានទូទាត់ជូនដល់ក្រុមគ្រួសារដែលរងផលប៉ះពាល់រួចហើយ។[១២០] យ៉ាងណាមិញ ការអះអាងនេះផ្ទុយនឹងព័ត៌មានដែលទទួលបានពីការស្រាវជ្រាវនៅមូលដ្ឋានដែលរកឃើញថា យ៉ាងហោចណាស់មានអ្នកភូមិមាត់ពាមពី ៤ ទៅ ៦គ្រួសារ និងអ្នកភូមិអណ្តូងជីមើនចំនួន៦គ្រួសារផ្សេងទៀតដែលរស់នៅក្បែរ ឬនៅក្រោមខ្សែបណ្តាញបញ្ជូនចរន្ត មិនទាន់ទទួល

[១១៧] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២; អង្គការ អាដហុក ខេត្តកំពត ២៣/៨/២០១២; អង្គការលីកាដូ ខេត្តកំពត ២៣/៨/២០១២; នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២; ពិភាក្សាក្រុម ភូមិស្នំប្រាំពីរ ២២/៨/២០១២; អនុប្រធាន ភូមិថ្មីខាងជើង ២៧/៨/២០១២; ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[១១៨] មន្ទីរទេសចរណ៍ ខេត្តកំពត ២៨/៨/២០១២

[១១៩] ប្រធានភូមិអូរតូច ១៨/៨/២០១២

[១២០] ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្តកំពត ២៩/៨/២០១២; ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្ត ៨/១០/២០១២

បានសំណងនៅឡើយ។ ដោយសារកត្តានេះហើយ ដែលនាំអោយអាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនស៊ីណូហៃដ្រូ បានប្រាប់គ្រួសារទាំងនោះថា អោយប្តូរទីលំនៅរបស់ពួកគេចេញ។ ករណីភាគច្រើនក្រុមគ្រួសារទាំងនោះបាននឹងកំពុងរង់ចាំសំណងលើសពី៩ខែមកហើយ ចាប់តាំងពីពួកគេត្រូវបានគេប្រាប់អោយរើចេញ ដោយមិនបានបញ្ជាក់ពីចំនួនប្រាក់សំណង ដែលគេនឹងទទួលបានឡើយ។ គេមិនទាន់ផ្តល់ដីថ្មី ឬផ្ទះដល់គ្រួសារទាំងនោះនៅឡើយទេ។[១២១] បន្ទាប់ពីពួកគាត់ត្រូវបានអាជ្ញាធរប្រាប់ថាវាមិនមានសុវត្ថិភាពឡើយក្នុងការបន្តរស់នៅទីនោះ ប្រជាជនមានការព្រួយបារម្ភពីគ្រោះថ្នាក់ដែលអាចកើតមានដល់សុខភាពរបស់ពួកគាត់។ ប៉ុន្តែ អាជ្ញាធរ ឬក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ មិនបានបញ្ជាក់ជូនពីហានិភ័យទាំងនេះដល់ពួកគាត់ឡើយ។[១២២] អាជ្ញាធរមូលដ្ឋានក៏បានទទួលស្គាល់ថា ពិតជាមានការខកខាន ឬការពន្យាពេលនៃការទូទាត់សំណងដល់គ្រួសារដែលរស់នៅក្រោមខ្សែបញ្ជូនចរន្តពិតប្រាកដមែន។



រូបភាព: គ្រួសាររស់នៅក្រោមខ្សែបញ្ជូនចរន្ត នៅភូមិមាត់ពាម

ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ យល់ថាការទូទាត់សំណងមានភាពស្មុគស្មាញ ដោយសារក្រុមហ៊ុនមានបទពិសោធន៍តិចតួចជាមួយបញ្ហានេះនៅពេលគេបានចាប់ផ្តើម។ ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូបាន

[១២១] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; ប្រធានភូមិមាត់ពាម ១៨/៨/២០១២; ស្ត្រីរស់នៅក្រោមបណ្តាញបញ្ជូនចរន្តនៅភូមិអណ្តូងជីមើន ២១/៨/២០១២; គ្រួសាររស់នៅជិតខ្សែបញ្ជូនចរន្តនៅភូមិអណ្តូងជីមើន ៣០/៨/២០១២; គ្រួសាររស់នៅក្រោមខ្សែបញ្ជូនចរន្តនៅភូមិមាត់ពាម ៣០/៨/២០១២

[១២២] ស្ត្រីរស់នៅក្រោមបណ្តាញបញ្ជូនចរន្តនៅភូមិអណ្តូងជីមើន ២១/៨/២០១២; គ្រួសាររស់នៅជិតខ្សែបញ្ជូនចរន្តនៅភូមិអណ្តូងជីមើន ៣០/៨/២០១២; គ្រួសាររស់នៅជិតខ្សែបញ្ជូនចរន្តនៅភូមិមាត់ពាម ៣០/៨/២០១២; គ្រួសាររស់នៅក្រោមខ្សែបញ្ជូនចរន្តនៅភូមិមាត់ពាម ៣០/៨/២០១២

ពន្យល់ថា ការទូទាត់សំណងជូនគ្រួសារដែលរងគ្រោះដោយគម្រោងធ្វើឡើង តាមរយៈអាជ្ញាធរខេត្តកំពត និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត។ ក្រុមហ៊ុនស៊ីណូហៃដ្រូ បានបង់លុយក្នុងចំនួនព្រមព្រៀងណាមួយអោយទៅអាជ្ញាធរ ខេត្ត ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកំពត ដែលក្រោយមកស្ថាប័ននេះជាអ្នក ទទួលបន្ទុកបង់ប្រាក់សំណងដល់អ្នកដែលរងផលប៉ះពាល់។ ប្រសិនបើអ្នកភូមិជួប ប្រទះបញ្ហាអ្វីមួយ ពួកគាត់ត្រូវប្តឹងទៅអាជ្ញាធរខេត្ត ដែលក្រោយមកអាជ្ញាធរខេត្តធ្វើ ការចរចារជាមួយក្រុមហ៊ុនដោយផ្ទាល់។

តាមការយល់ឃើញរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូ ការអោយរដ្ឋាភិបាលជាអ្នក ទូទាត់សំណងមានភាពងាយស្រួលជាង។ ក្នុងការធ្វើអោយប្រាកដថាសំណងត្រូវគេ ទូទាត់ជូនយ៉ាងត្រឹមត្រូវ ក្រុមហ៊ុនស៊ីណូហៃដ្រូទាមទារអោយមានឯកសារបញ្ជាក់ពី មន្ត្រីរាជរដ្ឋាភិបាលដោយមានហត្ថលេខាពីអ្នកភូមិ។ ទោះបីជាមានព័ត៌មានពិស្តារ អំពីការទូទាត់សំណងក៏ដោយ ក៏ព័ត៌មានទាំងនោះនៅតែជាព័ត៌មានសម្ងាត់រវាងក្រុម ហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាល ហើយវាត្រូវបានគេលាក់ជាអាថ៌កំបាំងពីសហ គមន៍ដែលរងផលប៉ះពាល់ និងមន្ត្រីមូលដ្ឋានដែលពាក់ព័ន្ធ។ នៅពេលធ្វើការ សម្ភាស ក្រុមហ៊ុនស៊ីណូហៃដ្រូ ហាក់បីដូចជាមិនបានដឹងអំពីសំណងដែលមិនទាន់ បានទូទាត់ជូនដល់គ្រួសារ ដែលរស់នៅខាងក្រោមខ្សែបញ្ចូនចរន្តនោះឡើយ។ ទោះបីជាមិនមានព័ត៌មានច្បាស់លាស់ពីមូលដ្ឋានក៏ដោយ ក្រុមហ៊ុននេះយល់ ថា ប្រជាជនទាំងនោះគួររើចេញព្រោះគេបានបង់សំណងជូនរួចរាល់ហើយ។[១២៣] ដូច្នេះ បញ្ហានៅគាំងត្រឹមអាជ្ញាធរខេត្ត និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ដែលជាអ្នកទទួលខុសត្រូវទូទាត់សំណងជូនប្រជាជនក្នុងនាមក្រុមហ៊ុន។ ជាទូទៅ ក្រុមហ៊ុនស៊ីណូហៃដ្រូ មិនចង់ជាប់ពាក់ព័ន្ធជាមួយនឹងសហគមន៍ដែលរងផល ប៉ះពាល់ដោយគម្រោង តាមរយៈផ្ទេរការងារនេះអោយទៅមន្ត្រីថ្នាក់ខេត្ត។ គុណវិបត្តិ នៃដំណើរការនេះនឹងមានពិភាក្សានៅក្នុងផ្នែកព័ត៌មាន និងការចូលរួម។ កង្វះការ ជាប់ពាក់ព័ន្ធរបស់ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ បានធ្វើអោយ

[១២៣] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២; ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្តកំពត ២៩/៨/២០១២

ប្រជាជនមិនមានជម្រើសអ្វីផ្សេងក្រៅពីពឹងផ្អែកលើអាជ្ញាធរមូលដ្ឋាន ដែលហាក់បីដូចជាមិនអាចជ្រៀតជ្រែកអំណាចការងារ របស់មន្ត្រីថ្នាក់ខេត្តបាន។

អាជ្ញាធរមូលដ្ឋានបានប្រាប់ប្រជាជន ដែលរងផលប៉ះពាល់រស់នៅជិតខ្សែបញ្ជូនចរន្តថា ពួកគាត់នឹងទទួលបានសំណង ប៉ុន្តែពួកគាត់មិនត្រូវបានគេប្រាប់នូវចំនួនទឹកប្រាក់ដែលពួកគាត់នឹងទទួលបាននោះឡើយ។ មានប្រជាជនខ្លះចង់ទាក់ទងក្រុមហ៊ុនស៊ីណូហៃដ្រូ ដើម្បីទទួលបានការបញ្ជាក់ពីសំណងរបស់ពួកគាត់ ប៉ុន្តែគ្មាននរណាម្នាក់ដឹងថាក្រុមហ៊ុនស៊ីណូហៃដ្រូ នៅទីណា ឬក៏ត្រូវទាក់ទងបែបណានោះទេ។ កត្តានេះធ្វើអោយប្រជាជនមានអារម្មណ៍ថាវាខ្វះតម្លាភាព ដោយសារពួកគាត់មិនដឹងថាសំណងអ្វីខ្លះ ដែលក្រុមហ៊ុនបានបង់អោយទៅអាជ្ញាធរ។[១២៤] ស្ថានភាពកាន់តែអាក្រក់របស់គ្រួសារដែលរងផលប៉ះពាល់នោះគឺ មានការភ័យខ្លាចក្នុងការធ្វើការដោយឆ្លងកាត់តាមអាជ្ញាធរមូលដ្ឋាន ដែលប្រការនេះត្រូវបានអ្នកភូមិអណ្តូងជីមើនម្នាក់បានពន្យល់ថា *«នៅក្នុងភូមិ ប្រជាជនខ្លាចមិនហ៊ានជជីកសួរអាជ្ញាធរឃុំ ឬតតាំងជាមួយអាជ្ញាធរឃុំ។ ដូចនេះ ប្រសិនបើពួកគាត់ត្រូវអាជ្ញាធរប្រាប់អោយរង់ចាំ ពួកគាត់នឹងត្រលប់មកផ្ទះ ហើយរង់ចាំបន្តទៀត។ ពួកគាត់មិនហ៊ានតតាំងជាមួយនោះទេ។»*[១២៥] ស្ថានភាពបែបនេះ រួមនឹងភាពក្រីក្រក្នុងគ្រួសារ នាំអោយប្រជាជនមានជម្រើសតិចតួចក្រៅពីរង់ចាំ និងសង្ឃឹមថាអាជ្ញាធរ និងក្រុមហ៊ុនស៊ីណូហៃដ្រូ នឹងមិនភ្លេចបញ្ហារបស់ពួកគាត់។[១២៦] ដូចបានរៀបរាប់ខាងលើ បញ្ហាដែលប្រឈមដល់គ្រួសារដែលរងផលប៉ះពាល់ដោយគម្រោង បង្ហាញថានីតិវិធីដែលអនុវត្តដោយក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា នៅខ្វះចន្លោះនៅឡើយ។ ការអនុវត្តបែបនេះមានភាពងាយស្រួលដល់ក្រុមហ៊ុន ក៏ប៉ុន្តែវាមិនបានបម្រើអោយ

---

[១២៤] បុរសមកពីភូមិមាត់ពាម ៣០/៨/២០១២

[១២៥] បុរសមកពីភូមិអណ្តូងជីមើន ២១/៨/២០១២

[១២៦] ស្ត្រីរស់នៅក្រោមបណ្តាញបញ្ជូនចរន្តនៅភូមិអណ្តូងជីមើន ២១/៨/២០១២; គ្រួសាររស់នៅជិតខ្សែបញ្ជូនចរន្តនៅភូមិអណ្តូងជីមើន ៣០/៨/២០១២; គ្រួសាររស់នៅជិតខ្សែបញ្ជូនចរន្តនៅភូមិមាត់ពាម ៣០/៨/២០១២; គ្រួសាររស់នៅក្រោមខ្សែបញ្ជូនចរន្តនៅភូមិមាត់ពាម ៣០/៨/២០១២

សេចក្តីត្រូវការ និងកង្វល់របស់អ្នកភូមិដែលរងផលប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គិសនីកំចាយឡើយ។

## ១.៨ អំពីយេនឌ័រ

ការស្រាវជ្រាវនេះបានរកឃើញថា ផលប៉ះពាល់គួរអោយកត់សម្គាល់ដែលស្ត្រីបានជួបប្រទះ គឺការផ្លាស់ប្តូរទម្រង់នៃការប្រមូលអនុផលព្រៃឈើរបស់ពួកគាត់ (ប្តូរពីអ្នកប្រមូលអនុផលព្រៃឈើទៅជាអ្នកមិនប្រមូលអនុផលព្រៃឈើ) ការធ្លាក់ចុះប្រាក់ចំណូល និងថវិកាសម្រាប់ស្ត្រីដែលមានប្រាក់ចំណូលពីវិស័យទេសចរណ៍ ហើយនឹងបន្ទុកដែលត្រូវថែរក្សាគ្រួសារ និងផ្ទះសម្បែងតែម្នាក់ឯង។ ពេលនៅផ្ទះស្ត្រី ហើយមានករណីខ្លះមានកូនៗផងដែរ មានការងារច្រើនជាងមុនក្នុងការងារផលិតល្វ (កញ្ជោ) ដោយសារបុរសក្នុងគ្រួសារមានពេលវេលានៅផ្ទះតិចជាងមុនដើម្បីជួយសម្រាលការងារដល់ស្ត្រី។ មុនពេលការបាត់បង់ព្រៃឫស្សីនៅតំបន់ទឹកឈូ បុរសមិនធ្លាប់ស្នាក់នៅក្នុងព្រៃឡើយ។[១២៧] បុរសដែលប្រពន្ធរបស់ខ្លួនធ្លាប់រកបានប្រាក់ចំណូលយ៉ាងច្រើនពីការប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូ ឥឡូវប្រឈមនឹងសម្ពាធក្នុងការស្វែងរកប្រភពប្រាក់ចំណូលផ្សេង។ បុរសមកពីគ្រួសារប្រកបរបរកាប់ឫស្សីបាត់បង់ពេលវេលារស់នៅជាមួយ និងថែរក្សាគ្រួសាររបស់ពួកគាត់នៅពេលពួកគាត់ត្រូវស្នាក់នៅក្នុងព្រៃ។ លើសពីនេះទៀត អ្នកតបសម្ភាសន៍ខ្លះបានបញ្ជាក់ថា អ្នកកាប់ឫស្សីមួយចំនួនបានឆ្លងជំងឺគ្រុនចាញ់ បន្ទាប់ពីពួកគាត់បានស្នាក់នៅក្នុងព្រៃនៅពេលយប់ ដែលនេះជាអ្វីដែលពួកគាត់មិនចង់ជួបឡើយ ។[១២៨] គួរអោយសោកស្តាយ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មិនបានយកចិត្តទុកដាក់លើបញ្ហាយេនឌ័រនិងតួនាទីរបស់បុរស និងស្ត្រីព្រមទាំងផលប៉ះពាល់ផ្សេងគ្នាដែលជួបប្រទះដោយបុរស និងស្ត្រីឡើយ។

---

[១២៧] ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[១២៨] គ្រួសារប្រកបរបរកាប់ឫស្សីនៅភូមិអូរតូច ៣១/៨/២០១២; ប្រធានភូមិអូរតូច ១៨/៨/២០១២

## ២. ការប្រើប្រាស់ទឹក ការផ្លាស់ប្តូរក្នុងវិស័យកសិកម្ម និងការប្រែប្រួលអាកាសធាតុ

### ២.១ ការប្រើប្រាស់ទឹកព្រែកកំចាយ និងគុណភាពទឹក

ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ និងមន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពតបានអោយដឹងថា ទឹកពីអាងស្តុកទឹកនៃទំនប់វារីអគ្គិសនីកំចាយភាគច្រើនត្រូវគេប្រើសម្រាប់ផលិតថាមពលអគ្គិសនី ហើយមិនមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់បញ្ចូលទឹកសម្រាប់ធ្វើកសិកម្មណាមួយត្រូវបានគេសាងសង់នោះទេ។ យោងតាមមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត ទឹកដែលបានពីទំនប់នៅខ្សែទឹកខាងក្រោម មិនគ្រប់គ្រាន់សម្រាប់ប្រព័ន្ធស្រោចស្រពខ្នាតធំ ហើយវាហាក់បីដូចជាពុំទាន់មានផែនការណាមួយ សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធបែបនេះនៅឡើយ។[១២៩]

នៅពេលដែលទឹកភាគច្រើនពីអាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយ ត្រូវបានគេបញ្ចេញ ប្រមាណជា ២.៤ គីឡូម៉ែត្រ នៅខ្សែទឹកខាងក្រោម បន្ទាប់ពីទឹកទាំងនោះប្រើសម្រាប់ផលិតថាមពលអគ្គិសនីរួច នៅរោងចក្រអគ្គិសនី១ លំហូរអប្បរមា ៤.៥ ម៉ែត្រគូប ក្នុង១នាទី ត្រូវគេរក្សាអោយមានជានិច្ចនៅខាងក្រោមទំនប់មេ។[១៣០] លំហូរនេះគេធ្វើឡើងដើម្បីរក្សាជំរកដល់ធនធានក្នុងទឹក ដែលមានកាលពីមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ បន្ទាប់ពីទឹកត្រូវគេបង្ហូរចេញពីអាងស្តុកទឹក ទឹកនោះត្រូវគេប្រើប្រាស់សម្រាប់ភ្ញៀវទេសចរនៅរមណីយដ្ឋានទឹកឈូមកលេង ហើយនៅខ្សែទឹកខាងក្រោមទឹកនេះ ជាប្រភពទឹកសម្រាប់ផ្គត់ផ្គង់អោយរដ្ឋាករទឹកខេត្តកំពត។ គ្រួសារមួយចំនួននៅតាមព្រែកកំចាយក៏ប្រើទឹកព្រែកនេះ សម្រាប់ស្រោចដំណាំឈើហូបផ្លែរបស់ពួកគាត់ និងប្រើប្រាស់ក្នុងផ្ទះសម្បែង រួមសម្រាប់ទទួលទានផងដែរ។ ដោយមានទឹកប្រៃហូរចូលនៅរដូវប្រាំង ការប្រើទឹកព្រែកកំចាយសម្រាប់ស្រោចដំណាំ និងប្រើប្រាស់ក្នុងគ្រួសារ ភាគច្រើនមានតែនៅតំបន់ខ្សែទឹកខាងលើ ចាប់ពីភូមិមាត់ពាម និងភូមិស្នំប្រាំពីរនៅម្តុំតំបន់រមណីយដ្ឋានទឹកឈូ។

---

[១២៩] មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពត ២៨/៨/២០១២; ក្រុមហ៊ុនស៊ីណូហៃដ្រូ ៩/១០/២០១២

[១៣០] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

## អំពីគុណភាពទឹក



រូបភាពៈ បម្រែបម្រួលគុណភាពទឹកបានធ្វើអោយកករជានជាប់នឹងដើមឈើនៅតាមព្រែកកំចាយ

គុណភាពទឹក នៅព្រែកកំចាយ មានការថយចុះយ៉ាងខ្លាំងនៅកំឡុងពេលនៃការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ។ កត្តានេះ បានបង្កឡើដោយសារការកាត់បន្ថយបរិមាណទឹកក្នុងព្រែក និងការបំពុលទឹក ដោយការសាងសង់ទំនប់តាមរយៈកាកសំណល់រាវ និងរឹងពីកម្មករ។ ដោយសារគុណភាពទឹក ប្រែជាអាក្រក់បែបនេះ រដ្ឋាករទឹកខេត្តកំពតត្រូវធ្វើប្រព្រឹត្តកម្មទឹកកាន់តែខ្លាំង ដែលកត្តានេះនាំអោយមានក្លិនសារធាតុគីមីនៅក្នុងទឹកស្អាត។[១៣១] បុរសម្នាក់ធ្វើការនៅជិតព្រែកកំចាយបានពន្យល់ថា ទឹកព្រែកនេះកាលពីមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ មានសភាពថ្លាខ្លាំងណាស់ ប៉ុន្តែនៅកំឡុងពេលសាងសង់ ទឹកព្រែកនេះបែរជាមានពណ៌ក្រហម។ សព្វថ្ងៃ បន្ទាប់ពីការសាងសង់បានបញ្ចប់ ទឹកព្រែកនៅមានពណ៌ក្រហមព្រឿងៗនៅឡើយ។ គាត់មិនហ៊ានចុះទៅក្នុងទឹកទៀតឡើយ ដោយគាត់បារម្ភថាទឹកនឹងធ្វើអោយប៉ះពាល់ដល់ស្បែករបស់គាត់ និងធ្វើអោយគាត់រមាស់។[១៣២] ប្រជាជនផ្សេងទៀត ដែលបានចូលរួមក្នុងការសម្ភាស ក៏បានបង្ហាញនូវកង្វល់ដូចៗគ្នា ហើយពួកគាត់នៅតែមិនហ៊ានចុះក្នុងទឹកនោះ បន្ទាប់ពីទំនប់បានសាងសង់រួច។ យ៉ាងណាមិញផលប៉ះពាល់ចំពោះសុខភាព ដូចជារមាស់ស្បែកគ្រាន់តែជាការភ័យខ្លាចក្នុងអារម្មណ៍របស់អ្នកភូមិតែប៉ុណ្ណោះ។ យោងតាមមន្ទីរសុខាភិបាលខេត្តកំពត មិនមានការកើនឡើងនៃករណីទាក់ទងទៅនឹងជំងឺឆ្លងតាមទឹកឬក៏ជំងឺរមាស់ស្បែកនៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយឡើយ។[១៣៣] ប្រធានភូមិមាត់ពាមក៏មិនបានដឹងពីជំងឺណាមួយដែល

---

[១៣១] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២

[១៣២] ស្ថានីយបូមទឹក ខេត្តកំពត ១៦/៨/២០១២

[១៣៣] មន្ត្រីសុខាភិបាល ខេត្តកំពត ២៤/៨/២០១២

បានកើតលើស្បែករបស់អ្នកភូមិផងដែរ ប៉ុន្តែគាត់បានបញ្ជាក់ថា អ្នកភូមិជាច្រើនខ្លាចមិនហ៊ានចូលទៅក្នុងទឹកព្រែក ក្នុងកំឡុងពេលនៃសាងសង់ទំនប់វារីអគ្គិសនីកំចាយហើយរហូតមកដល់សព្វថ្ងៃ ប្រជាជនខ្លះនៅតែព្រួយបារម្ភពីបញ្ហានេះនៅឡើយ។[១៣៤]

នៅពេលទៅមើលនៅអាងស្តុកទឹកដោយផ្ទាល់ ទឹកនៅក្នុងអាងនៅជិតជញ្ជាំងអាង មានពណ៌លឿង និងពណ៌ត្នោតព្រឿងៗ ហើយអាចមើលឃើញទៅក្រោមក្នុងជម្រៅទឹកប្រមាណជា ២ ទៅ ៤ម៉ែត្រ។ មានឈើជាច្រើន អណ្តែតមកទើនៅនឹងជ្រុង និងជញ្ជាំងទំនប់។[១៣៥] ក្រសួងបរិស្ថានបានទទួលស្គាល់ថា មានផលប៉ះពាល់ដល់គុណភាពទឹកនេះផងដែរ ប៉ុន្តែគេរំពឹងថាគុណភាពទឹកនឹងប្រែជាល្អដូចដើមវិញក្នុងរយៈពេលពីរទៅបីឆ្នាំខាងមុខ។[១៣៦] កង្វះអុកស៊ីសែនរួមនឹងមានដើមឈើនិងរុក្ខជាតិរលួយក្នុងអាងស្តុកទឹកដែលអាចបង្កអោយមានសត្វល្អិត ឬរុក្ខជាតិចង្រៃក្នុងទឹក ត្រូវបានគេលើកឡើងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។[១៣៧] តាមការត្រួតពិនិត្យដោយផ្ទាល់នៅត្រង់ចំណុចមួយនៃអាងស្តុកទឹក មើលដោយភ្នែកទទេ គេមិនឃើញមានរុក្ខជាតិដុះ ឬសត្វល្អិតច្រើនហួសហេតុនៅក្នុង ឬនៅក្បែរអាងស្តុកទឹកឡើយ។ ដូចគ្នានេះដែរ នៅកំឡុងពេលសម្ភាសក្នុងតំបន់គោលដៅនៃសិក្សានេះ មិនមានការចង្អុលបង្ហាញណាមួយទាក់ទងនឹងបញ្ហាខាងលើឡើយ។ ដោយឡែក តាមរយៈទំហំនៃការសិក្សានេះ គេមិនបានធ្វើការពិសោធន៍ដើម្បីពិនិត្យបញ្ហានេះឡើយ។ លោកមេឃុំម៉ាក់ប្រាងបានអះអាងថាទឹកព្រែកសព្វថ្ងៃមានគុណភាពដូចកាលពីមុន។[១៣៨] មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត ក៏បានយល់ស្របនឹងមតិរបស់លោកមេឃុំ ដោយបានបន្ថែមថា គុណភាពទឹកព្រែកមិនមាន

[១៣៤] ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[១៣៥] ទៅពិនិត្យមើល ទំនប់វារីអគ្គិសនីកំចាយ ២៩/០៨/២០១២

[១៣៦] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២

[១៣៧] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១ ទំព័រ.២៣០

[១៣៨] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២

បញ្ហាសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារទេ ទោះបីជាគុណភាពទឹកក្នុងអាងមិនទាន់ត្រូវបានគេពិសោធន៍ក៏ដោយ។[១៣៩]

### ២.១.១ ការប្រើប្រាស់ទឹកសម្រាប់វិស័យកសិកម្ម

នៅមុនពេលការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ទឹកជំនន់តូចៗមានជាញឹកញយក្នុងមួយឆ្នាំៗ ហើយបាននាំដីល្បាប់មកចាក់ដីដែលទឹកជន់លិចនោះ។ ការមិនមានទឹកជំនន់តូចៗនេះ បានធ្វើអោយប៉ះពាល់ដល់ដីកសិកម្មដែលពឹងផ្អែកលើទឹកជំនន់ប្រមាណជា៣០ហិចតា នៅឃុំម៉ាក់ប្រាង។ ទោះបីជាពេលវេលាមិនសមល្មមដើម្បីវាយតម្លៃហេតុប៉ះពាល់នៃការមិនមានទឹកជំនន់ក៏ដោយ កសិករប្រហែលជាមិនអាចស្ទូងស្រូវទាន់ពេលវេលា ហើយត្រូវធ្វើស្រែដោយរង់ចាំទឹកភ្លៀង។[១៤០] ប្រការនេះ អាចជាដើមចមនាំអោយមានការថយចុះទិន្នផលស្រូវពីដីស្រែទាំងនោះ នៅពេលមានការថយចុះដីល្បាប់ និងទឹកជាលក្ខណៈធម្មជាតិ។ ករណីទិន្នផលធ្លាក់ចុះ កសិករនឹងបង្កើនកត្តាផលិតកសិកម្មដូចជាជីកសិកម្ម កត្តានេះនាំអោយថ្លៃដើមផលិតកើនឡើង។ ទោះបីជាអាចនឹងមានផលប៉ះពាល់បែបនេះដល់ការធ្វើកសិកម្មក៏ដោយ វាហាក់បីដូចជាមិនទាន់មានការតាមដានការផ្លាស់ប្តូរនេះនៅឡើយ។

ការប្រើប្រាស់ទឹកសម្រាប់បង្ហូរចូលស្រែ ឬដំណាំផ្សេងៗ ជាទូទៅមិនចាំបាច់ឡើយនៅរដូវវស្សា។ ចំណែកនៅរដូវប្រាំងវិញ នៅពេលដែលកសិករត្រូវការទឹកសម្រាប់ដំណាំកសិកម្មផ្សេងៗ ទឹកប្រៃបានហូរចូលក្នុងព្រែកធ្វើអោយកសិករជាច្រើនមិនអាចប្រើប្រាស់ទឹកព្រែកនៅរដូវប្រាំងបាន។ ព្រំដែនបែងចែកទឹកសាប និងទឹកប្រៃធ្លាប់មាននៅប្រមាណជា១០០ម៉ែត្រ នៅខាងក្រោមស្ថានីយបូមទឹកដែលនៅជិតនឹងរមណីយដ្ឋានទឹកឈូ។ ចាប់តាំងពីប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយបានចាប់ផ្តើម វាហាក់បីដូចជាព្រំដែនបែងចែកទឹកសាបបានថយចុះទៅខាងស្ថានីយបូមទឹកប្រមាណជា១គីឡូម៉ែត្រ។ បើទឹកសាបអាចមានរហូតដល់ ២ ទៅ ៤ គីឡូម៉ែត្រខាងក្រោមស្ថានីយបូមទឹក កត្តានេះនាំអោយកសិករជាច្រើនដែលរស់នៅតាមព្រែក

---

[១៣៩] មន្ទីរធនធានទឹក និងឧតុនិយ ខេត្តកំពត ២៨/៨/២០១២

[១៤០] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២

កំចាយក្នុងឃុំម៉ាក់ប្រាងអាចប្រើទឹកនេះសម្រាប់បញ្ចូលស្រែ និងស្រោចដំណាំបាន។ នៅតាមដងព្រែកដែលពេលថ្មីៗមានទឹកសាបនៅរដូវប្រាំង មានក្រុមគ្រួសារចំនួន ៣០ ទៅ ៤០គ្រួសារ បានសាកល្បងប្រើទឹកពីព្រែកកំចាយសម្រាប់ដីដាំដើមឈើហូបផ្លែប្រមាណជា ៤០ហិចតា។[១៤១]

អត្ថប្រយោជន៍កសិកម្មពីការកើនឡើងនៃកម្រិតទឹកសាប អាចមានរហូតដល់តំបន់នៅតាមស្ទឹងកែវដែលជាដៃរបស់ព្រែកកំចាយ ដែលមានការរំខានពីទឹកប្រៃផងដែរ។ កសិករមួយចំនួននៅភូមិមាត់ពាមបានតាមដានបម្រែបម្រួលនៃកម្រិតទឹកប្រៃយ៉ាងជិតស្និទ្ធ ដោយសារមានសញ្ញាណមួយចំនួនបញ្ជាក់ថា នៅទីនោះមានទឹកសាបច្រើនជាងមុន។ នៅពេលកសិករជាច្រើនកំពុងរង់ចាំមើលជាយូរ ថាតើទឹកក្នុងព្រែកនឹងប្រែជាស្រស់ថ្លាឬអត់ ពួកគាត់នឹងសប្បាយរីករាយប្រសិនបើពួកគាត់អាចប្រើទឹកទាំងនោះនៅរដូវប្រាំងបាន។[១៤២] នៅឃុំកំពង់គ្រែង ប្រជាជនប្រើអាងឬអណ្តូងសម្រាប់ស្រោចដំណាំចូរនេរបស់ពួកគាត់ រីឯស្រូវវិញត្រូវគេដាំដុះតែនៅរដូវវស្សាប៉ុណ្ណោះ។ រហូតមកដល់ពេលនេះ មិនមានទឹកសាបនៅក្នុងផ្នែកណាមួយនៃព្រែកទៅដល់ទីនោះនៅរដូវប្រាំងឡើយ។[១៤៣]

### កម្រិតទឹកប្រៃ

លោកមេឃុំមាក់ប្រាងបានកត់សម្គាល់ថា មានការផ្លាស់ប្តូរនៃរបបទឹកដែលឈានទៅរកការកើនឡើងនៃបរិមាណទឹកសាបនៅក្នុងព្រែក។ ទោះបីជាមិនមានការបញ្ជាក់ច្បាស់លាស់ពីកន្លែងដែលគាត់បានអង្កេតក៏ដោយ គាត់បានប្រាប់អោយដឹងថា ទឹកសាបធ្លាប់មាននៅចន្លោះខែឧសភា ទៅ ខែវិច្ឆិកា។ សព្វថ្ងៃ ទឹកសាបនៅក្នុងព្រែកមាននៅចន្លោះខែឧសភា ទៅ ខែកុម្ភៈ ឬខែមីនា។[១៤៤] ការសង្កេតនេះត្រូវទៅនឹងការរំពឹងថាបរិមាណទឹកសាប ដែលគេបញ្ចេញពីទំនប់នឹងកើនឡើងនៅរដូវប្រាំង។

---

[១៤១] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; ស្ថានីយបូមទឹកខេត្តកំពត ១៦/៨/២០១២

[១៤២] ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[១៤៣] មេឃុំកំពង់គ្រែង ១៦/៨/២០១២

[១៤៤] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២

ការផ្លាស់ប្តូរនៃបរិមាណទឹកប្រៃនៅព្រែកកំចាយបង្ហាញទាំងឱកាស និងចំនុចអវិជ្ជមាន។ ដោយសារទឹកសមុទ្រដែលធម្មតាហូរចូលព្រែកកំចាយនៅរដូវប្រាំងត្រូវរារាំងដោយបរិមាណទឹកសាបច្រើនជាងមុននៅរដូវប្រាំង សមាសភាពសត្វក្នុងទឹកក៏មានការប្រែប្រួលផងដែរ។ ពពួកត្រី ឬសត្វសមុទ្រធម្មតារស់នៅផ្នែកខាងក្រោមនៃព្រែកនឹងត្រូវបាត់បង់នៅពេលដែលពពួកត្រី ឬសត្វទឹកសាបដែលមិនធ្វើចរាចរអាចនឹងបង្ហាញខ្លួន។ លើសពីផលប៉ះពាល់លើបរិស្ថានដែលត្រូវបានរៀបរាប់ខាងលើនេះ វាក៏មានផលប៉ះពាល់ដល់សង្គមផងដែរ ដោយសារអ្នកនេសាទដែលធ្លាប់នេសាទបង្គា និងពពួកត្រី ឬសត្វសមុទ្រនៅក្នុងទន្លេនឹងមិនអាចនេសាទបានតទៅទៀត។[១៤៥]

ចំពោះចំណុចវិជ្ជមានវិញប្រសិនជាទឹកនៅព្រែកកំចាយប្រែជាសាបពេញរដូវប្រាំង វានឹងក្លាយជាធនធានយ៉ាងសំខាន់សម្រាប់កសិកររស់នៅជិតព្រែកដែលអាចប្រើទឹកសាបក្នុងព្រែកកំចាយ សម្រាប់ស្រោចដំណាំឈើហូបផ្លែរបស់ពួកគាត់។ ទោះបីជាយ៉ាងណាក៏ដោយ គេមិនធ្លាប់ធ្វើពិសោធន៍កម្រិតទឹកប្រៃនៅក្នុងព្រែកកំចាយឡើយ។[១៤៦] នេះមានន័យថា បរិមាណទឹកប្រៃក្នុងព្រែកដែលបានមកពីឥទ្ធិពលនៃការផ្លាស់ប្តូរប្រព័ន្ធជលសាស្រ្ត ព្រែកកំចាយប្រែប្រួលទៅជាបែបណាក៏ដោយ ក៏មិនទាន់ត្រូវបានគេស្រាវជ្រាវបង្ហាញលទ្ធផលអោយដឹងនៅឡើយ។ ហេតុនេះ វាពិបាកក្នុងការវាយតម្លៃ និងធ្វើការឆ្លើយតបទៅនឹងការផ្លាស់ប្តូរនេះអោយបានពេញលេញណាស់។

## ២.២ ការផ្លាស់ប្តូរនៃវិស័យកសិកម្ម និងប្រព័ន្ធទឹកស្រោចស្រព

ក្រៅពីការផលិតថាមពលអគ្គិសនី គោលបំណងបន្ទាប់បន្សំផ្សេងទៀតនៃទំនប់វារីអគ្គិសនីកំចាយ គឺជាប្រភពសម្រាប់ជាទឹកស្រោចស្រព។[១៤៧] ទោះជាយ៉ាងនេះក្តី មិនមានការយកចិត្តទុកដាក់លើវិស័យកសិកម្ម និងទឹកស្រោចស្រពដែលមានរៀបរាប់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ហើយវាមិន

[១៤៥] កសិករភេទប្រុស មកពីភូមិម៉ាក់ប្រាង ១៦/៨/២០១២

[១៤៦] មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត ២៨/៨/២០១២

[១៤៧] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១២, សេចក្តីសង្ខេបជាភាសាអង់គ្លេស ទំព័រ.៤

ប្រាកដថាតើទំនប់វារីអគ្គិសនីកំចាយអាចឆ្លើយតបនឹងគោលបំណងនោះដែរ ឬទេ។ ជាលទ្ធផលនៃកិច្ចពិគ្រោះយោបល់ដែលធ្វើឡើងនៅខែមីនាឆ្នាំ២០១១ នៅខេត្តកំពត ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ បានយល់ព្រមសាងសង់ទំនប់រង នៅខាងក្រោមរមណីយដ្ឋានទឹកឈូ ដើម្បីធ្វើជាអាងស្តុកទឹកសម្រាប់ការពារ និង បង្កើនផលត្រី។ គេអាចនិយាយបានថា អាងស្តុកទឹកនេះអាចប្រើជាអាងទឹកសាប ដែលប្រជាជនអាចប្រើសម្រាប់ស្រោចស្រពដំណាំឈើហូបផ្លែរបស់ពួកគាត់។[១៤៨] ក៏ប៉ុន្តែ បើគេគិតដល់ផលប៉ះពាល់ដល់វិស័យទេសចរណ៍ ការសាងសង់ទំនប់រងមួយផ្សេងទៀតនៅកៀកនឹងរមណីយដ្ឋានទឹកឈូ ប្រហែលជាមិនអាចធ្វើទៅបានឡើយ។[១៤៩] ឧបមាថា មានការកើនឡើងនៃបរិមាណទឹកសាបនៅរដូវប្រាំងកសិករអាចនឹងប្រើប្រាស់ទឹកសាបយ៉ាងហោចណាស់ចំងាយ ១គីឡូម៉ែត្រ ពីស្ថានីយបូមទឹកនៅតំបន់ទឹកឈូ។[១៥០] នេះមានន័យថា លុះត្រាតែហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពត្រូវគេសាងសង់បន្ថែម បើពុំនោះទេអាងស្តុកទឹកថ្មីនោះនឹងមិនធ្វើអោយមានអ្វីប្លែកសម្រាប់កសិករនៅក្នុងតំបន់ឡើយ។

ការសម្ភាសជាមួយសហគមន៍មូលដ្ឋាន មន្ត្រីរដ្ឋាភិបាល និងក្រុមហ៊ុនស៊ីណូហៃដ្រូ រួមនឹងការអង្កេតនៅតំបន់សិក្សាផ្ទាល់បានបង្ហាញថា គ្មានសញ្ញាណាមួយពីហេដ្ឋារចនាសម្ព័ន្ធទឹកស្រោចស្រព ដែលបានមកពីគម្រោងទំនប់នេះឡើយ។[១៥១] នៅភូមិមាត់ពាម ប្រធានភូមិមិនបានសម្គាល់ថាមានការផ្លាស់ប្តូរដោយផ្ទាល់លើទឹកស្រោចស្រព ឬផលិតផលកសិកម្មឡើយ ក៏ប៉ុន្តែគាត់បានសំគាល់ថា ប្រជាជនសប្បាយចិត្តដែលសព្វថ្ងៃមិនមានទឹកជំនន់នៅក្នុងភូមិរបស់ពួកគាត់។ ទឹកជំនន់

---

[១៤៨] របាយការណ៍ ESIA ខែមេសាឆ្នាំ២០១១ ទំព័រ. ១៨៧

[១៤៩] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២; ខណ្ឌរដ្ឋបាលជលផល ខេត្តកំពត ២៨/៨/២០១២

[១៥០] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២

[១៥១] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; ប្រធានភូមិស្នំប្រាំពីរ និងអ្នកជំនួយការ ១៧/៨/២០១២; ប្រធានភូមិមាត់ពាម ១៨/៨/២០១២; មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត ២៨/៨/២០១២; ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២; ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២; ការស្ទង់មតិជាមួយអ្នកពាក់ព័ន្ធនឹងទេសចរណ៍១៤-១៨/៩/២០១២

ដែលធ្លាប់មានបីទៅបួនដងក្នុងមួយឆ្នាំ ពេលខ្លះបានបំផ្លិចបំផ្លាញដើមឈើហូបផ្លែ និងបសុសត្វ។[១៥២] អាជ្ញាធរនៅឃុំកំពង់ក្រែង និងឃុំអណ្តូងខ្មែរ ដែលឃុំទាំងពីរស្ថិតខ្សែទឹកខាងក្រោមនៅឆ្ងាយពីឃុំម៉ាក់ប្រាងបានពន្យល់ថា ប្រជាជននៅក្នុងភូមិសុទ្ធតែមិនអាចប្រើទឹកពីព្រែកកំចាយ សម្រាប់ជាទឹកស្រោចស្រពដំណាំនៅរដូវប្រាំងបានឡើយ។ ដោយឡែក ពួកគាត់បានបញ្ជាក់ថា វាខុសគ្នានឹងភូមិស្នំប្រាំពីរ ដែលដីស្រែមួយចំនួនទទួលបានប្រយោជន៍ពីទឹកជំនន់លក្ខណៈប្រពៃណី វាលស្រែនៅឃុំទាំងពីរនេះមិនពឹងផ្អែកលើទឹកជំនន់ទាំងនោះឡើយ។ ផ្ទុយទៅវិញ ទឹកជំនន់ទាំងនោះបានបំផ្លាញដំណាំស្រូវ និងឈើហូបផ្លែផ្សេងៗទៅវិញ។ យោងតាមប្រធានភូមិអូរតូច ការកើនឡើងនៃកម្រិតទឹកសាបក្នុងព្រែកកំចាយនឹងមិនមានឥទ្ធិពលមកលើភូមិរបស់គាត់ឡើយ ដោយសារអ្នកភូមិរបស់គាត់មិនមានដើមឈើហូបផ្លែ និងដីកសិកម្មនៅជិតព្រែកកំចាយឡើយ។[១៥៣]

លោក ហ្គ្រីមស្ឌិត្ឋ (Grimsditch) បានរៀបរាប់ពីបទពិសោធន៍របស់កសិករដែលមានដើមធូរេននៅជិតព្រែកកំចាយបានងាប់មែក។ ពួកគាត់ជឿថា កត្តានេះបង្កឡើងដោយការថយចុះនៃគុណភាពទឹកនៃព្រែកកំចាយ។[១៥៤] ប៉ុន្តែការសិក្សានេះមិនបានធ្វើការផ្ទៀងផ្ទាត់ផលប៉ះពាល់បែបនេះឡើយ។ ទោះបីជាកសិករខ្លះបានប្រាប់អោយដឹងពីការបាត់បង់ដើមធូរេនរបស់ពួកគាត់ក៏ដោយ គ្មាននរណាម្នាក់ក្នុងចំណោមអ្នកដែលគេបានសម្ភាសន៍ បានប្រាប់ថាគុណភាពទឹកគឺជាប្រភពបង្កអោយបាត់បង់ដើមធូរេនរបស់ពួកឡើយ។ ពួកគាត់បានសន្មត់ថាដើមឈើដែលបានងាប់គឺបង្កដោយទឹកជំនន់ដ៏ធំនៅឆ្នាំ២០០៩ ឬដោយសារជំងឺ។[១៥៥]

---

[១៥២] ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[១៥៣] មេឃុំកំពង់ក្រែង ១៦/៨/២០១២; មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; ប្រធានភូមិអូរតូច ១៨/៨/២០១២

[១៥៤] ហ្គ្រីមស្ឌត្ឋ (Grimsditch, M.) ឆ្នាំ ២០១២, ទំព័រ. ២១

[១៥៥] កសិករភេទប្រុស មកពីភូមិម៉ាក់ប្រាង ១៦/៨/២០១២; ម្ចាស់ហាងពីភូមិស្នំប្រាំពីរ ២០/៨/២០១២

## ២.៣ ការប្រែប្រួលអាកាសធាតុ និងទំនប់វារីអគ្គិសនីកំចាយ

នៅថ្នាក់ក្រសួង នាយកដ្ឋានឧទ្យានជាតិទទួលស្គាល់ថា ទំនប់នឹងធ្វើអោយប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុ ដោយសារការបាត់បង់ព្រៃឈើនៅតំបន់នៃអាងស្តុកទឹក។ ទោះជាទំហំនៃផលប៉ះពាល់ពិបាកប៉ាន់ស្មាន ប៉ុន្តែគេយល់ថាវាមានទំហំតូចជាងតម្លៃសេដ្ឋកិច្ចរបស់ទំនប់។[១៥៦] ការបំភាយឧស្ម័នផ្ទះកញ្ចក់ពីរុក្ខជាតិ និងដើមឈើដែលរលួយនៅក្នុងអាងស្តុកទឹកមិនត្រូវបានគេបញ្ជាក់ឡើយ។ មន្ទីរបរិស្ថានខេត្តកំពត បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការការពារព្រៃឈើដើម្បីកាត់បន្ថយផលប៉ះពាល់ដល់បម្រែបម្រួលអាកាសធាតុ ក៏ប៉ុន្តែផលប៉ះពាល់ដោយសារវត្ថុរលួយក្នុងអាងស្តុកទឹកមិនត្រូវបានគេយល់ថាជាបញ្ហាសំខាន់ឡើយ។ ផ្ទុយទៅវិញផលវិជ្ជមាននៃទំនប់វារីអគ្គិសនី ដែលជាមធ្យោបាយដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុត្រូវបានគេបង្ហាញ ហើយគេក៏បានលើកឡើងពីសំណើររបស់ក្រុមហ៊ុនស៊ីណូហៃដ្រូ ក្នុងការទទួលបានឥណទានកាបូនតាមរយៈយន្តការអភិវឌ្ឍន៍ស្អាត[១៥៧] ផងដែរ។[១៥៨]

មានការរិះគន់ផ្សេងៗអំពីសំណើរ សម្រាប់ឥណទានការអភិវឌ្ឍស្អាតនេះ ដោយលើកឡើងថា គេគួរលើកឡើងផងដែរពីឥទ្ធិពលអាក្រក់របស់ទំនប់វារីអគ្គិសនីមកលើបរិស្ថានដើម្បីបដិសេធសំណើបែបនេះ។[១៥៩] ការជំទាស់ដ៏សំខាន់នោះគឺមកពីការយល់ឃើញពីការខកខានមិនបានកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដោយសារគេបានសាងសង់ទំនប់វារីអគ្គិសនីរួចរាល់ទៅហើយ ទោះជាមិនទទួលបានឥណ

[១៥៦] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២

[១៥៧] យន្តការអភិវឌ្ឍន៍ស្អាតគឺជាការចាត់ចែងក្រោមអនុសញ្ញាក្យូតូ(Kyoto) ដែលអនុញ្ញាតអោយប្រទេសឧស្សាហកម្មប្តេជ្ញាកាត់បន្ថយឧស្ម័យផ្ទះកញ្ចក់ដោយធ្វើការវិនិយោគគម្រោង ដែលកាត់បន្ថយការបំភាយឧស្ម័ននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលជាជម្រើសទៅនឹងការចំណាយយ៉ាងថ្លៃក្នុងការកាត់បន្ថយការបំភាយឧស្ម័ននៅក្នុងប្រទេសរបស់ខ្លួន។

[១៥៨] មន្ទីរបរិស្ថានខេត្តកំពត ១៨/១០/២០១២

[១៥៩] អង្គការទន្លេអន្តរជាតិ ខែមករា ឆ្នាំ២០១២; អង្គការទន្លេអន្តរជាតិ ខែមីនា ឆ្នាំ២០១០; Globalization Monitor ឆ្នាំ ២០១០

ទានកាបូនក៏ដោយ។[១៦០] លើសពីនេះទៀត មានមតិជំទាស់ថាផលប៉ះពាល់អាក្រក់ដល់បរិស្ថាន និងសង្គមនៃគម្រោងទំនប់វារីអគ្គិសនី ផ្ទុយទៅនឹងគោលបំណងនៃយន្តការអភិវឌ្ឍន៍ស្អាត ហើយគេក៏បានជំទាស់ផងដែរថា គម្រោងទំនប់វារីអគ្គិសនីទាំងនោះមិនបានគោរពតាមសេចក្តីតម្រូវអោយមានការចូលរួមជាសាធារណៈឡើយ។[១៦១]

គេហទំព័ររបស់ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីស៊ីណូហៃដ្រូ បានលើកឡើងថា ក្រុមហ៊ុនមានការប្តេជ្ញាចិត្តខ្ពស់ចំពោះការថែរក្សាបរិស្ថាន ដោយរាប់បញ្ចូលទាំង «ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។»[១៦២] ការយកចិត្តទុកដាក់កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលអាចបង្កឡើងដោយទំនប់វារីអគ្គិសនីកំចាយ គឺជាបញ្ហាចោទយ៉ាងខ្លាំង។

ការសម្អាតនិងយករូបធាតុសរីរាង្គចេញពីអាងមិនបានល្អ វាទំនងជានាំអោយមានការបំភាយឧស្ម័នមេតាន និងឧស្ម័នដទៃទៀតជាច្រើនជាមិនខាន ដែលនឹងបង្កើននូវបរិមាណបំភាយឧស្ម័នក្នុងអាយុកាលរបស់ទំនប់។ របាយការណ៍ជាច្រើនបង្ហាញថាអាងស្តុកទឹកបានផលិតឧស្ម័នផ្ទះកញ្ចក់ក្នុងបរិមាណយ៉ាងច្រើនជាពិសេសនៅតំបន់ត្រូពិច។[១៦៣] ជាក់ស្តែងអាងស្តុកទឹកបញ្ចេញឧស្ម័នមេតានដែលបង្កជាឧស្ម័នផ្ទះកញ្ចក់ ២០ ទៅ ២៥ដង ខ្លាំងជាងឧស្ម័នកាបូនិចក្នុងមួយឯកត្តា។[១៦៤] ដំណើរការដែលនាំអោយមានការបំភាយឧស្ម័នផ្ទះកញ្ចក់ពីអាងស្តុកទឹកមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ «គ»។

---

[១៦០] គេសាងសង់ទំនប់បន្ថែមដោយសារគេទទួលបានថវិកាពីការលក់ឥណទានកាបូន។ នៅពេលទំនប់មិនមានលក្ខខណ្ឌបន្ថែមវាត្រូវគេផ្តល់មូលនិធិតាមរយៈការលក់ឥណទានកាបូនទោះបីជាវាត្រូវបានគេសាងសង់ដោយគ្មានចំណូលពីឥណទានទាំងនោះក៏ដោយ។ (CC Glossary, International Rivers)

[១៦១] អង្គការទន្លេអន្តរជាតិ ឆ្នាំ២០១២

[១៦២] http://eng.sinohydro.com/en/idems/dev.asp?showtype=2&ClassID=18 - ទាញយកអត្ថបទ ២៣/១០/២០១២

[១៦៣] គុមុ (Kummu, M. et al.) ឆ្នាំ២០១០; ហារកូណេន (Harkonen) ឆ្នាំ២០០៩; អាយ អ អិន (IRN) ឆ្នាំ២០០៧; អង្គការទន្លេអន្តរជាតិ ខែវិច្ឆិកា ឆ្នាំ២០០៨; អង្គការទន្លេអន្តរជាតិ ខែតុលា ឆ្នាំ២០០៨;ហ្វ្រេងគែល(Frankel, M.)ឆ្នាំ ២០១២

[១៦៤] ហ្វ្រេងគែល (Frankel, M.) Frankel, M. ២០១២; អង្គការទន្លេអន្តរជាតិ ខែវិច្ឆិកា ឆ្នាំ២០០៨; អាយ អ អិន (IRN) ឆ្នាំ ២០០៧



រូបភាព: អាងស្តុកទឹកនៃទំនប់កំចាយ រូបភាពតាមផ្កាយរណប ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១២
(ក្រុមហ៊ុនអារុណា តិចណូឡូជី អិលធីឌី)

ផ្ទៃទឹកនៃអាងស្តុកទឹក នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១២ ដូចឃើញនៅក្នុងរូបភាពតាមផ្កាយរណបខាងលើមានទំហំប្រមាណជា ១,៤២២ហិចតា បើយោងតាមអារុណាតិចណូឡូជី (Aruna Technology)។ ផ្ទៃអាងនេះមានទំហំតូចជាងផ្ទៃអាងស្តុកទឹកដែលគេបានពិពណ៌នាថាមានទំហំប្រហែលជា ២,០០០ហិចតា ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមខ្លាំងណាស់។ តាមការបង្ហាញនៅក្នុងរូបភាព តំបន់នៅជុំវិញអាងមានពេញទៅដោយរុក្ខជាតិពណ៌បៃតង។ សន្មត់ថាមានផ្ទៃដីទំហំប្រមាណ ៥០០ ទៅ ៦០០ហិចតា បន្ថែមទៀត នឹងជន់លិចនៅក្រោយខែឧសភា នេះបញ្ជាក់ថាគេមិនបានសម្អាតព្រៃអោយបានត្រឹមត្រូវក្នុងផ្ទៃអាងយ៉ាងហោចណាស់ ២៥% នៃផ្ទៃអាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយ។

រូបធាតុសរីរាង្គដែលងាយបង្កអោយទៅជាសារធាតុកាបូន ឃើញមាននៅក្នុងអាងស្តុកទឹកដែលទឹកទើបជន់លិច ជាទូទៅនាំអោយមានការផលិតឧស្ម័នផ្ទះកញ្ចក់ខ្ពស់នៅក្នុងអាងស្តុកទឹកថ្មី បើប្រៀបធៀបទៅនឹងអាងស្តុកទឹកដែលមានវ័យចាស់ជាង។ ការពុកផុយយ៉ាងយឺតៗនៃសារធាតុកាបូននៅក្នុងឫសឈើអាចធ្វើអោយបន្ត

មានការបំភាយឧស្ម័នក្នុងកម្រិតដ៏ខ្ពស់ ក្នុងរយៈពេលជាច្រើនទស្សវត្សរ៍ទៅមុខទៀត។[១៦៥] ដើម្បីកាត់បន្ថយការបំភាយឧស្ម័នអោយមានកម្រិតតិចបំផុត វាមានសារៈសំខាន់ណាស់ដែលត្រូវយករាល់សារធាតុសរីរាង្គ រួមមានគុម្ពោតព្រៃ និងរុក្ខជាតិតូចៗព្រមទាំងសារធាតុដែលងាយរលួយផ្សេងទៀតចេញអោយអស់ពីទីកន្លែងដែលត្រូវទឹកជន់លិចជាប្រចាំ។[១៦៦]

ការពន្យល់លើទំហំនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ ហើយនឹងផលប៉ះពាល់ផ្សេងទៀត ដែលបង្កដោយការសម្អាតអាងស្តុកទឹកមិនបានល្អ វាមានការលំបាកក្នុងកម្រិតនៃការសិក្សានេះ។ ក៏ប៉ុន្តែវាប្រាកដណាស់ថា ផលប៉ះពាល់លើការប្រែប្រួលអាកាសធាតុគឺទាមទារអោយមានការយកចិត្តទុកដាក់ និងពិនិត្យពិច័យថែមទៀត មិនត្រឹមតែការពិចារណាលើសំណើរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូ សម្រាប់ឥណទានកាបូនប៉ុណ្ណោះទេ។



រូបភាពៈ ដើមឈើដែលត្រូវទឹកជន់លិចក្នុងអាងស្តុកទឹកនៃទំនប់កំចាយ

[១៦៥] អេសធី លូវីស (St. Louis et al.) ឆ្នាំ២០០០, ដកស្រង់នៅក្នុងហារកូណេន (here in Harkonen) ឆ្នាំ២០០៩,ទំព័រ.១៦

[១៦៦] គុមុ (Kummu, M. et al.) ឆ្នាំ ២០១០

## ៣. ការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងទឹកជំនន់ ថាមពលអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធ

### ៣.១ ការផ្គត់ផ្គង់ទឹក

រាល់ការផ្គត់ផ្គង់ទឹកដោយរដ្ឋាករទឹកខេត្តកំពត មានប្រភពមកពីព្រែកកំចាយ តាមរយៈស្ថានីយបូមទឹកនៅខាងក្រោមរមណីយដ្ឋានទឹកឈូ ដែលមានចម្ងាយប្រមាណជា៨គីឡូម៉ែត្រ ពីក្រុងកំពត។ រដ្ឋាករទឹកខេត្តកំពតផ្គត់ផ្គង់ទឹកស្អាតទៅផ្នែកខ្លះនៃស្រុកទឹកឈូ និងស្រុកកំពត ក្នុងតម្លៃ១៨០០រៀល ក្នុងមួយម៉ែត្រគូប។ តម្លៃនេះដូចគ្នានឹងតម្លៃនៅមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ គេពិសោធន៍គុណភាពទឹកចំនួនបីដងគឺ ពេលគេបូមទឹកពីស្ថានីយបូមទឹក នៅពេលទឹកឆ្លងកាត់រោងចក្រប្រព្រឹត្តិកម្ម និងនៅពេលគេចែកចាយទឹកដល់អ្នកប្រើប្រាស់។ នៅកំឡុងពេលសាងសង់ទំនប់ រដ្ឋាករទឹកខេត្តកំពតជួបប្រទះការលំបាកជាមួយនឹងគុណភាពទឹកដែលមានប្រភពពីព្រែកកំចាយ ប៉ុន្តែសព្វថ្ងៃបញ្ហាទាំងនោះមិនមានទៀតឡើយ។ សព្វថ្ងៃ កម្រមានបញ្ហាជាមួយទឹកប្រៃចូលមកដល់ស្ថានីយបូមទឹកនេះណាស់ បញ្ហានេះបានកើតឡើងចុងក្រោយគេនៅឆ្នាំ២០០៣ ក៏ប៉ុន្តែដោយទំនប់បញ្ចេញទឹកច្រើននៅរដូវប្រាំង បញ្ហានេះហាក់បីដូចជាមិនកើតមានទៀតឡើយ។[១៦៧] នៅតាមភូមិភាគច្រើននៅតំបន់ខាងក្រោមទំនប់វារីអគ្គិសនីកំចាយ មិនអាចទទួលបានទឹកពីរដ្ឋាករទឹកខេត្តកំពតទេ ដោយសារបណ្តាញចែកចាយមិនទាន់ទៅដល់តំបន់ដាច់ស្រយាលទាំងនោះនៅឡើយ។

នៅភូមិស្នំប្រាំពីរ ក្រុមគ្រួសារជាច្រើនប្រើប្រាស់ទឹកពីក្រុមហ៊ុនផ្គត់ផ្គង់ទឹកឯកជនដែលមានប្រភពទឹកពីភ្នំនៅជិតភូមិ។ យូរៗម្តង ទឹកបានពីប្រភពនេះមិនមាន (រីងស្ងួត) ដែលនាំអោយអ្នកភូមិខ្លះប្រើទឹកព្រែកកំចាយសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារប្រចាំថ្ងៃ។[១៦៨] នៅភូមិដទៃទៀតនៅក្នុងតំបន់នោះ ទឹកអណ្តូង និងទឹកភ្លៀងជាប្រភពទឹកប្រើប្រាស់ចាំបាច់បំផុតសម្រាប់អ្នកភូមិ។ ប៉ុន្តែ នៅភូមិថ្មីខាងជើងមានក្រុមហ៊ុនផ្គត់ផ្គង់ទឹកឯកជនមួយដែលយកទឹកពីរដ្ឋាករទឹកខេត្តកំពតមកផ្គត់ផ្គង់។ ការសាង

---

[១៦៧] រដ្ឋករទឹកខេត្តកំពត ២៣/៨/២០១២

[១៦៨] ម្ចាស់ហាងនៅភូមិស្នំប្រាំពីរ ២០/៨/២០១២; ស្ត្រីប្រកបរបរលក់ដូរ មកពីភូមិស្នំប្រាំពីរ ១៦/៨/២០១២; មេឃុំម៉ាក់ប្រាង ១៥/៨-២០១២

សង់ទំនប់ មិនបានធ្វើអោយប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកស្អាតដល់ភូមិមួយចំនួនដែលបានជ្រើសរើសក្នុងការសិក្សានេះឡើយ។ ការសង្ខេបពីការផ្គត់ផ្គង់ទឹកស្អាតក្នុងភូមិដែលបានធ្វើការសិក្សាមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ «ឃ»។

ការស្ទង់មតិតាមក្រុមគ្រួសារបានបង្ហាញថា មានអ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូចំនួន ៩១% បានប្រើទឹកព្រែកកំចាយសម្រាប់ប្រើប្រាស់ក្នុងគ្រួសារប្រចាំថ្ងៃ នៅមុនពេលការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ ចំនួននេះបានថយចុះមកត្រឹមតែ ៩% បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយរួច។ មានអ្នកប្រកបរបរកាប់ឬស្សីចំនួន៩% បានប្រើទឹកព្រែកកំចាយសម្រាប់ប្រើប្រាស់ក្នុងគ្រួសារប្រចាំថ្ងៃ នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ[១៦៩] ហើយចំនួននេះបានកើនឡើងដល់៣៨% បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយបានបញ្ចប់។ ការកើនឡើងនេះ ត្រូវបានអ្នកប្រកបរបរកាប់ឬស្សីពន្យល់ថា ដោយសារពួកគាត់ត្រូវស្នាក់នៅក្នុងព្រៃនៅជិតនឹងអាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយ។ ការចំណាយពេលច្រើនជាងមុននៅឯអាងស្តុកទឹក នាំអោយអ្នកចូលទៅកាប់ឬស្សីប្រើទឹកអាងស្តុកទឹកសម្រាប់ផឹកច្រើនជាងមុន។ នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ អ្នកប្រកបរបរកាប់ឬស្សីប្រើប្រាស់ទឹកនេះ៨២% តែឥឡូវបន្ទាប់ពីការសាងសង់ការប្រើប្រាស់កើនឡើងដល់៩០%។ នៅខ្សែទឹកខាងក្រោមទំនប់វារីអគ្គិសនីកំចាយ ក្នុងចំណោមអ្នកលក់ដូរដែលបានចូលរួមក្នុងការសិក្សានេះ ការប្រើទឹកសម្រាប់ផឹកបានថយចុះពី៣៦% កាលពីមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយមកត្រឹម១៤% ក្រោយពេលសាងសង់ទំនប់នេះរួច។[១៧០]

---

[១៦៩] អ្នកភូមិអូរតូច ថ្មីខាងជើង មាត់ពាម ដែលគេបានស្ទង់មតិសុទ្ធតែរស់នៅឆ្ងាយពីទំនប់កំចាយ ពួកគេប្រើទឹកព្រែកកំចាយភាគច្រើននៅពេលគេទៅកាប់ឬស្សីនៅទឹកឈូ ឬនៅតំបន់ជិតអាងស្តុកទឹក។

[១៧០] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២; ការស្ទង់មតិជាមួយអ្នកពាក់ព័ន្ធនឹងទេសចរណ៍ ១៤-១៨/៩/២០១២

## ៣.២ ការគ្រប់គ្រងទឹកជំនន់

សមាជិកសហគមន៍ និងមន្ត្រីរាជរដ្ឋាភិបាលដែលបានចូលរួមក្នុងការសិក្សានេះភាគច្រើនបានបង្ហាញថាផលវិជ្ជមានពីទំនប់វារីអគ្គិសនីកំចាយ គឺការកាត់បន្ថយទឹកជំនន់នៅតំបន់ខាងក្រោមទំនប់វារីអគ្គិសនីកំចាយ រួមទាំងនៅក្រុងកំពតក្នុងរយៈពេលពីរឆ្នាំចុងក្រោយ។ មេឃុំអណ្តូងខ្មែរបានចង្អុលបង្ហាញអំពីឥទ្ធិពលវិជ្ជមាននៃការទប់ស្កាត់ទឹកជំនន់របស់ទំនប់ ដោយសម្គាល់ថា នៅមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយ មានទឹកជំនន់រៀងរាល់ឆ្នាំដែលបានធ្វើអោយខូចផ្លូវ ផ្ទះសម្បែង និងសម្លាប់សត្វចិញ្ចឹម។ ទឹកជំនន់ធ្លាប់បង្កបញ្ហាជាច្រើនដល់អាជ្ញាធរមូលដ្ឋាន និងមានផលប៉ះពាល់ដល់សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ បច្ចុប្បន្ន ដោយសារទឹកជំនន់ប្រហែលជាមិនកើតឡើងទៀត ប្រជាជនបានចាប់ផ្តើមដាំដើមឈើហូបផ្លែបន្ថែម និងកែលំអផ្ទះសម្បែងរបស់ពួកគាត់។ ដូច្នេះ គាត់យល់ថា ទំនប់ផ្តល់ប្រយោជន៍ដល់សហគមន៍របស់គាត់ទ្វេរដង ដោយសារពួកគាត់គេចផុតពីការបំផ្លិចបំផ្លាញពីទឹកជំនន់ និងអាចទទួលបានផលប្រយោជន៍ពីការវិនិយោគបន្ថែមលើការធ្វើកសិកម្ម និងការចិញ្ចឹមជីវិតផ្សេងៗ។[១៧១]

ទោះបីជាការកាត់បន្ថយទឹកជំនន់ និងភាពរឹងមាំរបស់ទំនប់ជាលទ្ធផលដែលគេរំពឹងទុកសម្រាប់ករណីទំនប់កំចាយក៏ដោយ ប៉ុន្តែលទ្ធភាពពិតប្រាកដរបស់ទំនប់ក្នុងការទប់ស្កាត់ទឹកជំនន់ដែលមានទំហំធំៗ មិនទាន់អាចដឹងច្បាស់នៅឡើយ។ យោងតាមមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត កម្រិតទឹកភ្លៀងក្នុងរយៈពេលពីរឆ្នាំកន្លងទៅមិនទាន់ដល់កម្រិតមួយ ដែលខេត្តកំពតត្រូវទទួលរងនូវទឹកជំនន់ធំឡើយ។ ដូច្នេះ វាហាក់បីដូចជាលឿនពេកដែលមានការសន្និដ្ឋានថាតើទំនប់វារីអគ្គិសនីកំចាយអាចទប់ស្កាត់ទឹកជំនន់ធំបាន ឬក៏មិនបាននោះ។[១៧២] ទោះជាមានការសន្និដ្ឋានពីលទ្ធភាពរបស់ទំនប់វារីអគ្គិសនីកំចាយក្នុងការទប់ស្កាត់ទឹកជំនន់ តែសមាជិកសហគមន៍បារម្ភថាទំនប់អាចនឹងបាក់រលំ។ ការភ័យខ្លាចនេះមួយចំនួនកើត

---

[១៧១] មេឃុំអណ្តូងខ្មែរ ២០/០៨-២០១២

[១៧២] មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត ២៨/៨/២០១២

ចេញពីកង្វះចំណេះដឹងអំពីទំនប់។ ជាក់ស្តែង ការសិក្សានេះបានរកឃើញថាគ្មានអ្នកភូមិណាមួយត្រូវបានគេប្រាប់អោយដឹងអំពីសុវត្ថិភាព ឬផលប៉ះពាល់បរិស្ថាន និងសង្គមរបស់ទំនប់ឡើយ។[១៧៣]

### ៣.៣ ការផ្លាស់ប្តូរការផ្គត់ផ្គង់ និងតម្លៃអគ្គិសនី

ក្នុងចំណោមភូមិចំនួនបី ក្នុងឃុំម៉ាក់ប្រាង មានតែភូមិស្នំប្រាំពីរប៉ុណ្ណោះមានអគ្គិសនីដែលផ្គត់ផ្គង់ដោយអគ្គិសនីខេត្តកំពត សម្រាប់ប្រើប្រាស់។ ប៉ុន្តែពេលបច្ចុប្បន្ន នៅក្នុងភូមិនោះមានតែប្រជាជនប្រមាណ ១០០គ្រួសារ ក្នុងចំណោម ៦៥៥ គ្រួសារប៉ុណ្ណោះដែលមានអគ្គិសនីប្រើប្រាស់ ហើយចំនួននេះដូចគ្នាទៅនឹងចំនួនមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយដែរ។[១៧៤] នេះមានន័យថា ការកើនឡើងនៃការផលិតថាមពលអគ្គិសនីក្នុងឃុំ មិនទាន់ធ្វើអោយកើនឡើងនូវការប្រើប្រាស់អគ្គិសនីនៅក្នុងសហាគមន៍មូលដ្ឋាននៅឡើយ។ ចំពោះគ្រួសារដែលបានភ្ជាប់បណ្តាញអគ្គិសនីរបស់រដ្ឋ បានកើនពី ១៦% ទៅ ២៣% ហើយបានកាត់បន្ថយតម្លៃអគ្គិសនីពី ១,១០០រៀល/គីឡូវ៉ាត់ម៉ោង នៅភូមិស្នំប្រាំពីរ និង ១២០០រៀល/គីឡូវ៉ាត់ម៉ោង នៅឃុំអណ្តូងខ្មែរ នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ មកត្រឹម៩២០រៀល/គីឡូវ៉ាត់ម៉ោង នៅក្រោយការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។[១៧៥] ក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីឯកជនចំនួន ៣ ទៅ ៤ ក្រុមហ៊ុន បានពង្រីកបណ្តាញចែកចាយអគ្គិសនីដល់តំបន់មួយចំនួននៃភូមិមាត់ពាម ដែលនៅទីនោះអគ្គិសនីមានតម្លៃ ២,០០០រៀល/គីឡូវ៉ាត់ម៉ោង។ ការពង្រីកបណ្តាញចែកចាយនេះបានកើនឡើងនៅមុន និងក្រោយការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។[១៧៦] ការបន្តពង្រីកការផ្គត់ផ្គង់អគ្គិសនីឯកជន

---

[១៧៣] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; ការពិភាក្សាជាក្រុម នៅភូមិថ្មីខាងជើង ២៧/៨/២០១២; ការពិភាក្សាជាក្រុមនៅភូមិអូរតូច ២៩/៨/២០១២; ការពិភាក្សាជាក្រុមនៅភូមិស្នំប្រាំពីរ ២២/៨/២០១២; ស្ត្រីប្រកបរបរលក់ដូរ មកពីភូមិស្នំប្រាំពីរ ១៦/៨/២០១២; គ្រួសារប្រកបរបរកាប់អុសពីភូមិស្នំប្រាំពីរ ៣១/៨/២០១២; គ្រួសាររស់នៅក្រោមខ្សែបញ្ជូនចរន្ត នៅភូមិមាត់ពាម ៣០/៨/២០១២

[១៧៤] មេឃុំម៉ាក់ប្រាង ១៥/៨-២០12

[១៧៥] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; មេឃុំអណ្តូងខ្មែរ ២០/០៨-២០១២

[១៧៦] ឃុំអណ្តូងខ្មែរ ២០/៨-២០១២

នៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយអាចបង្ហាញបានថា ក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីទាំងនោះប្រហែលជាមិនរំពឹងថា អគ្គិសនីរដ្ឋនឹងត្រូវគេចែកចាយមកដល់តំបន់នោះនៅពេលឆាប់ៗឡើយ ដោយសារកត្តានេះនឹងធ្វើអោយប៉ះពាល់ដល់ការវិនិយោគរបស់ពួកគេ។ ក្រុមហ៊ុនទាំងនោះបានចាប់ផ្តើមផ្គត់ផ្គង់អគ្គិសនីដល់ភូមិមាត់ពាមកាលពី៣ឆ្នាំមុន ហើយបច្ចុប្បន្នអ្នកភូមិប្រហែលពាក់កណ្តាលបានភ្ជាប់បណ្តាញអគ្គិសនីនេះ។ ប្រធានភូមិមិនបានដឹងអំពីគម្រោងផ្គត់ផ្គង់អគ្គិសនីរបស់រដ្ឋមកកាន់ភូមិគាត់ឡើយ។ ជាមួយនឹងតម្លៃសេវាភ្ជាប់អគ្គិសនីចំនួន ១៦០ដុល្លារអាមេរិក ដែលអ្នកភូមិត្រូវចំណាយលើសេវានេះដោយរាប់បញ្ចូលទាំងថ្លៃខ្សែភ្លើង ក្រុមគ្រួសារជាច្រើនយល់ថា ពួកគាត់មិនមានលទ្ធភាពភ្ជាប់បណ្តាញអគ្គិសនីនេះឡើយ។[១៧៧]

នៅឃុំកំពង់ត្រែង មេឃុំបានស្វាគមន៍ចំពោះការកើនឡើងនូវការផ្គត់ផ្គង់អគ្គិសនីរដ្ឋដែលមានតម្លៃថោកជាង មកជំនួសអគ្គិសនីឯកជន។ អគ្គិសនីឯកជនធ្លាប់មានតម្លៃ ២,១០០ ទៅ ២,២០០ រៀល/គីឡូវ៉ាត់ម៉ោង នៅពេលគេចាប់ផ្តើមផ្គត់ផ្គង់នៅឆ្នាំ២០០៦ ឬ២០០៧។ សព្វថ្ងៃ មានភូមិចំនួន៤ ក្នុងចំណោមភូមិទាំង៥ នៅក្នុងឃុំ មានអគ្គិសនីប្រើប្រាស់ ហើយភូមិចុងក្រោយគេគឺភូមិអណ្តូងជីមើនបានភ្ជាប់បណ្តាញបានខ្លះហើយ។ ការផ្គត់ផ្គង់អគ្គិសនីដែលប្រសើរឡើងនៅក្នុងភូមិទាំងនេះបានកើតឡើងនៅមុនការបញ្ចប់ការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ដូច្នេះ វាទំនងជាការរីកចំរើននេះមិនមែនជាលទ្ធផល ដែលបានពីទំនប់វារីអគ្គិសនីកំចាយនោះទេ។[១៧៨] ឃុំអណ្តូងខ្មែរដែលនៅជិតក្រុងកំពតជាងឃុំដែលត្រូវគេសិក្សាពីរទៀតនោះបច្ចុប្បន្នមានអគ្គិសនីផ្គត់ផ្គង់ដល់ភូមិទាំងប្រាំក្នុងឃុំនេះ។[១៧៩] ប៉ុន្តែ អ្នកភូមិនៅក្នុងឃុំនេះ មិនបានភ្ជាប់បណ្តាញអគ្គិសនីទាំងអស់គ្នានោះទេ។ ការស្ទង់មតិជាមួយអ្នកប្រកបរបរកាប់ឫស្សីនៅភូមិអូរតូច ភូមិថ្មីខាងជើង និងភូមិមាត់ពាម បានបង្ហាញថា មានតែប្រជាជនចំនួន ២៤% នៃប្រជាជន ៧៨គ្រួសារ ដែលបានចូលរួមក្នុងការសម្ភាស មានអគ្គិសនីប្រើប្រាស់បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។

---

[១៧៧] ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[១៧៨] មេឃុំកំពង់ត្រែង ១៦/៨/២០១២

[១៧៩] មេឃុំអណ្តូងខ្មែរ ២០/០៨-២០១២

កាលពី៥ឆ្នាំ មុន នៅមុនការសាងសង់ទំនប់ ប្រជាជនចំនួន១១.៥% នៃអ្នកភូមិទាំងនេះមានអគ្គិសនីប្រើប្រាស់។ ក្នុងចំណោមអ្នកដែលមានអគ្គិសនីប្រើប្រាស់ មានតែ ៥៤% ប៉ុណ្ណោះពេញចិត្តនឹងតម្លៃអគ្គិសនី។[១៨០] មានអ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូចំនួន៨២% នៅពេលសព្វថ្ងៃមានអគ្គិសនីប្រើប្រាស់ដែលប្រៀបធៀបកាលពី៥ឆ្នាំមុន អ្នកមានអគ្គិសនីប្រើប្រាស់មានត្រឹមតែ៧៧%។ ប៉ុន្តែ អ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូចំនួន៣៧,៥% ដែលមានអគ្គិសនីប្រើប្រាស់បានពេញចិត្តនឹងតម្លៃអគ្គិសនី។ ជាទូទៅ អ្នកភូមិជាច្រើនមកពីភូមិស្ពំប្រាំពីរគិតថាតម្លៃអគ្គិសនី គួរតែមានតម្លៃថោកជាងនេះដោយសារទំនប់នៅក្បែរផ្ទះរបស់ពួកគាត់។[១៨១]

នៅភូមិអូរតូចមិនមានការផ្គត់ផ្គង់អគ្គិសនីរដ្ឋឡើយ នៅមុនឆ្នាំ២០០៨ ឬ ២០០៩ ដែលនោះជាពេលដែលគេចាប់ផ្តើមផ្គត់ផ្គង់អគ្គិសនីដល់ផ្ទះមួយចំនួននៅក្នុងភូមិ។ រហូតមកដល់ខែមីនា ឆ្នាំ២០១២ តម្លៃអគ្គិសនីរដ្ឋគឺ ១,២០០រៀល/គីឡូវ៉ាត់ម៉ោង បន្ទាប់មកតម្លៃអគ្គិសនីបានធ្លាក់ចុះដល់ ៩២០រៀល/គីឡូវ៉ាត់ម៉ោង ជាតម្លៃនៅក្រោយប្រតិបត្តិការទំនប់កំចាយ។ ទោះបីជាសព្វថ្ងៃ មិនមានការផ្គត់ផ្គង់អគ្គិសនីឯកជនក៏ដោយ តែតំបន់ខ្លះនៃភូមិអូរតូចនៅជិតភូមិថ្មីខាងជើងធ្លាប់ប្រើអគ្គិសនីឯកជនដែលមានតម្លៃ ២,០០០រៀល/គីឡូវ៉ាត់ម៉ោង។ ប្រធានភូមិអូរតូចបានអះអាងថា ៩០% នៃអ្នកភូមិអូរតូចបច្ចុប្បន្នបានប្រើប្រាស់បណ្តាញអគ្គិសនីរបស់រដ្ឋ។[១៨២] យ៉ាងណាមិញ ការអង្កេតនៅតំបន់សិក្សា និងការស្ទង់មតិជាមួយអ្នកប្រកបរបរកាប់ឬស្សីបានបង្ហាញថា ភាគរយនៃអ្នកប្រើប្រាស់អគ្គិសនីគួរតែមានកម្រិតទាបជាងអ្វីដែលបានអះអាងរបស់ប្រធានភូមិ។ ភូមិថ្មីខាងជើងដែលជាភូមិនៅជាប់នឹងភូមិអូរតូចនៅពេលបច្ចុប្បន្នមានប្រជាជនភាគច្រើនមានអគ្គិសនីរដ្ឋប្រើប្រាស់។[១៨៣] ស្ថេរភាពអគ្គិសនីរួមនឹងការធ្លាក់ចុះនៃតម្លៃអគ្គិសនី ត្រូវបានអាជ្ញាធរទេសចរណ៍ជឿថាបាន

[១៨០] ការស្ទង់មតិអំពីអនុផលពីព្រៃឈើ ១៤-១៨/៩/២០១២

[១៨១] ការស្ទង់មតិជាមួយអ្នកពាក់ព័ន្ធនឹងទេសចរណ៍ ១៤-១៨/៩/២០១២

[១៨២] ប្រធានភូមិអូរតូច ១៨/៨/២០១២

[១៨៣] អនុប្រធានភូមិថ្មីខាងជើង ២៧/៨/២០១២

ផ្តល់ប្រយោជន៍ដល់វិស័យទេសចរណ៍ ដោយសារម៉ាស៊ីនភ្លើងនឹងមិនត្រូវបានគេប្រើសម្រាប់បម្រុងពេលមិនមានអគ្គិសនីទៀតនោះឡើយ។[១៨៤]

អ្នកស្រាវជ្រាវមិនអាចជួបសម្ភាសន៍ជាមួយមន្ត្រីអគ្គិសនីនៅខេត្តកំពត ឬនៅភ្នំពេញបានឡើយ ដូច្នេះ វាទាមទារអោយមានការបញ្ជាក់អោយបានច្បាស់អំពីការចែកចាយថាមពលអគ្គិសនី។ ទោះជាយ៉ាងនេះក្តី គេបានដឹងថាថាមពលអគ្គិសនីដែលផលិតចេញពីទំនប់វារីអគ្គិសនីកំចាយ ត្រូវគេប្រើសម្រាប់ផ្គត់ផ្គង់ដល់ទីក្រុងភ្នំពេញ ខេត្តតាកែវ ខេត្តកំពត និងខេត្តព្រះសីហនុ។ ក្រុមហ៊ុនស៊ីណូហៃដ្រូបញ្ជូនចរន្តអគ្គិសនីមកស្ថានីយរងនៅតាមផ្លូវជាតិលេខ៣ ជាទីកន្លែងដែលអគ្គិសនីកម្ពុជាចែកចាយបន្ត។ ក្រុមហ៊ុនស៊ីណូហៃដ្រូផលិតអគ្គិសនីអាស្រ័យទៅនឹងតម្រូវការជាក់ស្តែងដោយធ្វើការសហការជាមួយអគ្គិសនីកម្ពុជា ដើម្បីកំណត់ថាត្រូវផលិតថាមពលអគ្គិសនីក្នុងបរិមាណប៉ុន្មាន តាមកាលកំណត់ជាក់លាក់ណាមួយ។ បច្ចុប្បន្នថាមពលអគ្គិសនីប្រមាណជា៤០% នៅពេលថ្ងៃ និង៨០% នៅពេលយប់ត្រូវបានគេបញ្ជូនទៅកាន់ទីក្រុងភ្នំពេញ។[១៨៥]

មន្ត្រីមួយចំនួនបានលើកឡើងថា ការធ្លាក់ចុះនៃតម្លៃអគ្គិសនីបានចូលរួមកាត់បន្ថយភាពក្រីក្រ។[១៨៦] ប៉ុន្តែ ដោយសារការភ្ជាប់បណ្តាញនៅមានកម្រិត អ្នកភូមិភាគច្រើននៅក្នុងឃុំម៉ាក់ប្រាងមើលមិនឃើញពីផលប្រយោជន៍នៃការធ្លាក់ចុះតម្លៃអគ្គិសនីនេះឡើយ ដោយពួកគាត់យល់ថាទំនប់វារីអគ្គិសនីកំចាយបានផ្តល់ប្រយោជន៍ដល់ប្រជាជន និងពាណិជ្ជកម្មនានា ដែលនៅឆ្ងាយពីទំនប់វារីអគ្គិសនីកំចាយច្រើនជាង។ ប្រជាជនដែលនៅឆ្ងាយពីទំនប់មិនបានរងគ្រោះ ដោយសារការសាងសង់ទំនប់វារីអគ្គិសនីកំចាយនេះ ដូចគ្រួសារដែលនៅតំបន់ទំនប់នោះទេ។ អ្នកភូមិមួយចំនួននៅតំបន់ទំនប់វារីអគ្គិសនីកំចាយបានបង្ហាញនូវការខកចិត្ត ដោយពួកគាត់មិនមានអគ្គិសនីប្រើប្រាស់ «ងងឹតសូន្យ» ទោះបីជាការផលិតថាមពលអគ្គិសនីដ៏ធំមួយស្ថិត

---

[១៨៤] មន្ទីរទេសចរណ៍ ខេត្តកំពត ២៨/៨/២០១២

[១៨៥] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២; ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្តកំពត ២៩/៨/២០១២ ; មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២

[១៨៦] មន្ទីរទេសចរណ៍ ខេត្តកំពត ២៨/៨/២០១២

នៅក្បែរភូមិរបស់ពួកគាត់យ៉ាងណាក្តី។ អ្នកភូមិខ្លះទៀត បានចោទសួរថាហេតុអ្វីបានជាតម្លៃអគ្គិសនីដែលគេបង់ មានតម្លៃថ្លៃជាងតម្លៃអគ្គិសនីនៅតំបន់មួយចំនួនដូចជាទីក្រុងភ្នំពេញ និងខេត្តតាកែវ ដែលជាកន្លែងប្រើអគ្គិសនីពីទំនប់វារីអគ្គិសនីកំចាយ។[១៨៧] ទោះបីជាវាមានសារៈសំខាន់ដែលគេត្រូវដឹងអោយបានច្បាស់លាស់ថាតើគេកំណត់តម្លៃអគ្គិសនីដូចម្តេច និងហេតុអ្វីបានជាតម្លៃ អគ្គិសនីនៅភ្នំពេញ និងខេត្តតាកែវមានតម្លៃថោកជាងនៅតំបន់ទំនប់ ប៉ុន្តែគេមិនអាចជួបសម្ភាសន៍មន្ត្រីដែលអាចឆ្លើយនឹងសំណួរទាំងនេះបានឡើយ។[១៨៨] មន្ត្រីរាជរដ្ឋាភិបាលមួយចំនួនរំពឹងថាតម្លៃអគ្គិសនីនឹងត្រូវគេកាត់បន្ថយថែមទៀតនៅពេលអនាគត ដែលនេះជាមធ្យោបាយមួយក្នុងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែគេមិនបានផ្សព្វផ្សាយផែនការបែបនេះអោយដឹងជាទូទៅឡើយ។[១៨៩]

## ៣.៤ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ផ្លូវមួយខ្សែដែលគេសាងសង់ពីផ្លូវជាតិលេខ៣ ទៅទីតាំងសំណង់ទំនប់បានផ្តល់ប្រយោជន៍ដល់អ្នកភូមិអណ្តូងជីមើន និងភូមិមាត់ពាម ដោយផ្លូវមួយខ្សែនោះកាត់តាមភូមិទាំងពីរ។ ភ្ជាប់នឹងការសាងសង់ផ្លូវនេះផងដែរ ស្ពានមួយត្រូវបានគេសាងសង់ឆ្លងព្រែកស្ទឹងកែវ។[១៩០] ផ្លូវថ្មីមួយខ្សែនេះពិតជាបានរួមចំណែកធ្វើអោយមានការរីកចំរើនដល់ភូមិទាំងពីរនេះ ដោយសារវាបានសម្រួលដល់ការធ្វើដំណើរ និងភ្ជាប់ភូមិទាំងពីរទៅនឹងទីផ្សារ។ ក្រោយពេលការដឹកជញ្ជូនធុនធ្ងន់ៗកាត់ផ្លូវនេះនៅកំឡុងពេលការសាងសង់ទំនប់វារីអគ្គិសនីកំចាយ អ្នកភូមិមាត់ពាមត្រឹមតែ ៦០% ទៅ ៧០% ប៉ុណ្ណោះ ពេញចិត្តផ្លូវនេះ ដោយសារផ្លូវនេះបានខូចទ្រុឌទ្រោមយ៉ាងខ្លាំង។

---

[១៨៧] ម្ចាស់ហាងមកពីភូមិស្នំប្រាំពីរ ២០/៨/២០១២

[១៨៨] ការព្យាយាមសម្ភាសអគ្គិសនីកំពត មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត, អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មិនទទួលបានជោគជ័យឡើយ។អគ្គិសនីកំពត, មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត និងអាជ្ញាធរអគ្គិសនីកម្ពុជាសុទ្ធតែណែនាំអោយទៅសួរ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ប៉ុន្តែក្រសួងមិនបានឆ្លើយតបនឹងការសុំជួបសម្ភាសន៍ឡើយ។

[១៨៩] មេឃុំកំពង់ត្រែង ១៦/៨/២០១២; មេឃុំអណ្តូងខ្មែរ ២០/០៨-២០១២; មន្ទីរបរិស្ថាន ១៨/១០/២០១២

[១៩០] មេឃុំកំពង់ត្រែង ១៦/៨/២០១២

ប្រធានភូមិមាត់ពាមមានឱកាសនិយាយជាមួយក្រុមហ៊ុនស៊ីណូហៃដ្រូតែម្តងគត់ នៅក្នុងការប្រជុំមួយនៅខែកក្កដា ឆ្នាំ២០១១ ដើម្បីស្នើអោយក្រុមហ៊ុនកែលំអផ្លូវនេះ។ អស់រយៈពេលជាងមួយឆ្នាំទៅហើយ គាត់មិនទាន់ទទួលបានព័ត៌មានអ្វីមួយពីក្រុមហ៊ុនស៊ីណូហៃដ្រូ ទាក់ទងនឹងសំណើរបស់គាត់ឡើយ។[១៩១]

ផ្លូវថ្មីដែលគេបានសាងសង់ពីរមណីយដ្ឋានទឹកឈូទៅកាន់ទំនប់ ជាផ្លូវតែមួយគត់ដែលមានគុណភាពល្អ។ ប៉ុន្តែដោយសារផ្លូវនោះខ្ពីជាងផ្លូវដីកាលពីមុនដែលគេអាចធ្វើដំណើរទៅកាន់តំបន់ព្រៃឫស្សី និងរកធនធានអនុផលព្រៃឈើនៅទឹកឈូដែលត្រូវទឹកជន់លិច វាមិនបានបង្ហាញពីភាពប្រសើរឡើងទាំងស្រុងសម្រាប់អ្នកប្រើប្រាស់ផ្លូវនេះឡើយ។ នៅពេលសួរថា តើក្រុមហ៊ុនស៊ីណូហៃដ្រូមានគម្រោងសាងសង់ផ្លូវផ្សេងទៀត ដែលអាចអោយគេធ្វើដំណើរចូលទៅដល់កន្លែងកាប់ឫស្សីសំខាន់ៗដែរឬទេ ក្រុមហ៊ុនស៊ីណូហៃដ្រូមិនបានឆ្លើយច្បាស់ឡើយ។ ទោះយ៉ាងណាក៏ដោយ អ្នកតំណាងរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូម្នាក់ បានប្រាប់អោយដឹងថាក្រុមហ៊ុនគិតថា វាមិនមានភាពចាំបាច់ណាមួយដែលត្រូវសាងសង់ផ្លូវបន្ថែមទៀតនោះទេ ដោយសារក្រុមហ៊ុនស៊ីណូហៃដ្រូ បានសាងសង់ផ្លូវជាច្រើននៅលើភ្នំរួចហើយ។[១៩២] គំនិតនេះផ្ទុយទៅនឹងសេចក្តីត្រូវការ ដែលលើកឡើងដោយសមាជិកសហាគមន៍ជាច្រើន ដែលអាស្រ័យលើព្រៃឈើសម្រាប់ការរស់នៅរបស់ពួកគាត់ ដោយពួកគាត់យល់ថាការសាងសង់ផ្លូវថ្មី ដែលមានប្រវែងប្រមាណពី ៣ទៅ ៤ គីឡូម៉ែត្រ អាចនឹងអោយពួកគាត់ធ្វើដំណើរទៅដល់ព្រៃខាងឆ្វេងដៃ នៃអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីកំចាយ និងជួយអោយពួកគាត់ចូលទៅដល់បណ្តាញផ្លូវតូចៗនៅលើភ្នំដែលនឹងអាចអោយពួកគាត់ចូលទៅកន្លែងប្រមូលអនុផលព្រៃឈើ បានប្រសើរជាងសព្វថ្ងៃ។[១៩៣]

[១៩១] ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[១៩២] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២; ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្តកំពត ២៩/៨/២០១២

[១៩៣] ការពិភាក្សាក្រុម នៅភូមិអូរតូច ២៩/៨/២០១២





រូបភាព: ផ្លូវថ្មីទៅកាន់តំបន់ទំនប់ដោយកាត់តាមផ្លូវជាតិលេខ៣ (ខាងឆ្វេង)
និងផ្លូវទៅកាន់អាងស្តុកទឹកនៃទំនប់កំចាយ (ខាងស្តាំ)

នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គេបានសរសេរអំពីកង្វល់លើកឡើងដោយមនុស្សចំនួន ២៣៣នាក់ ដែលគេបានប្រឹក្សាយោបល់ នៅកំឡុងដំណើរការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (តាមរយៈការសម្ភាស ឬប្រជុំ)។ ក្នុងចំណោមសំណូមពរទាំងនោះ មានសំណូមពរថាអោយក្រុមហ៊ុនស៊ីណូហៃដ្រូជួសជុលផ្លូវ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតអោយរឹងមាំ និងមានគុណភាពល្អ មុនពេលផ្ទេរហេដ្ឋារចនាសម្ព័ន្ធទាំងនោះអោយរាជរដ្ឋាភិបាល។ ដំណោះស្រាយដែលសរសេរនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលឆ្លើយតបទៅនឹងសំណើនេះគឺ ក្រុមហ៊ុនស៊ីណូហៃដ្រូត្រូវ *«មានផែនការជួសជុលរាល់ហេដ្ឋារចនាសម្ព័ន្ធគម្រោង ហើយត្រូវធានាថាហេដ្ឋារចនាសម្ព័ន្ធទាំងនោះ ស្របតាមគុណភាពដែលគេតម្រូវអោយមាន។»*[១៩៤] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មិនបានពន្យល់ច្បាស់លាស់ ថាតើក្រុមហ៊ុននឹងទទួលខុសត្រូវជួសជុលហេដ្ឋារចនាសម្ព័ន្ធគម្រោងតាមការស្នើសុំនៅមុនពេលប្រគល់វាអោយរាជរដ្ឋាភិបាលដែរ ឬទេ។ ប៉ុន្តែការអង្កេតនៅតំបន់សិក្សាប្រាំបួនខែ ក្រោយពីការសម្ពោធដាក់អោយទំនប់ប្រតិបត្តិការបានបង្ហាញថា ទាំងផ្លូវទៅកាន់ទំនប់ពីផ្លូវជាតិលេខ៣ និងផ្លូវតូចៗនៅតាមជម្រាលភ្នំនៅជិតទំនប់ សុទ្ធតែស្ថិតក្នុងសភាពទ្រុឌទ្រោមទាំងអស់។

[១៩៤] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១ ទំព័រ.១៨៤

មានពាក្យចចាមអារ៉ាមអំពីការសាងសង់ផ្លូវថ្មីពីភ្នំបូកគោ មកកាន់រមណីយដ្ឋានទឹកឈូ។[១៥៥] ផ្លូវនោះអាចនាំអោយមានការរីកចំរើនដល់វិស័យទេសចរណ៍ដោយសារភ្ញៀវទេសចរអាចនឹងមកទស្សនារមណីយដ្ឋានទឹកឈូថែមទៀត ប្រសិនបើផ្លូវនោះអាចមកដល់រមណីយដ្ឋានទឹកឈូងាយស្រួលជាងមុន។ ប៉ុន្តែ បើតាមទិសដៅនៃផ្លូវថ្មីនេះ វាអាចនឹងធ្វើអោយបាត់បង់ជម្រកសត្វព្រៃនៅឧទ្យានជាតិបូកគោបន្ថែមទៀត។

នៅតំបន់ក្បែរទំនប់ អាគារបណ្តោះអាសន្ន និងសំណង់ផ្សេងៗទៀតជាច្រើនដែលត្រូវបានគេប្រើនៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ បានបន្សល់ទុកដោយមានផ្នែកខ្លះត្រូវបានគេរើចេញ។ កត្តានេះនាំអោយខូចសោភ័ណភាពនៅតំបន់នោះ ហើយនាំអោយមានចំណាប់អារម្មណ៍មិនល្អពីសំណាក់ភ្ញៀវទេសចរដែលមកទស្សនាតំបន់នោះ។

## ៤. វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម : ការសន្យា និងការអនុវត្ត

យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ខែមេសា ឆ្នាំ២០១១[១៥៦] ក្រុមហ៊ុនស៊ីណូហៃដ្រូទទួលខុសត្រូវរៀបចំវិធានការផ្សេងៗ និងផែនការគ្រប់គ្រងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន។ ក្រុមហ៊ុនស៊ីណូហៃដ្រូ និងក្រសួងបរិស្ថានទទួលខុសត្រូវធ្វើផែនការ និងបង្កើតក្រុមការងារដោយមានសមាជិកមកពីក្រសួងពាក់ព័ន្ធ ភាគីក្រុមហ៊ុនស៊ីណូហៃដ្រូ និងអាជ្ញាធរមូលដ្ឋាន។ ក្រុមការងារនេះ គេចែកជាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលបន្ទុកសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននិងសម្រាប់ធ្វើរបាយការណ៍

---

[១៥៥] ប្រធានភូមិស្នំប្រាំពីរ ១៧/៨/២០១២

[១៥៦] ច្បាប់ ESIA ចុងក្រោយដែលមានគឺនៅខែមេសា ឆ្នាំ២០១១។ របាយការណ៍នេះត្រូវគេដឹងជាទូទៅថាជារបាយការណ៍ចុងក្រោយ។ ប៉ុន្តែយោងតាមនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របាយការណ៍ESIA ចុងក្រោយរបស់ទំនប់កំចាយត្រូវគេអនុម័តយល់ព្រមនៅខែកក្កដា ឆ្នាំ២០១២។ របាយការណ៍ដែលគេមានអនុម័តយល់ព្រមនេះមិនត្រូវក្រសួងបរិស្ថានចែករំលែកឡើយ ហើយវាមិនមានសាធារណៈជនដឹងឡើយថាតើរបាយការណ៍នោះដូចនឹងរបាយការណ៍នៅ ខែមេសា ឆ្នាំ២០១១ ដែរ ឬទេ។

ជូនក្រសួងបរិស្ថាន។ សម្រាប់តារាងសមាជិកក្រុមការងារពេញលេញសូមមើលឧបសម្ព័ន្ធ «ឃ»។ វិធានការកាត់បន្ថយហេតុប៉ះពាល់ដែលគេសរសេរនៅក្នុងផែនការគ្រប់គ្រងបរិស្ថានត្រូវគេអនុវត្តរៀងរាល់ ៣ ទៅ ៦ខែ នៅកំឡុងពេលសាងសង់ និងប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយ។[១៩៧]

ក្រុមហ៊ុនស៊ីណូហៃដ្រូត្រូវធ្វើការជាមួយក្រសួងបរិស្ថាន ដើម្បីអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។ ប៉ុន្តែ នៅកំឡុងពេលសម្ភាសនៅខែតុលា ឆ្នាំ២០១២ ប្រហែលជា ១០ខែ បន្ទាប់ពីការប្រតិបត្តិទំនប់វារីអគ្គិសនីកំចាយបានចាប់ផ្តើម ក្រុមហ៊ុនស៊ីណូហៃដ្រូ បានបង្ហាញនូវភាពមិនច្បាស់លាស់ថាតើ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថានដូចម្តេច។ យោងតាមទស្សនៈរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូ ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានគឺអាស្រ័យលើរាជរដ្ឋាភិបាលកម្ពុជា *«ក្រុមហ៊ុនស៊ីណូហៃដ្រូ នឹងធ្វើតាមតែរាជរដ្ឋាភិបាលកម្ពុជា»*។[១៩៨] ក្រុមហ៊ុនហាក់បីដូចជាពឹងផ្អែកលើរាជរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន វាជាការចាំបាច់ដែលមន្ត្រីទទួលបន្ទុកផ្តល់ការណែនាំដល់ក្រុមហ៊ុនស៊ីណូហៃដ្រូ អោយធ្វើការបានទាន់ពេលវេលា។ ស្របគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែធ្វើការគ្រប់គ្រងដោយមិនលំអៀង និងបើកចំហដើម្បីធានាបានថាកិច្ចការពារបរិស្ថាន និងសង្គមដែលគេតម្រូវអោយធ្វើត្រូវបានអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួន។

យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ក្រុមហ៊ុនបម្រុងថវិកាចំនួន ១៧.៥លានដុល្លារអាមេរិក សម្រាប់ការការពារបរិស្ថានក្នុងនោះ ១២លានដុល្លារអាមេរិក ត្រូវបានគេប្រើនៅកំឡុងការសាងសង់រយៈពេល៤ឆ្នាំ និង ៥.៥លានដុល្លារអាមេរិក សម្រាប់ការអនុវត្តផែនការការពារបរិស្ថានរយៈពេល៤០ ឆ្នាំ នៅកំឡុងពេលប្រតិបត្តិគម្រោងទំនប់វារីអគ្គិសនីកំចាយ។[១៩៩] ការបែងចែកនេះធ្វើអោយគេមានថវិកាសម្រាប់ចំណាយ ១៣៧.៥០០ ដុល្លារអាមេរិក ក្នុង១ឆ្នាំ។ ឧទាហ រណ៍មួយចំនួននៃការប្រើប្រាស់ថវិកា ១២លានដុល្លារអាមេរិក ដែលបម្រើអោ

---

[១៩៧] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ៣២៨-៣៣០

[១៩៨] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២

[១៩៩] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ.៣៣០

យការថែរក្សាបរិស្ថាននៅកំឡុងពេលការសាងសង់ទំនប់ គឺការសាងសង់ជញ្ជាំងការពារដីបាក់ (១លានដុល្លារអាមេរិក) ការសាងសង់ឃ្លាំង/អាងស្តុកការពារកុំអោយប្រេងហូរចូលព្រៃក (៥០០.០០០ដុល្លារអាមេរិក) ការទិញដី (៣,៥លានដុល្លារអាមេរិក) ការកាប់ និងសម្អាតព្រៃឈើក្នុងអាងស្តុកទឹក (២លានដុល្លារអាមេរិក) និងការផ្តល់សំណងសម្រាប់ការបាត់បង់ព្រៃឈើ (៥ដុល្លារអាមេរិក)។[២០០] នៅពេលដែលការកាប់និងសម្អាតអាង និងការសាងសង់ជញ្ជាំង និងអាងស្តុក (មិនអោយបាក់ដី និងមិនអោយប្រេងហូរចូលក្នុងព្រៃក) អាចចាត់ទុកថាជាកិច្ចការពារបរិស្ថានជំនួសអោយការចំណាយលើការសាងសង់ ក៏ប៉ុន្តែវាពិបាកយល់ថា ហេតុអ្វីបានជាការទិញដីត្រូវគេបញ្ចូលក្នុងការចំណាយសម្រាប់ការថែរក្សាបរិស្ថានដែរ។

សម្រាប់ការផ្តល់ប្រាក់គាំទ្រការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ក្រុមហ៊ុនស៊ីណូហៃដ្រូ *«មិនមែនគ្រាន់តែអោយប្រាក់ទៅពួកគេប៉ុណ្ណោះទេ។ ពួកគេនឹងចំណាយប្រាក់សម្រាប់គម្រោងនេះ ប៉ុន្តែមិនបែងចែកថវិកាឡើយ។»*[២០១] នេះបង្ហាញថា ក្រុមហ៊ុនស៊ីណូហៃដ្រូ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរដ្ឋាភិបាល ដើម្បីអោយផែនការគ្រប់គ្រងបរិស្ថានកើតចេញជារូបរាង តែស្ថានភាពបែបនេះមិនទាន់មាននៅឡើយ។ ដោយពិនិត្យលើថវិកាសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ក្រុមហ៊ុនស៊ីណូហៃដ្រូ មានការទទួលខុសត្រូវ ដើម្បីអោយស្របតាមកិច្ចការពារបរិស្ថាន និងសង្គម ដែលមានចែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ នៅពេលសួរអំពីចំនួនថវិកាសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ក្រុមហ៊ុនស៊ីណូហៃដ្រូ បានថ្លែងបញ្ជាក់ថា គេចាត់ចែងថវិកាអាស្រ័យលើសេចក្តីត្រូវការជាក់ស្តែង។[២០២] កត្តានេះនាំអោយមានចម្ងល់ថា តើរាល់ថវិកាដែលរៀបរាប់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នឹងត្រូវគេប្រើប្រាស់ស្របតាមគោលបំណងរបស់វាដែរឬទេ។ ផលប៉ះពាល់ដែលគេកំណត់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងវិធានការកាត់បន្ថយ

---

[២០០] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ១៣៨-១៤០

[២០១] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២

[២០២] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២

ហេតុប៉ះពាល់នានា ដែលគេគ្រោងនឹងធ្វើ មានបង្ហាញជូនខាងក្រោម ដែលការអនុវត្ត នេះក៏ត្រូវគេពិភាក្សាផងដែរ។

## ៤.១ ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានសំខាន់ៗ នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

### ៤.១.១ ផលប៉ះពាល់លើប្រព័ន្ធជលសាស្ត្ររបស់ព្រែកកំចាយ

នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម គេបានទទួលស្គាល់ថា ការស្តុកទឹកនៅក្នុងអាងនឹងប៉ះពាល់ដល់របបទឹកហូរធម្មជាតិ និងប្រព័ន្ធជលសាស្ត្ររបស់ព្រែកកំចាយ។ វានឹងធ្វើអោយមានការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេ ហើយចម្ងាយតាមផ្លូវទឹកប្រហែលជា២.៤គីឡូម៉ែត្រ ពីទំនប់ធំទៅរោងចក្រអគ្គិសនីទី១ នឹងមិនមានទឹក។ ការដែលមិនមានទឹកគ្រាប់គ្រាន់នេះ ដោយសារគេបញ្ចេញទឹកតាមបំពង់ពីអាងស្តុកទឹកទៅទួប៊ីននៅឯរោងចក្រអគ្គិសនី ខ្សែទឹកខាងក្រោម។ ផលប៉ះពាល់ពីគម្រោងមួយផ្សេងទៀត គឺការអាចកើនឡើងកម្រិតទឹកក្រោមដីនៅតំបន់ខាងក្រោមទំនប់។

ដើម្បីកាត់បន្ថយនូវផលប៉ះពាល់លើជលសាស្ត្ររបស់ព្រែកកំចាយ ក្រុមហ៊ុនស៊ីណូហៃដ្រូ នឹងអនុវត្តនូវវិធានខាងក្រោមនេះ៖[២០៣]

- បញ្ចេញទឹកតិចបំផុត ៤,៥១ ម៉ែត្រគូប/វិនាទី ទាំងរដូវវស្សា និងរដូវប្រាំងដើម្បីរក្សាអេកូឡូស៊ីរបស់ព្រែកកំចាយនៅចន្លោះទំនប់ធំ និងទំនប់និយ័តករទឹកទី២ (second re-regulator dam)។
- បញ្ចេញទឹកចន្លោះពី ៥៥ ទៅ ១៦០ ម៉ែត្រគូប/វិនាទី ពីទំនប់ទី២ ទៅក្នុងព្រែកកំចាយ ដើម្បីថែរក្សាប្រព័ន្ធជលសាស្ត្ររបស់ព្រែកកំចាយ។
- សិក្សា និងត្រួតពិនិត្យកម្រិតនៃទឹកក្រោមដី និងផ្ទៃទឹកខាងលើជាប្រចាំ។
- សាងសង់ស្ថានីយជលសាស្ត្រសម្រាប់សិក្សានិងតាមដានការផ្លាស់ប្តូរជលសាស្ត្ររបស់ព្រែកកំចាយ។

[២០៣] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ២២៩

ទីតាំង និងវិធីសាស្ត្រសម្រាប់ធ្វើការត្រួតពិនិត្យទឹកក្រោមដី និងផ្ទៃទឹកខាងលើជាប្រចាំមិនបានត្រូវគេបញ្ជាក់អោយបានច្បាស់ឡើយ។ ដូចគ្នានេះដែរ មិនមានព័ត៌មានពិស្តារអំពីការសាងសង់ស្ថានីយជលសាស្ត្រឡើយ។[២០៤] ក៏ប៉ុន្តែទាក់ទងទៅនឹងការបញ្ចេញទឹកពីទំនប់ទី២ វាមានការផ្លាស់ប្តូរ ដោយគេបានបញ្ជាក់ផងដែរថា ក្នុងលក្ខខណ្ឌណាមួយគេនឹងបញ្ចេញទឹកពីទំនប់ទី២ មិនអោយតិចជាង ០,៣ ម៉ែត្រគូប/វិនាទី ទាំងរដូវវស្សា និងរដូវប្រាំង។[២០៥] កម្រិតទឹកហូរដ៏តិចតួចបែបនេះ អាចធ្វើអោយប៉ះពាល់ជាអវិជ្ជមានដល់វិស័យទេសចរណ៍ និងកម្រិតទឹកប្រៃក្នុងព្រែកនៅខ្សែទឹកខាងក្រោម។ ការសម្ភាសជាមួយស្ថាប័នរដ្ឋាភិបាល បានបង្ហាញថាមន្ត្រីរដ្ឋាភិបាលមិនបានតាមដានការបញ្ចេញទឹកជាក់ស្តែងពីទំនប់ទី១ និង ទំនប់ទី២ឡើយ។ មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត មិនបានដឹងពីការតាមដានណាមួយនៅពេលបច្ចុប្បន្នទេ ប៉ុន្តែបានប្រាប់អោយដឹងថា ការតាមដានត្រូវគ្រប់គ្រងដោយស្ថាប័នថ្នាក់ជាតិ ដូច្នេះ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត នឹងជាប់ពាក់ព័ន្ធនឹងការងារទាំងនោះប្រសិនបើចាំបាច់។[២០៦] លើសពីនេះ ក្រុមហ៊ុនស៊ីណូហៃដ្រូមិនបានឆ្លើយតបនឹងសំណួរអំពីការសាងសង់ស្ថានីយជលសាស្ត្រ ដែលមានរៀបរាប់ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមទេ។ ការសិក្សាមិនបានធ្វើការត្រួតពិនិត្យលំហូរទឹកជាក់ស្តែងនោះទេ ប៉ុន្តែការមិនបានយកចិត្តទុកដាក់របស់រដ្ឋាភិបាលលើបញ្ហានេះបង្ហាញថា ការតាមដានលំហូរទឹកត្រូវបានគេបណ្តែតបណ្តោយ។

បើគេតែងតែបញ្ចេញទឹកអប្បរមា ៩,៥ម៉ែត្រគូប/វិនាទី នៅខាងក្រោមអាងស្តុកទឹកធំរបស់ទំនប់វារីអគ្គិសនីកំចាយ នោះវាទំនងជាអាចរក្សាជីវិតសត្វព្រៃ និងធនធានក្នុងទឹកមួយចំនួនដែលអាស្រ័យនឹងព្រែកកំចាយបាន។ ទោះបីជាគេឃើញមានទឹកតិចតួចនៅត្រង់ផ្នែកខ្លះនៃព្រែកកំចាយ ប៉ុន្តែការប្រែប្រួលទីជម្រកធម្មជាតិ

---

[២០៤] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ២៧១

[២០៥] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ២២៩

[២០៦] មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពត ២៨/៨/២០១២; នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

ពិតជាមាន ដោយសារផ្ទៃដ៏ធំធេងនៃបាតព្រែកតឡូវរីងស្ងួត។ ទោះបីជាកម្រិតអប្បរមានៃលំហូរទឹកប្រហែលជាអាចកាត់បន្ថយផលប៉ះពាល់មួយចំនួនក៏ដោយ តែវាមិនអាចអោយត្រីចរាចរបានឡើយ។ លើសពីនេះទៀត កត្តានេះធ្វើអោយមានការនាំល្បាប់មកកាន់ខ្សែទឹកខាងក្រោមតិចតួចបំផុត ព្រោះដីល្បាប់នឹងស្ថិតនៅក្នុងអាងស្តុកទឹក។ ទោះបីជាឥទ្ធិពលវិជ្ជមាន និងអវិជ្ជមាននៃប្រព័ន្ធជលសាស្ត្ររបស់ព្រែកមិនទាន់ត្រូវគេវាយតម្លៃក៏ដោយ វាស្តែងអោយឃើញថាប្រព័ន្ធជលសាស្ត្របានប្រែប្រួលរួចទៅហើយ។ មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត បានលើកឡើងពីផលអវិជ្ជមាននៃការបន្ថយល្បឿន ឬបញ្ឈប់ទួប៊ីនដែលកើតឡើងយូរៗម្តង ពីព្រោះវាធ្វើអោយមានផលប៉ះពាល់ដល់វិស័យទេសចរណ៍នៅរមណីយដ្ឋានទឹកឈូ ព្រោះបម្រែបម្រួលលំហូរទឹកអាចធ្វើអោយបរិមាណដីល្បាប់នៅក្នុងទឹកកើនឡើង។[២០៧]

### ៤.១.២ ការបាត់បង់ព្រៃឈើ និងជម្រកសត្វព្រៃ

យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការប្រែក្លាយតំបន់ព្រៃឈើ និងជម្រកសត្វព្រៃទៅជាអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីកំចាយនឹងធ្វើអោយថយចុះជម្រកសត្វ និងសត្វព្រៃ។ ដើម្បីប៉ះប៉ូវការបាត់បង់នេះ ក្រុមហ៊ុនស៊ីណូហៃដ្រូ នឹងបម្រុងថវិកាមួយចំនួនសម្រាប់ដាំកូនឈើនៅតំបន់ដទៃ។ ប៉ុន្តែ គេមិនបានបញ្ជាក់ពីទីតាំងនៃការដាំកូនឈើថ្មីឡើយ។ លើសពីនេះទៀត ក្រុមហ៊ុនស៊ីណូហៃដ្រូ នឹងបំពាក់ឧបករណ៍សម្រាប់ប្រកាសអាសន្ន ដើម្បីអោយគេដឹងនៅពេលមានភ្លើងឆេះព្រៃ។ ការងារទាំងនេះនឹងត្រូវអនុវត្តដោយក្រុមហ៊ុនស៊ីណូហៃដ្រូ ដោយមានកិច្ចសហការជាមួយក្រសួងបរិស្ថាន និងឧទ្យានជាតិបូកគោ។[២០៨]

នៅខែតុលា ឆ្នាំ២០១២ ប្រមាណ ១០ខែ ក្រោយការសម្ពោធទំនប់ក្រុមហ៊ុនស៊ីណូហៃដ្រូ និងក្រសួងពាក់ព័ន្ធមិនទាន់បានអនុវត្តផែនការដាំកូនឈើនៅឡើយ។ យោងតាមក្រសួងបរិស្ថាន ក្រុមហ៊ុនស៊ីណូហៃដ្រូ និងក្រសួងបរិស្ថានមិនទាន់មានផែនការ និងថវិកាជាក់លាក់សម្រាប់គម្រោងដាំកូនឈើនៅឡើយដែរ។ តាមរយៈការ

[២០៧] មន្ទីរធនធានទឹក និងឧតុនិយមខេត្ត កំពត ២៨/៨/២០១២

[២០៨] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ២៣១-២៣២

សម្ភាស ក្រសួងបរិស្ថានរំពឹងថានឹងពិភាក្សាគម្រោងដាំកូនឈើជាមួយក្រុមហ៊ុនស៊ីណូហៃដ្រូ *«មួយឆ្នាំ ឬយូរជាងនេះបន្ទាប់ពីប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយចាប់ផ្តើម។»*[២០៩] យ៉ាងណាមិញ យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គម្រោងដាំកូនឈើគឺជាសកម្មភាពដែលត្រូវធ្វើនៅកំឡុងពេលសាងសង់ទំនប់៤ឆ្នាំ។

ដូច្នេះ ការខកខានអនុវត្តន៍វិធានការនេះ គឺស្មើនឹងការពន្យាពេលសកម្មភាពនេះ។ យោងតាមកំណត់ហេតុប្រជុំអន្តរក្រសួងនៅខែមេសា ឆ្នាំ២០១២ ការដាំកូនឈើលើផ្ទៃដី ១៩៦២ហិចតា នឹងត្រូវគេអនុវត្តក្នុងរយៈពេល១០ឆ្នាំខាងមុខ ដោយមានថវិកាប្រមាណ៤លានដុល្លារអាមេរិក។ វាអាស្រ័យនឹងក្រសួងបរិស្ថានពិភាក្សាជាមួយក្រុមហ៊ុនស៊ីណូហៃដ្រូ ថាតើត្រូវអនុវត្តគម្រោងដាំកូនឈើនេះដូចម្តេច។[២១០] ដោយមានការយឺតយ៉ាវក្នុងការពិភាក្សា និងធ្វើផែនការដាំកូនឈើ ក្រុមហ៊ុនស៊ីណូហៃដ្រូ យល់ថារាជរដ្ឋាភិបាលប្រហែលជាមានការលំបាកក្នុងការស្វែងរកកន្លែងសមរម្យណាមួយសម្រាប់គម្រោងដាំកូនឈើ កត្តានេះនាំអោយមានក្តីបារម្ភពីការអនុវត្តវិធានការនេះអោយបានត្រឹមត្រូវ។ បន្ថែមលើក្តីបារម្ភខាងលើនេះ ក្រុមហ៊ុនស៊ីណូហៃដ្រូ បានអោយសញ្ញាថាគេនឹងធ្វើការចរចារជាមួយរាជរដ្ឋាភិបាលកម្ពុជាអំពីគម្រោងដាំកូនឈើនេះ ព្រោះរដ្ឋាភិបាលបានទទួលចំណូលពីការកាប់ដើមឈើទាំងនោះ រីឯក្រុមហ៊ុនមិនបានទទួលប្រាក់ចំណូលទាល់តែសោះ។[២១១]

ចំពោះជីវចម្រុះ ត្រូវបានគេរកឃើញថាមាននៅក្នុងអាងស្តុកទឹកនៅក្នុងការសិក្សាមុនៗ ការបាត់បង់ជម្រកសត្វអាចនឹងប៉ះពាល់ដល់ជីវិតសត្វព្រៃនៅក្នុងតំបន់នោះ។[២១២] លើសពីនេះទៀត វាមិនអាចទៅរួចឡើយថាតំបន់ព្រៃថ្មីដែលគេនឹងដាំកូនឈើនៅពេលអនាគត អាចនឹងផ្តល់ជម្រកដល់សត្វព្រៃផ្លាស់ទីនៅពេលអាងស្តុកទឹកត្រូវគេរៀបចំ និងបញ្ចូលទឹក។ គេទទួលស្គាល់ថា វានឹងធ្វើអោយឧទ្យានជាតិបូកគោ

---

[២០៩] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

[២១០] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២

[២១១] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២

[២១២] មីដុលតុន (Middleton, C.) ឆ្នាំ២០០៨ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ឆ្នាំ២០០៧

ប្រសើរឡើង ប្រសិនបើគេអាចរក្សាព្រៃឈើទាំងនោះបាន ហើយនាយកដ្ឋានឧទ្យានជាតិគិតថា ជាប្រការល្អដោយសារតំបន់ព្រៃដែលទឹកជន់លិចនោះមិនមានផ្លូវរបៀងសម្រាប់សត្វព្រៃឡើយ។[២១៣]

យោងតាមក្រសួងបរិស្ថាន សកម្មភាពតាមដានមួយដែលទំនងជាគេបានអនុវត្តនោះគឺការល្បាតព្រៃ។ ក្នុងការប្រឹងប្រែងល្បាតព្រៃ អ្នកល្បាតព្រៃរបស់ឧទ្យានជាតិបូកគោ បានសហការជាមួយក្រុមហ៊ុនស៊ីណូហៃដ្រូ ដើម្បីត្រួតពិនិត្យឈើ ឬបញ្ហាផ្សេងទៀតនៅក្នុងផ្ទៃអាងស្តុកទឹករៀងរាល់ពីរទៅបីថ្ងៃម្តង។ អ្នកល្បាតព្រៃក៏យកចិត្តទុកដាក់ក្នុងការការពារព្រៃឈើនៅជុំវិញអាងស្តុកទឹកផងដែរ ដោយសារព្រៃទាំងនោះអាចជួយការពារការហូរច្រោះដី។ សម្រាប់ឧទ្យានជាតិបូកគោទាំងមូលមានអ្នកល្បាតព្រៃចំនួន៥៥នាក់ ដែលល្បាត និងតាមដានសត្វព្រៃ និងអនុវត្តច្បាប់។ ក្រុមហ៊ុនស៊ីណូហៃដ្រូ មានទូក និងការគាំទ្រផ្សេងៗដល់អ្នកល្បាតព្រៃ ដើម្បីឃ្លាំមើលអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីកំចាយ។ ទោះជាយ៉ាងនេះក្តី សកម្មភាពល្មើសច្បាប់នៅតែបន្តកើតមានឡើងនៅតំបន់ឧទ្យានជាតិរាល់ថ្ងៃ រួមបញ្ចូលទាំងតំបន់ទំនប់វារីអគ្គិសនីកំចាយផងដែរ។[២១៤] មន្ទីរបរិស្ថានខេត្តកំពតបានប្រាប់អោយដឹងថា ទាហានល្បាតឧទ្យាន ដែលសព្វថ្ងៃស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរបរិស្ថានខេត្ត ទទួលបានប្រាក់បៀវត្ស ១៤០.០០០រៀល ក្នុងមួយខែ សម្រាប់ការងារពេញម៉ោង។ វាពិតជាមានការពិបាក ដោយសារថវិកាសម្រាប់ទ្រទ្រង់ប្រាក់បៀវត្សបុគ្គលិកមន្ទីរបរិស្ថានខេត្តចំនួន៥នាក់ ក្នុងការការពារព្រៃឈើដែលក្រុមហ៊ុនស៊ីណូហៃដ្រូបានសន្យាមិនទាន់បានទទួលនៅឡើយ។[២១៥] វត្តមាននៃដុំឈើស្រស់ជាច្រើននៅតាមផ្លូវនៅតំបន់ជិតអាងស្តុកទឹក និងពាក្យចចាមអារ៉ាមអំពីឡានដឹកឈើជាច្រើននៅពេលយប់ គេអាចគិតដល់សកម្មភាពខុសច្បាប់មួយចំនួនដែលអាចនឹងគំរាមកំហែងដល់ព្រៃឈើ ដែលជាជម្រកសត្វព្រៃនៅជុំវិញអាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយ។

---

[២១៣] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២

[២១៤] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២

[២១៥] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២





រូបភាព: ឈើស្រស់នៅតាមផ្លូវនៅជិតទីតាំងទំនប់វារីអគ្គិសនីកំចាយ (រូបខាងឆ្វេង) និងរថយន្តរៀបចំដឹកជញ្ជូនអុស និងឫស្សីចេញពីតំបន់ទំនប់វារីអគ្គិសនីកំចាយ (រូបខាងស្តាំ)

### ៤.១.៣ ផលប៉ះពាល់លើធនធានជលផល

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បានទទួលស្គាល់ថា ការបិទព្រែកកំចាយអាចធ្វើអោយប៉ះពាល់ពូជត្រីដែលជិតផុតពូជមួយចំនួន និងរារាំងដល់ការចរាចររបស់ត្រី ហើយវាក៏ជាឧបសគ្គដល់ការពងកូនរបស់ត្រីដែរ។ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើធនធានជលផល នៅតាមព្រែកកំចាយ ក្រុមហ៊ុនស៊ីណូហៃដ្រូ ត្រូវសាងសង់អាងស្តុកទឹកមួយនៅខាងក្រោមទំនប់វារីអគ្គិសនីសម្រាប់អោយត្រីបង្កាត់ពូជ និងពងកូន ព្រមទាំងសម្រាប់លែងកូនត្រី។ គេប៉ាន់ប្រមាណថា កត្តានេះនឹងអាចបង្កើនផលត្រី និងជួយការពារពពួកត្រីជិតផុតពូជមួយចំនួន។[២១៦] វាមិនទាន់ប្រាកដនៅឡើយថាតើអាងស្តុកទឹកបន្ថែមនោះនឹងអាចការពារមិនអោយបាត់បង់ពូជត្រីដែលជិតផុតពូជនោះយ៉ាងដូចម្តេចទេ។

១០ខែ បន្ទាប់ពីប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយបានចាប់ផ្តើម អាងចិញ្ចឹមត្រីមិនទាន់កើតចេញជារូបរាងនៅឡើយ។ ក្រសួងបរិស្ថានបានបញ្ជាក់ថា គេកំពុងពិភាក្សាគម្រោងនេះ ហើយវាជាផែនការដែលគេត្រូវអនុវត្តដើម្បីឆ្លើយតបទៅនឹងការថយចុះនៃធនធានជលផលធម្មជាតិ។ ខាងក្រោមគឺជាវិធានការដែលគេត្រូវអនុវត្ត៖

- សាងសង់ទំនប់ទីបីដើម្បីទប់ទឹកខាងក្រោមទំនប់សម្រាប់អភិរក្សត្រី។

[២១៦] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ.១៨៧

- លែងកូនត្រី ១០០.០០០ ក្បាល ក្នុងមួយឆ្នាំ ក្នុងរយៈពេល ១០ ឆ្នាំ។
- ល្បាត និងគ្រប់គ្រងធនធានជលផល ក្នុងរយៈពេល ១០ ឆ្នាំ។

រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលគួរតែជាអ្នកទទួលបន្ទុកនៃការលែងកូនត្រី ចំណែកឯក្រសួងបរិស្ថានដើរតួជាអ្នកសម្របសម្រួល។[២១៧] ធនធានជលផលទាំងអស់ ស្ថិតនៅក្រោមការចាត់ចែងរបស់រដ្ឋបាលជលផល ប៉ុន្តែវាមិនទាន់ច្បាស់នៅឡើយថា តើអ្នកណានឹងតាមដានធនធានជលផលដែលទាក់ទងនឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។ កន្លងមក ខណ្ឌរដ្ឋបាលជលផលមិនបានជាប់ពាក់ព័ន្ធជាមួយការតាមដានណាមួយឡើយ។[២១៨] ក្រុមហ៊ុនស៊ីណូហៃដ្រូ បានអះអាងថាក្រុមហ៊ុនបានពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជា អំពីការសាងសង់អាងចិញ្ចឹមត្រី ប៉ុន្តែព័ត៌មានដែលខណ្ឌជលផលអាចបញ្ជាក់បាននោះ គឺគម្រោងនេះអាចនឹងត្រូវគេអនុវត្តក្នុងរយៈពេលបី ឬបួនឆ្នាំទៀត។ វាហាក់បីដូចជា មិនមានផែនការច្បាស់លាស់ និងមិនទាន់មានការសម្រេចចិត្តណាមួយត្រូវបានគេធ្វើឡើងនៅឡើយ។ បើយោងតាមក្រុមហ៊ុនស៊ីណូហៃដ្រូ ការលែងកូនត្រីនឹងមិនមានចោទជាបញ្ហាឡើយ បើសិនជារាជរដ្ឋាភិបាលកម្ពុជា មានបំណងធ្វើវា *«វាមានសារៈសំខាន់ណាស់ដែលត្រូវការពារត្រី ដូច្នេះប្រសិនបើរាជរដ្ឋាភិបាលស្នើសុំ នោះក្រុមហ៊ុនស៊ីណូហៃដ្រូនឹងធ្វើការងារនេះ។»* [២១៩]

### ៤.១.៤ ផលប៉ះពាល់លើគុណភាពទឹក

យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម អាងស្តុកទឹករបស់ទំនប់កំចាយនឹងជន់លិចផ្ទៃដីទំហំ ២០១៥.៧ហិចតា ដើម្បីស្តុកទឹកច្រើនជាង ៧១៨លានម៉ែត្រគូប យកទៅផលិតថាមពលអគ្គិសនីអោយបាន ១៩៤ម៉េហ្គាវ៉ាត់។[២២០] ការជន់លិចនេះ អាចធ្វើអោយប៉ះពាល់ដល់គុណភាពទឹក ដោយសារព្រៃ

[២១៧] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

[២១៨] ខណ្ឌរដ្ឋបាលជលផល ខេត្តកំពត ២៨/៨/២០១២

[២១៩] ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២

[២២០] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ.២៣៨

ឈើដែលត្រូវទឹកលិចនោះផលិតសារធាតុគីមី និងសារធាតុសរីរាង្គ។ លើសពីនេះ កំពស់ទឹកក្នុងអាងស្តុកទឹកនឹងធ្វើអោយទឹកខ្វះអុកស៊ីសែន។ កត្តាទាំងពីរនេះ អាចនាំអោយទឹកធុំក្លិន។ ដើម្បីកាត់បន្ថយផលប៉ះពាល់លើគុណភាពទឹក ក្រុមហ៊ុនស៊ីណូហៃដ្រូ នឹងអនុវត្តនូវវិធានការដូចខាងក្រោម៖[២២១]

- នៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ៖ ត្រួតពិនិត្យ និងតាមដានដើម្បីធានាបានថាព្រៃឈើ និងរុក្ខជាតិនៅតំបន់នៃអាងស្តុកទឹកត្រូវគេកាប់ និងសម្អាតមុនពេលគេបញ្ចូលទឹកក្នុងអាងស្តុកទឹក។
- នៅកំឡុងពេលប្រតិបត្តិ និងថែទាំគម្រោងទំនប់វារីអគ្គិសនីកំចាយ៖ ត្រួតពិនិត្យ និងតាមដានគុណភាពទឹកក្នុងអាងស្តុកទឹករៀងរាល់៣ខែម្តង។
- បំពាក់ឧបករណ៍សម្អាត និងសម្លាប់សត្វល្អិតចង្រៃក្នុងទឹក និងរុក្ខជាតិទឹកដែលដុះនៅក្នុងអាងស្តុកទឹក។

ផ្ទុយនឹងអ្វីដែលគេតម្រូវអោយធ្វើ ព្រៃក្នុងអាងស្តុកទឹកមិនត្រូវបានគេកាប់ និង សម្អាតអោយអស់មុនពេលបញ្ចូលទឹកក្នុងអាងស្តុកទឹកឡើយ។ នៅមានកំណាត់ឈើ ដើមឈើ និងរុក្ខជាតិជាច្រើនដែលត្រូវទឹកលិចនៅក្នុងអាងស្តុកទឹក។[២២២] សមាជិកសហគមន៍មកពីភូមិដែលរងផលប៉ះពាល់បានប្រាប់អោយដឹងថា ឈើមានតម្លៃត្រូវបានគេប្រមូល និងដឹកជញ្ជូនចេញពីតំបន់នោះ។ ចំពោះដើមឈើ និងរុក្ខជាតិដទៃទៀត ដូចជាព្រៃឫស្សីត្រូវបានគេដុតដោយប្រើប្រេងសាំង។ ប៉ុន្តែ ព្រៃឈើជាច្រើនមិនបានឆេះអស់នោះទេ ហើយដើមឫស្សីមួយចំនួនបានដុះឡើងវិញនៅមុនពេលទឹកជន់លិចវា។ នៅពេលដែលសួរថា តើគេធ្វើដូចម្តេចចំពោះឫសឈើ និងគុម្ពោតព្រៃ សិក្ខាកាមម្នាក់ក្នុងកិច្ចពិគ្រោះយោបល់ជាមួយសហគមន៍បានចោទសួរត្រឡប់វិញថា *«ប្រសិនបើគេមិនអាចយកដើមឈើចេញអោយអស់ពីអាងស្តុកទឹក*

---

[២២១] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ២៣០-២៣១

[២២២] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២; មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២ ការបង្ហាញរបកគំហើញទៅសហគមន៍មូលដ្ឋានខេត្តកំពត ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២; ស្ត្រីលក់ត្រីនៅផ្សារស្ទុំប្រាំពីរ ២២/៨/២០១២; អ្នកប្រកបរបរកាប់អុស និងបើកក្បូន ២០/១០/២០១២; ទស្សនាអាងស្តុកទឹកទំនប់កំចាយ ២០/១០/២០១២

*ផង តើគេអាចជីក និងសម្អាតឫសឈើដូចម្តេចទៅ?»*[២២៣] បុរសម្នាក់ផ្សេងទៀតបានប្រាប់អោយដឹងថា គេសម្អាតតែតំបន់ក្បែរៗទំនប់ប៉ុណ្ណោះ ប៉ុន្តែតំបន់ខាងក្នុងអាង និងឆ្ងាយៗពីទីតាំងទំនប់ គេគ្រាន់តែយកឈើមានតម្លៃចេញប៉ុណ្ណោះ។

ក្រុមហ៊ុនស៊ីណូហៃដ្រូបានដឹងថា តាមគោលការណ៍ ពួកគេត្រូវតែសម្អាតព្រៃឈើ និងរុក្ខជាតិនៅតំបន់ទាំងអស់រហូតដល់កំពស់ ១៥០ម៉ែត្រ ខាងលើកម្រិតទឹកសមុទ្រ។[២២៤] ប៉ុន្តែ ចំណុចនេះមិនត្រូវបានគេអនុវត្តឡើយ។ យោងតាមក្រសួងបរិស្ថាន គណៈកម្មការអន្តរក្រសួងគឺជាអ្នកទទួលបន្ទុកសម្អាត និងលក់ឈើនៅតំបន់អាងស្តុកទឹក។ ការសម្អាតផ្ទៃអាងមិនបានត្រឹមត្រូវបណ្តាលមកពីសមត្ថភាពដ៏មានកម្រិតនៃក្រុមហ៊ុន ដែលរាជរដ្ឋាភិបាលកម្ពុជាជួលអោយធ្វើការងារនេះ។ ទោះបីជាមានឈើជាច្រើននៅសល់ក្នុងអាង រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូលទឹកក្នុងអាងស្តុកទឹក នៅពេលដែលក្រុមហ៊ុនស៊ីណូហៃដ្រូ បានអះអាងថាការបញ្ចូលទឹកក្នុងអាងស្តុកទឹកនឹងមិនធ្វើអោយប៉ះពាល់ដល់ទំនប់។[២២៥] ទង្វើនេះ ផ្ទុយពីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលកត្តានេះបង្ហាញនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិច្ចការពារបរិស្ថាន ដែលគេចាត់ទុកថាជាចំនុចដ៏សំខាន់សម្រាប់គម្រោងទំនប់វារីអគ្គិសនីកំចាយ។

ដូចគេបានព្យាករ នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម វត្តមាននៃរូបធាតុសរីរាង្គនៅក្នុងអាងស្តុកទឹកបានធ្វើអោយគុណភាពទឹកថយចុះ ដោយមើលទៅលើពណ៌ និងក្លិនទឹកដែលគេបញ្ចេញពីអាងស្តុកទឹក។[២២៦] ទោះបីជាទំហំថយចុះនៃគុណភាពទឹកពិបាកនឹងវាស់វែងក៏ដោយ តាមការអង្កេតផ្ទាល់នៅឯអាងស្តុកទឹក គេឃើញពពុះឧស្ម័នបញ្ចេញពីបាតអាងស្តុកទឹកលេចឡើងមកផ្ទៃខាងលើជាញឹកញាប់។

---

[២២៣] ការបង្ហាញរបកគំហើញទៅសហគមន៍មូលដ្ឋានខេត្តកំពត ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

[២២៤] ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្តកំពត ២៩/៨/២០១២

[២២៥] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២

[២២៦] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២



រូបភាព: ពពុះហ្គាសផុសចេញមកផ្ទៃខាងលើអាងស្តុកទឹក ដែលជាកន្លែងមានកាកសំណល់ប្រេងផងដែរ

បន្ថែមលើក្លិន និងពណ៌ទឹក ដែលបានធ្វើអោយអ្នកស្រុក និងភ្ញៀវទេសចរមិនហ៊ានលេងទឹក នៅរមណីយដ្ឋានទឹកឈូ និងនៅខ្សែទឹកខាងក្រោម។ ការបញ្ចេញឧស្ម័ននេះ វាទំនងជានឹងរួមចំណែកធំធេងដល់ការប្រែប្រួលអាកាសធាតុ។ ផលប៉ះពាល់ពីការរលួយរុបធាតុសរីរាង្គនេះ មិនត្រូវបានគេលើកឡើង ក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឡើយ។ ការត្រួតពិនិត្យដោយទាហានល្បាតព្រៃនៅតំបន់អាងស្តុកទឹក គឺផ្តោតតែលើការការពារព្រៃឈើប៉ុណ្ណោះ ហើយពួកគេ មិនបានត្រួតពិនិត្យគុណភាពទឹកនោះទេ។[២២៧] យោងតាមក្រសួងបរិស្ថានការតាមដានគុណភាពទឹកដែលគេត្រូវធ្វើរៀងរាល់៣ខែ ម្តងនៅកំឡុងពេលប្រតិបត្តិការគម្រោងទំនប់វារីអគ្គិសនីកំចាយ ក្រុមហ៊ុនស៊ីណូហៃដ្រូធ្លាប់បានធ្វើតែម្តងប៉ុណ្ណោះគឺនៅមុនប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយ។[២២៨] មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត មិនបានជាប់ពាក់ព័ន្ធនឹងការងារតាមដានណាមួយឡើយ ហើយមន្ទីរនេះក៏មិនបានដឹងថាតើការតាមដានទឹកក្រោមដី និងទឹកនៅផ្ទៃខាងលើកំពុងតែកើតឡើងដែរ ឬទេ ឬវានឹងត្រូវគេតាមដាននៅពេលអនាគតដែរ ឬទេ។[២២៩] ដូច្នេះវាអាចមិនមានការតាមដានគុណភាពទឹកនៅកំឡុងពេល១០ខែដំបូង នៃការប្រតិបត្តិគម្រោងទំនប់វារីអគ្គិសនីកំចាយឡើយ។ យោងតាមក្រសួងបរិស្ថាន នាយកដ្ឋានគ្រប់គ្រងការបំពុលបរិស្ថានមានតួនាទីត្រួតពិនិត្យ និងយល់ព្រមលើលទ្ធផលដែលប្រគល់ជូនដោយក្រុមហ៊ុនស៊ីណូហៃដ្រូ។[២៣០] ការអនុវត្តដោយមានក្រុមហ៊ុនស៊ីណូ

[២២៧] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២

[២២៨] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

[២២៩] មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត ២៨/៨/២០១២

[២៣០] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

ហៃដ្រូខ្លួនឯងជាអ្នកតាមដានគុណភាពទឹក ធ្វើអោយមានមន្ទិលសង្ស័យដោយសារក្រុមហ៊ុននឹងទទួលបានផលប្រយោជន៍ពីការបង្ហាញលទ្ធផលល្អ។ ដើម្បីធានាបាននូវអព្យាក្រឹត្យភាព ភាគីឯករាជ្យគួរតែត្រូវបានគេពិចារណាសម្រាប់អនុវត្តការងារនេះ។

ដោយសារមានការកើនឡើងនូវការធ្វើដំណើរដោយទូក នៅក្នុងអាងស្តុកទឹក ជាពិសេសក្បូនប្រើម៉ាស៊ីនតូចៗ អាចនឹងកើនឡើងការបំពុលបរិស្ថានដោយសារការកំពប់ប្រេងទៅក្នុងទឹក។ ដោយចរាចរតាមផ្លូវទឹកមានទំហំតូច ផលប៉ះពាល់ដល់គុណភាពទឹកប្រហែលជាអាចមានកម្រិតតិចតួច ឬមិនសំខាន់។ ទោះយ៉ាងណាវាជាបញ្ហាមួយដែលគេគួរតែធ្វើការតាមដាននៅពេលអនាគតផងដែរ។

### ៤.១.៥ ផលប៉ះពាល់លើវិស័យទេសចរណ៍ និងគ្រួសារពឹងផ្អែកលើអនុផលព្រៃឈើ

ផលប៉ះពាល់លើអ្នកប្រកបរបរកាប់ឫស្សី និងអ្នកប្រមូលអនុផលព្រៃឈើព្រមទាំងគ្រួសារដែលពឹងផ្អែកលើវិស័យទេសចរណ៍ សម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់ ត្រូវបានគេបញ្ចូលខ្លះដែរ នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ហើយថវិកាមួយចំនួនត្រូវបានគេលៃទុកសម្រាប់ទូទាត់សងដល់អ្នករងគ្រោះទាំងនេះ។ គេលៃថវិកាចំនួន ៥០០.០០០ ដុល្លារអាមេរិក ទុកសម្រាប់ការបាត់បង់ប្រាក់ចំណូលពីផលិតផលព្រៃឈើ និងថវិកាចំនួន ៥០០.០០០ ដុល្លារអាមេរិក ផ្សេងទៀត សម្រាប់ការបាត់បង់ប្រាក់ចំណូលពីវិស័យទេសចរណ៍។ ក៏ប៉ុន្តែក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គេមិនបានរៀបរាប់លំអិតថាតើថវិកាទាំងនេះនឹងត្រូវគេប្រើសម្រាប់អ្វីខ្លះ ហើយថាតើវិធានការទូទាត់សំណងនឹងត្រូវគេធ្វើបែបណា និងនៅពេលណានោះទេ។[២៣១] គួរអោយសោកស្តាយនោះ រហូតមកដល់ខែតុលា ឆ្នាំ២០១២ មិនមានសញ្ញាណាមួយបង្ហាញថាគេបានអនុវត្តវិធានការខាងលើឡើយ។

នៅកំឡុងពេលនៃការពិភាក្សាជាក្រុមនៅក្នុងការប្រជុំពិគ្រោះយោបល់ ដែលធ្វើនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ មានការពិភាក្សាអំពីបញ្ហានៃផលប៉ះពាល់លើ

---

[២៣១] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ៣៣៨-៣៣៩

សង្គម-សេដ្ឋកិច្ចរបស់គម្រោងទំនប់វារីអគ្គិសនីកំចាយ។ គេបានរកឃើញថាប្រជាជនដែលពឹងផ្អែកលើព្រៃឈើសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់ នឹងត្រូវបាត់បង់មុខរបរប្រមូលអនុផលព្រៃឈើ។ គេក៏បានទទួលស្គាល់ថា ផលប៉ះពាល់មានលក្ខណៈធ្ងន់ធ្ងរនៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ ប៉ុន្តែគេមិនបានលើកឡើងពីផលប៉ះពាល់ក្រោយពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយឡើយ។ អ្នកចូលរួមក្នុងកិច្ចប្រជុំនោះបានស្នើសុំអោយក្រុមហ៊ុនស៊ីណូហៃដ្រូផ្តល់វគ្គបណ្តុះបណ្តាល បង្កើតការងារសម្រាប់អ្នកប្រមូលអនុផលព្រៃឈើ និងបង្កើតសហគមន៍ឫស្សី និងផ្តៅ។[២៣២] ជាលទ្ធផលនៃកិច្ចប្រជុំ ក្រុមហ៊ុនស៊ីណូហៃដ្រូ បានយល់ព្រមបង្កើតសហគមន៍មួយ ឬលើសពីមួយដើម្បីដាំឫស្សី និងផ្តៅនៅជុំវិញភ្នំកំចាយ។[២៣៣] គេហាក់បីដូចជាមិនបានបំពេញវិធានការដែលគេបានស្នើឡើងឡើយ។ មិនមានអ្នកភូមិដែលបានជួបសម្ភាសន៍ណាម្នាក់ប្រាប់ថា មានការបណ្តុះបណ្តាលអ្នកប្រមូលអនុផលព្រៃឈើ ឬការបង្កើតការងារណាមួយឡើយ ហើយដូចបានពិពណ៌នាខាងដើម សហគមន៍ឫស្សីដែលមានស្រាប់ហើយមិនដំណើរការនៅភូមិអូរតូចនោះ មិនជាប់ទាក់ទងនឹងក្រុមហ៊ុនស៊ីណូហៃដ្រូឡើយ។

## ៤.២ ស្ថានភាព និងអនាគតនៃផែនការគ្រប់គ្រងបរិស្ថាន និងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

ដូចបានបញ្ជាក់ខាងដើម ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងទំនប់វារីអគ្គិសនីកំចាយកន្លងមកនៅមានភាពខ្វះចន្លោះ។ តារាងទី៤ សង្ខេបអំពីវិធានការកាត់បន្ថយហេតុប៉ះពាល់សំខាន់ៗ ហើយនឹងស្ថានភាពនៃការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានទាំងនោះ។

---

[២៣២] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ១៨៩

[២៣៣] ចូរសំគាល់ថាភ្នំកំចាយជាភ្នំដែលផ្សេងពីរភ្នំទឹកចេញដែលជាភ្នំនៅជិតភូមិអូរតូច ដូចនេះគម្រោងដាំកូនឈើដែលបានលើកឡើងមិនទាក់ទងនឹងសហគមន៍ឫស្សីនៅភូមិអូរតូចឡើយ។

តារាងទី៩: ស្ថានភាពនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន

| វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានក្នុងផែនការគ្រប់គ្រងបរិស្ថាន[២៣៤] | |
|---|---|
| វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន | ស្ថានភាព |
| សម្អាតព្រៃឈើ និងរុក្ខជាតិនៅតំបន់អាងស្តុកទឹក | អនុវត្តមិនត្រឹមត្រូវ |
| ដាំកូនឈើនៅតំបន់ដទៃ ដើម្បីទូទាត់ការបាត់បង់ព្រៃឈើនៅតំបន់អាងស្តុកទឹក | មិនទាន់អនុវត្ត |
| សាងសង់អាងសម្រាប់បង្កើនផលត្រី និងអភិរក្សពពួកត្រី ដែលជិតផុតពូជ | មិនទាន់អនុវត្ត |
| ពិនិត្យគុណភាពទឹកក្នុងអាងស្តុកទឹក | មិនទាន់អនុវត្ត |
| បំពាក់ឧបករណ៍នៅក្នុងអាងស្តុកទឹក ដើម្បីសំអាតនិងសំលាប់សត្វល្អិត និងរុក្ខជាតិក្នុងទឹកចង្រៃ | មិនអាចដឹងបាន |
| សាងសង់ស្ថានីយជលសាស្ត្រ ដើម្បីសិក្សា និងតាមដានការផ្លាស់ប្តូរនៃជលសាស្ត្ររបស់ព្រែក | មិនអាចដឹងបាន |
| បំពាក់ឧបករណ៍ពន្លត់អគ្គិសនីភ័យ និងឧបករណ៍ស្វ័យប្រវត្តិសម្រាប់អោយដឹងប្រសិនបើមានភ្លើងឆេះព្រៃ | មិនអាចដឹងបាន[២៣៥] |

ទោះបីជាគេមិនទាន់ធ្វើផែនការ ឬមិនទាន់អនុវត្តផែនការគ្រប់គ្រងបរិស្ថានក៏ដោយ[២៣៦] យោងតាមមន្ទីរបរិស្ថានខេត្តកំពត គេមានគម្រោងបង្កើតផែនការមេសម្រាប់ទូទាត់សំណង និងការដាំកូនឈើ។ ផែនការនេះគួរត្រូវបានអនុវត្តដោយក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នផ្សេងៗទៀត។ វានឹងអាស្រ័យលើក្រសួងទាំងនេះក្នុងការជម្រុញក្រុមហ៊ុនស៊ីណូហៃដ្រូ អោយអនុវត្តន៍ផែនការទាំងនោះ។ គេបម្រុងថវិកាជិត ៦ លានដុល្លារអាមេរិក សម្រាប់ដាំកូនឈើឡើងវិញ និងទូទាត់សំណងជូនដល់ប្រជាជនរងគ្រោះ ដែលពាក់ព័ន្ធនឹងធនធានធម្មជាតិ និងបញ្ហាសេដ្ឋកិច្ច-សង្គមកិច្ច។

[២៣៤] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ៣៣១-៣៣៦

[២៣៥] ក្រុមហ៊ុនស៊ីណូហៃដ្រូ មិនបានឆ្លើយតបនឹងសំណើរសុំអោយបញ្ជាក់ពីការសាងសង់ស្ថានីយជលសាស្ត្រនិងការបំពាក់ឧបករណ៍នៅក្នុងអាងស្តុកទឹកដើម្បីសម្លាប់សត្វល្អិតនិងរុក្ខជាតិព្រមទាំងការបំពាក់ឧបករណ៍ពន្លត់អគ្គីភ័យ

[២៣៦] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/២០១២; នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

យោងតាមកំណត់ហេតុនៃកិច្ចប្រជុំអន្តរក្រសួងនៅខែមេសា ឆ្នាំ២០១២ គេបម្រុងថវិកាខាងក្រោមសម្រាប់៖[២៣៧]

- ដាំកូនឈើរយៈពេល ១០ឆ្នាំ (ប្រមាណ ២,០០០ហិចតា) ស្មើនឹង ៩លានដុល្លារអាមេរិក
- ធនធានជលផល: លែងកូនត្រីរយៈពេល១០ឆ្នាំស្មើនឹង៩៥០.០០០ដុល្លារអាមេរិក
- សាងសង់អាងសម្រាប់អភិរក្សត្រី(សង់អាងថ្មី) ស្មើនឹង ៨០០.០០០ដុល្លារអាមេរិក
- មូលនិធិសេដ្ឋកិច្ច-សង្គមកិច្ច៖ សម្រាប់សហគមន៍ឫស្សី និងគាំទ្រអ្នកនេសាទ ស្មើនឹង ៥៧០.៣៧៤ ដុល្លារអាមេរិក

ទាក់ទងទៅនឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងវិធានការកាត់បន្ថយហេតុប៉ះពាល់ផ្សេងទៀតដែលពាក់ព័ន្ធនឹងរាជរដ្ឋាភិបាលកម្ពុជា កង្វះយន្តការសម្រាប់ផ្តល់ថវិកា ជាសញ្ញាគួរអោយបារម្ភក្នុងការធ្វើអោយសកម្មភាពទាំងនោះកើតមានជារូបរាង។ យោងតាមមន្ទីរបរិស្ថានខេត្តកំពត សព្វថ្ងៃមិនទាន់មានគោលការណ៍ជាក់លាក់ ដើម្បីផ្ទេរថវិកាពីក្រុមហ៊ុនស៊ីណូហៃដ្រូសម្រាប់អនុវត្តសកម្មភាពទូទាត់សំណងផលប៉ះពាល់លើសង្គម និងបរិស្ថាននៅឡើយ។ ដោយហេតុនេះហើយបានជាមន្ទីរបរិស្ថានខេត្តមិនទាន់បានប្រើប្រាស់ថវិកា ដែលបានកំណត់ក្នុងរបាយការណ៍គម្រោងទំនប់វារីអគ្គិសនីកំចាយ។ មន្ទីរបរិស្ថានខេត្តកំពត ចង់ឃើញថ្នាក់ជាតិរៀបចំគោលការណ៍ និងបញ្ជាក់តួនាទី និងការទទួលខុសត្រូវដល់ថ្នាក់ក្រោមជាតិ។[២៣៨] នៅក្រសួងបរិស្ថាន នាយកដ្ឋានឧទ្យានជាតិ ប្រធាននាយកដ្ឋានក៏មិនបានដឹងនូវយន្តការផ្ទេរមូលនិធិណាមួយ ដែលត្រូវបានគេប្រើសម្រាប់ការអនុវត្តផែនការទាំងនោះដែរ។[២៣៩] ចំណែកនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានប្រាកដថា ផែនការគ្រប់គ្រងបរិស្ថានសម្រាប់ទំនប់វារីអគ្គិសនីកំចាយនឹងមាន ហើយនឹងត្រូវបានគេអនុវត្តចាប់ពីដើមឆ្នាំ២០១៣។[២៤០]

---

[២៣៧] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២
[២៣៨] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២
[២៣៩] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២
[២៤០] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

## ៤.៣ កត្តាប្រឈមនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន

ទោះជាមានរយៈពេលកន្លងទៅជិតមួយឆ្នាំ ចាប់តាំងពីការសម្ពោធទំនប់វារីអគ្គិសនី ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលគេបានលើកឡើងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម នៅខ្វះចន្លោះនៅឡើយ។ វិធានការភាគច្រើនដែលបានលើកឡើងមិនទាន់ត្រូវបានគេអនុវត្ត ឬគ្រាន់តែត្រូវគេអនុវត្តដោយអន្លើៗប៉ុណ្ណោះ។ បន្ថែមលើកត្តាដែលគួរអោយបារម្ភខាងលើ គេនៅមិនទាន់មានផែនការច្បាស់លាស់នៅឡើយ សម្រាប់ដោះស្រាយការអនុវត្តផែនការទាំងនោះ។ នៅពេលចោទសួរថា អ្នកណានឹងនាំមុខគេក្នុងដំណើរការអនុវត្តការងារទាំងនោះ ក្រុមហ៊ុនស៊ីណូហៃដ្រូ និងក្រសួងបរិស្ថានបានចង្អុលដាក់គ្នាទៅវិញទៅមក។ ក្រសួងបរិស្ថានចង់ឃើញតួនាទីរបស់ខ្លួន ជាអ្នកត្រួតពិនិត្យលទ្ធផលនៃសកម្មភាពតាមដានរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូនៅពេលអនាគត។[២៤១] ភាពមិនច្បាស់លាស់ក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ អំពីការអនុវត្តលើតួនាទីរបស់ខ្លួន បានធ្វើអោយខូចប្រយោជន៍រួមក្នុងការកំណត់ផលប៉ះពាល់បរិស្ថាន និងសង្គមនៃការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។

ដោយធ្វើការពិនិត្យទៅលើគោលបំណង នៃដំណើរការរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដើម្បីផ្តល់ចំណេះដឹងគ្រប់គ្រាន់ក្នុងការសម្រេចចិត្តអោយបានត្រឹមត្រូវ ភាពយឺតយ៉ាវខ្លាំងនៃការធ្វើការសម្រេច និងអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងទំនប់វារីអគ្គិសនីកំចាយគឺជាបញ្ហាដ៏ធំ។ កាលដែលមានការអនុម័តយល់ព្រមលើការវាយតម្លៃគម្រោងទំនប់វារីអគ្គិសនីកំចាយ នៅក្រោយការចាប់ផ្តើមការសាងសង់ និងរហូតដល់ក្រោយការបញ្ចប់ការសាងសង់ទំនប់ ធ្វើអោយដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ស្ទើរតែគ្មានប្រយោជន៍។ បើគេមិនបានបញ្ចប់ មិនបានអនុម័តយល់ព្រម និងមិនបានផ្សាយជាសាធារណៈនូវផែនការសម្រាប់កាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមពីគម្រោងសាងសង់ និងប្រតិបត្តិការ ការអនុវត្តកិច្ច

[២៤១] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២; ក្រុមហ៊ុនស៊ីណូហៃដ្រូ ៨/១០/២០១២

ការពារទាំងអស់អាចនឹងមានលក្ខណៈស្មុគស្មាញ និងអនុវត្តជាន់គ្នា។ កង្វះផែនការជាក់លាក់ និងការបែងចែកការទទួលខុសត្រូវ ជាការគំរាមកំហែងដល់ឱកាសនៃការអនុវត្តគម្រោងប្រកបដោយតម្លាភាព និងមានការចូលរួមពេញលេញ។

ក្រសួងបរិស្ថានបានលើកហេតុផលថា ផែនការច្បាស់លាស់សម្រាប់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងការអនុវត្តន៍លើការគ្រប់គ្រងបរិស្ថានមិនទាន់បានអនុវត្តបណ្តាលមកពីការអនុម័តយឺតពេលប្រមាណជា៥ឆ្នាំ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ យោងតាមនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានមិនចាំបាច់ចាប់ផ្តើមទេ រហូតទាល់តែការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមបានរយៈពេល៦ខែ ពោលគឺការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននឹងត្រូវគេអនុវត្តន៍នៅខែមករា ឆ្នាំ២០១៣។[២៤២] យ៉ាងណាមិញតាមទស្សនៈបរិស្ថាន និងការចិញ្ចឹមជីវិតជាមូលដ្ឋាន នៅពេលដែលទំនប់បានប្រតិបត្តិការជិតមួយឆ្នាំ នៅមុនការចាប់ផ្តើមសកម្មភាពតាមដានដែលគេតម្រូវអោយធ្វើជារៀងរាល់ត្រីមាស ឬឆមាស គឺវាមិនមែនជាការល្អប្រសើរឡើយ។ ដូចគ្នានេះដែរការបញ្ចប់ និងការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលយឺតពេលនេះ នាំអោយមានចំណោទថាតើវិធានការការពារជាមុនដល់បរិស្ថាន និងសង្គម ដែលអាចកើតមានឡើងនៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយត្រូវបានគេអនុវត្តយ៉ាងដូចម្តេច។

[២៤២] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

# ការពិភាក្សា

## ១. កត្តាប្រឈមពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនីកំចាយ

នៅពេលពិនិត្យអំពីការផ្តល់ព័ត៌មាន និងការរាប់បញ្ចូលភាគីពាក់ព័ន្ធផ្សេងៗ តាមរយៈការចូលរួមកំណត់ហេតុនៃគម្រោងទំនប់វារីអគ្គិសនីកំចាយ វាមិនមានលក្ខណៈល្អប្រសើរឡើយ។ ការទទួលបានព័ត៌មានដ៏មានកម្រិត ធ្វើអោយមានការលំបាកដល់សហគមន៍ សង្គមស៊ីវិល និងស្ថាប័នរាជរដ្ឋាភិបាលក្នុងការតាមដានសកម្មភាពកាត់បន្ថយហេតុប៉ះពាល់នានានៅកំឡុងពេល និងក្រោយពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ លើសពីនេះទៀត ភាពអាថ៌កំបាំងនៃព័ត៌មានអំពីគម្រោងចាប់ពីការពិភាក្សា និងយល់ព្រមនៅគ្រាដំបូងរហូតដល់ការសាងសង់ និងប្រតិបត្តិការគម្រោងនៅឆ្នាំទី១ ធ្វើអោយសហគន៍ និងសង្គមស៊ីវិលស្ទើរតែមិនបានបញ្ចេញមតិនៅក្នុងដំណើរការសម្រេចចិត្ត ឬស្ទើរតែមិនអាចធ្វើអោយកង្វល់របស់ពួកគាត់បានឮដល់ភាគីពាក់ព័ន្ធ។ ជាលទ្ធផល ការដាក់បញ្ចូលកង្វល់របស់សហគមន៍ក្នុងការសម្រេចចិត្តទៅលើគម្រោង ត្រូវបានរាំងស្ទះ ហើយការកាត់បន្ថយហេតុប៉ះពាល់មិនសូវជាឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង។

ជារឿយៗ គម្រោងអភិវឌ្ឍន៍ខ្នាតធំតែងតែមានអ្នកចំណេញ និងអ្នកខាតប្រយោជន៍ ក្នុងចំណោមប្រជាជនមូលដ្ឋាននៅពេលដែលគម្រោងនោះផ្តល់ផលប្រយោជន៍ និងផលប៉ះពាល់របស់វា។ ក្នុងគម្រោងទំនប់វារីអគ្គិសនីកំចាយផលប្រយោជន៍ ហាក់បីដូចជាមិនសូវបានផ្តល់ទៅដល់ជនក្រីក្រក្នុងសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរជាងគេបំផុតដោយសារគម្រោងទេ។ ផ្ទុយទៅវិញ អ្នកមានធនធាន និងទ្រព្យសម្បត្តិអាចទាញយកប្រយោជន៍ពីគម្រោងបានយ៉ាងច្រើន។ ឧទាហរណ៍ គ្រួសារដែលមានជីវភាពធូរធារអាចទទួលបានផលប្រយោជន៍ពីការដឹកជញ្ជូនឫស្សីពីអាងស្តុកទឹក តាមរយៈការជួលរថយន្តនៅពេលដែលអ្នកកាប់ឫស្សីក្រីក្រប្រឈមនឹងការកើនឡើងក្នុងការចំណាយលើការធ្វើដំណើរទៅកាប់ និងដឹកជញ្ជូនឫស្សីដែលពួកគាត់អាស្រ័យផល។ មានករណីលើកលែងសម្រាប់អ្នក

ប្រកបរបរកាប់អុស ដែលប្រាក់ចំណូលពួកគាត់កំពុងកើនឡើងក្នុងពេលថ្មីៗនេះ។ ទោះយ៉ាងណាក៏ដោយ ផលវិជ្ជមាននេះទំនងជាមានក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

## ១.១ ការរង់ចាំការអនុវត្តៈក្តីរំពឹងចំពោះក្រុមហ៊ុនស៊ីណូហៃដ្រូនិងរាជរដ្ឋាភិបាលកម្ពុជា

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បានបង្ហាញថាមានថវិកាចំនួន ១លានដុល្លារអាមេរិក សម្រាប់អនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ដល់សហគមន៍ ដែលរងផលប៉ះពាល់ដោយសារការបាត់បង់ឱកាសចូលទៅប្រមូលអនុផលព្រៃឈើ និងការថយចុះនៃចំនួនភ្ញៀវទេសចរនៅរមណីយដ្ឋានទឹកឈូ។ ប៉ុន្តែសមាជិកសហគមន៍ ក្រុមហ៊ុនស៊ីណូហៃដ្រូ និងមន្ត្រីរាជរដ្ឋាភិបាល សុទ្ធតែមិនដឹងអំពីគម្រោងណាមួយក្នុងការអនុវត្តនូវការសន្យានេះឡើយ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនស៊ីណូហៃដ្រូ នៅតែអាចកែតម្រូវស្ថានភាពនេះបានដោយទទួលស្គាល់ថា សហគមន៍មូលដ្ឋាន ពិតជាបានរងផលប៉ះពាល់អវិជ្ជមានពីគម្រោង និងកំពុងត្រូវការការជួយគាំទ្រផងដែរ។

កិច្ចសហការរវាងក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា ភាគច្រើនហាក់ដូចជាចែកព្រំដែន «ការងារពាក់ព័ន្ធ» ជាផ្នែកៗនៃស្ថាប័នរដ្ឋាភិបាលដូចជាមានការងារច្រើនសម្រាប់ក្រសួង និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល អាជ្ញាធរអគ្គិសនី និងអាជ្ញាធរខេត្ត ហើយមានការងារតិចតួចសម្រាប់ក្រសួង និងស្ថាប័នពាក់ព័ន្ធនឹងការងារបរិស្ថាន។ មន្ទីរបរិស្ថានខេត្តកំពតយល់ថាកិច្ចសហការជាមួយក្រុមហ៊ុនស៊ីណូហៃដ្រូមិនមានលក្ខណៈប្រាកដប្រជាឡើយ។ កន្លងមកកត្តាប្រឈមសំខាន់បំផុតក្នុងកិច្ចសហការជាមួយក្រុមហ៊ុន គឺទាក់ទងទៅនឹងការសម្របសម្រួលអោយក្រុមហ៊ុនស៊ីណូហៃដ្រូ និងសហគមន៍មូលដ្ឋានចូលរួមការពារឧទ្យានជាតិបូកគោ និងការធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងរវាងភាគីទាំងពីរ។[២៤៣] ដើម្បីកែលំអស្ថានភាពនេះ មន្ទីរបរិស្ថានខេត្តកំពតយល់ឃើញថា វាអាចនឹងមានផលប្រយោជន៍ប្រសិនបើ ក្រុមហ៊ុនស៊ីណូហៃដ្រូ រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍មូលដ្ឋាន

---

[២៤៣] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២

អាចជួបប្រជុំគ្នា។ កិច្ចសហការថ្នាក់មូលដ្ឋានក៏ត្រូវគេជឿថាប្រសើរឡើងផងដែរ ប្រសិនបើគេរៀបចំការប្រជុំជាច្រើននៅថ្នាក់ខេត្ត ប៉ុន្តែកត្តានេះមិនទាន់កើតឡើងនៅឡើយ ហើយក៏មិនទាន់មានថវិកាផងដែរ។ ឥទ្ធិពលនៃកង្វះកិច្ចសហការនាំអោយមិនមានភាពច្បាស់លាស់នៃការផ្ទេរការទទួលខុសត្រូវរវាងស្ថាប័នទាំងឡាយ។[២៤៤] ធាតុសំខាន់មួយផ្សេងទៀតគឺ ការចែងអោយច្បាស់នូវគោលការណ៍សម្រាប់ការបែងចែកមូលនិធិពីថ្នាក់ជាតិមកថ្នាក់ក្រោមជាតិ។ កត្តានេះបានបង្ហាញអោយឃើញតាមរយៈផែនការដែលមិនទាន់លេចជារូបរាងរបស់មន្ទីរបរិស្ថានខេត្តកំពត ដែលបង្កើតថ្នាលបណ្តុះកូនឈើ និងគាំទ្រសហគមន៍ឫស្សី ដោយសារគេមិនបានបង្កើតយន្តការច្បាស់លាស់សម្រាប់ការផ្តល់មូលនិធិសម្រាប់ការផ្ទេរការទទួលខុសត្រូវ និងការធ្វើអោយប្រសើរឡើងនូវការសម្របសម្រួល។[២៤៥]

មេឃុំម៉ាក់ប្រាង ប្រាថ្នាចង់ឃើញប្រជាជនចំនួន៩គ្រួសារ ដែលរស់នៅក្រោមបណ្តាញចែកចាយចរន្តអគ្គិសនី នៅភូមិមាត់ពាមទទួលបានសំណងពីក្រុមហ៊ុនស៊ីណូហៃដ្រូ និងសង្ឃឹមផងដែរថា ការផ្គត់ផ្គង់ និងតម្លៃអគ្គិសនីនឹងប្រសើរឡើង។[២៤៦] នៅភូមិមាត់ពាម អ្នកភូមិប្រាថ្នាអោយក្រុមហ៊ុនស៊ីណូហៃដ្រូកែលំអផ្លូវទៅកាន់ផ្លូវជាតិលេខ៣ ហើយការងារក៏ត្រូវគេបង្កើតនៅទីនោះ។[២៤៧] ក្រសួងបរិស្ថានសង្កត់ធ្ងន់លើសារៈសំខាន់របស់ក្រុមហ៊ុនស៊ីណូហៃដ្រូ ក្នុងការថែរក្សាព្រៃឈើ ដើម្បីការពារអាងស្តុកទឹកដែលទំនប់វារីអគ្គិសនីកំចាយពឹងផ្អែកលើដោយខានមិនបាន។ ជាផ្នែកមួយនៃកិច្ចការពារ ក្រុមហ៊ុនស៊ីណូហៃដ្រូត្រូវរកវិធីបែបណាដើម្បីធ្វើអោយប្រសើរឡើងនូវការចិញ្ចឹមជីវិតរបស់ប្រជាជននៅមូលដ្ឋាន ដោយសារកត្តានេះអាចជួយទប់ស្កាត់ប្រជាជនពីការកាប់ឈើនៅក្នុងតំបន់។[២៤៨] មន្ទីរបរិស្ថានខេត្ត ក៏បានអំពាវនាវអោយក្រុមហ៊ុនស៊ីណូហៃដ្រូ គោរពតាមការសន្យាដែលទ្រទ្រង់ថវិកាដល់បុគ្គលិក

---

[២៤៤] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២

[២៤៥] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២

[២៤៦] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២

[២៤៧] ប្រធានភូមិមាត់ពាម ១៨/៨/២០១២

[២៤៨] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២

របស់មន្ទីរបរិស្ថានខេត្តដើម្បីការពារព្រៃឈើ។ ក្រុមហ៊ុនស៊ីណូហៃដ្រូបានយល់ព្រមជាមួយគណៈកម្មការអន្តរក្រសួងក្នុងការផ្តល់មូលនិធិ ប៉ុន្តែមន្ទីរបរិស្ថានខេត្តកំពតមិនទាន់ឃើញការអនុវត្តនូវកិច្ចព្រមព្រៀងនោះនៅឡើយទេ។[២៤៩]

វាជាការចាំបាច់ដែលរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនស៊ីណូហៃដ្រូ គួររៀនពីគុណវិបត្តិទាំងឡាយនៃការអនុវត្តគម្រោងទំនប់កំចាយ ក្នុងន័យដើម្បីធានាបានថាគម្រោងទំនប់វារីអគ្គិសនីដទៃទៀតនៅពេលអនាគតមានបញ្ចូលការពិគ្រោះយោបល់ទាន់ពេលវេលា និងគោរពតាមរាល់ដំណើរការច្បាប់ ជាពិសេសនោះគឺការអនុវត្តនូវកិច្ចការពារបរិស្ថានយ៉ាងម៉ឺងម៉ាត់ និងយ៉ាងច្បាស់លាស់។ គេគួររាប់បញ្ចូលរាល់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការពិគ្រោះយោបល់ ក្នុងន័យដើម្បីបញ្ចៀសស្ថានភាពមួយដែលគម្រោងអភិវឌ្ឍន៍ថ្នាក់ជាតិ រងឥទ្ធិពលអវិជ្ជមានដល់ការចិញ្ចឹមជីវិតរបស់សមាជិកសហាគមន៍មូលដ្ឋាន។ យន្តការតឹងរឹងដើម្បីកាត់បន្ថយផលប៉ះពាល់លើការចិញ្ចឹមជីវិតរបស់សហាគមន៍មូលដ្ឋានពីការបាត់បង់ប្រាក់ចំណូល គួរដាក់បញ្ចូលក្នុងគម្រោងអភិវឌ្ឍន៍ធំៗ ដូចជាគម្រោងទំនប់វារីអគ្គិសនីកំចាយដែលមានតម្លៃ ២៨០ លានដុល្លារអាមេរិកនេះជាដើម។

ដើម្បីធ្វើអោយប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ នៃគម្រោងទំនប់វារីអគ្គិសនីដំបូងគេបង្អស់នៅកម្ពុជា និងដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើការចិញ្ចឹមជីវិតដែលប្រឈមនៅតាមមូលដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើយ៉ាងណាអោយក្រុមហ៊ុនស៊ីណូហៃដ្រូគោរពតាមការសន្យារបស់ខ្លួន។ រាជរដ្ឋាភិបាលកម្ពុជាគួរមានចំណាត់ការណ៍សមរម្យមួយ ដើម្បីសម្របសម្រួលកិច្ចពិគ្រោះយោបល់ថ្នាក់មូលដ្ឋាននៅក្នុងឃុំដែលរងផលប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គិសនី ដើម្បីអោយប្រជាជនបានដឹងថាតើមានវិធានការកាត់បន្ថយហេតុប៉ះពាល់ណាខ្លះ ដែលនឹងផ្តល់ប្រយោជន៍ខ្លាំងបំផុតដល់ការចិញ្ចឹមជីវិតរបស់ពួកគាត់។ ព័ត៌មាន និងអនុសាសន៍ណែនាំនៃរបាយការណ៍នេះគួរជាចំណុចចាប់ផ្តើមដ៏សមហេតុផលមួយ សម្រាប់ជាប្រយោជន៍ក្នុងការអនុវត្តដែលគេទន្ទឹងរង់ចាំយ៉ាងយូរនោះ។

[២៤៩] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២

## ១.២ ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដ៏អាថ៌កំបាំង

តាមរយៈការសិក្សានេះ បានបង្ហាញថា ដើម្បីទទួលបានចំណេះដឹងពីដំណើរវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម វាមានការលំបាក និងចំណាយពេលច្រើនណាស់។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយសម្រាប់គម្រោងទំនប់វារីអគ្គិសនីកំចាយដែលបានអនុម័តយល់ព្រមនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ ២០១២ មិនអាចរកបានសម្រាប់ការសិក្សានេះឡើយ ទោះជាមានការស្នើសុំរបាយការណ៍នេះដល់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំនួន ៧លើកក៏ដោយ។ ទោះបីជាបានស្នើសុំរបាយការណ៍ តាមរយៈលិខិតផ្លូវការទៅកាន់ទេសរដ្ឋមន្ត្រីក្រសួងបរិស្ថានក៏ដោយ គេនៅតែមិនអាចទទួលបានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចុងក្រោយបំផុតដែរ។ ក្នុងពេលខិតខំស្នើសុំរបាយការណ៍នេះ យើងបានដឹងថាគេគិតថារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជា «កម្មសិទ្ធិបញ្ញា» របស់ក្រុមហ៊ុនស៊ីណូហៃដ្រូ ដូច្នេះហើយ បានជាក្រសួងបរិស្ថានត្រូវតែការពាររបាយការណ៍នោះ។ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានបញ្ជាក់ច្បាស់ថា គេមិនអាចចែកចាយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជាសារណៈបានឡើយ។ ចំនុចនេះ ផ្ទុយទៅនឹងមាត្រា១នៃអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលចែងថា គោលបំណងមួយនៃគោលបំណងសំខាន់ជាច្រើននៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គឺដើម្បី *«បំផុសឲ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគំរោង នៅមុនពេលការអនុវត្តគម្រោងណាមួយ។»*[២៥០]

តាមរយៈការពិគ្រោះយោបល់ ជាមួយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំណាប់អារម្មណ៍រួមគឺថា រាជរដ្ឋាភិបាលកម្ពុជា ផ្តល់អទិភាពដល់ការការពារអ្នកវិនិយោគខ្ពស់ជាងការទទួលបាននូវការចូលរួមជាសាធារណៈ និងកិច្ចការពារសង្គម និងបរិស្ថាន។ ដូច្នេះ វាហាក់បីដូចជាការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចមានសារៈ

[២៥០] អនុក្រឹត្យស្តីកិច្ចពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន១៩៩៩, មាត្រា១

សំខាន់ដល់រាជរដ្ឋាភិបាលកម្ពុជា ជាងការពិចារណាដល់សង្គម និងកំណើនសេដ្ឋកិច្ច ដែលមានការគាំទ្រដល់ជនក្រីក្រ។[២៥១] ទោះបីជាគេរក្សាជាអាថ៌កំបាំងពីសាធារណជនក៏ដោយ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានអះអាងថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវគេចែកចាយយ៉ាងទូលំទូលាយដល់ក្រសួង និងអាជ្ញាធរពាក់ព័ន្ធ។[២៥២] ប៉ុន្តែ នៅពេលធ្វើការសម្ភាសនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ប្រមាណជា៣ខែកន្លះ ក្រោយការអនុម័តយល់ព្រមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅមន្ទីរបរិស្ថានខេត្តកំពតមិនបានដឹងថាមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ចុងក្រោយនេះឡើយ។ មន្ទីរបរិស្ថានខេត្តកំពត មានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជំហ៊ានដំបូងនៅឆ្នាំ២០០៦ និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ខែមេសា ឆ្នាំ២០១១ ដែលមន្ទីរបរិស្ថានខេត្តកំពត ចាត់ទុកថាជាច្បាប់ចុងក្រោយ។[២៥៣]

ក្រសួងបរិស្ថានបាននិយាយការពារមួយផ្នែក ចំពោះការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ដែលបានធ្វើឡើងនៅមុនការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ចំនួនបួនទៅប្រាំឆ្នាំនោះថា មានការសិក្សាពីមុនៗ ដែលគេបានស្រាវជ្រាវអំពីសក្តានុពលរបស់ទំនប់នេះរួចហើយ។[២៥៤] ការដោះសារការពារចំពោះការមិនអនុវត្តតាមគោលការណ៍ច្បាប់ និងគោលការណ៍ណែនាំសម្រាប់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាការគួរអោយខកចិត្ត និងផ្តល់ចំណាប់អារម្មណ៍ថា រាជរដ្ឋាភិបាលកម្ពុជាមិនប្រកាន់ខ្ជាប់នូវកាតព្វកិច្ចស្របតាមផ្លូវច្បាប់របស់ខ្លួនក្នុងការការពារបរិស្ថាន។

---

[២៥១] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២; ពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថាន, នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១១/១០-២០១២, ២២/១០-២០១២, ២៣/១០-២០១២, ៣០/១០-២០១២ និង០៥/១១-២០១២

[២៥២] នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ១០/១០-២០១២

[២៥៣] មន្ទីរបរិស្ថាន ខេត្តកំពត ១៨/១០/ ២០១២

[២៥៤] នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២

## ១.៣ ការចូលរួម និងការទទួលបានព័ត៌មាន

### ការចូលរួមរបស់សហគមន៍ និងអង្គការសង្គមស៊ីវិល

ក្នុងរយៈពេលនៃគម្រោងសាងសង់ទំនប់វារីអគ្គិសនី និងរហូតដល់ពេលនៃការសិក្សានេះ សហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោងមិនបានទទួលព័ត៌មានអំពីទំនប់ និងផលប៉ះពាល់របស់វាឡើយ។ ជាលទ្ធផល ប្រជាជនមូលដ្ឋានមិនសូវមានចំណេះដឹងអំពីទំនប់វារីអគ្គិសនីកំចាយ ហើយក៏មិនដឹងថា តើទំនប់ដំណើរការដូចម្តេច ដោយរាប់បញ្ចូលទាំងសុវត្ថិភាពរបស់វាផងដែរ។ លើសពីនេះទៀតកង្វះព័ត៌មាន និងការចូលរួមនាំអោយអ្នកភូមិមិនដឹងថាតើគេត្រូវបង្ហាញកង្វល់ និងសំណួររបស់ខ្លួនទៅកាន់អ្នកណា។

ការប្រជុំអំពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ត្រូវបានគេរៀបចំភាគច្រើនសម្រាប់ភាគីរាជរដ្ឋាភិបាលកម្ពុជា ហើយសូម្បីតែការចែករំលែកព័ត៌មានដល់អាជ្ញាធរភូមិ និងឃុំក៏នៅមានកម្រិតនៅឡើយ។ ការប្រជុំផ្តល់ព័ត៌មានជាសាធារណៈដើម្បីពន្យល់អំពីទំនប់វារីអគ្គិសនីកំចាយ ផលប៉ះពាល់របស់វា និងវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តមិនមានឡើយនៅក្នុងសហគមន៍រងគ្រោះ។[២៥៥] យោងតាមការស្ទង់មតិជាមួយក្រុមគ្រួសារចំនួន ១០០គ្រួសារ នៅភូមិអូរតូច ភូមិថ្មីខាងជើង ភូមិមាត់ពាម និងភូមិស្នំប្រាំពីរ ប្រជាជនជាង៩៥% មិនត្រូវបានគេអញ្ជើញអោយចូលរួមក្នុងការប្រជុំណាមួយស្តីអំពីទំនប់ឡើយ។[២៥៦]

រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនស៊ីណូហៃដ្រូ ហាក់បីដូចជាមិនស្វាគមន៍ប្រជាជនមូលដ្ឋាន និងសង្គមស៊ីវិលនៅក្នុងដំណើរការរៀបចំរបាយការណ៍វាយតម្លៃ

---

[២៥៥] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២; អនុប្រធានភូមិថ្មីខាងជើង ២៧/៨/២០១២; ពិភាក្សាក្រុមភូមិថ្មីខាងជើង ២៧/៨/២០១២; ពិភាក្សាក្រុមភូមិអូរតូច ២៩/៨/២០១២; ពិភាក្សាក្រុមភូមិស្នំប្រាំពីរ ២២/៨/២០១២; គ្រួសារអ្នកកាប់អុសនៅភូមិស្នំប្រាំពីរ ៣១/៨/២០១២; គ្រួសាររស់នៅក្រោមខ្សែបញ្ជូនចរន្ត នៅភូមិមាត់ពាម ៣០/៨/២០១២

[២៥៦] ៩៥% នៃគ្រួសារអាស្រ័យលើទេសចរណ៍ដែលបានត្រូវគេស្ទង់មតិចំនួន ២២គ្រួសារមិនធ្លាប់ត្រូវគេអញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំណាមួយឡើយហើយ ៩៧%នៃគ្រួសារកាប់ឫស្សីចំនួន៧៨គ្រួសារក៏មិនត្រូវគេអញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំផងដែរ។

ហេតុប៉ះពាល់បរិស្ថាន និងសង្គម និងនៅក្នុងការដោះស្រាយនូវផលលំបាកទាក់ទងនឹងការសាងសង់ទំនប់។ អង្គការនៅមូលដ្ឋានដូចជា អង្គការលីកាដូ ខេត្តកំពត ជាទូទៅបានជាប់ទាក់ទងនឹងគម្រោង នៅពេលមានគេទទួលពាក្យបណ្ដឹងពីអ្នកភូមិនៅទីនោះប៉ុណ្ណោះ។ នៅពេលសុំព័ត៌មានលំអិតសម្រាប់ទំនាក់ទំនងជាមួយអ្នកតំណាងរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូ ពីអាជ្ញាធរខេត្ត អង្គការលីកាដូ ត្រូវបានអាជ្ញាធរខេត្តប្រាប់ថា មិនមានភាពចាំបាច់ត្រូវទាក់ទងជាមួយក្រុមហ៊ុននោះទេ។[២៥៧] ជាទូទៅអង្គការសង្គមស៊ីវិលយល់ឃើញថា ការទទួលបានព័ត៌មានអំពីគម្រោងនៅមានកម្រិតនៅឡើយ *«វាហាក់បីដូចជាមិនមានព័ត៌មានណាមួយពីក្រុមហ៊ុន។ អ្នកស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាល ហាក់បីដូចជាជួបការលំបាកក្នុងទទួលបានព័ត៌មានពីក្រុមហ៊ុនស៊ីណូហៃដ្រូ។»*[២៥៨]

ក្នុងដំណើរការនៃការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមក្រុមហ៊ុនប្រឹក្សាយោបល់ សាវ៉ាក់(SAWAC) ដែលជាអ្នកសរសេររបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បានធ្វើការប្រជុំ និងសម្ភាសជាច្រើនដោយមានអ្នកចូលរួម ២៣៣នាក់ នៅឆ្នាំ២០១០។ ក្នុងនោះ ១៨នាក់ ជាអាជ្ញាធរមូលដ្ឋាន នៅខេត្តកំពត និង២១៥នាក់ ផ្សេងទៀតគឺជា «ប្រជាជនដែលពាក់ព័ន្ធ» ដែលរស់នៅតំបន់ក្បែរទំនប់។[២៥៩] មេគ្រួសារនៃអ្នកប្រកបរបរកាប់ឫស្សី និងផ្តៅចំនួន២៤គ្រួសារនៅភូមិអូរតូច និងចំនួន៧គ្រួសារនៅភូមិថ្មីខាងជើង ត្រូវបានគេសម្ភាសន៍។ នៅភូមិសំប្រាំពីរ ដែលមានរមណីយដ្ឋានទឹកឈូស្ថិតនៅទីនោះ គេបានសម្ភាសមេគ្រួសារនៃគ្រួសារដែលពឹងផ្អែកលើវិស័យទេសចរណ៍ចំនួន៣២នាក់។[២៦០] សម្រាប់បញ្ជីរាយនាមការសម្ភាស ភេទនៃអ្នកតបសម្ភាសមិនត្រូវគេបញ្ជាក់អោយបានច្បាស់លាស់នោះឡើយ ដូច្នេះវាមិនប្រាកដថាតើព័ត៌មានដែលគេប្រមូលសម្រាប់

[២៥៧] អង្គការលីកាដូ ខេត្តកំពត ២៣/៨/២០១២

[២៥៨] អង្គការលីកាដូ ខេត្តកំពត ២៣/៨/២០១២

[២៥៩] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ១៨៩

[២៦០] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ទំព័រ. ១៤៩-១៥១

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឆ្លុះបញ្ចាំងពីទស្សនៈរបស់ស្ត្រី និងបុរស ដែរឬទេ។

## ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន

សមាជិកសហគន៍ជាច្រើនទទួលបានព័ត៌មានតិចតួច ហើយគេបានអញ្ជើញអ្នកភូមិតិចតួចប៉ុណ្ណោះ អោយចូលរួមក្នុងការប្រជុំផ្តល់យោបល់ ឬលើកជាសំណួរដែលទាក់ទងទៅនឹងគម្រោងទំនប់ រីឯអាជ្ញាធរតាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិមានឱកាសចូលរួមច្រើនជាង ឬយ៉ាងហោចណាស់ត្រូវគេជូនដំណឹងអោយដឹង។ ឧទាហរណ៍ មេឃុំម៉ាក់ប្រាងបានចាំថាមានការប្រជុំបួនទៅប្រាំលើក ហើយការប្រជុំចំនួនបីមានក្រុមហ៊ុនសាវ៉ាក់បានចូលរួម និងការប្រជុំចំនួនមួយ ឬពីរ ផ្សេងទៀតជាការប្រជុំរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការទូទាត់សំណង។[២៦១] ប៉ុន្តែ អាជ្ញាធរមូលដ្ឋាននៅសហគមន៍រងគ្រោះមិនសូវបានទទួលព័ត៌មាន អំពីវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានឡើយ។ ទោះបីជាអាចមានការព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនស៊ីណូហៃដ្រូក៏ដោយ យោងតាមមេឃុំម៉ាក់ប្រាងអាជ្ញាធរមូលដ្ឋានមិនបានជាប់ពាក់ព័ន្ធនឹងការពិភាក្សានេះឡើយ។ នៅឃុំអណ្តូងខ្មែរដែលអ្នកភូមិនៅភូមិអូរតូច និងភូមិថ្មីខាងជើង ពឹងផ្អែកលើមុខរបរកាប់ឫស្សី មេឃុំដែលបានធ្វើការក្នុងតំណែងមេឃុំយូរឆ្នាំមកហើយនោះ មិនធ្លាប់ទទួលបានព័ត៌មានទាក់ទងនឹងក្រុមហ៊ុនស៊ីណូហៃដ្រូឡើយ។ ដូចគ្នានេះដែរ អនុប្រធានភូមិថ្មីខាងជើងក៏មិនធ្លាប់ឮព័ត៌មានពីការប្រជុំណាមួយ ដែលរៀបចំឡើងដោយក្រុមហ៊ុនស៊ីណូហៃដ្រូ ឬរាជរដ្ឋាភិបាលកម្ពុជា ដើម្បីពន្យល់ប្រជាជនអំពីគម្រោងទំនប់វារីអគ្គិសនីកំចាយដែរ។ គេមិនបានរៀបចំការប្រជុំជាសាធារណៈណាមួយដើម្បីផ្តល់ព័ត៌មានដល់អ្នកភូមិ អំពីទំនប់វារីអគ្គិសនីកំចាយឡើយ។[២៦២]

យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម កិច្ចប្រជុំពិគ្រោះយោបល់មួយដែលដឹកនាំដោយក្រុមហ៊ុនសាវ៉ាក់ ឬក្រុមហ៊ុនស៊ីណូហៃដ្រូ

---

[២៦១] មេឃុំម៉ាក់ប្រាង ១៥/៨-២០១២

[២៦២] មេឃុំម៉ាក់ប្រាង១៥/៨-២០១២; មេឃុំអណ្តូងខ្មែរ២០/០៨-២០១២; អនុប្រធានភូមិថ្មីខាងជើង ២៧/៨/២០១២

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ នៅខេត្តកំពត មានគោលបំណងដើម្បីផ្តល់ឱកាសដល់អាជ្ញាធរ ស្ថានប័នពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន បញ្ចេញនូវកង្វល់របស់ពួកគាត់។ ប៉ុន្តែ ក្នុងចំណោមអ្នកចូលរួមចំនួន ៣៩នាក់ មានតែអ្នកចូលរួមចំនួន២នាក់ប៉ុណ្ណោះ មកពីអង្គការសង្គមស៊ីវិល (សម្ព័ន្ធទន្លេកម្ពុជា និងអង្គការអាដហុក) ហើយមិនមានអ្នកចូលរួមណាម្នាក់ជាសមាជិកសហគមន៍ឡើយ។ អ្នកចូលរួមស្ទើរតែទាំងអស់ជាអាជ្ញាធរចាប់ពីថ្នាក់ខេត្តដល់ថ្នាក់ភូមិ។[២៦៣] បញ្ជីឈ្មោះអ្នកចូលរួមនេះបង្ហាញពីចន្លោះប្រហោងរវាងទស្សនៈរបស់រាជរដ្ឋាភិបាល និងសង្គមស៊ីវិល ទៅលើគំនិតនៃការចូលរួម។ វាមានសារៈសំខាន់ណាស់ដែលរាជរដ្ឋាភិបាលកម្ពុជា បើកឱកាសអោយទូលាយ និងរាប់បញ្ចូលសហគមន៍រងគ្រោះក្នុងដំណើរការមួយប្រកបដោយការចូលរួមពីភាគីពាក់ព័ន្ធទាំងឡាយ។

### ១.៤ លទ្ធផលនៃកង្វះព័ត៌មាន និងការចូលរួម

ការទទួលបានព័ត៌មានមិនគ្រប់គ្រាន់ និងការចូលរួមដ៏មានកម្រិតធ្វើអោយសមាជិកសហគមន៍មូលដ្ឋាន មានភាពមិនច្បាស់លាស់អំពីឱកាសនៃការចិញ្ចឹមជីវិតរបស់ពួកគាត់នៅពេលអនាគត និងធ្វើអោយពួកគាត់មិនអាចត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរអោយទាន់ពេលវេលា។ ការព្រួយបារម្ភអំពីការបាក់ទំនប់នឹងត្រូវកាត់បន្ថយបានច្រើន ប្រសិនបើគេបានប្រាប់ប្រជាជនអោយដឹងអំពីតួនាទីរបស់ទំនប់ និងយន្តការសុវត្ថិភាពរបស់វា។ ពាក្យចចាមអារ៉ាមជាច្រើនបានសាយភាយនៅក្នុងសហគមន៍ជាច្រើន និងនៅរមណីយដ្ឋានទឹកឈូ។ ប្រជាជនជាច្រើនបានឮនៅមុនការបញ្ចប់ការសាងសង់ទំនប់វារីអគ្គិសនីកំចាយថា ប្រជាជននៅក្នុងតំបន់នឹងទទួលបានអគ្គិសនីពីទំនប់ប្រើប្រាស់ដោយមិនគិតថ្លៃ។ ពាក្យចចាមអារ៉ាមមិនពិតបែបនេះនឹងមិនកើតមានឡើយ ប្រសិនបើប្រជាជនអាចទទួលបានព័ត៌មានអំពីគម្រោង។ ដំណើរការនៃការទូទាត់សំណងមានភាពយឺតយ៉ាវយ៉ាងខ្លាំងពេក ហើយវាមិនមានតម្លាភាពទៀតផងសម្រាប់គ្រួសារមួយចំនួន ដែលរងផលប៉ះពាល់ដោយការសាង

---

[២៦៣] របាយការណ៍ ESIA ខែមេសា ឆ្នាំ២០១១, ឧបសម្ព័ន្ធ៦ បញ្ជីអ្នកចូលរួម

សង់បណ្តាញចែកចាយចរន្ត។ ស្ថានភាពនេះយ៉ាងហោចណាស់មួយភាគអាចបណ្តាលមកពីកង្វះព័ត៌មាន និងយន្តការដោះស្រាយបណ្តឹងសារទុក្ខ។

សំខាន់បំផុតនោះ នៅពេលគ្មានវិធានការសម្រាប់ធានាបាននូវការទាក់ទងព័ត៌មានគ្នាទៅវិញទៅមក កង្វល់របស់សមាជិកសហគមន៍មិនអាចឮដល់ក្រុមហ៊ុនស៊ីណូហៃដ្រូ ឬរាជរដ្ឋាភិបាលកម្ពុជា ដោយងាយស្រួលឡើយ។ នៅពេលមិនបានដឹងពីកង្វល់របស់សហគមន៍ ក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាមិនស្ថិតនៅក្នុងជំហរមួយ ដែលអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍រងគ្រោះបានឡើយ។ ស្ត្រីដែលប្រកបរបរលក់ដូរម្នាក់មកពីភូមិស្ទឹងប្រាំពីរដែលជាទូទៅពេញចិត្តនឹងទំនប់វារីអគ្គិសនីកំចាយដោយសារវាបានទប់ស្កាត់ទឹកជំនន់ បានប្រាប់អោយដឹងអំពីផលប៉ះពាល់ដ៏សំខាន់ដែលសហគមន៍មានភាពមិនច្បាស់លាស់ ទាក់ទងនឹងទំនប់វារីអគ្គិសនីកំចាយ និងសុវត្ថិភាពរបស់វា *«តម្លៃអគ្គិសនីថោកជាងមុនគឺវាល្អហើយ ប៉ុន្តែវាមិនអាចប្រៀបធៀបបានឡើយបើសិនជាទំនប់បាក់ ដោយសារយើងទាំងអស់គ្នានឹងត្រូវស្លាប់ដោយសារទំនប់វារីអគ្គិសនីកំចាយ។»*[២៦៤]

តាមរយៈការសម្ភាសជាច្រើន វាច្បាស់ណាស់ថាសហគមន៍មូលដ្ឋាន រួមទាំងអាជ្ញាធរមូលដ្ឋានមិនដឹងថា តើក្រុមហ៊ុនស៊ីណូហៃដ្រូនឹងគ្រប់គ្រងការបញ្ចេញទឹកពីទំនប់ដូចម្តេចឡើយ។ កត្តានេះធ្វើអោយមានភាពមិនច្បាស់លាស់សម្រាប់អ្នកភូមិថាតើនឹងមានទឹកដើម្បីទាក់ទាញភ្ញៀវទេសចរដែរ ឬទេ ហើយការបញ្ចេញទឹកពីទំនប់នៅរដូវប្រាំងនឹងធានាអោយមានទឹកសាបក្នុងព្រែកនៅខ្សែទឹកខាងក្រោម ឆ្ងាយជាងមុនដែរ ឬទេ។

## ១.៥ ផលប៉ះពាល់ចំពោះអ្នកប្រកបរបរកាប់ឫស្សី

មន្ត្រីរាជរដ្ឋាភិបាលមួយចំនួនបាននិយាយពីភាពវិជ្ជមាន នៃការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ ឧទាហរណ៍ មន្ត្រីជាច្រើនបាននាំគ្នាពិពណ៌នាថាផ្លូវថ្មីបាននាំមកនូវភាពងាយស្រួលជាងមុនដល់ប្រជាជនដែលធ្វើដំណើរទៅកាប់ឫស្សី។ ទោះជាយ៉ាងណាក៏ដោយ ពួកគេមិនបានគិតដល់ ឬលើកឡើងពីពេលវេលា និងការ

[២៦៤] ស្ត្រីប្រកបរបរលក់ដូរ មកពីភូមិស្ទឹងប្រាំពីរ ១៦/៨/២០១២

ខិតខំប្រឹងប្រែងច្រើនជាងមុនដែលអ្នកប្រកបរបរកាប់ឫស្សីត្រូវឡើងជម្រាលភ្នំ ឬឆ្លងអាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយទេ។ មន្ត្រីខ្លះថែមទាំងបានផ្តល់យោបល់ថា សព្វថ្ងៃជីវភាពរស់នៅរបស់អ្នកប្រកបរបរកាប់ឫស្សីទាំងនោះ កាន់តែងាយស្រួល ដោយសារពួកគេអាចបណ្តែតឫស្សីតាមទឹកក្នុងអាងស្តុកទឹក។ ក៏ប៉ុន្តែ មន្ត្រីទាំងនោះមិនបានលើកឡើងពីពេលវេលាបន្ថែមសម្រាប់បណ្តែតឫស្សី ឬការដែលអ្នកប្រកបរបរកាប់ឫស្សីត្រូវដឹកជញ្ជូនឫស្សីពីអាងស្តុកទឹក ត្រឡប់មកភូមិរបស់ពួកគេវិញនោះទេ។[២៦៥] តាមពិតប្រជាជនធ្លាប់ចូលទៅកាប់ឫស្សី និងប្រមូលអនុផលព្រៃឈើដទៃទៀតនៅជិតផ្ទះរបស់ពួកគាត់បំផុត នៅមុនពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ លើសពីនេះទៀត រយៈពេលធ្វើដំណើរជាទូទៅគឺឆាប់ជាងនេះខ្លាំងណាស់ ហើយការងារវិញក៏មិនសូវពិបាកដែរ។ ការយល់ឃើញរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូ គឺថាអត្ថប្រយោជន៍រួមសម្រាប់ប្រទេសមានទំហំលើសលុបលើ «*ផលប៉ះពាល់បន្តិចបន្តួច*» ឧទាហរណ៍ បញ្ហាដែលអ្នកប្រមូលអនុផលព្រៃឈើបានជួបប្រទះ។[២៦៦] ទោះបីជាយ៉ាងណាក៏ដោយអត្ថប្រយោជន៍ទាំងអស់នេះ បានបង្ហាញពីការមិនយកចិត្តទុកដាក់ដល់សហគមន៍រងគ្រោះ។ ការសន្មត់ដែលគេលើកឡើងថា ជីវភាពរស់នៅរបស់អ្នកប្រកបរបរកាប់ឫស្សីឥឡូវប្រសើរឡើងជាងមុន ដោយមិនយកចិត្តទុកដាក់អំពីកត្តាប្រឈមរបស់ប្រជាជនរងគ្រោះនោះ គឺដោយសារការខ្វះចំណេះដឹងអំពីស្ថានភាពជាក់ស្តែង ដូច្នេះការបង្កើនការចូលរួមរបស់ប្រជាជនមូលដ្ឋានច្រើនអាចនឹងជួយអោយរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនស៊ីណូហៃដ្រូបានដឹងអំពីផលលំបាករបស់ប្រជាជនទាំងនេះ។

[២៦៥] មេឃុំអណ្តូងខ្មែរ ២០/០៨-២០១២; នាយកដ្ឋានឧទ្យានជាតិ ០៩/១០-២០១២; ប្រធានភូមិអូរតូច ១៨/៨/២០១២

[២៦៦] ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្តកំពត ២៩/៨/២០១២

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## សេចក្តីសន្និដ្ឋាន

ផលប្រយោជន៍ផ្សេងៗ និងថាមពលអគ្គិសនីដែលផលិតបានពីទំនប់វារីអគ្គិសនីកំចាយ បានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ប្រជាជន និងឧស្សាហកម្មដែលនៅឆ្ងាយពីទំនប់។ ប៉ុន្តែនៅតំបន់មូលដ្ឋានវិញ ការសាងសង់ទំនប់វារីអគ្គិសនីបានធ្វើអោយបាត់បង់ព្រៃឈើ និងកែប្រែលក្ខណៈធម្មជាតិរបស់ព្រែកនៅភាគអាគ្នេយ៍នៃឧទ្យានជាតិបូកគោ។ ផលប៉ះពាល់ចំពោះសេដ្ឋកិច្ចសង្គមខ្លាំងបំផុត គឺទាក់ទងនឹងការបាត់បង់ប្រាក់ចំណូល ដែលគ្មានសំណងវិញពីការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរនៅរមណីយដ្ឋានទឹកឈូ និងពីការប្រមូលអនុផលពីព្រៃឫស្សីដ៏ច្រើនក្រៃលែង នៅទីតាំងអាងស្តុកទឹកដែលត្រូវទឹកជន់លិចបច្ចុប្បន្ន និងជាតំបន់ដែលប្រើប្រាស់របស់សហគមន៍នៅមុនការសាងសង់ទំនប់។ ផលប៉ះពាល់អវិជ្ជមានដទៃទៀត រួមមានករណីសំណងមិនទាន់ទូទាត់ជូនដល់ប្រជាជនយ៉ាងហោចណាស់ចំនួន១០គ្រួសារ ដែលរងផលប៉ះពាល់ដោយសារការសាងសង់បណ្តាញបញ្ជូនចរន្ត ព្រមទាំងការធ្លាក់ចុះយ៉ាងខ្លាំងនូវផលនេសាទជាលក្ខណៈគ្រួសារ នៅខ្សែទឹកខាងក្រោមទំនប់កំចាយ។ ការយកដើមឈើចេញពីអាងស្តុកទឹកមិនអស់ នៅមុនពេលបញ្ចូលទឹកក្នុងអាងបាននាំមកនូវអត្ថប្រយោជន៍បណ្តោះអាសន្ន ដល់គ្រួសារមួយចំនួនដែលបានចាប់យកមុខរបរកាប់អុស និងលក់អុសជាមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគាត់។

ដោយសារការធ្លាក់ចុះយ៉ាងខ្លាំងនូវចំនួនភ្ញៀវទេសចរ អ្នកដែលមានមុខរបររកស៊ីនៅរមណីយដ្ឋានទឹកឈូ សព្វថ្ងៃអាចរកប្រាក់ចំណូលបានជាមធ្យមត្រឹមតែ ២៨% នៃប្រាក់ចំណូលដែលពួកគាត់ធ្លាប់ទទួលបាននៅមុនការសាងសង់ទំនប់។ ទន្ទឹមគ្នានេះដែរ គ្រួសារដែលប្រកបរបរកាប់ឫស្សីយល់ឃើញថាប្រាក់ចំណូលជាមធ្យមរបស់ពួកគាត់បានធ្លាក់ចុះយ៉ាងច្រើន។ នៅមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយ ប្រជាជនចំនួន ៤៧% នៃគ្រួសារដែលប្រកបរបរកាប់ឫស្សីមានប្រាក់ចំណូលលើសពី២០.០០០រៀល ក្នុង១ថ្ងៃ ក៏ប៉ុន្តែចំនួននេះបានធ្លាក់ចុះមកត្រឹម ២១% ប៉ុណ្ណោះ។ សព្វថ្ងៃ គ្រួសារដែលប្រកបរបរកាប់ឫស្សីភាគច្រើន (៧៩%) មានប្រាក់

ចំណូលរវាង១០.០០០រៀល ទៅ២០.០០០រៀល ក្នុង១ថ្ងៃ។ ទោះបីជាមានការខូចប្រយោជន៍ដល់សមាជិកសហាគមន៍រងគ្រោះក៏ដោយ ក៏មិនមានគម្រោងសំខាន់ណាមួយត្រូវបានអនុវត្តដោយក្រុមហ៊ុនស៊ីណូហៃដ្រូ ឬរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ចំពោះការចិញ្ចឹមជីវិតរបស់សមាជិកសហាគមន៍ទាំងនេះឡើយ។ ការសិក្សាបានរកឃើញថា ស្ត្រីក្នុងគ្រួសារប្រកបរបរកាប់ឫស្សី ឬគ្រួសារប្រកបរបរប្រមូលអនុផលព្រៃឈើ បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទំរង់នៃការប្រមូលផលរបស់ពួកគាត់ (ប្តូរពីអ្នកប្រមូលផលទៅជាអ្នកមិនប្រមូលផលព្រៃឈើ) ហើយស្ត្រីដែលពឹងផ្អែកលើវិស័យទេសចរណ៍ជាមុខរបរ បានជួបប្រទះការធ្លាក់ចុះនូវប្រាក់ចំណូល និងប្រាក់សម្រាប់ចំណាយរបស់ពួកគាត់។ លើសពីនេះ ស្ត្រីជាច្រើនប្រឈមនឹងបន្ទុកការងារបន្ថែម ដោយសារបុរសកាន់តែច្រើនត្រូវស្នាក់នៅក្នុងព្រៃដើម្បីកាប់ឫស្សី។

នៅក្នុងសហាគមន៍មួយចំនួន ក្រុមគ្រួសារជាច្រើននៅមិនទាន់មានអគ្គិសនីប្រើប្រាស់នៅឡើយ។ ក៏ប៉ុន្តែ ក្រុមគ្រួសារដែលបានភ្ជាប់បណ្តាញអគ្គិសនីរដ្ឋរួចហើយបានអោយដឹងថា តម្លៃអគ្គីសនីធ្លាក់ចុះប្រមាណជា១៦% ទៅ២៣% ពោលគឺ៩២០រៀល/គីឡូវ៉ាត់ម៉ោង។ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាផ្នែកមួយនៃគម្រោងទំនប់វារីអគ្គិសនីកំចាយ ប៉ុន្តែផ្លូវថ្នល់មិនទាន់ឆ្លើយតបទៅនឹងការចង់បានរបស់សហាគមន៍មូលដ្ឋានដែលរំពឹងថាក្រុមហ៊ុនស៊ីណូហៃដ្រូ នឹងជួសជុលផ្លូវដែលមានសភាពទ្រុឌទ្រោមទាំងនោះនៅឡើយ។ សំណង់បណ្តោះអាសន្នសម្រាប់ប្រើប្រាស់នៅកំឡុងពេលការសាងសង់ទំនប់ ត្រូវគេបន្សល់ទុកខ្លះនៅតំបន់ក្បែរទំនប់វារីអគ្គិសនីដែលធ្វើអោយខូចសោភ័ណភាពនៅទីកន្លែងនោះ។

គោលបំណងនៃការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គឺដើម្បីអោយមានព័ត៌មានច្បាស់លាស់ក្នុងការសម្រេចចិត្តចុងក្រោយ និងការអនុម័តថាអោយមានគម្រោងអភិវឌ្ឍន៍កើតឡើង ឬអត់។ ប៉ុន្តែបើឆ្លុះបញ្ចាំងពីគម្រោងតំបន់វារីអគ្គិសនីកំចាយនេះវិញ គេបានអនុម័តយល់ព្រមលើគម្រោងនេះតាំងពីមុនពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបានបញ្ចប់ និងឯកភាពទៅទៀត។ រាជរដ្ឋាភិបាលកម្ពុជាមិនបានបង្កើតយន្តការការពារគ្រប់គ្រាន់សម្រាប់កាត់

បន្ថយផលប៉ះពាល់នៃការសាងសង់ទំនប់ឡើយ។ ដូច្នេះបានជាគម្រោងនេះមិនបានស្របតាមមូលដ្ឋានច្បាប់របស់ខ្លួន។ ការសម្អាតដើមឈើ និងរូបធាតុសរីរាង្គនៅក្នុងអាងស្តុកទឹកមិនអស់បង្ហាញថា ការបំភាយឧស្ម័យផ្ទះកញ្ចក់ដែលគេមិនចង់បាននោះអាចនឹងបន្តមានជាច្រើនទសវត្សទៅមុខទៀត ហើយនឹងចូលរួមចំណែកធ្វើអោយមានការប្រែប្រួលអាកាសធាតុ។ ប្រសិនបើក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា ប្រកាន់ខ្ជាប់នូវរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់នៃផែនការគ្រប់គ្រងបរិស្ថាននោះ ស្ថានភាពនេះនឹងមិនអាចកើតឡើងឡើយ។ ស្របគ្នានេះដែរ ការធ្លាក់ចុះនៃប្រាក់ចំណូល និងការថយចុះនៃការចិញ្ចឹមជីវិតរបស់ប្រជាជនរាប់រយគ្រួសារនៅសហាគមន៍រងគ្រោះ ដោយរាប់បញ្ចូលទាំងភាពមិនត្រឹមត្រូវដែលគួរអោយរំខាន ឬការពន្យាពេលក្នុងករណីទូទាត់សំណង គឺស្ថិតនៅក្នុងភាពមិនស្របគ្នាជាមួយនឹងគោលបំណងនៃកំណើនសេដ្ឋកិច្ច ដោយមានការគាំទ្រដល់ជនក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

ការយល់ខុសជាទូទៅ ក្នុងចំណោមមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាព្រមទាំងក្រុមហ៊ុនស៊ីណូហៃដ្រូ គឺថាការចិញ្ចឹមជីវិតរបស់ប្រជាជននៅមូលដ្ឋានមានភាពប្រសើរឡើងដោយសារការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ មតិជារួមគឺថាអ្នកប្រកបរបរកាប់ឫស្សី ឥឡូវអាចចូលទៅរកធនធានដែលពួកគាត់អាស្រ័យសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់ប្រសើរជាងមុន។ យ៉ាងណាមិញ គំនិតបែបនេះគឺវាផ្ទុយទាំងស្រុងទៅនឹងបទពិសោធន៍របស់ប្រជាជន ដែលចិញ្ចឹមជីវិតដោយពឹងផ្អែកលើឫស្សី និងអនុផលព្រៃឈើផ្សេងៗទៀត។ ពួកគាត់បានអះអាងរួមគ្នាថា ពួកគាត់បានប្រឈមការលំបាកក្នុងការស្វែងរក និងប្រមូលឫស្សី និងអនុផលព្រៃឈើផ្សេងៗទៀតជាងមុនយ៉ាងខ្លាំងបន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយ។ គម្រោងទំនប់វារីអគ្គិសនីនេះមិនបានប្រព្រឹត្តទៅតាមស្តង់ដារបរិស្ថាន និងសង្គមដែលគេរំពឹងថានឹងបានពីក្រុមហ៊ុនអភិវឌ្ឍន៍មួយ ក្នុងចំណោមក្រុមហ៊ុនអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីនាំមុខគេរបស់ពិភពលោកឡើយ។ កំហុសឆ្គងធ្ងន់ធ្ងរជាច្រើន ដូចជាផលប៉ះពាល់អវិជ្ជមានចំពោះការចិញ្ចឹមជីវិតនៅមូលដ្ឋាននិងកង្វះការចូលរួមដែលគេបានដឹងជាទូទៅបានចង្អុលបង្ហាញពីលក្ខណៈអភិវឌ្ឍន៍របស់ទំនប់កំចាយ។ សហាគមន៍

ដែលរងគ្រោះដោយសារផលប៉ះពាល់ទាំងនេះទទួលបានការគាំទ្រតិចតួចពីអាជ្ញាធរមូលដ្ឋានដែលទំនងជាត្រូវគាបសង្កត់ដោយមន្ត្រីថ្នាក់លើរបស់ពួកគាត់ ឬដោយក្រុមហ៊ុនស៊ីណូហៃដ្រូដែលមិនសូវខ្វល់ខ្វាយកែតម្រូវស្ថានការណ៍នេះឡើយ។

ទោះបីជា មានការយកចិត្តទុកដាក់លើវិស័យកសិកម្មដែលគេបង្ហាញនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមក៏ដោយ កន្លងទៅមិនមានគម្រោងណាមួយធ្វើឡើងដើម្បីអភិវឌ្ឍន៍ប្រព័ន្ធទឹកស្រោចស្រពឡើយ។ ទោះជាយ៉ាងនេះក្តី កំណើនទឹកសាបនៅរដូវប្រាំងដែលគេរំពឹងទុកនោះអាចជួយបង្កើនផលិតផលកសិកម្មពីដើមឈើហូបផ្លែ។ លើសពីនេះ ការរំពឹងទុកចំពោះការកាត់បន្ថយទឹកជំនន់ និងមហន្តរាយរបស់វានឹងធ្វើអោយមានការរីកលូតលាស់នៃការដាំដុះដំណាំនៅកន្លែងថ្មីៗថែមទៀត។ ប៉ុន្តែវាអាចបង្អាក់ផលិតផលកសិកម្មផ្សេងទៀតដោយសារការថយចុះនៃការបែងចែកជីវជាតិពីល្បាប់ ដែលទឹកជំនន់ធ្លាប់នាំមកកាន់ដីស្រែមួយចំនួននៅផ្នែកខាងក្រោមនៃទំនប់។ អវត្តមាននៃទឹកជំនន់ធំៗក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយបានធ្វើអោយមានការសាទរចំពោះទំនប់វារីអគ្គិសនីកំចាយ។ យ៉ាងណាមិញ វាឆាប់ពេកក្នុងការសន្មត់ថាទំនប់វារីអគ្គិសនីកំចាយ មានលទ្ធភាពទប់ស្កាត់ទឹកជំនន់ ដោយបរិមាណទឹកភ្លៀងនៅក្នុងតំបន់ក្នុងរយៈពេលពីរឆ្នាំចុងក្រោយមានកម្រិតទាបជាងកម្រិតដែលបង្ករអោយមានទឹកជំនន់នៅឆ្នាំមុនៗ។

ប្រសិនបើ លំហូរទឹកនៅរដូវប្រាំងកើនឡើង និងមានភាពទៀងទាត់ត្រូវបានរក្សាដោយអ្នកប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយ នោះចំណាប់អារម្មណ៍ជារួមគឺថាវានឹងផ្តល់ផលប្រយោជន៍បន្តិចបន្តួចដល់ផលិតផលកសិកម្ម នៅក្រោយការសាងសង់ទំនប់កំចាយ។ ប៉ុន្តែ ការព្យាករបម្រែបម្រួលជលសាស្ត្រ និងគុណភាពទឹកដែលតម្រូវអោយមាន ហាក់ដូចជាមិនត្រូវបានគេអើពើឡើយ។ ស្ថានភាពនេះបានកម្រិតលទ្ធភាព ដើម្បីទាញយកផលប្រយោជន៍ពីការផ្លាស់ប្តូរវិជ្ជមាននៃរបបទឹកដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរអវិជ្ជមានដែលអាចនឹងកើតមាន។

ការធ្វើអោយខូចគុណភាពទឹក និងការដែលមានទឹកតិចតួចនៅក្នុងព្រែកគឺជាមូលហេតុដ៏សំខាន់នាំអោយថយចុះនូវចំនួនត្រីវទេសចរ នៅរមណីយដ្ឋានទឹកឈូ

នៅកំឡុងពេលសាងសង់ទំនប់ (ថយចុះពី២៧៧.៩៧៧នាក់ នៅឆ្នាំ២០០៦ ទៅ ៦៥.២៣២នាក់ នៅឆ្នាំ២០១១)។ ក្រោយការចាប់ផ្តើមប្រតិបត្តិការទំនប់វារីអគ្គិសនីកំចាយអស់រយៈពេលជាង៩ខែ មានគ្រួសារជាច្រើននៅបន្តបាត់បង់ប្រាក់ចំណូលដោយសារការថយចុះនៃចំនួនភ្ញៀវទេសចរនៅឡើយ។ ក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា គួរកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់សហគមន៍មូលដ្ឋាន ដោយការអនុវត្តរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដែលគេបានលើកឡើងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឬផែនការគ្រប់គ្រងបរិស្ថាន។ ស្ពានយោលដែលបានបាក់រលំនៅឆ្នាំ២០០៩ កំឡុងពេលការសាងសង់ទំនប់វារីអគ្គិសនីកំចាយ គួរតែត្រូវគេសាងសង់ឡើងវិញនៅរមណីយដ្ឋានទឹកឈូ ហើយផ្លូវប្រវែង ៣ ទៅ ៩គីឡូម៉ែត្រ ដែលអាចនឹងធ្វើអោយអ្នកប្រកបរបរកាប់ឫស្សីអាចចូលទៅដល់តំបន់ព្រៃឫស្សីដែលនៅសេសសល់ប្រសើរជាងមុន ក៏គួរតែត្រូវគេសាងសង់ដែរ។ ក៏ប៉ុន្តែ គេមិនបានបង្កើតវិធានការកាត់បន្ថយហេតុប៉ះពាល់ណាមួយនៅឡើយទេ។

កង្វះការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ធ្វើអោយសហគមន៍ជាច្រើនស្ថិតក្នុងភាពស្រពេចស្រពិល ហើយបន្សល់ទុកនូវក្តីសង្ឃឹមបន្តិចបន្តួចថានឹងមានកិច្ចសហការនៅពេលអនាគតរវាងក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់កិច្ចការពារអោយបានគ្រប់គ្រាន់ ដើម្បីគេចអោយផុតពីឥទ្ធិពលអាក្រក់លើការចិញ្ចឹមជីវិតរបស់សហគមន៍រងគ្រោះ។ ក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជា មិនបានអនុវត្តការតាមដានអោយបានច្បាស់លាស់អំពីការប្រែប្រួលគុណភាពទឹក ប្រព័ន្ធជលសាស្ត្រកម្រិតទឹកប្រៃ និងធនធានជលផលនោះទេ។ កត្តានេះធ្វើអោយមានការលំបាកដល់ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់អោយបានទាន់ពេលវេលា ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ប្តូរទាំងនេះ។ លើសពីនេះ ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានមិនបានពេញលេញ បានកាត់បន្ថយឱកាសក្នុងការទទួលបានបទពិសោធន៍ល្អៗពីគម្រោងទំនប់វារីអគ្គិសនីកំចាយ។ ផ្ទុយទៅវិញ គម្រោងនេះបង្ហាញពីផលវិបាកមួយចំនួនដែលអ្នកអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកម្ពុជា គួរយកចិត្តទុកដាក់សម្រាប់គម្រោងទំនប់វារីអគ្គិសនីនៅពេលអនាគត។

ដំណើរការអនុវត្តគម្រោងបង្ហាញថា គេត្រូវកែលំអភាពផ្ទុយគ្នារវាងវិធានការតម្រូវដោយច្បាប់ និងការអនុវត្តគម្រោងវារីអគ្គិសនីជាក់ស្តែង។ ស្ថានភាពនេះទាមទារអោយមានការពិនិត្យឡើងវិញនូវរាល់គម្រោងប្រភេទនេះ នៅក្នុងប្រទេសកម្ពុជា។ ដំណាក់កាលទី១ គឺរាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើការតាមដានអោយបានហ្មត់ចត់លើផែនការគ្រប់គ្រងបរិស្ថាន និងវិធានការកាត់បន្ថយហេតុប៉ះពាល់ផ្សេងៗទៀតដែលគេបានសន្យា ដែលមានចែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងទំនប់វារីអគ្គិសនីដែលគេកំពុងធ្វើផែនការឬកំពុងអនុវត្ត។ ដោយគិតពីទំហំនៃការខិតខំប្រឹងប្រែងជាច្រើនបែបនេះ រាជរដ្ឋាភិបាលកម្ពុជាអាចទទួលបានផលប្រយោជន៍ តាមរយៈការផ្សព្វផ្សាយរបាយការណ៍វាយតម្លៃទាំងនោះ និងផ្តល់ឱកាសអោយអ្នកសិក្សា សង្គមស៊ីវិល និងអ្នកជំនាញដទៃទៀត ជួយធ្វើការវាយតម្លៃចំពោះហេតុប៉ះពាល់នានា ហើយផ្តល់ជាមធ្យោបាយល្អៗដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមានអោយស្ថិតនៅក្នុងកម្រិតតិចតួចបំផុត សម្រាប់គម្រោងបែបនេះ។

ដើម្បីធ្វើអោយប្រសើរឡើងនូវកិត្តិស័ព្ទ នៃគម្រោងទំនប់វារីអគ្គិសនីខ្នាតធំដំបូងគេបង្អស់នៅប្រទេសកម្ពុជាមួយនេះ និងដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមាន ដែលសមាជិកសហគន៍មូលដ្ឋានកំពុងប្រឈម គេត្រូវចាត់វិធានការបន្ទាន់មួយចំនួន។ សកម្មភាពដ៏សមរម្យមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា គឺត្រូវសម្របសម្រួលកិច្ចពិគ្រោះយោបល់នៅថ្នាក់ភូមិនៅក្នុងឃុំទាំងឡាយដែលរងគ្រោះដោយសារទំនប់វារីអគ្គិសនីអោយបានលឿនតាមដែលអាចធ្វើទៅបាន ដើម្បីស្វែងយល់ថា តើវិធានការកាត់បន្ថយហេតុប៉ះពាល់ណាខ្លះនឹងផ្តល់ជាប្រយោជន៍ដល់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។

ការយកចិត្តទុកដាក់តិចតួចរបស់ក្រុមហ៊ុនស៊ីណូហៃដ្រូ ក្នុងការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលគេមានផែនការរួចហើយនោះ បង្ហាញថាកិច្ចការពារបរិស្ថាន និងសង្គមមិនមែនជាអទិភាពសម្រាប់ក្រុមហ៊ុនស៊ីណូហៃដ្រូទេ។ ហេតុដូច្នេះ ស្ថានភាពបច្ចុប្បន្នទាមទារជាចាំបាច់អោយរាជរដ្ឋាភិបាលកម្ពុជាពង្រឹងការអនុវត្តច្បាប់អោយបានតឹងរ៉ឹង។ នេះអាចនិយាយបានថា ក្រុមហ៊ុនស៊ីណូហៃដ្រូ

ត្រូវតែទទួលខុសត្រូវចំពោះការងាររបស់ខ្លួន ហើយគួរតែធានាបានថាការអនុវត្តកិច្ចការពារបរិស្ថាន និងសង្គមសម្រាប់គម្រោងទំនប់វារីអគ្គិសនីកំចាយដែលគេមិនបានធ្វើអោយពេញលេញរហូតមកដល់បច្ចុប្បន្ន នឹងត្រូវកែតម្រូវក្នុងខែ និងឆ្នាំខាងមុខនេះ ដោយខានតែបាន។

ចំពោះការអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនីខ្នាតធំៗ នៅប្រទេសកម្ពុជា ដែលគេបានធ្វើផែនការរួច ឬកំពុងដាក់អោយសាងសង់ វាចាំបាច់ណាស់ដែលរាជរដ្ឋាភិបាលកម្ពុជាគួរតែចាត់វិធានការណ៍ និងប្តេជ្ញាចិត្តខ្ពស់ដើម្បីធ្វើអោយប្រសើរឡើងនូវការអនុវត្តរាល់គោលការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះគម្រោងទាំងនោះ។ គេត្រូវតែធ្វើអោយប្រសើរឡើងនូវកំណត់ហេតុដែលមិនល្អនៃការចូលរួមតិចតួច និងកង្វះគណនេយ្យភាព។ បើពុំនោះទេ សហគមន៍ដែលរងគ្រោះដោយសារគម្រោងទំនប់វារីអគ្គិសនី អាចនឹងមិនត្រូវគេយកចិត្តទុកដាក់សារជាថ្មីសម្រាប់គម្រោងជាច្រើនទៀតនៅពេលអនាគត ហើយវានឹងផ្តល់ផលអាក្រក់ជាច្រើនដែលកើតចេញពីលទ្ធផលនៃការអភិវឌ្ឍនៅប្រទេសកម្ពុជា។

## អនុសាសន៍

ដើម្បីចៀសឆ្ងាយពីកំហុសឆ្គងនានា ដែលប្រទេសដទៃមានក្នុងអតីតកាល ដូចជាការធ្វើការសម្រេចចិត្តលើការអភិវឌ្ឍថាមពលវារីអគ្គិសនី ដោយផ្អែកលើចំណេះដឹងមិនគ្រប់គ្រាន់អំពីទំនប់វារីអគ្គិសនី គេគួរធ្វើការសិក្សា និងពិចារណាអោយបានពេញលេញលើគម្រោងទំនប់វារីអគ្គិសនីលើកក្រោយៗ មុនពេលធ្វើការសម្រេចចិត្តលើគម្រោងថ្មី។ នៅពេលធ្វើផែនការ និងអភិវឌ្ឍន៍គម្រោងថាមពលវារីអគ្គិសនី គេគួរតែណែនាំយ៉ាងម៉ឺងម៉ាត់អោយធ្វើការសិក្សាលើអនុសាសន៍ដែលគណៈកម្មការពិភពលោក ស្តីពីទំនប់វារីអគ្គិសនីបានធ្វើឡើងនៅឆ្នាំ២០០០ ហើយគេត្រូវកែតម្រូវគម្រោងដោយអនុលោមតាមអនុសាសន៍ទាំងនោះ។ អនុសាសន៍របស់គណៈកម្មការពិភពលោក ស្តីពីទំនប់វារីអគ្គិសនី គឺផ្អែកទៅលើការសិក្សាយ៉ាងទូលំទូលាយលើទំនប់វារីអគ្គិសនីជាច្រើនពាសពេញពិភពលោក ដោយធ្វើការពិនិត្យលើឥទ្ធិពលវិជ្ជមាន និងអវិជ្ជមាននៃការសាងសង់ទំនប់វារីអគ្គិសនីកាត់ទន្លេ។ បន្ថែម

លើអនុសាសន៍របស់គណៈកម្មការពិភពលោក ស្តីពីទំនប់វារីអគ្គិសនី និងផ្អែកលើលទ្ធផលនៃការសិក្សានេះ អនុសាសន៍ណែនាំជាក់លាក់មួយចំនួនត្រូវគេផ្តល់ជូន។ ដំបូងបង្អស់គេបង្ហាញពីអនុសាសន៍ទូទៅ សម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅប្រទេសកម្ពុជាបន្ទាប់មកគឺ អនុសាសន៍ជាក់លាក់ស្តីពីគម្រោងទំនប់វារីអគ្គិសនីកំចាយ។

### ❖ អនុសាសន៍សម្រាប់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅកម្ពុជា

### អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

ដើម្បីពិនិត្យសេចក្តីត្រូវការក្នុងការពង្រឹងក្របខណ្ឌស្ថាប័ន សម្រាប់ជាដំណោះស្រាយដល់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងការអនុវត្តនូវវិធានការកាត់បន្ថយហេតុប៉ះពាល់នានា រាជរដ្ឋាភិបាលកម្ពុជាត្រូវៈ

- ពិនិត្យឡើងវិញរាល់នីតិវិធី និងគោលការណ៍ច្បាប់ដែលមានស្រាប់ទាំងផ្លូវការ និងមិនផ្លូវការដែលពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនីនៅកម្ពុជា។ គួរពង្រឹងក្របខណ្ឌច្បាប់សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងចាត់វិធានការដើម្បីធានាបាននូវការប្រព្រឹត្តតាមគោលការណ៍ច្បាប់នៅពេលអនាគត ដោយអ្នកអភិវឌ្ឍគម្រោង និងរាជរដ្ឋាភិបាលកម្ពុជាខ្លួនឯង។
- ធានាថាមានការកែសម្រួលឡើងវិញនូវក្របខណ្ឌ នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានបច្ចុប្បន្នដើម្បីអនុញ្ញាតអោយភាគីពាក់ព័ន្ធទាំងអស់មានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅមុនការធ្វើការសម្រេចចិត្តចុងក្រោយ។
- ពិនិត្យឡើងវិញនូវទំហំការងារ និងសមត្ថភាពបុគ្គលិកនៅនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាននាពេលបច្ចុប្បន្ន ក៏ដូចជាពិនិត្យឡើងវិញនូវរាល់ដំណើរការងារនៅក្នុងនាយកដ្ឋាននេះ។ ត្រូវពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមអោយបានហ្មត់ចត់ និងផ្តល់យោបល់ត្រឡប់មកវិញអោយទាន់ពេលវេលា។ ត្រូវតាមដាន និងពង្រឹងអោយបានហ្មត់ចត់ចំពោះការអនុវត្តកិច្ចព្រមព្រៀងរបស់គម្រោងទំនប់វារីអគ្គិសនីដោយតម្រូវអោយ

មានបុគ្គលិកដែលមានជំនាញច្បាស់លាស់ និងមានពេលវេលាគ្រប់គ្រាន់ក្នុងកម្រិតអាចទុកចិត្តបាន។ សមត្ថភាពស្ថាប័នទាំងមូលត្រូវពង្រឹងដោយរាប់បញ្ចូលទាំងការបង្កើនចំនួនបុគ្គលិកនៅក្នុងនាយកដ្ឋាននេះផងដែរ។

- លើកកម្ពស់វប្បធម៌នៃការវាយតម្លៃ និងការឆ្លុះបញ្ចាំងខ្លួនឯង ដើម្បីបង្កើនការរៀនសូត្របន្តពីការអភិវឌ្ឍថាមពលវារីអគ្គិសនី។ នីតិវិធីដែលសមស្របគួរតែបានបង្កើតឡើងដើម្បីធានាបាននូវចំនុចនេះ។
- បង្កើតគោលការណ៍ណែនាំសម្រាប់គម្រោងថាមពលវារីអគ្គិសនី ដោយផ្អែកលើអនុសាសន៍ណែនាំរបស់គណៈកម្មការពិភពលោក ស្តីពីទំនប់វារីអគ្គិសនី។ ចំណុចនេះនឹងមានប្រយោជន៍ចំពោះរាជរដ្ឋាភិបាលកម្ពុជា នៅពេលព្យាយាមគេចចេញអោយឆ្ងាយពីកំហុសឆ្គងនានាដែលគេរៀបរាប់ក្នុងការសិក្សានេះ។
- ធ្វើអោយប្រសើរឡើងនូវការតាមដានគម្រោងទំនប់វារីអគ្គិសនី ទាំងកំឡុងពេលសាងសង់ និងប្រតិបត្តិគម្រោង ដើម្បីធានាបានថាក្រុមហ៊ុនគោរពតាមគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងគោលការណ៍ច្បាប់ទូទៅ។
- ត្រូវធានាអោយបានថា សាធារណជនអាចរករបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បានដោយងាយស្រួលដើម្បីអនុញ្ញាតអោយប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បម្រើអោយគោលបំណងចំបងរបស់វា។ ការវិភាគអោយបានត្រឹមត្រូវនៃហេតុប៉ះពាល់បរិស្ថាននិងសង្គមសំខាន់ៗនៃគម្រោងអភិវឌ្ឍន៍ គឺជាផលប្រយោជន៍រយៈពេលវែងរបស់ប្រទេសកម្ពុជា។
- ត្រូវធានាបានថា មានការផ្តល់អាទិភាពដល់កង្វល់អំពីបរិស្ថាន និងសង្គម ដោយរាប់បញ្ចូលទាំងវិធានការកាត់បន្ថយហេតុប៉ះពាល់នានា នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅពេលអនាគត ដូច្នេះ ផលអាក្រក់មិនត្រូវធ្លាក់លើបុគ្គលណាម្នាក់ ក្រោយការអនុវត្តគម្រោងអភិវឌ្ឍន៍ណាមួយឡើយ។
- គួរពិចារណាពីការបង្កើតច្បាប់ ដែលធានាបាននូវការចែករំលែកផលប្រយោជន៍របស់គម្រោងទំនប់វារីអគ្គិសនី ដល់សហគមន៍រងគ្រោះ។

- គួរអនុញ្ញាត និងលើកទឹកចិត្តដល់សហគមន៍មូលដ្ឋានចូលរួមអោយបានសកម្ម ក្នុងការសិក្សាវាយតម្លៃនានា ដែលជាមូលដ្ឋានសម្រាប់របាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គម។ វាសំខាន់ណាស់ដែលត្រូវយល់ដឹងពី យោបល់ និងកង្វល់នៅមូលដ្ឋាន ដើម្បីទទួលបានការយល់ព្រមពីភាគីសំខាន់ៗ ទាំងនោះ។ កត្តានេះ អាចនឹងចំណាយពេលច្រើនជាងពេលវេលាដែលគេ ចំណាយនៅពេលបច្ចុប្បន្ន។
- គួរអោយតម្លៃលើកត្តាបរិស្ថាន និងសង្គម អោយដូចទៅនឹងកត្តាបច្ចេកទេសម៉ាក្រូ សេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅពេលធ្វើការវាយតម្លៃគម្រោងថាមពលវារីអគ្គិសនី។
- ត្រូវតែធ្វើផែនការអំពីវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននិងសង្គមអោយ បានគ្រប់គ្រាន់ ហើយត្រូវកំណត់ការទទួលខុសត្រូវរបស់ក្រុមហ៊ុន និងស្ថាប័ន រាជរដ្ឋាភិបាលពាក់ព័ន្ធនីមួយៗអោយបានច្បាស់លាស់។
- ការអនុម័តយល់ព្រមលើគម្រោង ត្រូវអាស្រ័យលើការវាយតម្លៃដែលមាន លក្ខណៈត្រឹមត្រូវ និងពេញលេញ ដោយមានការពិចារណាលើផលប៉ះពាល់ រយៈពេលវែង។ កត្តានេះ អាចសម្រេចបានលុះត្រាតែមានមន្ត្រីអាជ្ញាធរពាក់ព័ន្ធ ប្រកបដោយសមត្ថភាព និងអ្នកជំនាញជាច្រើនទៀតដូនជាមជ្ឈដ្ឋានអ្នកសិក្សា និង អង្គការសង្គមស៊ីវិលត្រូវគេអនុញ្ញាតអោយអានរបាយការណ៍វាយតម្លៃហេតុ ប៉ះពាល់បរិស្ថាន និងសង្គមជាមុន និងផ្តល់ឱកាសដើម្បីផ្តល់យោបល់ដល់ការ វាយតម្លៃគម្រោងទំនប់វារីអគ្គិសនីទាំងអស់នោះ។
- គួរធ្វើអោយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម រួមបញ្ចូល ទាំងវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលគេបានកំណត់ និងយល់ព្រមអោយ មានជាសាធារណៈហើយគួរគោរពតាមអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន ឆ្នាំ១៩៩៩ និងគោលការណ៍សម្រាប់សរសេររបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន ឆ្នាំ២០០៩។ គួររៀបចំរបាយការណ៍ទាំងនោះ ជាភាសា ខ្មែរ និងភាសាអង់គ្លេស។

- ការបញ្ចប់ និងការអនុម័តយល់ព្រមលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ គួរមានជាស្រេចនៅមុនការអនុម័តយល់ព្រមចំពោះគម្រោងទំនប់វារីអគ្គិសនី។

**បន្ថែមលើអនុសាសន៍ទាក់ទងនឹងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមខាងលើរាជរដ្ឋាភិបាលកម្ពុជាត្រូវ ៖**

- រិះរកមធ្យោបាយថ្មីៗ ដោយមានបញ្ចូលសហគមន៍មូលដ្ឋានក្នុងដំណើរការទាំងឡាយណាដែលតម្រូវអោយមានការចូលរួម នៅកំឡុងពេលសិក្សាអំពីហេតុប៉ះពាល់នានា។ ត្រូវបង្ហាញលទ្ធផលនៃការវាយតម្លៃអោយសមស្របជាមួយនឹងស្ថានភាពនៅមូលដ្ឋាន ហើយធ្វើការពិចារណាលើកត្តាមួយចំនួនដូចជាកម្រិតវប្បធម៌ និងភាពមិនចេះអក្សរជាដើម។
- សម្របសម្រួលការបង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មាន នៅក្នុងសហគមន៍រងគ្រោះអោយដើរតួជាកន្លែងមួយដែលប្រជាជនអាចរៀនអំពីគម្រោង និងឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានរបស់វា និងលើកឡើងនូវរាល់កង្វល់ដែលសហគមន៍រងគ្រោះមាន។
- បង្កើនការយកចិត្តទុកដាក់លើផលប៉ះពាល់ ពីអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីទៅលើការប្រែប្រួលអាកាសធាតុ ក្នុងន័យដើម្បីយល់ពីទិដ្ឋភាពទូទៅនៃទំហំប៉ះពាល់ជាអវិជ្ជមាននេះ នៅមុនការអនុម័តយល់ព្រមគម្រោងទំនប់វារីអគ្គិសនី។
- គួរតែធ្វើកិច្ចព្រមព្រៀងរវាងមន្ត្រីពាក់ព័ន្ធ និងក្រុមហ៊ុនលើការប្រើប្រាស់ និងគ្រប់គ្រងទឹកក្នុងអាងរបស់ទំនប់វារីអគ្គិសនីអោយរួចជាស្រេច នៅក្នុងដំណើរការអភិវឌ្ឍន៍ ដើម្បីបង្កើនផលប្រយោជន៍ដ៏មានសក្តានុពលពីទំនប់វារីអគ្គិសនីនៅពេលអនាគត សម្រាប់វិស័យកសិកម្ម។ នេះជាជំហានដ៏ចាំបាច់ដើម្បីធានាបាននូវការដាក់បញ្ចូលគោលបំណងកសិកម្ម ដោយចៀសវាងការផ្តោតលើតែការផលិតថាមពលវារីអគ្គិសនីមួយមុខ។

## អនុសាសន៍ចំពោះអង្គការសង្គមស៊ីវិល

ស្ថិតក្នុងបរិបទនៃការអភិវឌ្ឍយ៉ាងឆាប់រហ័ស នៃវិស័យថាមពលវារីអគ្គិសនី នៅក្នុងប្រទេសកម្ពុជា អង្គការសង្គមស៊ីវិលគួរចាប់យកឱកាសនេះដើរតួជាអ្នកឃ្លាំមើលបរិស្ថាន និងសង្គម។ អង្គការសង្គមស៊ីវិលត្រូវៈ

- ខិតខំពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថាន និងស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត ដើម្បីធ្វើអោយប្រសើរឡើងនូវការទទួលបានឯកសារពាក់ព័ន្ធ ដូចជារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាដើម។ កត្តានេះចាំបាច់ណាស់ ដើម្បីអាចធ្វើការលើបញ្ហាទាក់ទងទៅនឹងបរិស្ថាននិងសង្គមអោយមានប្រយោជន៍។
- តាមដានការអភិវឌ្ឍនៃច្បាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្មី ដើម្បីធានាបានថាគេយកចិត្តទុកដាក់ពង្រឹងច្បាប់នេះគ្រប់គ្រាន់ ដើម្បីធ្វើអោយប្រសើរឡើងនូវការចូលរួម ហើយធានាបានថាវាជួយសម្របសម្រួលអោយកើនឡើងនូវការប្រព្រឹត្តតាមគោលការណ៍ច្បាប់ផងដែរ។
- ស្នើសុំ និងប្រមូលព័ត៌មានស្តីពីទំនប់វារីអគ្គិសនីនៅប្រទេសកម្ពុជា ហើយបន្តរំលឹករាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជននូវកាតព្វកិច្ចរបស់ពួកគេដើម្បីសម្រួលអោយគម្រោងអភិវឌ្ឍន៍ទាំងនោះមានតម្លាភាព និងប្រកបដោយគណនេយ្យភាព។ ព័ត៌មានដែលប្រមូលបានត្រូវចែករំលែកជាទូទៅ ដើម្បីលើកកម្ពស់តម្លាភាព និងការបើកទូលាយដល់អ្នកពាក់ព័ន្ធទាំងឡាយ។
- ធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអ្នកអភិវឌ្ឍគម្រោងដើម្បីធានាបានថាយន្តការបណ្តឹងសារទុក្ខមានជាស្រេចសម្រាប់ជនរងគ្រោះ ដែលស្វែងរកដំណោះស្រាយ។
- ដើរតួជាអ្នកឃ្លាំមើលការប្រព្រឹត្តិតាមកិច្ចព្រមព្រៀង និងកិច្ចការដែលអ្នកអភិវឌ្ឍទំនប់វារីអគ្គិសនី និងរាជរដ្ឋាភិបាលកម្ពុជាសន្យាថានឹងធ្វើ ។
- ជួយភាគីរងគ្រោះស្វែងរកដំណោះស្រាយ ក្នុងករណីដែលយន្តការរបស់រាជរដ្ឋាភិបាលកម្ពុជាមិនទាន់មានគ្រប់គ្រាន់។ ប្រើប្រព័ន្ធផ្សព្វផ្សាយក្នុងករណីចាំបាច់ណាមួយ។

## ❖ អនុសាសន៍ទាក់ទងនឹងគម្រោងទំនប់វារីអគ្គិសនីកំចាយ

### អនុសាសន៍ចំពោះរាជរដ្ឋាភិបាលកម្ពុជា

ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងវិធានការកាត់បន្ថយហេតុប៉ះពាល់ដទៃទៀតសម្រាប់គម្រោងទំនប់វារីអគ្គិសនីកំចាយបានរាំងស្ទះ ដោយសារការខ្វះការផ្ទេរការទទួលខុសត្រូវរវាងក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាអោយបានច្បាស់លាស់។ ស្ថានភាពបែបនេះត្រូវការអោយមានការកែតម្រូវមុនពេលការអភិវឌ្ឍសំខាន់ណាមួយអាចកើតមានឡើង។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវៈ

- រៀបចំអោយមានការប្រជុំជាន់ខ្ពស់សម្រាប់ក្រសួង និងមន្ទីរទទួលបន្ទុកទាំងអស់។ ការប្រជុំគួរតែកំណត់ការបែងចែកការទទួលខុសត្រូវអោយបានច្បាស់លាស់រវាងក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាដោយដាក់បញ្ចូលតួនាទីរបស់ក្រសួង និងមន្ទីរផ្សេងៗផងដែរ។ ត្រូវកំណត់អោយបានថាតើនរណាទទួលបន្ទុកក្នុងការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននីមួយៗដែលគេបានចែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម/ផែនការគ្រប់គ្រងបរិស្ថាន។
- បោះពុម្ពផ្សាយការបែងចែកការទទួលខុសត្រូវ ដែលគេបានសម្រេចចុងក្រោយ និង ផែនការដាក់លាក់សម្រាប់ការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់។ កត្តានេះនឹងអនុញ្ញាតអោយគ្រប់ភាគីទាំងអស់ដឹងថាតើវិធានការការពារបរិស្ថាន និងសង្គមណាខ្លះគេរៀបចំឡើង ដើម្បីធ្វើការតាមដានការអនុវត្តវិធានការទាំងនោះ។

មានការផ្តល់ជូននូវព័ត៌មាន និងការចូលរួមដ៏តិចតួចដល់សហគមន៍មូលដ្ឋានអាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល។ កត្តានេះ បាននាំអោយភាគីពាក់ព័ន្ធនៅតាមមូលដ្ឋានស្នើសុំអោយមានការជាប់ពាក់ព័ន្ធបន្ថែមទៀត ក្នុងដំណើរការអភិវឌ្ឍន៍ដូចជាករណីទូទាត់សំណង និងករណីផ្សេងទៀតទាក់ទងនឹងការចិញ្ចឹមជីវិតរបស់ពួកគាត់។ វិធីសាស្ត្រដែលគេបានអនុវត្តកន្លងទៅ គឺការអោយមន្ត្រីថ្នាក់ខេត្តដើរតួជាអ្នកនាំពាក្យ និងអ្នកចរចាជាមួយក្រុមហ៊ុន ដូច្នេះសហគមន៍រងគ្រោះយល់ឃើញថា

វាមិនមានប្រសិទ្ធភាព ហើយមានលក្ខណៈស្មុគស្មាញ។ ហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវៈ

- ធ្វើការប្រជុំនៅថ្នាក់ភូមិ ដើម្បីប្រាប់សហគមន៍មូលដ្ឋាននូវព័ត៌មានថ្មីៗ អំពីទំនប់វារីអគ្គិសនី សុវត្ថិភាពរបស់វា និងការរំពឹងទុកនៃការផ្លាស់ប្តូរលំហូរទឹក និងកម្រិតទឹកប្រែតាមព្រែកកំចាយ។
- ផ្តល់វេទិកាមួយ សម្រាប់ដោះស្រាយរាល់បញ្ហាដែលសមាជិកសហគមន៍រងគ្រោះអាចនឹងមាន។ វេទិកានេះគួរធានាបាននូវការចូលរួមទាំងអ្នកភូមិរងគ្រោះ និងក្រុមហ៊ុនស៊ីណូហៃដ្រូ ប្រសិនបើគេគិតថាជាប់ពាក់ព័ន្ធចាំបាច់ដោយភាគីណាមួយ អ្នកតំណាងអង្គការសង្គមស៊ីវិលក៏ត្រូវចូលរួមផងដែរ។
- ធានាបានថា ក្រុមហ៊ុនស៊ីណូហៃដ្រូ អនុវត្តរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់ដែលគេបានសន្យា ដោយរាប់បញ្ចូលទាំងសំណងសម្រាប់ការបាត់បង់ឱកាសក្នុងការចូលទៅប្រមូលអនុផលព្រៃឈើ និងការបាត់បង់ប្រាក់ចំណូលពីការថយចុះក្នុងវិស័យទេសចរណ៍។
- ជម្រាបសហគមន៍មូលដ្ឋាននូវព័ត៌មានលំអិត នៃវិធានការដែលគេគ្រោងនឹងធ្វើដើម្បីកាត់បន្ថយផលប៉ះពាល់ទាក់ទងនឹងការបាត់បង់ឱកាសចូលទៅប្រមូលអនុផលព្រៃឈើ និងពីការបាត់បង់ប្រាក់ចំណូលពីការថយចុះក្នុងវិស័យទេសចរណ៍ភ្លាមៗ តាមដែលអាចធ្វើទៅបាន បន្ទាប់ពីគេសម្រេចផែនការចុងក្រោយ។
- ជម្រាបដល់សហគមន៍អំពីផែនការសម្រាប់ធ្វើការតាមដានផលប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងនៅឆ្នាំបន្តបន្ទាប់។
- តាមដានលំហូរទឹកជាក់ស្តែង ដែលត្រូវបញ្ចេញពីទំនប់ពេញមួយឆ្នាំ។ មន្ត្រីទទួលបន្ទុកការងារនេះគួរត្រួតពិនិត្យ និង ធានាបានថាការបញ្ចេញទឹកមានកម្រិតគ្រប់គ្រាន់សម្រាប់ថែរក្សាលំហូរបរិស្ថានធម្មជាតិ នៅខ្សែទឹកខាងក្រោមទំនប់វារីអគ្គិសនីកំចាយ។
- អនុញ្ញាតអោយអង្គការសង្គមស៊ីវិលតាមដាន និង ត្រួតពិនិត្យការដាំកូនឈើឡើងវិញ។ កត្តានេះនឹងបង្កើនតម្លាភាព និងគណនេយ្យភាពរបស់គម្រោងទំនប់វារីអគ្គិសនីកំចាយ។

លើសពីនេះទៀត ដើម្បីធ្វើអោយប្រសើរឡើងនូវផលិតផលកសិកម្មនៅតំបន់ខ្សែទឹកខាងក្រោម ក្រុមហ៊ុនស៊ីណូហៃដ្រូ មន្ទីរនានានៅខេត្តកំពត និងមន្ត្រីមូលដ្ឋានត្រូវបង្កើតអោយមានកិច្ចសន្ទនា ក្នុងន័យអោយមានការយល់ដឹងជារួមថាតើការបញ្ចេញទឹកពីទំនប់នឹងប៉ះពាល់ផលិតផលកសិកម្មនៅខ្សែទឹកខាងក្រោម ដូចម្តេចខ្លះ។ នៅពេលដែលមានការបញ្ជាក់បន្ថែមអោយកាន់តែច្បាស់ កត្តានេះអាចជួយអោយកសិករតាមមូលដ្ឋានធ្វើផែនការសម្រាប់អនាគតរបស់គេបាន។

ដើម្បីយល់ដឹងពីផលប៉ះពាល់ជាក់ស្តែង ដែលបណ្តាលមកពីការសាងសង់ទំនប់វារីអគ្គិសនីកំចាយ គេគួរវាយតម្លៃគម្រោងទាំងមូលអោយបានទៀងទាត់ ដូចជារៀងរាល់បីឆ្នាំម្តង។ ការវាយតម្លៃរាល់ផលប៉ះពាល់ផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម ព្រមទាំងនីតិវិធីរបស់ស្ថាប័ន គឺសុទ្ធតែមានសារៈសំខាន់ក្នុងការវាយតម្លៃហេតុប៉ះពាល់នានា។ ចំណេះដឹងដែលបានមកពីការវាយតម្លៃនេះអាចជួយអោយអ្នកសម្រេចចិត្តយកទៅប្រើប្រាស់សម្រាប់ធ្វើអោយមានការរីកចម្រើនជាងមុន ហើយស្របពេលនេះដែរ វានឹងផ្តល់ជាមូលដ្ឋានសំខាន់ដើម្បីធ្វើការសម្រេចចិត្តទាក់ទងនឹងគម្រោងទំនប់វារីអគ្គិសនីនានាដែលគេគ្រោងនឹងធ្វើនាពេលអនាគត។ វានឹងក្លាយជាគន្លឹះដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាអាចគេចផុតពីកំហុសឆ្គងផ្សេងៗដែលប្រទេសដទៃធ្លាប់មានរួចហើយ។

## អនុសាសន៍ចំពោះក្រុមហ៊ុនស៊ីណូហៃដ្រូ

ក្នុងនាមជាអ្នកអភិវឌ្ឍគម្រោង និងជាអ្នកប្រតិបត្តិគម្រោងទំនប់វារីអគ្គិសនីកំចាយ ក្រុមហ៊ុនស៊ីណូហៃដ្រូគឺជាតួអង្គសំខាន់ក្នុងការធានាបាននូវការអនុវត្តគម្រោងអោយបានត្រឹមត្រូវ។ ចំណុចនេះរាប់បញ្ចូលទាំងការអនុវត្តយន្តការការពារនានាអោយបានត្រឹមត្រូវ ដើម្បីកាត់បន្ថយឥទ្ធិពលអាក្រក់ដល់បរិស្ថាន និងសង្គម។ ប៉ុន្តែក្រុមហ៊ុនស៊ីណូហៃដ្រូបានផ្ទេរការទទួលខុសត្រូវនៃការដោះស្រាយផ្ទាល់ជាមួយសហគមន៍មូលដ្ឋានអោយទៅមន្ត្រីថ្នាក់ខេត្ត។ ការអនុវត្តបែបនេះ មិនអាចដោះស្រាយសេចក្តីត្រូវការ និងកង្វល់របស់សហគមន៍មូលដ្ឋានបានឡើយ។ ដូច្នេះក្រុមហ៊ុនស៊ីណូហៃដ្រូត្រូវ៖

- ប្រតិកម្មត្រលប់ និងស្នើអោយមានកិច្ចប្រជុំជាន់ខ្ពស់ជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីទទួលបានការកំណត់ច្បាស់លាស់នៃការទទួលខុសត្រូវ ទាក់ទងនឹងការប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន និងវិធានការកាត់បន្ថយហេតុប៉ះពាល់ដទៃទៀត។ ក្រុមហ៊ុនស៊ីណូហៃដ្រូត្រូវតែសម្រេចបាននូវរាល់កាតព្វកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ និងអោយទាន់ពេលវេលា។
- បំពេញការទទួលខុសត្រូវរបស់ខ្លួនចំពោះសហាគមន៍មូលដ្ឋាន តាមរយៈការជម្រុញអោយមានកិច្ចសន្ទនាដោយផ្ទាល់ជាមួយអ្នកភូមិរងគ្រោះ។
- គោរពតាមច្បាប់ និងគោលការណ៍ណែនាំអោយបានសកម្ម ហើយធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាអោយបានថាគេប្រកាន់ខ្ជាប់ និងគោរពតាមច្បាប់របស់ប្រទេសកម្ពុជាទាំងអស់ ។
- គោរពតាមស្តង់ដារដែលគេទទួលស្គាល់ជាអន្តរជាតិ សម្រាប់ការអភិវឌ្ឍទំនប់វារីអគ្គិសនី ពិសេសនោះ នៅពេលដែលច្បាប់ក្នុងប្រទេសមានលក្ខណៈទន់ខ្សោយ។
- ដឹកនាំក្នុងការធានាអោយបានថា ការពិគ្រោះយោបល់ជាសាធារណៈជាមួយសហាគមន៍រងគ្រោះត្រូវតែបានធ្វើឡើង។
- ធ្វើអោយរាល់ព័ត៌មានទាក់ទងនឹងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមអាចរកបានជាសាធារណៈ ហើយគោរពតាមរាល់វិធានការដែលគេបង្ហាញនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។
- បង្កើតយន្តការបណ្តឹងសារទុក្ខ ដែលអាចអោយសហាគមន៍លើកឡើងនូវបញ្ហារបស់ពួកគាត់ដោយផ្ទាល់ជាមួយក្រុមហ៊ុន។
- ជូនដំណឹង និងផ្តល់ព័ត៌មានជាទៀងទាត់ដល់សហាគមន៍ចំពោះកាលវិភាគនៃការបិទ និងបើកទ្វារទំនប់ ដើម្បីអោយសហាគមន៍មានលទ្ធភាពគ្រប់គ្រាន់ក្នុងការកាត់បន្ថយផលប៉ះពាល់ពីលំហូរទឹក។

ដោយមានភាពខ្វល់ខ្វាយពីការទទួលខុសត្រូវ និងកេរ្តិ៍ឈ្មោះរបស់ខ្លួន ក្រុមហ៊ុនស៊ីណូហៃដ្រូ គួរតែចាប់អារម្មណ៍អំពីសេចក្តីត្រូវការ កង្វល់ និងការចិញ្ចឹម

ជីវិតរបស់សហគមន៍ដែលរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារទំនប់វារីអគ្គិសនីកំចាយ។ ក្រុមហ៊ុនស៊ីណូហៃដ្រូ គួរតែចាត់វិធានការណ៍បន្ទាន់ដើម្បីស្វែងយល់ពីស្ថានភាពនៃអ្នកភូមិរងគ្រោះ ហើយឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពួកគាត់។ ជាពិសេសនោះ ក្រុមហ៊ុនស៊ីណូហៃដ្រូត្រូវៈ

- ត្រួតពិនិត្យឡើងវិញនូវការសហការរបស់ខ្លួនជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាបានថារាល់វិធានការកាត់បន្ថយហេតុប៉ះពាល់ និងការទូទាត់សំណងដែលបានផ្តល់ជូនកន្លងមកឆ្លើយតបទាំងស្រុងទៅនឹងសេចក្តីត្រូវការរបស់សហគមន៍រងគ្រោះ។
- ធ្វើការពិនិត្យពិច័យជាពិសេសលើករណីសំណង ដែលគេមិនបានដោះស្រាយជូនដល់អ្នកភូមិរងគ្រោះ ដោយសារការសាងសង់ខ្សែបណ្តាញបញ្ជូនចរន្ត ហើយធានាថាគេអាចរកឃើញដំណោះស្រាយសម្រាប់អ្នកភូមិដែលកំពុងរង់ចាំទទួលសំណងទាំងនោះ។
- ជម្រាបដល់អ្នកភូមិរងគ្រោះ អំពីចំនួនប្រាក់សំណង និងពេលវេលានៃការទូទាត់សំណង។ ក្រុមហ៊ុនស៊ីណូហៃដ្រូត្រូវបង់ប្រាក់សំណងជូនដល់អ្នកភូមិទាំងរងគ្រោះទាំងនោះដោយផ្ទាល់។
- សម្របសម្រួលអោយមានការសាងសង់ស្ពានយោលថ្មីមួយ នៅរមណីយដ្ឋានទឹកឈូ។
- កសាងផ្លូវដើម្បីធ្វើអោយប្រសើរឡើងដល់ការធ្វើដំណើរចូលទៅកាប់ឫស្សី និងធនធានអនុផលព្រៃឈើដទៃទៀត។
- រុះរើ និងយកអាគារបណ្តោះអាសន្ន និងសំណង់ដទៃទៀតដែលប្រើប្រាស់នៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ ចេញអោយអស់ពីតំបន់នោះ។ ការធ្វើបែបនេះ ធ្វើអោយសោភ័ណភាពនៅតំបន់ជុំវិញទំនប់វារីអគ្គិសនីកំចាយប្រសើរឡើង។
- តាមដានគោលបំណងដែលបានលើកឡើងថា ធ្វើអោយទំនប់ក្លាយជាតំបន់រមណីដ្ឋានទេសចរណ៍។

## អនុសាសន៍ចំពោះអង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិល គួរតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងបង្កើនការយកចិត្តទុកដាក់ដើម្បីធានាអោយបានថាក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាអនុវត្ត និងប្រព្រឹត្តិតាមវិធានការការពារនានា។ ជាពិសេស អង្គការសង្គមស៊ីវិលត្រូវៈ

- ជួយសហគមន៍មូលដ្ឋានតាមរយៈការធ្វើយ៉ាងណាអោយកង្វល់ និងសេចក្តីត្រូវការរបស់ពួកគេបានដឹងឮដល់រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនស៊ីណូហៃដ្រូ។
- ស្នើអោយក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាអនុវត្តរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីទូទាត់សំណងដល់ការបាត់បង់ឱកាសចូលទៅរកអនុផលព្រៃឈើ និងពីការថយចុះនៃវិស័យទេសចរណ៍នៅរមណីយដ្ឋានទឹកឈូ។ អង្គការសង្គមស៊ីវិលគួរជួយត្រួតពិនិត្យថាតើគេបានបំពេញតាមការសន្យាទាំងនោះដែរឬទេ។
- តាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងវិធានការកាត់បន្ថយផ្សេងទៀត ដើម្បីធានាថាក្រុមហ៊ុនស៊ីណូហៃដ្រូ និងរាជរដ្ឋាភិបាលកម្ពុជាបំពេញរាល់ការទទួលខុសត្រូវរបស់ខ្លួន។
- តាមដានការដាំកូនឈើឡើងវិញអោយបានជិតស្និទ្ធ និងស្នើអោយមានការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់នេះអោយមានតម្លាភាព។
- ទាមទារអោយមានការបោះពុម្ពផ្សាយនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថាន និងសង្គម។

អនុសាសន៍ខាងលើបានមកពីការសិក្សានៃទំនប់វារីអគ្គិសនីកំចាយ ដូច្នេះអនុសាសន៍ភាគច្រើនអាស្រ័យលើព័ត៌មានដែលបានពីលទ្ធផលស្រាវជ្រាវ។ រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីទាំងអស់គួរតែពិនិត្យឡើងវិញ និងពិចារណាពីអនុសាសន៍របស់គណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនីដែលមានលក្ខណៈទូលំទូលាយជាងការសិក្សានេះ ដែលជាក្របខណ្ឌមួយអាចជួយធានាបាននូវការអភិវឌ្ឍថាមពលវារីអគ្គិសនីមួយដែលមាននិរន្តរភាពយូរអង្វែង ពោរពេញទៅដោយការចូលរួម និងរាប់បញ្ចូលរាល់ភាគីពាក់ព័ន្ធទាំងឡាយ។

# ឯកសារយោង

ESIA April 2011, "*Environmental and Social Impact Assessment (ESIA) Development of Kamchay Hydroelectric Project*", SAWAC Consultants Ltd. Prepared for Sinohydro Corporation Ltd.

ESIA April 2011 English Summary, "*Kamchay Hydroelectric Project, Environmental Impact Assessment (Revised draft, September 2011) Executive Summary.*", English Translation.

Forbes, R. S. et al. 2012, "*Environmental Assessment Law for a Healthy, Secure and Sustainable Canada - A Checklist for Strong Environmental Laws*", February 2012.Authored by: Rachel S. Forbes, Stephen Hazell, Jamie Kneen, Josh Paterson and Dr. John Sinclair.

Frankel, M. 2012, "*Reservoirs May Produce 20 Times More Methane than Normal During Water 'Drawdown'*", Max Frankel, Climate Progress, August 9, 2012.

Globalization Monitor 2010, Letter of Concern over applications for carbon credits for Kamchay and Nam Lik 1 hydropower projects in Cambodia and Laos, Globalization Monitor, Hong Kong, February 16, 2010.

Grimsditch, M. 2012, "*China's Investments in Hydropower in the Mekong Region: The Kamchay Hydropower Dam, Kampot, Cambodia.*", Mark Grimsditch, January 2012.

Harkonen 2009, "*Greenhouse Gas Emissions from Reservoirs: Assessing the Net Emissions.*", Saku Härkönen, Master of Science Thesis, Helsinki University of Technology, Faculty of Engineering and Architecture, Department of Civil and Environmental Engineering, 2009.

Hensengerth, O. 2012, "*Hydropower Planning in Informal Institutional Settings: Chinese Institutions and the Failure of Environmental and Social Regulation in Cambodia.*", August 17, 2012. "Forthcoming in: Waltina Scheumann and Oliver Hensengerth (eds.) (2013), Evolution of Dam Policies: Evidence from the Big Hydropower States (Berlin and Heidelberg: Springer)."

International Rivers January 2008, International Rivers, The Rivers Coalition in Cambodia and The NGO Forum on Cambodia 2008, "*New Report Urges Better Energy Planning in Cambodia before Hydropower Dams are Developed.*", Press Release - January 28, 2008.

International Rivers February 2008, "*The World Commission on Dams Framework- A Brief Introduction*", February 29, 2008, http://www.internationalrivers.org/resources/the-world-commission-on-dams-framework-a-brief-introduction-2654- Accessed on December 4, 2012.

International Rivers November 2008, "*Dirty Hydro: Dams and Greenhouse Gas Emissions"*, International Rivers, November 2008.

International Rivers March 2010, Letter of Concern to SGS (Thailand) Limited: "*Re: Submission for carbon credits of the Kamchay Hydroelectric BOT Project*", International Rivers, March 11, 2010.

International Rivers October 2011, "*Wrong Climate for Big Dams - Destroying Rivers will Worsen Climate Crisis*", International Rivers Fact sheet, October 2011.

International Rivers 2011, "*Advancements in the Field of Reservoir Emissions - A Briefing on Recent Research and Guidelines*", Prepared by Dr. Payal Parekh for International Rivers December 2, 2011.

International Rivers January 2012, "*Comments to CF Carbon Fund II Limited Regarding the Kamchay Hydropower Project (Cambodia)*", International Rivers, January 20, 2012.

International Rivers, "*Climate Change Glossary*", International Rivers, http://www.internationalrivers.org/resources/climate-change-glossary-3588- Accessed on November 5, 2012

IPS 2008, "*DEVELOPMENT-CAMBODIA: Bowing to Regional Hydropower Demands*", Inter Press Service News Agency, Andrew Nette, Phnom Penh, March 20, 2008.

IRN 2007, "*Frequently Asked Questions: Greenhouse Gas Emissions from Dams*", International Rivers Network (IRN), May 2007.

Kummu, M. et al. 2010, "*Greenhouse gas emissions from reservoirs – case Cambodia*", Matti Kummu, Olli Varis and Timo Räsänen, Water & Development Research Group, Aalto University, Finland, March 31, 2010, Draft.

Middleton, C. 2008, "*Cambodia's Hydropower Development and China's Involvement*", Middleton, C. 2008, International Rivers and The Rivers Coalition in Cambodia.

MIME 2012, National Stakeholder Consultation Workshop, "*ADB TA7764-REG: Ensuring Sustainability of the GMS Regional Power Development*", Ministry of Industry, Mines and Energy, Sunway Hotel, October 2, 2012, Phnom Penh.

MIME July 2009, "*National Power and Hydropower Development Plans in Cambodia.*", Presentation by CHEA Piseth, Hydro-Electricity Department, General Department of Energy, July 16-17, 2009, Phnom Penh, Cambodia.

NGOF/Kavenagh, M. et al. 2012, "*Free, Prior and Informed Consent in the Development Process in Indigenous People Communities of Mondulkiri and Ratanakiri province*", January 2012, Researched by: Dr. Mark Kavenagh, Dom Renfrey & Erin Flynn, Published by: The NGO Forum on Cambodia, Land and Livelihoods Programme, Indigenous Peoples Land Rights Project.

NGOF 2012, "*Mekong River-Dependent Livelihoods - The Sambor Baseline Survey*", April 2012, The NGO Forum on Cambodia.

NGOF 2009, "*Lower Sesan 2 Hydro Project EIA Review*", The NGO Forum on Cambodia, Phnom Penh, Cambodia, August 2009.

NGOF 2007, "*Kamchay Baseline Study - Mak Prang Commune, Kampot District, Kampot Province*", December 2007, The NGO Forum on Cambodia.

Phnom Penh Post, November 29, 2012, Article on the Lower Sesan 2 Hydropower Dam.

Phnom Penh Post, November 4-18, 2005, "*China revives dreams of Kampot mega-dam*".

Royal Government of Cambodia, "*Proclamation on General Guideline for Writing a Preliminary and Final Report on Environmental Impact Assessment.*" 2009.

Royal Government of Cambodia, "*Sub-decree on Environmental Impact Assessment Process 1999*", The Royal Government of Cambodia, No: 72 ANRK.BK, Phnom Penh, August 11, 1999.

Sinohydro 2007, "*Kamchay Hydroelectric BOT Project, Progress Report*", Sinohydro Kamchay Hydroelectric Project Co. Ltd., August 2007.

The Cambodia Daily 23/11/2012, "*1 in 20 Firms Carry Out Environment Assessments*", The Cambodia Daily, Volume 53 Issue 50, November 23, 2012.

The Cambodia Daily 24-25/11/2012, "*Hydropower Is the Future, yet Villagers in the Dark*", The Cambodia Daily, Volume 53 Issue 51, November 24-25, 2012.

WCD 2000, "*Dams and Development - A New Framework for Decision-Making*", The Report of the World Commission on Dams, World Commission on Dams, Earthscan Publications, November 2000.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ «ក»: ផែនទីអាងស្តុកទឹក និងភូមិនៅខ្សែទឹកខាងក្រោមទំនប់វារីអគ្គិសនីកំចាយ

អាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយ និងទីតាំងរបស់វាដែលភ្ជាប់ទៅនឹងក្រុងកំពត (របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ខែមេសា ឆ្នាំ២០១១)



## ឧបសម្ព័ន្ធ «ខ»: ការសម្ភាស និងការសិក្សានៅមូលដ្ឋាន

<u>ក្រុមហ៊ុនស៊ីណូហៃដ្រូ និងក្រសួងនានា:</u>

២៩/៨/២០១២ ក្រុមហ៊ុនស៊ីណូហៃដ្រូ ខេត្តកំពត

៩/១០/២០១២ ក្រុមហ៊ុនស៊ីណូហៃដ្រូ ក្រុងភ្នំពេញ

៩/១០/២០១២ នាយកដ្ឋានឧទ្យានជាតិ នៃក្រសួងបរិស្ថាន

១០/១០/២០១២ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន

<u>អាជ្ញាធរ និងអង្គការមិនមែនរដ្ឋាភិបាលនៅខេត្តកំពត:</u>

១៦/៨/២០១២ ស្ថានីយបូមទឹកខេត្តកំពត

២៣/៨/២០១២ រដ្ឋាករទឹកខេត្តកំពត

២៤/៨/២០១២ មន្ទីរសុខាភិបាលខេត្តកំពត

២៨/៨/២០១២ មន្ទីរទេសចរណ៍ខេត្តកំពត

២៨/៨/២០១២ ខណ្ឌរដ្ឋបាលជលផលខេត្តកំពត

២៨/៨/២០១២ មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត

១៨/១០/២០១២ មន្ទីរបរិស្ថានខេត្តកំពត

២៣/៨/២០១២ អង្គការអាដហុកខេត្តកំពត

២៣/៨/២០១២ អង្គការលីកាដូខេត្តកំពត

<u>អាជ្ញាធរមូលដ្ឋាន:</u>

១៥/៨/២០១២ មេឃុំម៉ាក់ប្រាង

១៦/៨/២០១២ មេឃុំកំពង់គ្រែង

១៧/៨/២០១២ ប្រធានភូមិស្នំប្រាំពីរ

១៨/៨/២០១២ ប្រធានភូមិអូរត្លូច

១៨/៨/២០១២ ប្រធានភូមិមាត់ពាម

២០/៨/២០១២ មេឃុំអណ្តូងខ្មែរ

២៧/៨/២០១២ អនុប្រធានភូមិថ្មីខាងជើង

<u>ភាគីពាក់ព័ន្ធនៅសហគមន៍មូលដ្ឋាន:</u>

១៦/៨/២០១២ សម្ភាសន៍ជាមួយស្ត្រីលក់ដូរចល័តមកពីភូមិស្នំប្រាំពីរ

១៦/៨/២០១២ ជជែកជាមួយម្ចាស់ហាងភេសជ្ជៈមកភូមិស្នំប្រាំពីរ

១៦/៨/២០១២ ជជែកជាមួយក្រុមអ្នកប្រកបរបរកាប់អុសមកពីភូមិក្រាំង

១៦/៨/២០១២ សម្ភាសន៍កសិករដាំធូរ៉េនមកពីភូមិកំណប់ ដែលជាផ្នែកមួយនៃ ភូមិម៉ាក់ប្រាង ក្នុងឃុំកំពង់ត្រែង

២០/៨/២០១២ ទៅទស្សនា និងជជែកជាមួយប្រជាជននៅផ្សារស្នំប្រាំពីរ

២០/៨/២០១២ សម្ភាសន៍អ្នកនេសាទនៅភូមិស្នំប្រាំពីរ

២០/៨/២០១២ សម្ភាសន៍អ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូ

២០/៨/២០១២ សម្ភាសន៍គ្រូបង្រៀន និងជាម្ចាស់ភោជនីដ្ឋាននៅជិតព្រែកទឹកឈូ

២០/៨/២០១២ សម្ភាសន៍បុរសប្រកបរបរកាប់ឫស្សីនៅភូមិអូរតូច

២១/៨/២០១២ ទៅទស្សនាឃុំម៉ាក់ប្រាង ភូមិមាត់ពាម និងធ្វើការសម្ភាសជាមួយគ្រួសាររស់នៅក្រោមខ្សែបញ្ជូនចរន្ត

២២/៨/២០១២ សម្ភាសន៍ស្ត្រីលក់ត្រីនៅផ្សារស្នំប្រាំពីរ

២២/៨/២០១២ សម្ភាសន៍គ្រួសារប្រកបរបរកាប់ឫស្សីនៅភូមិអូរតូច

២២/៨/២០១២ សម្ភាសន៍ប្រធានសហគមន៍ឫស្សីនៅភូមិអូរតូច

២៧/៨/២០១២ សម្ភាសន៍អ្នកតំណាងសហគមន៍នៅភូមិអូរតូច

៣០/៨/២០១២ សម្ភាសន៍គ្រួសារ ដែលរស់នៅជិតខ្សែបញ្ជូនចរន្តនៅភូមិអណ្តូងជីមើន

៣០/៨/២០១២ សម្ភាសន៍គ្រួសារធ្វើកន្ត្រក់ឫស្សី(ខេង)សម្រាប់ដាក់ត្រីចំហុយនៅភូមិមាត់ពាម

៣០/៨/២០១២ សម្ភាសគ្រួសារ ដែលរស់នៅក្រោមខ្សែបញ្ជូនចរន្តនៅភូមិមាត់ពាម

៣០/៨/២០១២ អង្កេត និងជជែកជាមួយគ្រួសាររស់នៅក្នុងខ្សែបញ្ជូន ចរន្តនៅភូមិមាត់ពាម

៣១/៨/២០១២ ជជែកជាមួយបុរសម្នាក់មកពីភូមិស្នំប្រាំពីរ

៣១/៨/២០១២ សម្ភាសន៍គ្រួសារប្រកបរបរកាប់អុសនៅភូមិស្នំប្រាំពីរ

៣១/៨/២០១២ សម្ភាសន៍ជាមួយគ្រួសារប្រកបរបរកាប់ឫស្សីនៅភូមិអូរតូច (សម្ភាសន៍លើកទីពីរ)

០១/៩/២០១២ សម្ភាសន៍ជាមួយស្ត្រីប្រកបរបរលក់មាន់អាំងចល័តនៅរមណីយដ្ឋានទឹកឈូ

២០/១០/២០១២ សម្ភាសន៍បុរសជាអ្នកប្រកបរបរកាប់ឫស្សីនៅជិតទំនប់វារីអគ្គិសនីកំចាយ

<u>ពិភាក្សាក្រុម:</u>

២២/៨/២០១២ ពិភាក្សាក្រុមនៅភូមិស្នំប្រាំពីរអំពីផ្លែឈើព្រៃ និងការប្រកបរបរកាប់អុស

២៧/៨/២០១២ ពិភាក្សាក្រុម នៅភូមិថ្មីខាងជើងអំពីការប្រកបរបរកាប់ឫស្សី

២៩/៨/២០១២ ពិភាក្សាក្រុមនៅភូមិអូរតូចអំពីអនុផលព្រៃឈើ និងការប្រកបរបរកាប់ឫស្សី

០១/៩/២០១២ ពិភាក្សាក្រុមនៅភូមិស្នំប្រាំពីរ ជាមួយអ្នកប្រកបរបរលក់ដូរនៅរមណីយដ្ឋានទឹកឈូ

**ទស្សនាទីតាំងផ្សេងទៀតនៅខេត្តកំពត:**

១៨/៨/២០១២ ទស្សនាតំបន់នៅក្បែរទំនប់វារីអគ្គិសនីកំចាយ

២៩/៨/២០១២ ទស្សនាទំនប់វារីអគ្គិសនីកំចាយ

៣០/៨/២០១២ ទស្សនាភូមិអណ្តូងជីមើន

២០/១០/២០១២ ទស្សនាអាងស្តុកទឹកទំនប់វារីអគ្គិសនីកំចាយ។ ជជែកជាមួយអ្នកប្រកបរបរកាប់អុស និងម្ចាស់ទូក។

## ឧបសម្ព័ន្ធ «គ»: ដំណើរការដែលនាំអោយមានការបំភាយឧស្ម័នផ្ទះកញ្ចក់ពីអាងស្តុកទឹកនៃទំនប់វារីអគ្គិសនី

កាបូន និងឧស្ម័នផ្ទះកញ្ចក់ប្រែប្រួលក្នុងអាងស្តុកទឹកទំនប់វារីអគ្គិសនី




(ប្រភព: គំនូសតាងពី Varis et al. in press, នៅក្នុង Harkonen 2009, ទំព័រ ៦)

## ឧបសម្ព័ន្ធ «ឃ»: ប្រភពនៃការផ្គត់ផ្គង់ទឹកនៅក្នុងភូមិដែលបានសិក្សា

| ភូមិ | ប្រភពទឹកសំខាន់ | ប្រភពទឹកផ្សេងទៀត | យោបល់ |
|---|---|---|---|
| **ស្ពុំប្រាំពីរ** | ទឹកទុយយោពីភ្នំនៅជិតភូមិ (១,០០០រៀល/ម៉ែត្រគូប)<br>អ្នកភូមិខ្លះទៀតប្រើទឹករដ្ឋករទឹកកំពត (១,៨០០រៀល/ម៉ែត្រគូប) | ទឹកពីព្រែកកំចាយអាង/អណ្តូង | នៅមុនការសាងសង់ទំនប់វារីអគ្គិសនីកំចាយ អ្នកភូមិខ្លះប្រើទឹកព្រែកសម្រាប់ផឹក។ ប៉ុន្តែនៅកំឡុងពេលសាងសង់ទំនប់វារីអគ្គិសនីកំចាយ និងសព្វថ្ងៃស្ទើរតែ ពុំមានអ្នកភូមិណាម្នាក់ ផឹកទឹកព្រែក។<br>មិនមានការប្រែប្រួលចំពោះការផ្គត់ផ្គង់ទឹកទេ។ |
| **មាត់ពាម** | ទឹកអណ្តូង/អាង និងទឹកភ្លៀងត្រូវគេប្រើជាធម្មតា | | មិនមានទឹកទុយយោផ្គត់ផ្គង់នៅក្នុងភូមិ |
| **អូរតូច** | ទឹកអណ្តូង/អាងត្រូវគេប្រើជាធម្មតា។ អ្នករស់នៅតាមដងផ្លូវទៅកាន់តំបន់ទឹកឈូ ប្រើទឹករបស់រដ្ឋាករទឹកកំពត។ | អ្នកខ្លះទិញទឹកពីអ្នកភូមិដទៃទៀតដែលប្រើទឹកពីរដ្ឋាករទឹកកំពត | មិនមានការប្រែប្រួលការផ្គត់ផ្គង់ទឹកទេ។ |
| **ថ្មីខាងជើង** | ប្រជាជនស្ទើរតែទាំងអស់ប្រើទឹកផ្គត់ផ្គង់ដោយឯកជនដែលមានប្រភពមកពីរដ្ឋករទឹកកំពត(២,៥០០រៀល/ម៣). | អ្នកភូមិតិចតួចប្រើទឹកពីរដ្ឋករទឹកកំពតដោយផ្ទាល់។អ្នកខ្លះទៀតជីកអណ្តូងយកទឹកក្រោមដីប្រើ។ | |
| **អណ្តូងជីមើន** | ទឹកអណ្តូង/អាងត្រូវគេប្រើជាធម្មតា | | មិនមានការផ្គត់ផ្គង់ទឹករដ្ឋនៅក្នុងភូមិ។ |

ប្រភព: អនុប្រធានភូមិថ្មីខាងជើង ២៧/៨/២០១២; ប្រធានភូមិអូរតូច ១៨/៨/២០១២; មេឃុំអណ្តូងខ្មែរ ២០/៨/២០១២; មេឃុំអណ្តូងជីមើន ១៦/៨/២០១២; ប្រធានភូមិមាត់ពាម ១៨/៨/២០១២; មេឃុំម៉ាក់ប្រាង ១៥/៨/២០១២

## ឧបសម្ព័ន្ធ «ខ»: ស្ថាប័នដែលតាមដានមើលការអនុវត្ត EMP

ស្ថាប័នដែលគេរាប់បញ្ចូលក្នុងក្រុមការងារចម្រុះសម្រាប់តាមដានការអនុវត្ត EMP ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ:

| ថ្នាក់ជាតិ | ថ្នាក់ក្រោមជាតិ |
|---|---|
| ▪ ក្រសួងបរិស្ថាន<br>▪ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>▪ ក្រសួងធនធានទឹក និងឧតុនិយម<br>▪ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>▪ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ<br>▪ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>▪ ក្រសួងទេសចរណ៍<br>▪ ក្រសួងសាធារណការ និងដឹកជញ្ជូន<br>▪ រដ្ឋបាលជលផល<br>▪ រដ្ឋបាលព្រៃឈើ<br>▪ ក្រុមហ៊ុន Sinohydro | ▪ មន្ទីរបរិស្ថាន<br>▪ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល<br>▪ មន្ទីរធនធានទឹក និងឧតុនិយម<br>▪ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>▪ មន្ទីរកសិកម្ម<br>▪ មន្ទីររៀបំដែនដី នគរូបនីយកម្ម និងសំណង់<br>▪ មន្ទីរទេសចរណ៍<br>▪ មន្ទីរសាធារណការ និងដឹកជញ្ជូន<br>▪ ខណ្ឌរដ្ឋបាលជលផលកំពត<br>▪ ខណ្ឌរដ្ឋបាលព្រៃឈើកំពត<br>▪ ក្រុមហ៊ុន Sinohydro<br>▪ អាជ្ញាធរមូលដ្ឋានៈ មន្ត្រីភូមិ ឃុំ ស្រុក និងខេត្ត |

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ **ngoforum@ngoforum.org.kh**
គេហទំព័រៈ **www.ngoforum.org.kh**